ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ប្រចាំតំបន់អាស៊ីអាគ្នេយ៍
- ការដោះស្រាយវិបត្តិផ្លូវចិត្តដោយរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩១ ខែកក្កដា ឆ្នាំ២០០៧

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ៩១ ខែកក្កដា ឆ្នាំ២០០៧

## មាតិកា

◆ សំបុត្រ ៖ មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ ..................១

**ផ្នែកឯកសារ**

◆ ភាពសោកស្ដាយនៅក្រោយពេលតស៊ូធ្វើបដិវត្តន៍ ..............................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ......................................................................១០

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ..........................................១៨

◆ សេចក្ដីរំពឹងទុកចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ..............១៨

◆ យុវជនកម្ពុជាសញ្ជឹងគិតទៅរកការផ្សះផ្សាជាតិ ...............................២០

◆ ការផ្សារជាយោធាវរៈ១១២របស់ លន់ ...............................២៣

◆ គ្រោះថ្នាក់ដោយប្រយោលទៅកាន់មនុស្សទី២ ..........................២៥

◆ ការចង់បានរបស់ប្រជាជនកម្ពុជានៅតាមជនបទ .........................២៨

**ផ្នែកច្បាប់**

◆ តួនាទីទូលំទូលាយរបស់សាលាក្ដី ............................................៣៨

**វេទិកាពិភាក្សាសាធារណៈ**

◆ ការវិនិច្ឆ័យលើអំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ .........៤៤

◆ ការដោះស្រាយបញ្ហាវិបត្តិផ្លូវចិត្តដោយរបបខ្មែរក្រហម ...............៤៧

◆ សេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា ................................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ស្ទើរបាត់បង់ជីវិតដោយសារប្រឆាំងនឹងបដិវត្តន៍ .........................៥៤


ប្រជាជនទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


ប្រជាជនទស្សនាអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាលេខនេះ ៖** អេង កុកថាយ, ផេង ពង្សរ៉ាស៊ី, ឌី ខាំបូលី, គង់ សុកគឿន, លី សុខឃាង និងកែវ ដាស៊ីល, សារ៉ាស ចនឌី, អ៊ីសាក់ ថាប៊ីរ, ជី ទេរិទ្ធិ, លោកស្រី ជា លាង និង រ៉ូប៊ឺត ពើទីត, អ៊ូ ដាវ ហៅ អ៊ុំ សឿន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ណយ សុផារី, តាត លកិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ **Email: dccam@online.com.kh, Homepage: www.dccam.org**

*សំបុត្រ :*

# មជ្ឈមណ្ឌលស្រាវជ្រាវអំពីប្រល័យពូជសាសន៍ប្រចាំតំបន់អាស៊ីអាគ្នេយ៍

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងជាអង្គភាពឯករាជ្យមួយនៅឆ្នាំ១៩៩៧ ។ ក្នុងអំឡុងពេល១០ឆ្នាំកន្លងមកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយខ្លួនទៅជាអង្គការក្រៅរដ្ឋាភិបាលដ៏រឹងមាំមួយនិងមានឈ្មោះល្បីល្បាញទាំងនៅក្នុងស្រុកនិងលើឆាកអន្តរជាតិ ។ ចាប់តាំងពីពេលបង្កើតមជ្ឈមណ្ឌលនេះជាលើកដំបូង មជ្ឈមណ្ឌលបានដើរតាមគោលការណ៍ជាមូលដ្ឋានចំនួនពីរគឺយុត្តិធម៌និងការចងចាំ ។ «ការចងចាំ»សំដៅលើការខិតខំប្រឹងប្រែងស្រាវជ្រាវរឿងរ៉ាវប្រវត្តិសាស្ត្រដ៏ជូរចត់របស់កម្ពុជានៅក្នុងសម័យខ្មែរក្រហមដើម្បីឲ្យកូនខ្មែរជំនាន់ក្រោយបានយល់ដឹងនិងរៀនសូត្រអំពីទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់កម្ពុជា ។ «យុត្តិធម៌»សំដៅទៅលើការប្រឹងប្រែងបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងជួយជ្រោមជ្រែងឲ្យតុលាការនេះមានដំណើរការទៅមុខដោយគ្មានភាពរអាក់រអួល តាមរយៈការផ្តល់ឯកសារនិងព័ត៌មានទាក់ទងទៅនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នៅពេលនេះយើងអាចសន្និដ្ឋានបានថា គោលដៅទីពីរនេះទទួលបានជោគជ័យមួយផ្នែកធំ កាលពីថ្ងៃទី១៨ ខែកក្កដាកន្លងទៅនេះក្នុងពេលដែលការិយាល័យសហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីថ្លែងការណ៍ថា សហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានឲ្យស៊ើបសួរទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ នៅក្នុងដីកាសន្និដ្ឋាននោះអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ចំនួនប្រាំរូបត្រូវបានបញ្ជូនឈ្មោះឲ្យស៊ើបអង្កេត ។ ទោះបីជាមិនទាន់មានឈ្មោះមេដឹកនាំណាមួយត្រូវបានប្រកាស ក៏យើងអាចសន្និដ្ឋានបានថា នេះជាជំហានដ៏ធំមួយទាក់ទងទៅនឹងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រជាជនកម្ពុជាជាច្រើនត្រេកអរឥតឧបមាចំពោះការវិវត្តន៍នេះហើយត្រៀមខ្លួនជានិច្ចដើម្បីសហការបន្ថែមទៀតជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញដើម្បីធ្វើយ៉ាងណាឲ្យប្រជាជនកម្ពុជាអាចទទួលបានយុត្តិធម៌កាន់តែឆាប់រហ័ស ។

ចំពោះគោលដៅទីមួយទាក់ទងទៅនឹងការចងចាំក្នុងដំណាក់កាលនេះយើងអាចវាយតម្លៃបានថា មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើបានសម្រេចមួយផ្នែកធំរួចមកហើយដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមែប្រមូលចងក្រង និងអភិរក្សឯកសារខ្មែរក្រហមរាប់សែនទំព័រសម្រាប់ការស្រាវជ្រាវ និងបានជួយប្រជាជនខ្មែររាប់រយនាក់ស្វែងរកបងប្អូនញាតិមិត្ត ដែលបានបាត់ខ្លួននៅក្នុងសម័យខ្មែរក្រហម ។ លើសពីនេះ មជ្ឈមណ្ឌលបានស្រាវជ្រាវបន្ថែមតាមរយៈការចុះសម្ភាសប្រជាជនកម្ពុជានៅតាមជនបទរាប់ម៉ឺននាក់ និងបានបោះពុម្ពផ្សាយសៀវភៅជាភាសាខ្មែរនិងអង់គ្លេសជាច្រើនក្បាល ។ ទស្សនាវដ្តីស្វែងរកការពិតជាការបោះពុម្ពផ្សាយមួយដែលប្រជាជនកម្ពុជាស្គាល់ច្បាស់ជាងគេថាជាព្រឹត្តិប័ត្រប្រចាំខែតែមួយគត់ដែលបោះពុម្ពផ្សាយអំពីរឿងរ៉ាវទាក់ទងទៅនឹងខ្មែរក្រហមសុទ្ធសាធ ។ ប្រជាជនមួយចំនួនធំបានឲ្យតម្លៃនិងរក្សាទុកទស្សនាវដ្តីនេះគ្រប់លេខ ។

ដោយឡែកអ្វីដែលសំខាន់ជាងនេះ គឺក្នុងពេលថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ សរសេរដោយអ្នកនិពន្ធខ្មែរជំនាន់ក្រោយ ។ សៀវភៅនេះមានសារប្រយោជន៍ណាស់ពីព្រោះសៀវភៅនេះត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំថា អាចប្រើប្រាស់បានជាឯកសារដ៏សំខាន់ក្នុងការអប់រំយុវជនខ្មែរជំនាន់ក្រោយអំពីអំពើប្រល័យពូជសាសន៍កម្ពុជា ។ សរុបសេចក្តីមកនៅក្នុងអំឡុងពេល១០ឆ្នាំមកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការរំឭកស្មារតីប្រជាពលរដ្ឋកម្ពុជាឲ្យខំប្រឹងប្រែងពិភាក្សាឡើងវិញ និងស្វែងយល់អំពីសម័យខ្មែរក្រហមដើម្បីជាការចងចាំ ការស្វែងរកយុត្តិធម៌(ជូនជនរងគ្រោះជិតពីរលាននាក់ដែលបានស្លាប់បាត់បង់ជីវិតដោយការសម្លាប់ ការអត់ឃ្លាន ការធ្វើការបាក់កម្លាំង និងជំងឺ) និងការការពារមិនឲ្យអំពើបែបនេះកើតឡើងជាថ្មីម្តងទៀត ។

គាំងនាមជាគ្រឹះស្ថានដែលមានតួនាទីអប់រំប្រជាជនខ្មែរអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាក្រោមការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជាកំពុងប្រែខ្លួនឲ្យទៅជាមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍មិនត្រឹមតែនៅ

កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែប្រចាំតំបន់អាស៊ីអាគ្នេយ៍ថែមទៀតផង ។ មជ្ឈមណ្ឌលថ្មីនេះ នឹងធ្វើការស្រាវជ្រាវដើម្បីប៉ាន់ប្រមាណទុកជាមុននិងចាត់វិធានការទប់ស្កាត់មិនឲ្យមានអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់ ។

## ទ្រឹស្តីជាមូលដ្ឋាន

អំពើប្រល័យពូជសាសន៍គឺជាបាតុភូតមួយដែលមានលក្ខណៈចម្រែក និង មានភាពធ្ងន់ធ្ងរនៅក្នុងសង្គមមនុស្ស និងជាគ្រោះថ្នាក់ដ៏ធំបំផុតមួយដែលអាចធ្វើឲ្យអារ្យធម៌ពិភពលោកសាបរលាបទៅវិញ ។ អ្នកប្រវត្តិវិទូមួយចំនួនបានអះអាងថា អំពើប្រល័យពូជសាសន៍មិនមែនជាព្រឹត្តិការណ៍ថ្មីដែលកើតមានឡើងតែក្នុងសតវត្សរ៍ទី២០ និង២១ នេះទេ គឺបានកើតឡើងជាច្រើនលើកច្រើនសារួចមកហើយនៅក្នុងប្រវត្តិសាស្ត្រ ទាំងនៅទ្វីបអឺរ៉ុប អាហ្វ្រិកនិងអាស៊ី ។ បាតុភូតនេះតែងតែកើតឡើងនៅពេលមានសង្គ្រាមនិងប្រព្រឹត្តឡើងជាទូទៅដោយកងទ័ពរបស់អ្នកឈ្នះទៅលើកងទ័ពនិងប្រជាជនរបស់ប្រទេសឬភូមិដ្ឋានរបស់ភាគីចាញ់ ។ ជាក់ស្តែងក្រោយពីបានទទួលជ័យជម្នះលើសមរភូមិ កងទ័ពម៉ុងហ្គោលីរបស់ ហ្សង់ហ្ស៊ីខាន់ តែងតែធ្វើការកាប់សម្លាប់ និងដុតបំផ្លាញភូមិដ្ឋានរបស់សត្រូវជានិច្ច ប៉ុន្តែបញ្ញាជនខ្លះមិនយល់ស្របថា ទង្វើនេះជាអំពើប្រល័យពូជសាសន៍ទេ ពីព្រោះកម្រិតយល់ដឹងរបស់មនុស្សក្នុងសម័យនោះមានកម្រិតទាបនៅឡើយ ។

ទោះជាយ៉ាងណាក៏ដោយ បញ្ញាជនភាគច្រើនយល់ស្របថា អំពើប្រល័យពូជសាសន៍ជាបាតុភូតមួយដែលក្នុងនោះមនុស្សនៃក្រុមមួយធ្វើការកាប់សម្លាប់មនុស្សមួយក្រុមទៀតនិងមានបំណងចង់លុបបំបាត់ប្រជាជនក្នុងក្រុមនេះឲ្យអស់ ។ ជាពិសេសការកាប់សម្លាប់ក្នុងទ្រង់ទ្រាយធំនេះ ច្រើនផ្អែកទៅលើកត្តាអត្តសញ្ញាណក្រុមដែលអាចមានលក្ខណៈជាសាសនា ពូជសាសន៍ ជនជាតិ ជាតិពន្ធនិងលក្ខណៈផ្សេងទៀតដែលអាចកកើតឡើងតាមលក្ខខណ្ឌសង្គមសេដ្ឋកិច្ច ។

នៅឆ្នាំ១៩៤៨ ក្រោយពីសង្គ្រាមលោកលើកទីពីរត្រូវបានបញ្ចប់ ដែលក្នុងនោះពូជសាសន៍ជ្វីហ្វ៦លាននាក់ត្រូវបានសម្លាប់ដោយពួកណាហ្ស៊ីក្រោមការដឹកនាំរបស់អ៊ីត្លែរ អង្គការសហប្រជាជាតិបានបង្កើតអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដែលបានចុះហត្ថលេខាគាំទ្រយ៉ាងទូលំទូលាយពីសំណាក់ប្រទេសជាច្រើនក្នុងពិភពលោក ។ នេះគឺជាការវិវត្តន៍មួយជំហានធំទាក់ទងទៅនឹងការលុបបំបាត់អំពើប្រល័យពូជសាសន៍ក្នុងពិភពលោក ទោះជាមានសម្តីរិះគន់ថា អនុសញ្ញានេះមានភាពលម្អៀងពីព្រោះវាមិនបានរាប់បញ្ចូលក្រុមទាំងឡាយដែលមានមនោគមវិជ្ជា និងខ្សែបន្ទាត់នយោបាយដាច់ដោយឡែក ។ នៅក្នុងអនុសញ្ញានេះអំពើប្រល័យពូជសាសន៍ត្រូវបានឲ្យនិយមន័យថាជា «អំពើទាំងឡាយណាដែលបានប្រព្រឹត្តឡើងក្នុងគោលបំណងកម្ទេចក្រុមសាសនា ពូជសាសន៍ ជនជាតិ និងជាតិពន្ធ ទាំងស្រុងឬមួយផ្នែក» ។ បច្ចុប្បន្ននិយមន័យនេះត្រូវបានប្រើប្រាស់នៅក្នុងច្បាប់អន្តរជាតិ ទាំងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ក៏ដូចជាតុលាការខ្មែរក្រហមនៅកម្ពុជាដែរ ។

បច្ចុប្បន្នតំបន់អាស៊ីអាគ្នេយ៍កំពុងតែឋិតនៅក្រោមការគំរាមកំហែងពីអំពើប្រល័យពូជសាសន៍ ។ ហេតុនេះការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ប្រចាំតំបន់ជាការចាំបាច់បំផុត ។ កន្លងមកអំពើប្រល័យពូជសាសន៍ច្រើនតែកើតមាននៅក្នុងប្រទេសដែលមានសង្គ្រាម ពិសេសប្រទេសដែលកំពុងរំដោះខ្លួនចេញពីនឹមអាណានិគមនិយម ។ លើសពីនេះវាអាចកើតមាននៅក្នុងសម័យសង្គ្រាមត្រជាក់ នៅពេលដែលជម្លោះមនោគមវិជ្ជារីករាលដាលបង្កឲ្យមានការកាប់សម្លាប់គ្នាកាន់តែឃោរឃៅ ហើយប្រទេសមហាអំណាចមិនអើពើចំពោះអ្វីដែលកើតឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ប៉ុន្តែបច្ចុប្បន្នគ្មានការធ្វើអាណានិគម និងចលនាទាមទារឯករាជ្យជាតិ ហើយក៏គ្មានជម្លោះមនោគមវិជ្ជាក្នុងរូបភាពជាសង្គ្រាមត្រជាក់រវាងលោកខាងលិចនិងខាងកើតទៀតទេ ។ តើហេតុអ្វីបានជាតំបន់អាស៊ីអាគ្នេយ៍បែរជាមានគ្រោះថ្នាក់ពីអំពើប្រល័យពូជសាសន៍ទៅវិញ?

នៅឆ្នាំ១៩៩៣ គឺក្រោយពីសង្គ្រាមត្រជាក់បានបញ្ចប់នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ បញ្ញាជនអាមេរិកម្នាក់ឈ្មោះ សាមូអែល ហាន់ទីងតុន បានបោះពុម្ពផ្សាយទ្រឹស្តីថ្មីមួយដែលទាក់ទងទៅនឹងមូលហេតុនៃសង្គ្រាមលោកក្នុងសតវត្សរ៍ក្រោយៗ ។ ហាន់ទីងតុនបានដាក់ឈ្មោះទ្រឹស្តីនោះថា «ទំនាស់អារ្យធម៌» ។ ជារួមទ្រឹស្តីនោះបានអះអាងថា នៅថ្ងៃមុខ សង្គ្រាមនឹងផ្ទុះឡើងដោយសារការបែងចែកក្រុមតាមខ្សែបន្ទាត់អារ្យធម៌ និងវប្បធម៌ រួមមានអាស៊ី អឺរ៉ុប អាហ្វ្រិក និងអារ៉ាប់ជាដើម ។ ទ្រឹស្តីនេះត្រូវបានទទួលការគាំទ្រយ៉ាងទូលំទូលាយពីសំណាក់អ្នកនយោបាយ អ្នកសិក្សាស្រាវ

ជ្រាវ និងពីសង្គមស៊ីវិល ។ អ្នកខ្លះប្រើប្រាស់ទ្រឹស្តីរបស់ហាន់ទីងតុន ដើម្បីពន្យល់មូលហេតុដែលនាំឲ្យកើតមានឡើងនូវអំពើភេរវកម្ម រវាងអ៊ីស្លាមនិងបស្ចិមប្រទេស ។

ដើម្បីពន្យល់អំពីបាតុភូតប្រល័យពូជសាសន៍នៅអាស៊ីអាគ្នេយ៍ ត្រូវទាមទារឲ្យមានការស្វែងយល់អំពីបាតុភូតពីរទៀត គឺសាកលភាវូបនីយកម្មនិងការបែកបាក់ ។ សាកលភាវូបនីយកម្ម សំដៅទៅលើការខិតចូលកាន់តែជិតរវាងប្រទេសនិងក្រុមមនុស្ស ផ្សេងៗទូទាំងពិភពលោកតាមរយៈសមាហរណកម្មសេដ្ឋកិច្ចនិង ការរីកចម្រើនខាងបច្ចេកវិទ្យា ផ្នែកគមនាគមន៍និងទូរគមនាគមន៍ ។ ថ្វីដ្បិតតែមានផលប្រយោជន៍មួយកម្រិតទាំងផ្នែកសេដ្ឋកិច្ចនិង សង្គមកិច្ច សាកលភាវូបនីយកម្មបានជះឥទ្ធិពលអាក្រក់មួយចំនួន ពិសេសគឺការបែកបាក់ផ្នែកសង្គម ឬគ្មានការរួបរួមគ្នា ។ ការប្រឈបាច់ចូលគ្នានិងការប៉ះទង្គិចគ្នារវាងក្រុមមនុស្សផ្សេងៗដែល ធ្លាប់តែនៅដាច់ពីគ្នា បង្កឲ្យមានជាបាតុភូតបែកបាក់គ្នាវិញក្នុង រូបភាពជាទំនាស់សង្គ្រាម ឬជាការកាប់សម្លាប់គ្នាតាមរយៈអំពើ ប្រល័យពូជសាសន៍ ។

តំបន់អាស៊ីអាគ្នេយ៍ជាតំបន់មួយដែលទទួលរងឥទ្ធិពល យ៉ាងខ្លាំងពីចលករសាកលភាវូបនីយកម្ម ប៉ុន្តែផ្ទុយទៅវិញជាតំបន់ ដែលមានប្រជាជនបង្កឡើងដោយក្រុមមនុស្សច្រើនដែលមាន ប្រវត្តិសាស្ត្រនិងវប្បធម៌ខុសៗគ្នា ។ ជាក់ស្តែងកំណើនសេដ្ឋកិច្ច នៅប្រទេសសិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ និង វៀតណាម ជាភស្តុតាងនៃការបើកចំហទ្វារទៅនឹងឥទ្ធិពលពីខាងក្រៅនិងទំនាក់ ទំនងយ៉ាងស្អិតល្មួតផ្នែកសេដ្ឋកិច្ចរវាងប្រទេសទាំងនេះនិងសេដ្ឋកិច្ច ពិភពលោក ។ សមាហរណកម្មសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងដែនការ របស់អាស៊ានកាន់តែធ្វើឲ្យល្បឿននៃការរួបរួមគ្នានិងទំនាក់ទំនងគ្នា កើនឡើងកាន់តែខ្លាំង ហើយក្នុងពេលនោះធ្វើឲ្យឱកាសនៃការប៉ះ ទង្គិចគ្នាកាន់តែកើនឡើងដែរ ។

បច្ចុប្បន្នជនជាតិភាគតិចដែលរស់នៅក្នុងតំបន់ភាគឦសាន នៃប្រទេសកម្ពុជា ភាគកណ្តាលនៃប្រទេសវៀតណាមនិងភាគខាង ត្បូងនៃប្រទេសឡាវបាននិងកំពុងទទួលឥទ្ធិពលយ៉ាងខ្លាំងពីវប្បធម៌ ខាងក្រៅ ដែលជាហេតុធ្វើឲ្យអត្តសញ្ញាណរបស់ក្រុមនេះប្រែប្រួល ហើយជួនកាលវប្បធម៌ត្រូវបាត់បង់បន្តិចម្តងៗ ។ ជាក់ស្តែង មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងមួយដែលសិក្សា ស្រាវជ្រាវអំពីកម្រិតនៃការបាត់បង់វប្បធម៌ដើមរបស់ជនជាតិ ភាគតិចនិងតួនាទីការអប់រំក្នុងការរក្សាអត្តសញ្ញាណក្រុមនិងជាតិ ។

ក្រុមប្រទេសដែលមានទីតាំងនៅម្តុំប្រជុំកោះដូចជាប្រទេស ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន មានគ្រោះថ្នាក់កាន់តែខ្លាំងពី អំពើប្រល័យពូជសាសន៍ដោយសារមូលហេតុច្រើនយ៉ាង ។ ជាទូទៅ ប្រទេសទាំងនេះមានប្រជាជនច្រើន មានក្រឡាផ្ទៃធំធេង និងមាន ទីតាំងភូមិសាស្ត្រលាតសន្ធឹងលើផ្ទៃទឹកធំទូលំទូលាយ ។ កត្តានេះធ្វើឲ្យ ពិបាកក្នុងការបង្កើតជាអត្តសញ្ញាណជាតិរួម ។ ប្រទេសខ្លះមានកោះ ដល់ទៅរាប់ពាន់ ហើយនៅលើកោះនីមួយៗដោយសារពុំសូវមាន ទំនាក់ទំនងញឹកញាប់នឹងគ្នា តែងតែមានរបៀបរបបនៃការរស់នៅ ដាច់ដោយឡែកពីគ្នា ហើយក្នុងរយៈពេលយូរអង្វែងកាន់តែធ្វើឲ្យ មានការកកើតឡើងនូវវប្បធម៌ ប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធ សង្គម និងនយោបាយខុសពីគ្នា ។ ការប្រឡប់ចូលគ្នាភ្លាមៗនូវប្រជាជន ទាំងនេះតាមរយៈសមាហរណកម្មសេដ្ឋកិច្ចអាចធ្វើឲ្យមានជម្លោះ ។

កោះទីម័រខាងកើត និងបាន់ដាអាសេ ជាឧទាហរណ៍បញ្ជាក់ អំពីភាពខ្វែងគ្នារបស់អត្តសញ្ញាណជាតិនិងតំបន់ ដោយសារកោះ ទាំងពីរនេះបានធ្វើចលនាផ្តាច់ខ្លួនចេញប្រទេសឥណ្ឌូនេស៊ី ។ ប្រជាជននៅលើកោះនេះយល់ថាខ្លួនមានអត្តសញ្ញាណខុសពីគេ ហើយមិនអាចរួមរស់ដោយសុខស្រួលជាមួយនឹងប្រជាជន ឥណ្ឌូនេស៊ីទូទៅបាន ។ លើសពីនេះជម្លោះដែលកាន់តែមានភាព ឃោរឃៅនៅភាគខាងត្បូងនៃប្រទេសថៃនិងរបបយោធាផ្តាច់ការ នៅប្រទេសភូមាក៏ជាករណីគួរឲ្យចាប់អារម្មណ៍ និងជាភស្តុតាង បញ្ជាក់ពីភាពចាំបាច់ក្នុងការបង្កើតឲ្យមានមជ្ឈមណ្ឌលស្រាវជ្រាវ អំពើប្រល័យពូជសាសន៍ពិតប្រាកដ ។

តាមរយៈការប្រើប្រាស់ធនធាននិងជំនាញផ្នែកស្រាវជ្រាវ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មជ្ឈមណ្ឌលថ្មីនឹងសហការយ៉ាង ស្អិតល្មួតជាមួយនឹងសមាគមអន្តរជាតិនៃអ្នកស្រាវជ្រាវអំពើ ប្រល័យពូជសាសន៍ សាកលវិទ្យាល័យនានានៅទូទាំងពិភពលោក និងមជ្ឈមណ្ឌលចងក្រងឯកសារផ្សេងទៀតនៅបរទេសដើម្បីធ្វើ យ៉ាងណាកុំឲ្យអំពើប្រល័យពូជសាសន៍កើតមានម្តងទៀតនៅក្នុង តំបន់អាស៊ីអាគ្នេយ៍ តាមរយៈការព្យាករណ៍សង្គ្រាម ការការពារ និងការធ្វើអន្តរាគមន៍នៅក្នុងជម្លោះដែលបង្កឲ្យមានការស្លាប់បាត់ បង់ជីវិតមនុស្សច្រើននាក់ ។ **ឃ្មេង កុកថាយ**

# ភាពសោកស្តាយនៅក្រោយពេលគស៊ូធ្វើបដិវត្តន៍

តាមផ្លូវលំមួយដែលមានដើមឈើដុះអមសងខាងលាស់ស្លឹកបៃតងចាស់ខ្ចីនារដូវវស្សាបានផ្តល់ជាម្លប់ត្រឈឹងត្រឈៃសម្រាប់អ្នកភូមិដែលដើរទៅមកតាមផ្លូវនេះ ហើយក៏ជាទីកន្លែងរស់នៅយ៉ាងសុខដុមរបស់ មីងធឿន ដែលស្ថិតនៅក្នុងឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ហាក់ដូចជាដឹងមុន គ្រាន់តែខ្ញុំទៅដល់ភ្លាម មីងធឿន ស្រាប់តែមកដល់ពីផ្សារទិញម្ហូបដែរ។ មីងធឿន គ្មានការឆ្ងល់ឆ្ងល់ឡើយ ពេលដែលខ្ញុំប្រាប់គាត់ថាខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ មីងប្រញាប់ប្រញាល់យកម្ហូបទៅទុក ហើយអញ្ជើញខ្ញុំឲ្យអង្គុយនៅលើគ្រែបន្ទះក្តារមួយនៅក្រោមដំបូលផ្ទះប្រក់ក្បឿងជាមួយនឹងខ្យល់បក់ត្រសៀកៗគួរឲ្យចង់រស់នៅ។ បើមើលតាមសភាពខាងក្រៅជាមួយនឹងស្នាមញញឹមនិងភាពរួសរាយរាក់ទាក់របស់មីង ខ្ញុំហាក់ដូចជាមិនចង់ជឿថាមីងជាអតីតកម្មាភិបាលខ្មែរក្រហមឡើយ។ តាមពិត ធឿន ជាកម្មាភិបាលខ្មែរក្រហមថ្នាក់មធ្យមម្នាក់ដែលបានវិលត្រឡប់មកស្រុកកំណើតវិញនៅក្រោយឆ្នាំ១៩៧៩ ដោយពាំនាំមកជាមួយនូវអតីតកាលមួយដែលប្រវត្តិសាស្ត្របានកត់ត្រាទុក។ ធឿន ទទួលការរិះគន់យ៉ាងខ្លាំងពីសំណាក់អ្នកភូមិនិងមជ្ឈដ្ឋានជុំវិញ ដោយសារតែអតីតភាពធ្លាប់បម្រើការឲ្យរបបខ្មែរក្រហម។


ធឿន អាយុ ៥៨ឆ្នាំ

ធឿន កើតនៅឆ្នាំ១៩៤៩ ក្នុងគ្រួសារកសិករមធ្យមមួយ។ ឪពុករបស់ ធឿន បានធ្វើមរណកាលនៅឆ្នាំ១៩៩៦ ដោយជំងឺមហារីកបំពង់ក ចំណែកម្តាយបានស្លាប់នៅឆ្នាំ១៩៦៧។ ធឿន ជាកូនស្រីទី៣និងជាកូនដែលទទួលបានការសិក្សាអប់រំជ្រៅជ្រះជាងគេក្នុងចំណោមបងប្អូនប្រុសស្រីទាំង៨នាក់។ ធឿន មិនមែនជាសិស្សឆ្នើមនៅក្នុងថ្នាក់ទេ ប៉ុន្តែគាត់មានចិត្តអំណត់ព្យាយាមរៀនសូត្រណាស់រហូតរៀនបានដល់ថ្នាក់ទី៣ទំនើបជាតិនៅវិទ្យាល័យសោភ័ន្ទ ដែលសព្វថ្ងៃហៅថាវិទ្យាល័យហ៊ុនសែនប្រសូត្រ។ ធឿន ចេះអាននិងនិយាយភាសាបារាំងបានតិចតួចដែរ។

ដោយសារការទម្លាក់គ្រាប់បែកពីកងយន្តហោះ លន់ នល់ ចេះតែបន្ត បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ធឿន បានបង្ខំចិត្តឈប់រៀន។ ពេលនោះសភាពការណ៍នៅក្នុងភូមិកាន់តែមានភាពច្របូកច្របល់ខ្លាំងឡើងៗ ខ្មែរក្រហមចាប់ផ្តើមជ្រើសរើសយុវជននិងយុវនារីឲ្យចូលបម្រើបដិវត្តន៍តាមការឃោសនារបស់ តាខសា ជាសន្តិសុខ ឃុំ និងប្រពន្ធរបស់គាត់ យាយសាអែម ជានារីឃុំ។ ធឿននិងក្មេងៗដែលមានអាយុស្របាលគ្នា បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍តាមឃោសនារបស់អ្នកទាំងពីរ។ ពីដំបូង តាខសា និង យាយសាអែម បានចាត់តាំងឲ្យ ធឿន ធ្វើជានារីឃុំប្រចាំឃុំសំបួរ បន្ទាប់មកបញ្ជូនគាត់ឲ្យទៅឃោសនានៅភូមិឈើទាល ឃុំគគីរសោម ស្រុកស្វាយទាប។ ក្រុមរបស់ ធឿន មានសមាជិកទាំងអស់ប្រាំមួយនាក់។ មុនពេលចេញទៅឃោសនាម្តងៗ ថ្នាក់លើបានចាត់ឲ្យ យាយសាអែម នារីស្រុក ឬនារីខេត្តមកបង្រៀនពីរបៀបឃោសនាជាមុនសិន។ ការងាររបស់ ធឿន គឺប្រមូលប្រជាជនក្នុងភូមិឲ្យមកប្រជុំស្រង់ឈ្មោះនិងឃោសនាឲ្យប្រជាជនចូលបដិវត្តន៍។ ក្រៅពីការងារទាំងនោះ ធឿន ត្រូវជួយធ្វើរបាយការណ៍ ធ្វើកំណត់ហេតុ និងរៀបចំកិច្ចប្រជុំទៀតផង។

## ការងារនៅមន្ទីរពេទ្យ

នៅឆ្នាំ១៩៧២ តាខសា បានជ្រើសរើស ធឿន ឲ្យទៅរៀនមុខវិជ្ជាពេទ្យនៅស្រុករំដួលតំបន់២៣ ដោយគាត់ជាអ្នកជូនទៅផ្ទាល់តែម្តង។ សិស្សពេទ្យទាំងអស់មានប្រហែលពី៣០ទៅ៤០នាក់ដែលប្រមូលមកពីឃុំផ្សេងៗ។ វគ្គសិក្សារៀនសូត្រនេះមានរយៈពេល៣ខែ ក្រោមការបង្ហាត់បង្រៀនពីគ្រូពេទ្យជំនាញជនជាតិវៀតណាមនិងជនជាតិខ្មែរ។ សិស្សត្រូវរៀនចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ ហើយនៅក្នុងនោះក៏មានការបែងចែកជាក្រុមតូចៗដើម្បីពិភាក្សាគ្នាទៀតផង។ ជួនពេលខ្លះ ធឿន ត្រូវរៀនយប់បន្ថែមទៀតប្រសិនបើមានមេរៀនច្រើន។ មុខវិជ្ជាដែល

ត្រូវរៀនមានជំងឺទូទៅ របៀបរុំរបួស លាងរបួស ការប្រើថ្នាំ និងចាក់ថ្នាំជាដើម ។ បន្ទាប់ពីបញ្ចប់វគ្គរៀនសូត្រ សិក្ខាកាមទាំងអស់ត្រូវចាប់ផ្តើមអនុវត្តការងារផ្ទាល់របស់ខ្លួននៅតាមមន្ទីរពេទ្យនានា ។ ធឿន ត្រូវបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរពេទ្យស្រុកប្រសូត្រ ដែលមានប្រធានគ្រប់គ្រងឈ្មោះ ហ៊ុល ។ មន្ទីរពេទ្យនេះមានពីរខ្នង មិនទាន់មានលក្ខណៈពេញលេញជាមន្ទីរពេទ្យនៅឡើយទេ ។ ធឿន ដែលនៅក្នុងក្រុមរបស់គាត់មានគ្នា៣នាក់ ឋិតក្រោមការគ្រប់គ្រងផ្ទាល់ពីប្រធានក្រុមឈ្មោះ ឈិត និងឆាំ ។ គាត់ទាំងបីនាក់មានភារកិច្ចលាងរបួសមួយសប្តាហ៍និងចាក់ថ្នាំមួយសប្តាហ៍ ។ ភាគច្រើនអ្នកជំងឺដែលមកដេកនៅមន្ទីរពេទ្យនេះជាយោធាដែលរងរបួសនៅក្នុងសមរភូមិប្រយុទ្ធ ។ អ្នករបួសដែលបញ្ជូនមកម្តងៗមានពី៣០ទៅ៤០នាក់ ហើយត្រូវដាក់ឲ្យសម្រាកដង្ហែរគ្នាជាជួរក្នុងគេហដ្ឋានមួយ ។ នៅទីនេះ ធឿន ទទួលបានរបបបាយបីពេលក្នុងមួយថ្ងៃ និងទទួលការអនុញ្ញាតឲ្យមកលេងផ្ទះបានមួយថ្ងៃដែរក្នុងខណៈពេលដែលពេទ្យបុរស១ចេញទៅយកអ្នករបួស ។

## ហាត់យោធា

ខែមករា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមជិតចូលវាយលុកដល់ទីក្រុងភ្នំពេញ គ្រួសាររបស់ ធឿន ត្រូវអង្គការជម្លៀសទៅនៅព្រៃទទឹង ។ ចំណែក ធឿន វិញត្រូវ តាខសា និងយាយសាអែម បញ្ជូនឲ្យហាត់ក្បួនទ័ពនៅខេត្តព្រៃវែង ស្ថិតនៅក្នុងតំបន់២៤ ភូមិភាគបូព៌ា ដែលមាន សោ ភឹម ជាប្រធានភូមិភាគ ។ កងទ័ពនារីទាំងអស់ដែលទៅហាត់ក្បួនទ័ពនៅទីនេះមានចំនួន៣វរៈ ។ ធឿន ត្រូវបានចាត់តាំងឲ្យធ្វើជាអនុប្រធានផ្នែក "គ" និង ធី ជាប្រធាន ក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ ទាញ និងប្រធានវរៈឈ្មោះ លឿ ។ នៅក្នុងអង្គភាព "គ" អង្គការបានបែងចែកចេញជាបីផ្នែកមាន "ក" "ខ" និង "គ" ។ អង្គភាព "ក" ជាអង្គភាពតូចជាងគេ មានសមាជិកពី១០ទៅ១៣នាក់ ។ នៅក្នុងអង្គភាព "ខ" មាន៣ "ក" មានសមាជិកប្រហែល៣០នាក់ ។ រីឯអង្គភាព "គ" មានបី"ខ" ដែរ ។ ដូចនេះនៅក្នុងក្រុមរបស់ ធឿន មានសមាជិកប្រហែលជា១០០នាក់ ។ អង្គភាព"គ" មានផ្ទះបីខ្នងសម្រាប់ឲ្យកងទ័ពស្នាក់នៅ ។ ដោយសារ ធឿន មានតួនាទីជាអនុប្រធាន ដូច្នេះគាត់អាចទៅស្នាក់នៅផ្ទះណាមួយក៏បានដែរ ។

វគ្គហ្វឹកហ្វឺននេះមានគ្រូបង្រៀនពីរនាក់ឈ្មោះ លឿ និង លី បង្រៀនផ្នែកទ្រឹស្តី ។ កងទ័ពទាំងអស់មិនអនុញ្ញាតឲ្យកាន់អាវុធគ្រប់ដៃទេ អ្នកទាំងនេះអាចមានសិទ្ធិត្រឹមតែឈរមើលតំណាងក្រុមរបស់ខ្លួនម្នាក់ឡើងសម្តែងពីរបៀបប្រើកាំភ្លើងបាញ់ស៊ីបនិងដោះបង់កាំភ្លើងប៉ុណ្ណោះ ។ ធឿន ត្រូវបានអនុញ្ញាតឲ្យកាន់កាំភ្លើងនិងឡើងសម្តែងឲ្យអង្គភាព "គ"មើល ។ ក្រោយពីហាត់រៀនចប់ កាំភ្លើងទាំងអស់ត្រូវប្រមូលយកទៅទុកនៅកន្លែងដើមវិញ ។ ក្រៅពីហាត់ក្បួនទ័ព ធឿន ត្រូវទៅធ្វើពលកម្មបន្ថែមទៀត ដូចជាលើកដីនិងលើកទំនប់ជាដើម ។ នៅទីនេះ ធឿន មិនសូវមានការលំបាកក្នុងការហូបចុកឡើយ ប៉ុន្តែគាត់បែរជាមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនទៅវិញ ពីព្រោះថាមនុស្សនៅក្នុងអង្គភាពរបស់គាត់ចេះតែបាត់ខ្លួនជាបណ្តើរៗ ដូចជាប្រធានកងរបស់គាត់ឈ្មោះ ទាញ ត្រូវអង្គការចាប់បណ្តើរយកទៅបាត់ ។

## ការងារផ្នែកក្រឡឹង

នៅឆ្នាំ១៩៧៦ កងទ័ពនារីទាំងអស់ដែលបានហ្វឹកហ្វឺនផ្នែកយោធាត្រូវអង្គការរំសាយនិងបញ្ជូនឲ្យធ្វើការនៅភ្នំពេញវិញ ។ កងវរៈរបស់ ធឿន ត្រូវបានបញ្ជូនតាមកប៉ាល់ទៅមុនគេឆ្លងកាត់ព្រៃវែងមកដល់កំពង់ភ្នំខាងកើតអ្នកលឿង រួចជិះរថយន្តបន្តមកកាន់ទីក្រុងភ្នំពេញ ។ តាមពិត ធឿន មិនទាន់ត្រូវបានបញ្ជូនទៅឡើយ ប៉ុន្តែដោយសារនៅក្រុមគាត់មានម្នាក់ត្រូវបាត់ខ្លួន ដូចនេះឈ្មោះរបស់ ធឿន ត្រូវទៅជំនួសវិញ ។ មុនចូលដល់ទីក្រុង ធឿន សម្រាកនៅផ្ទះ ឌុក រ៉ាស៊ី នៅច្បារអំពៅមួយយប់សិន រួចទើបចេញពីទីនោះឆ្ពោះមកកាន់ទួលគោក ដែលមាន តាលឿ ជាអ្នកចាំទទួល ។ ការងារនៅទួលគោកមានបែងចែកជាបួនផ្នែក ៖ មានផ្នែកក្រឡឹង ផ្នែកកាត់ដេរ ផ្នែករំសេវ និងផ្នែកភស្តុភារ ។ ធឿន ស្ថិតនៅក្នុងក្រុមក្រឡឹងដែលមានសមាជិកក្រុមចំនួន១០នាក់ ។ បន្ទាប់ពីទទួលការបង្ហាត់បង្រៀនពីគ្រូបង្វឹកចេះចប់សព្វគ្រប់ ធឿន ចាប់ផ្តើមក្រឡឹងខ្មៅកាំភ្លើង ។ ផ្នែកក្រឡឹងនេះគឺជាផ្នែករោងជាងសិប្បកម្មតូចមួយដែលមានម៉ាស៊ីនក្រឡឹងតែមួយគ្រឿងសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ ។ ការហូបចុករបស់ ធឿន នៅទីនោះគឺបានគ្រប់គ្រាន់ ប៉ុន្តែគាត់ត្រូវរ៉ាប់រងការងារច្រើនរហូតទាល់តែគ្មានឱកាសបានមកលេងផ្ទះ ។

នៅខែមិថុនា ឆ្នាំ១៩៧៦ ធឿន បានរៀបការជាមួយបុរសម្នាក់ឈ្មោះ ប៊ុត ហាន ដែលជាប្រធានផ្នែកក្រឡឹង។ ធឿន រៀបរាប់ថា ពីដំបូងគាត់មិនស្រឡាញ់ ហាន ទេ បុរសដែលគាត់ស្រឡាញ់ឈ្មោះ សង ជាប្រធានផ្នែករំសេវ ។ សង ធ្លាប់ស្នើគាត់រៀបការម្តងដែរ ប៉ុន្តែគាត់បានបដិសេធព្រោះដឹងថា ផល ដែលជាមិត្តភក្តិរបស់គាត់លួចស្រឡាញ់ សង ដូចគ្នា ។ ទោះបីយ៉ាងណាអាពាហ៍ពិពាហ៍របស់គាត់មិនមែនកើតឡើងដោយការបង្ខំដែរ ធឿន សម្រេចចិត្តរៀបការតាមការពន្យល់ណែនាំពីមិត្តភក្តិស្និទ្ធស្នាលម្នាក់ឈ្មោះ ផល ។ ធឿន បានរៀបការជាមួយ ហាន បន្ទាប់ពី ផល រៀបការបានរយៈពេលមួយខែ ។ នៅថ្ងៃរៀបការអង្គការបានសូត្រប្រវត្តិរូបរបស់អ្នកទាំងពីរមួយចប់ បន្ទាប់មក ធឿន និង ហាន ឡើងប្តេជ្ញាចិត្តនៅចំពោះមុខអង្គការថា រស់នៅជាមួយគ្នាអស់មួយជីវិត ។ មង្គលការរបស់ ធឿន អាចចាត់ទុកថាពិសេសជាងគេ ព្រោះថាអង្គការមានស្រាឲ្យផឹកនិងអញ្ជើញបុគ្គលិកទាំងអស់ក្នុងរោងចក្រក្រឡឹងឲ្យចូលរួម ។ ធឿន បានមានប្រសាសន៍ថា ប្តីរបស់គាត់ស្រឡាញ់គាត់ណាស់ ហើយមិនដែលចង់ឲ្យគាត់ទៅណាឆ្ងាយពីខ្លួនឡើយ សូម្បីតែអង្គការបញ្ជូនឈ្មោះគាត់ឲ្យទៅរៀនវគ្គបច្ចេកទេសខាងរំសេវនៅប្រទេសចិន ក៏ស្វាមីរបស់គាត់បដិសេធដែរព្រោះខ្លាចស្ថានការណ៍ប្រែប្រួលនាំឲ្យបែកគ្នា ហើយស្វាមីថែមទាំងនិយាយថា *«បើទៅត្រូវទៅទាំងអស់គ្នា បើងាប់ត្រូវងាប់ទាំងអស់គ្នា»* ។

## ការងារធ្វើរំសេវនៅចក្ការដូង

ធ្វើការនៅទីនោះបានជិតមួយឆ្នាំ ធឿន បានបែកចេញពីស្វាមីដោយសារគាត់ត្រូវបញ្ជូនទៅធ្វើការផ្នែកកាត់ដេរ ។ ប៉ុន្តែដោយអង្គការមើលឃើញថា ធឿន មានចំណេះវិជ្ជានិងរៀនសូត្របានច្រើន អង្គការក៏ផ្លាស់គាត់ទៅធ្វើរំសេវនៅវិទ្យាល័យចក្ការដូងជំនួសវិញ ដែលមាន ហួ ជាអ្នកគ្រប់គ្រង ។ ការងារនៅទីនោះមិនសូវលំបាកទេ ប៉ុន្តែគាត់ត្រូវប្រឈមមុខនឹងគ្រោះថ្នាក់គ្រប់ពេលវេលា ព្រោះថាត្រូវធ្វើការពិសោធន៍ជាតិគីមីដើម្បីផលិតគ្រាប់រំសេវ ។ ពេលធ្វើការក្នុងបន្ទប់ពិសោធន៍ម្តងៗ ធឿន ភ័យខ្លាចមានគ្រោះថ្នាក់ណាស់ដោយសារគាត់បានឃើញគំរូម្នាក់ឈ្មោះ ធុក ដែលធ្វើការនៅក្នុងបន្ទប់ជាមួយគ្នា បានកំបុតដៃម្ខាងពេលធ្វើការពិសោធន៍ ។

ធឿន ធ្វើការនៅក្នុងបន្ទប់ពិសោធន៍មួយដែលមានយុទ្ធជន ៥នាក់ ក្នុងនោះមាន រ៉េន ជាប្រធានក្រុមពិសោធន៍ និង ចាវ ជាគ្រូបង្រៀនខាងធ្វើរំសេវ ។ ធឿន ត្រូវធ្វើការចាប់ពីម៉ោង ៧ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ និងពីម៉ោង១ដល់ម៉ោង៥ ពេលយប់ត្រូវធ្វើបន្តរហូតដល់ម៉ោង១០ ឬ១១យប់ទៀត ។ ក្នុងមួយថ្ងៃ ធឿន ធ្វើបានកិបគ្រាប់កាំភ្លើង (សម្រាប់ធ្វើឲ្យគ្រាប់ផ្ទុះ) ចំនួន ៣ទៅ៤កិប ។ កិបនេះមានសារសំខាន់ណាស់សម្រាប់ធ្វើជាគ្រាប់បែកឬគ្រាប់មីន ។ ថ្វីត្បិតតែ ធឿន ធ្វើការនៅផ្នែកនេះមែន ប៉ុន្តែគាត់មិនបានដឹងថាសារធាតុគីមីដែលយកមកពិសោធន៍មានប្រភពមកពីណាទេ ។ *«សូម្បីតែដឹកចូលក៏ខ្ញុំមិនដឹងដែរ ខ្ញុំមិនដែលបានទាក់ទងជាមួយអ្នកផ្សេងដែលធ្វើការជាមួយគ្នាទេ គឺខំតែធ្វើការ ដល់ម៉ោងធ្វើការត្រូវចូលធ្វើការ ដល់ម៉ោងហូបបាយត្រូវ*



ហូបបាយ សម្រាកត្រូវសម្រាក» ។

ក្នុងមួយសប្តាហ៍សមាជិកនៅក្នុងក្រុមពិសោធន៍ត្រូវចូលរួមប្រជុំគ្នាម្តង ហើយប្រសិនបើមានប្រជុំធំម្តងៗដូចជាប្រជុំសាខាបក្ស គឺត្រូវធ្វើនៅទីស្នាក់ការនៅទួលគោកដោយមាន ហួ ជាអ្នកឡើងថ្លែងសុន្ទរកថាបើកអង្គប្រជុំ ។ គោលបំណងនៃការប្រជុំនោះធ្វើឡើងដើម្បីពង្រឹងមាគ៌ាបក្ស លទ្ធផលការងារដែលសម្រេចបាននិងការសារភាពទោសកំហុសរបស់សមាជិកម្នាក់ៗរួចរាយការណ៍ប្រាប់ទៅថ្នាក់លើប្រសិនបើខុសបន្តិចបន្តួចត្រូវកសាងអប់រំកែប្រែ ។

ចាប់តាំងពីមកធ្វើការនៅចម្ការដូង ធឿន មិនសូវមានពេលវេលាគ្រប់គ្រាន់ជួបជាមួយស្វាមីទេ ព្រោះរវល់ការងាររៀងៗខ្លួន ក្នុងរយៈពេលប្រហែលជា១០ថ្ងៃ ទើបអង្គការអនុញ្ញាតឲ្យគាត់ទាំងពីរជួបមុខគ្នាម្តង ។ ធឿន បន្តថា នៅក្នុងអំឡុងពេលដែលគាត់ធ្វើការនោះ គាត់កម្រឃើញមេដឹកនាំធំៗចុះមកកន្លែងធ្វើការណាស់ ប៉ុន្តែមានម្តងនោះ ចាវ បានខ្សឹបទាមប្រាប់ឲ្យស្គាល់ថានេះជាតា នួន ជា ឬហៅតាលេខ២ ដែលបានចុះមកពិនិត្យមើលការងារនៅក្នុងបន្ទប់ពិសោធន៍ប្រហែលជា១៥នាទី ជាមួយកងការពាររបស់គាត់ម្នាក់និងពិភាក្សាគ្នាជាមួយ ហួ អំពីផលប្រយោជន៍នៃការធ្វើរំសេវនេះ ។

**ការងារនៅព្រៃកហូរ ក្រោយថ្ងៃចាប់ខ្លួនរបស់ ហាន**

នៅវេលាយប់ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៧ អង្គការបានហៅស្វាមីរបស់គាត់ទៅប្រជុំ ដែលពេលនោះ ធឿន មិនបាននៅក្បែរស្វាមីឡើយ ។ ធឿន បានដឹងព័ត៌មានតាមរយៈកងការពាររបស់ ហាន ប៉ុណ្ណោះ ។ មុនពេលចាកចេញ ស្វាមីរបស់ ធឿន បានផ្តាំផ្ញើកងការពាររបស់គាត់ឈ្មោះ រ៉ន ឲ្យខ្ញុំមកប្រាប់ថា កុំឲ្យទៅតាមគាត់ឲ្យសោះ ។ ចាប់តាំងពីពេលនោះមកស្វាមីរបស់គាត់



បានបាត់ខ្លួនរហូត ។ ធឿន បានព្យាយាមសួរអ្នកនៅក្បែរនិងអ្នកធ្វើការជាមួយគ្នាដែរ ដូចជា តាខាត់ ក្រែងបានដំណឹងខ្លះពីស្វាមីគាត់ ដុយទៅវិញចម្លើយដែល ធឿន បានទទួលគឺត្រឹមតែពាក្យថា "ប្តីហ្អែងទៅធ្វើការកុំទៅតាមឲ្យសោះ» ។

ពីរថ្ងៃក្រោយមក មានរថយន្តហ្ស៊ីបមួយគ្រឿងបានមកទទួល ធឿន ដោយប្រាប់ថាឲ្យទៅតាមប្តីមិនបាច់យករបស់របរអ្វីទៅទេ ។ ធឿន និងនារី៥ម្នាក់ទៀតត្រូវបានដឹកតាមរថយន្តឆ្លងកាត់ក្រុងតាខ្មៅមកទម្លាក់នៅមណ្ឌលអប់រំព្រៃកហូរដែលមានអ្នកគ្រប់គ្រងឈ្មោះ សុខ ។ ធឿន មិនបានជួបស្វាមីរបស់គាត់តាមការសន្យារបស់ខ្មែរក្រហមឡើយ ។ ភី ជាមិត្តភក្តិរបស់គាត់ក៏ត្រូវអង្គការបញ្ជូនទៅទីនោះដែរ ។ ពេលនោះ ធឿន និង ភី កំពុងមានផ្ទៃពោះ៧ខែ ។ តាមការសង្កេតរបស់ ធឿន បានឲ្យដឹង

ថាអ្នកដែលត្រូវចាប់ខ្លួនបញ្ជូនមកទីនេះ សុទ្ធតែជាប្រពន្ធកម្មាភិបាល ប៉ុន្តែគាត់មិនបានដឹងពីមូលហេតុនៃការចាប់ខ្លួននេះទេ សូម្បីតែខ្លួនគាត់ក៏មិនដឹងពីមូលហេតុច្បាស់ដែរ ។ ធឿន គ្រាន់តែដឹងថា មុនពេលចាប់ខ្លួន គាត់ត្រូវបញ្ឈរជើង២ថ្ងៃមិនឲ្យធ្វើអ្វីទាំងអស់ "ខ្ញុំឆ្ងល់ដែរ ព្រោះធ្លាប់តែធ្វើការ" ។ ការងារប្រចាំថ្ងៃរបស់ ធឿន គឺធ្វើជី ស្រោចដំណាំ និងកាប់ទន្រ្ទានខែត្រ ។ ក្រោយមកអង្គការចាប់ផ្តើមធ្វើប្រវត្តិរូប សួរឈ្មោះ និងទីកន្លែងកំណើត បន្ទាប់មកថតរូប ។ ធឿន ស្ថិតនៅក្នុងក្រុមនារីដែលមានសមាជិក១៣នាក់ សម្រាកនៅក្នុងផ្ទះរួមមួយ ។ ការរស់នៅទីនោះរបស់ ធឿន មានលក្ខណៈកាន់តែលំបាកឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ខ្មែរក្រហមបានបង្អត់អាហារប្រជាជនដោយផ្តល់របបឲ្យហូបមិនឆ្អែត ហើយធ្វើការយ៉ាប់យឺនជាងមុនទៅទៀត ។ ធឿន សម្រាលកូនបានប្រហែលកន្លះខែ អង្គការក៏ចាត់តាំងឲ្យគាត់ធ្វើការងារស្រាលៗ ដូចជាដាំដំឡូង បោចស្មៅ និងមើលថែទាំទារក ។ មួយខែក្រោយមកអង្គការបានបញ្ជូនឲ្យទៅដកសំណាបនិងស្ទូងស្រូវនៅជិតព្រៃស ។ ធឿន បានឃើញក្មេងៗស្លាប់ជាច្រើននាក់ ទោះបីជាមាន សុវណ្ណ ជាពេទ្យប្រចាំការនៅទីនោះចាំមើលក៏ដោយដែលធ្វើឲ្យគាត់នឹកឃើញដល់សុវត្ថិភាពកូនប្រុសរបស់គាត់ដែលមានអាយុទើបតែ៧ខែ ហើយត្រូវទុកចោលនៅមណ្ឌលកុមារ ដោយសារគាត់ត្រូវទៅធ្វើការនៅកន្លែងឆ្ងាយ ហើយប្រហែលជាម៉ោង១១យប់ ទើបត្រឡប់មកដល់ផ្ទះវិញ ។ មិនយូរប៉ុន្មានការព្រួយបារម្ភនេះបានធ្លាក់មកលើ ធឿន មែន ព្រោះកូនរបស់គាត់ត្រូវស្លាប់ដោយសារជំងឺអាសន្នរោគ ។ ចំណែកអ្នកដែលមើលថែកូនរបស់ ធឿន ត្រូវបាត់ខ្លួនដំណាលគ្នានឹងកូនរបស់គាត់ស្លាប់ដែរ ។ នៅពាក់កណ្តាលអធ្រាត្រ ធឿន បានឮសំឡេងក្មេងយំរាល់ថ្ងៃដោយ-សារបាត់ម្តាយ ជួនកាលគាត់លបមើលឃើញអង្គការបណ្តើរម្តាយយកទៅ ប៉ុន្តែមិនដឹងយកទៅទីណាទេ ។ អ្នកដែលត្រូវបណ្តើរយកទៅបាត់ខ្លួនរហូតមិនដែលឃើញត្រឡប់មកវិញឡើយ ។ ក្រៅពីនេះ ធឿន បានឃើញអង្គការបណ្តើរតាម្នាក់ដោយចងដាក់ច្រវាក់ដាក់លើឡាន ។

### ភៀសខ្លួនទៅបាត់ដំបង

នៅពេលកងទ័ពរំដោះវាយចូលក្រុងភ្នំពេញនៅដើម ១៩៧៩ ធឿន និងក្រុមរបស់គាត់ចំនួន១៣នាក់បានព្យាយាមរត់គេចខ្លួនចេញពីទីនោះ ប៉ុន្តែត្រូវមេកងស្រីម្នាក់ដែលគាត់មិនបានចាំឈ្មោះសម្បុរខ្មៅបានព្យាយាមដេញតាមជាប់រហូត ។ ធឿន និងក្រុមរបស់គាត់បានភៀសខ្លួនរហូតដល់ប្រឡាយតាព្រហ្ម ខេត្តបាត់ដំបង ។ ពេលនោះ ក្រុមរបស់គាត់នៅសល់តែ៣នាក់ប៉ុណ្ណោះ រួមទាំងគាត់ម្នាក់ផង ដែលអ្នកទាំងពីរនោះមានឈ្មោះ រើត និង សៀម ។ សកម្មភាពរបស់មេកងស្រីមិនបានបញ្ឈប់ឡើយ មេកងស្រីនោះនៅឃ្លាំមើលពួកគាត់និងប្រជាជនគ្រប់ពេលវេលា ពេលណាសភាពការណ៍ស្ងាត់ល្អនឹងកៀងប្រជាជនឲ្យត្រឡប់ទៅក្រោយវិញ ។ ធឿន សំណាងណាស់ពេលរត់ទៅដល់ទីនោះគាត់បានស្គាល់មិត្តភក្តិម្នាក់ធ្លាប់រៀនជាមួយគ្នានៅវិទ្យាល័យប្រសូត្រ ។ ប្រពន្ធរបស់គាត់បានផ្តល់កន្លែងស្នាក់នៅនិងផ្តល់អាហារឲ្យហូបមួយរយៈពេលខ្លី ។ ក្រោយមក ធឿន បានជួបបុរសចំណាស់ចិត្តធម៌ម្នាក់ដែលបានផ្តល់កន្លែងឲ្យគាត់ទាំងបីលាក់ខ្លួនដើម្បីគេចឲ្យផុតពីការតាមដានរបស់មេកងស្រីនោះ ។ គ្រាន់តែមេកងស្រីដើរហួសពីកន្លែងលាក់ខ្លួនបន្តិច បុរសវ័យកណ្តាលម្នាក់ដៃកាន់កាំបិតខ្វេវស្ទុះទៅកាប់មេកងស្រីនោះដាច់ជាពីរកំណាត់ ។ ធឿន ភ័យរន្ធត់យ៉ាងខ្លាំងពេលឃើញហេតុការណ៍នេះ ។ ពេលដឹងថាខ្លួនមានសុវត្ថិភាពហើយ គាត់ទាំងបីនាក់បានបំបែកផ្លូវគ្នាហើយធ្វើដំណើរត្រឡប់មករកគ្រួសារនិងបងប្អូននៅស្រុកកំណើតរៀងៗខ្លួនវិញ ។ ធឿន ធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល៦ខែទើបមកដល់ភូមិកំណើតវិញនៅខែកក្កដា ឆ្នាំ១៩៧៩ ។

### លទ្ធផលក្រោយការតស៊ូបដិវត្តន៍

គោលបំណងរបស់ ធឿន ដែលចូលបម្រើបដិវត្តន៍គឺដើម្បីរំដោះប្រទេសជាតិមាតុភូមិ ក៏ប៉ុន្តែបន្ទាប់ពីការតស៊ូអស់រយៈពេលជាច្រើនឆ្នាំ ធឿន បានទទួលត្រឹមតែពាក្យថា "សោកស្តាយប៉ុណ្ណោះ ព្រោះអ្វីដែលធ្វើទៅមិនបានទទួលផលប្រយោជន៍អ្វីទាំងអស់" ដោយសារគាត់ត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ស្ទើរតែស្លាប់បាត់បង់ជីវិត ហើយព្រាត់ពីស្វាមីនិងកូនជាទីស្រឡាញ់ស្លាប់ចោលទៀត ចំណែកចំណេះវិជ្ជាដែលគាត់រៀនសូត្របានតិចតួចនិងមិនមានជំនាញច្បាស់លាស់ទៀត ។ ទោះបីជាយ៉ាងក៏ដោយ ធឿន មិនបានបោះបង់គំនិតក្នុងការស៊ើបសួរដំណឹងពីស្វាមីគាត់

ដែរ ។ ធឿន សម្រេចចិត្តទៅលេងស្រុកកំណើតខាងប្ដីនៅខេត្តព្រៃវែង ដើម្បីស៊ើបសួរដំណឹង ប៉ុន្តែរកមិនឃើញដោយសារមិនស្គាល់សាច់ញាតិខាងប្ដី ។ ក្រោយមក ធឿន បានពឹងឲ្យបងប្អូនទៅជួយរកទៀត ប៉ុន្តែនៅតែគ្មានដំណឹង ។ មានម្ដងនោះពេលដែលមកលេងនៅភ្នំពេញ ធឿន បានឆ្លៀតចូលមើលសារមន្ទីរឧក្រិដ្ឋប្រល័យពូជសាសន៍ទួលស្លែងដើម្បីរកមើលរូបថតស្វាមីរបស់គាត់ ។ អ្វីដែលធ្វើឲ្យ ធឿន មានការចាប់អារម្មណ៍បំផុតនោះ គឺរូបថតដែលដាក់តាំងនៅក្នុងអាគារបេ ។ ធឿន បានដើរពិនិត្យមើលរូបថតម្ដងមួយៗក្រែងប្រទះឃើញរូបថតប្ដីរបស់គាត់ ប៉ុន្តែបែរជាឃើញតែរូបថតរបស់គាត់ទៅវិញ ។ ធឿន ងឿងឆ្ងល់ថា ហេតុអ្វីបានជារូបថតរបស់គាត់មកនៅទីនោះទៅវិញ ។ វត្តមានរូបថតមួយសន្លឹកនេះបានធ្វើឲ្យ ធឿន នឹកស្រណោះដល់សម្ដីដែលស្វាមីរបស់គាត់ធ្លាប់និយាយទៅកាន់មិត្តភក្ដិដែលធ្វើការនៅក្នុងក្រុមជាមួយគ្នាថា ប្រសិនបើគ្មានរបបខ្មែរក្រហមនេះទេ គាត់មិនឲ្យប្រពន្ធគាត់ធ្វើអ្វីទាំងអស់ ។ យ៉ាងណាក៏ដោយ ធឿន មិនសង្ឃឹម-ថា ប្ដីរបស់គាត់នៅរស់ទេ ប៉ុន្តែយ៉ាងហោចណាស់ក៏គាត់គ្រាន់តែចង់ដឹងឲ្យច្បាស់ថាស្លាប់ឬរស់ប៉ុណ្ណោះ ។

## សាងជីវិតថ្មីជាគ្រូបង្រៀន

នៅឆ្នាំ១៩៨១ ក្រសួងអប់រំបានប្រកាសជ្រើសរើសអ្នកមានចំណេះដឹង ដើម្បីឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋ ។ ធឿន បានប្រលងជាប់ជាគ្រូបង្រៀននៅឆ្នាំនោះ ប៉ុន្តែមុនចូលបង្រៀន ធឿន ត្រូវឆ្លងកាត់ការសិក្សានៅសាលាគរុកោសល្យនៅខេត្តស្វាយរៀងរយៈពេលមួយខែសិន ។ ក្រោយពីរៀនចប់ក្រសួងបានបញ្ជូន ធឿន ឲ្យទៅបង្រៀនសិស្សថ្នាក់ទី៤នៅសាលាបឋមសិក្សាខ្ជាយ ក្នុងភូមិខ្ជាយ ឃុំរមាំងថ្កោល ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលនៅឆ្ងាយពីភូមិរបស់គាត់ ។ ធឿន ត្រូវស្នាក់នៅផ្ទះក្នុងសាលារៀនដែលនៅក្បែរវត្តរយៈពេលមួយខែ ទើបគាត់មកលេងផ្ទះម្ដង ។ ក្រៅពីការងារបង្រៀនសិស្ស ធឿន ឆ្លៀតក្រោកពីព្រលឹមដើម្បីធ្វើចង្ហាន់ទៅប្រគេនព្រះសង្ឃ និងជួយធ្វើការបន្តិចបន្តួចឲ្យដូនជីនៅពេលទំនេរ ។ ភាពឧស្សាហ៍ព្យាយាមរបស់ ធឿន បានធ្វើឲ្យព្រះចៅអធិការវត្តជួយទំនុកបម្រុងជាអង្ករនិងម្ហូបអាហារប្រចាំថ្ងៃ ។ ចំណែកប្រាក់ខែដែលទទួលបាន៧០រៀលក្នុងមួយខែ ធឿន ទិញជាផ្លែឈើផ្ញើមកផ្ទះ ជួនពេលខ្លះផ្ញើជាលុយឲ្យមកឪពុកដើម្បីផ្គត់ផ្គង់គ្រួសារ ។ បង្រៀនបានរយៈពេល១៨ឆ្នាំ នៅឆ្នាំ១៩៩៨ ធឿន បានសុំផ្លាស់មកបង្រៀននៅសាលាបឋមសិក្សាបន្ទាយដែលនៅក្បែរផ្ទះវិញដើម្បីបានជួបជុំគ្រួសារ ។ ២ឆ្នាំក្រោយមក ធឿន បានផ្លាស់ពីភារកិច្ចបង្រៀនមកធ្វើខាងផ្នែកសាលាកម្រងមានតួនាទីគ្រប់គ្រងសម្ភារៈនិងមើលការខុសត្រូវបុគ្គលិកក្នុងការិយាល័យវិញ ។

## ផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើការងារនិងការរស់នៅបច្ចុប្បន្ន

ទោះបីជារបបខ្មែរក្រហមដួលរលំទៅក៏ពិតមែន ប៉ុន្តែរឿងរ៉ាវអតីតកាលដែលបានកើតឡើងក្នុងជីវិតរបស់ ធឿន នៅតែដក់ជាប់នៅក្នុងចិត្តរបស់គាត់ជាប់ជានិច្ច ។ ធឿន សប្បាយចិត្តយ៉ាងខ្លាំងពេលត្រឡប់មកដល់ផ្ទះវិញ បានជួបឪពុកនិងបងប្អូនដែលនៅរស់រានមានជីវិតទាំងអស់គ្នា ប៉ុន្តែគាត់បែរជាឮពាក្យសម្ដីផ្ដែផ្កាពីអ្នកភូមិជិតខាងរបស់គាត់ថា អ្នកដែលធ្លាប់ធ្វើខ្មែរក្រហមគឺជាមនុស្សអាក្រក់ ។ ធឿន អាក់អន់ចិត្តយ៉ាងខ្លាំងពេលដឹងថាអ្នកទាំងនេះគិតមិនល្អអំពីគាត់ដោយមិនបានគិតថា គាត់ក៏ជាជនរងគ្រោះនៃរបបនោះដែរ ។ ទោះយ៉ាងណាក៏ ធឿន មិនអាចហាមឃាត់មិនឲ្យមនុស្សគ្រប់គ្នានិយាយបានទេ ។ ដោយសារអតីតភាពរបស់គាត់ជាកម្មាភិបាលខ្មែរក្រហម ធឿន មិនត្រឹមតែប្រឈមមុខនឹងពាក្យសម្ដីរបស់អ្នកភូមិប៉ុណ្ណោះទេ សូម្បីតែអ្នកធ្វើការរួមអាជីពជាមួយគ្នាជាគ្រូបង្រៀនក៏មានការរើសអើងចំពោះគាត់ដែរ ។ ធឿន នៅតែឮពាក្យខ្សឹបខ្សៀវថា «ធឿន ធ្លាប់ធ្វើជាខ្មែរក្រហម» ។ ធឿន ធ្លាប់ឮសម្ដីចេញពីមាត់គ្រូៗផ្ទាល់ថា «បញ្ជូនឲ្យរៀនវគ្គហ្វឹកហ្វឺននៅខេត្តព្រៃវែងធ្វើអី វាធ្លាប់ធ្វើជាប៉ុល ពត» ។ ក្រោយមកទៀត ធឿន ត្រូវបានស្នើឈ្មោះទៅមន្ទីរអប់រំខេត្តតែងតាំងជានាយកសាលា ប៉ុន្តែគាត់បដិសេធវិញ ព្រោះគិតថា ទោះបីជាគាត់ធ្វើក៏នៅតែមានអ្នកខ្លះមិនពេញចិត្តដែរ ។ សព្វថ្ងៃនេះ ធឿន រស់នៅតែម្នាក់ឯងមិនយកគ្រួសារថ្មីទេ ។ ក្រៅពីបំពេញកាតព្វកិច្ចជាគ្រូល្អម្នាក់ ធឿន ប្រកបមុខរបរធ្វើស្រែប្រវាស់ជាមួយបងប្អូនរបស់គាត់ដើម្បីផ្គត់ផ្គង់ជីវភាពឲ្យកាន់តែប្រសើរឡើង ។

**គាត លក្ខិណា**

# គុកខ្មែរក្រហម

**(តពីលេខមុន)**

### ១០) មន្ទីរសន្តិសុខនៅវិទ្យាល័យញឹម វណ្ណដា ពារាំង

មន្ទីរសន្តិសុខប្រចាំស្រុកពារាំងត្រូវខ្មែរក្រហមបង្កើតឡើង នៅឆ្នាំ១៩៧៥ បច្ចុប្បន្ននៅក្នុងបរិវេណវិទ្យាល័យ ញឹម វណ្ណដា ពារាំង ។ មន្ទីរសន្តិសុខនេះមានទីតាំងនៅក្នុងភូមិត្នោត ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដោយមានឃុំឃាំងជនរងគ្រោះគ្រប់ប្រភេទ ទាំងអ្នកទោសធ្ងន់និងស្រាលដែលអ្នកទាំងនោះមួយចំនួនជាមន្ត្រីនិងទាហាននៃរបបសាធារណរដ្ឋខ្មែរ ។ កាក់ ហាក់ អាយុ


កាក់ ហាក់

៥០ឆ្នាំ ជាគ្រូបង្រៀននៅវិទ្យាល័យ ញឹម វណ្ណដា ពារាំង បានប្រាប់ថាខ្មែរក្រហមបានបញ្ជូនអ្នកទោសដែលអង្គការស៊ើបដឹងថាមានជាប់និន្នាការនយោបាយពីសង្គមចាស់មកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខស្រុកពារាំង ដើម្បីអប់រំនិងកែប្រែរួមជាមួយប្រជាជន ១៧មេសា និងអ្នកមូលដ្ឋានមួយចំនួន ។ អ្នកទោសទាំងនេះត្រូវកងសន្តិសុខនាំយកទៅសួរចម្លើយម្តងម្នាក់ ហើយជួនកាលសម្លាប់ចោលនៅពេលសួរចម្លើយតែម្តង ។ ហាក់ ធ្លាប់បានឮសម្រែកជនរងគ្រោះលាន់ឮចេញពីបន្ទប់សួរចម្លើយ ។ សាកសពដែលស្លាប់ត្រូវកងឈ្លបបញ្ជាឲ្យអូសយកទៅកប់នៅខាងក្រោយមន្ទីរ ។

ក្នុងអំឡុងឆ្នាំ១៩៧៧ អ្នកទោសភាគច្រើនត្រូវបានសម្លាប់ និងមួយចំនួនបានរត់គេចខ្លួនចេញពីមន្ទីរឃុំឃាំង ។ ហាក់ បានបកស្រាយរឿងអ្នកទោសលួចរត់ចេញពីមន្ទីរថា ដោយសារការបាចគ្រាប់ពីលើយន្តហោះមួយគ្រឿងដែលហោះក្រឡឹងជុំវិញមន្ទីរសន្តិសុខ ។ គ្រាប់ដែលបាចនោះមានខ្លឹមសារថា "តាមរកចាប់ខ្លួនមេដឹកនាំភូមិភាគបូព៌ាឈ្មោះ សោភឹម ជាបន្ទាន់ ព្រោះគាត់ក្បត់នឹងបដិវត្តន៍" ។ ការគ្រប់គ្រងនៅមន្ទីរសន្តិសុខស្រុកពារាំងត្រូវបានជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតីវិញ ។ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតីបានធ្វើឲ្យមន្ទីរឃុំឃាំងផ្ទុកទៅដោយអ្នកទោសកាន់តែច្រើន ដែលរួមមានទាំងកម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាផង ។ នៅក្នុងឆ្នាំដែលកម្មាភិបាលគ្រប់គ្រងមន្ទីរសន្តិសុខស្រុកពារាំងបានផ្ទេរអ្នកទោសស្រាលទៅដាក់នៅមន្ទីរសន្តិសុខមួយថ្មីទៀតដែលអង្គការបង្កើតឡើងនៅក្នុងបរិវេណវត្តក្រាំងពិសី ។ អ្នកទោសដែលនៅសេសសល់ក្នុងមន្ទីរសន្តិសុខពារាំង ត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅទួលអ្នកតាចិននិងស្នាយដូច ។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ រណ្តៅមួយចំនួននៅក្នុងបរិវេណវិទ្យាល័យពារាំងត្រូវប្រជាជនគាស់ឡើង ហើយអដ្ឋិធាតុទាំងអស់ក៏មិនប្រមូលទុកដាក់ឲ្យបានសមរម្យដែរ ។ សព្វថ្ងៃវិទ្យាល័យនេះបានប្តូរឈ្មោះទៅជាវិទ្យាល័យ ញឹម វណ្ណដា ពារាំង វិញ ។

### ស្រុកព្រះស្តេច

### ១១) មន្ទីរសន្តិសុខទួលអ្នកតាស្នាយ


មន្ទីរសន្តិសុខទួលអ្នកតាស្នាយ

មន្ទីរសន្តិសុខទួលអ្នកតាស្នាយ មានទីតាំងស្ថិតនៅភូមិតាម៉ៅ

ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង នៅចម្ងាយប្រហែល២០ គីឡូម៉ែត្រពីសាលាស្រុកព្រះស្តេច ប៉ែកខាងជើងឆៀងខាងលិច ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានយកទួលនេះធ្វើជាមន្ទីរសន្តិសុខដើម្បីឃុំឃាំងជនរងគ្រោះជាប្រជាជនមូលដ្ឋាននិងប្រជាជនជម្លៀសមកពីខេត្តស្វាយរៀង ព្រមទាំងយុទ្ធជនរបស់ សោ ភឹម ។ ជនរងគ្រោះត្រូវកងឈ្លបនាំមកកាន់មន្ទីរសន្តិសុខតាមរទេះគោនិងដោយថ្មើរជើង ហើយត្រូវបានសម្លាប់ដោយវាយនឹងត្បូងចប រួចហើយកប់ក្នុងរណ្តៅធំៗចំនួន៥និងរណ្តៅតូចៗជាង១០០ទៀត នៅក្នុងបរិវេណទីតាំងសម្លាប់ទួលអ្នកតាស្វាយ ដែលស្ថិតនៅក្បែរមន្ទីរសន្តិសុខដែរ ។

សាត ដេង បានប្រាប់ថា គាត់បានឃើញកងសន្តិសុខសម្លាប់អ្នកទោសនៅពេលគាត់កំពុងឃ្វាលគោក្បែរនោះ ។ អ្នកទោសប្រហែលពី២០០ទៅ៣០០នាក់ ត្រូវកងសន្តិសុខសម្លាប់ដោយត្បូងចបវាយកញ្ចឹង-ក ដែលអ្នកទាំងនោះភាគច្រើនជាយុទ្ធជនរបស់ សោ ភឹម ។

លុន គឺជាប្រធានមន្ទីរសន្តិសុខទួលអ្នកតាស្វាយ និង ហន ជាអនុប្រធាន ។ ចំណែក យ៉ុន ដែលជាកងសន្តិសុខ ត្រូវបានសម្លាប់ដោយរដ្ឋអំណាចមូលដ្ឋាននៅទីនោះ ។ តាមការជាន់ស្មានក្នុងរបាយការណ៍ឆ្នាំ១៩៨២បានឲ្យដឹងថា ជនរងគ្រោះដែលត្រូវខ្មែរក្រហមសម្លាប់នៅទីតាំងទួលអ្នកតាស្វាយមានចំនួនជាង ៨.០០០នាក់ ។

## ១២) មន្ទីរសន្តិសុខអ្នកតាយ៉ុងយ៉ូយ

អ្នកតាយ៉ុងយ៉ូយ មានទីតាំងស្ថិតនៅភូមិកោះកូនសត្វ ឃុំបឹងដោល ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខ ប្រចាំស្រុកព្រះស្តេចឬអ្នកតាយ៉ុងយ៉ូយ ត្រូវបានបង្កើតឡើងដើម្បីឃុំឃាំងអ្នកទោស ហើយអ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះមុនគេគឺជាទាហានរបបសាធារណរដ្ឋខ្មែរប្រមាណពី៥០០ទៅ៦០០នាក់ និងបន្ទាប់មកគឺប្រជាជនជម្លៀសនិងប្រជាជនមូលដ្ឋាន ។ នួន ណៃ ជាប្រជាជនរស់នៅភូមិកោះកូនសត្វ ឃុំបឹងដោល ស្រុកព្រះស្តេច បានរៀបរាប់ថា កម្មាភិបាលគ្រប់គ្រងនៅមន្ទីរសន្តិសុខអ្នកតាយ៉ុងយ៉ូយមានច្រើននាក់ណាស់ ប៉ុន្តែត្រូវបានផ្លាស់ប្តូរគ្នាតាម


នួន ណៃ

ទិសដៅរបស់អង្គការមានតែឈ្មោះ ឈឹន ម្នាក់គត់ដែលប្រជាជនស្គាល់ច្បាស់ថាជាប្រធានមន្ទីរសន្តិសុខអ្នកតាយ៉ុងយ៉ូយ ។

អ្នកទោសត្រូវកងសន្តិសុខប្រើឲ្យជីកស្រះធំមួយនៅលើទួលអ្នកតាយ៉ុងយ៉ូយ ហើយក្រៅពីនេះបណ្តើរឲ្យធ្វើការផ្សេងៗទៀតដូចជាជីកប្រឡាយ ធ្វើស្រែវស្សា និងស្រែប្រាំងជាដើម ។ របបអាហារបានត្រូវផ្តល់ឲ្យអ្នកទោសទៅតាមកម្លាំងពលកម្មដែលបានធ្វើ ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោលនៅត្រពាំងប៉ារ៉ា និងត្រពាំងរាំង ។

មន្ទីរសន្តិសុខនេះបានដំណើរការរហូតមកដល់ឆ្នាំ១៩៧៨ ទើបត្រូវបញ្ចប់បន្ទាប់ពីបានជម្លៀសអ្នកទោសដែលនៅសេសសល់ទៅកាន់កន្លែងផ្សេងទៀត ។ អ្នកទោសថ្មីៗជាច្រើននាក់ត្រូវកងឈ្លបចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខនេះ នៅមុនពេលត្រូវអង្គការរំលាយចោល ហើយក្រោយមកអ្នកទោសទាំងនោះក៏ត្រូវជម្លៀសចេញបន្តទៀត ។

## ស្រុកព្រៃវែង

## ១៣) ទួលក្រាំងស្វាយ

ទួលក្រាំងស្វាយ ស្ថិតនៅក្នុងភូមិកូនត្នោត ឃុំដំរីពួន ស្រុកព្រៃវែង ខេត្តព្រៃវែង ។ មេឃុំដំរីពួន ឈ្មោះ យ៉ែម ឈាន បានឃើញប្រជាជនជីកគាស់រណ្តៅសាកសពចំនួន៤១ នៅជុំវិញមន្ទីរសន្តិសុខទួលក្រាំងស្វាយដោយផ្ទាល់ភ្នែកកាលពីឆ្នាំ១៩៨២ ។ អគារចំនួនបីសម្រាប់ឃុំឃាំងអ្នកទោសត្រូវបានសាងសង់ឡើងនៅលើទួលក្រាំងស្វាយនេះ ។ អគារនេះសង់ពីឈើ ជញ្ជាំងធ្វើពីដីអិដ្ឋលាយចំបើងនិងដំបូលប្រក់ស្លឹកត្នោត ។



មន្ទីរសន្តិសុខទួលក្រាំងស្វាយ

## ១៤) មន្ទីរសន្តិសុខតាកេត

តាកេត ស្ថិតនៅភូមិជ្រៃលើង ឃុំពានរោង ស្រុកព្រៃវែង ខេត្តព្រៃវែង ។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខតាកេតនៅភូមិចាស់មួយឈ្មោះថា "ភូមិតាកេត" ។ ប៉ុន្តែបច្ចុប្បន្នអតីតភូមិនេះបានក្លាយជាទីរហោឋានមួយ ។ យ៉ុន ហ៊ាង បានរៀបរាប់ប្រាប់ថា នៅដើមឆ្នាំ១៩៧៤ កងសន្តិសុខពីរ-បីនាក់បានដើរកាត់ភូមិជ្រៃលើងចុះឡើងៗ រួចក៏សម្រេចចិត្តជ្រើសរើសយកទីទួលមួយក្នុងភូមិតាកេតធ្វើជាកន្លែងឃុំឃាំងឈ្លើយសឹកជាទាហានរបបសាធារណរដ្ឋខ្មែរ ។

នៅខែមេសា ឆ្នាំ១៩៧៥ អ្នកទោសទាំងនោះត្រូវកងសន្តិសុខចាប់មកពីខេត្តព្រៃវែង ហើយបញ្ជូនមកឃុំឃាំងនៅមន្ទីរសន្តិសុខភូមិតាកេត ។ យ៉ុន ហ៊ាង ធ្លាប់ឃើញកងសន្តិសុខវាយធ្វើបាបអ្នកទោសនៅពេលសួរចម្លើយម្តងៗ ក្នុងពេលដែលគាត់ទៅឃ្វាលគោនៅក្បែរមន្ទីរឃុំឃាំង ។ ក្នុងចំណោមឈ្លើយសឹកប្រមាណ២០០នាក់ ត្រូវបានសម្លាប់ចោលនៅក្នុងបរិវេណមន្ទីរសន្តិសុខតាកេតក្នុងរយៈពេលប្រមាណតែមួយឆ្នាំ ក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ប៉ុណ្ណោះ ។ ឈ្លើយសឹកមួយចំនួនទៀតត្រូវកងឈ្លបនាំទៅកាន់មន្ទីរសន្តិសុខមួយផ្សេងឈ្មោះ "មន្ទីរសន្តិសុខតំបន់២៤ទួលកគោ" បន្ទាប់ពីមន្ទីរឃុំឃាំងភូមិតាកេតត្រូវរំលាយចោលនៅក្នុងអំឡុងឆ្នាំ១៩៧៦ ។ រណ្តៅពីរ-បីដែលជីកដោយកងសន្តិសុខខ្មែរក្រហមមានផ្ទុកសាកសពអ្នកទោសពេញទាំងអស់ ។ ហ៊ាង បានប្រាប់ថា ការសម្លាប់បានប្រព្រឹត្តទៅក្នុងស្ថានភាពស្ងាត់ស្ងៀមបំផុត ពីព្រោះកងសន្តិសុខប្រើឧបករណ៍សម្លាប់ដូចជាព្រនង់និងដែកគោ្ករទេះប៉ុណ្ណោះ ។ កងសន្តិសុខម្នាក់អាចគ្រប់គ្រងមន្ទីរនេះតែ៣ទៅ៤ថ្ងៃ ក៏ត្រូវផ្លាស់ចេញដោយដាក់អ្នកថ្មីជំនួសវិញ ។



យ៉ុន ហ៊ាង

## ១៥) មន្ទីរសន្តិសុខតំបន់២៤ទួលកគោ

ទួលកគោ ស្ថិតនៅក្នុងភូមិជ្រៃលើង ឃុំពានរោង ស្រុកព្រៃវែង ខេត្តព្រៃវែង ។ ទួលកគោនេះត្រូវបានខ្មែរក្រហមយកធ្វើមន្ទីរសន្តិសុខប្រចាំតំបន់២៤ ។ តាមការអះអាងរបស់ ធឹម ធួន, យ៉ុន ហ៊ាង និង ឈុន យ៉េង ជាប្រជាជនរស់នៅភូមិជ្រៃលើង ឃុំពានរោង ស្រុកព្រៃវែងថា មន្ទីរសន្តិសុខតំបន់២៤ ឬទួលកគោបង្កើតឡើងនៅឆ្នាំ១៩៧៣ ដែលមានទីតាំងស្ថិតនៅចម្ងាយប្រហែលមួយគីឡូម៉ែត្រកន្ទះប៉ែកខាងជើងភូមិអ្នកស្រុកសម្រាប់ឃុំឃាំងអ្នកទោសជាឈ្លើយសឹកសង្រ្គាម ។ ដើមឈើធំៗនិងខ្ពស់ច្រូងច្រាងជាច្រើនដើមបានក្លាយទៅរបងយ៉ាងមាំដែលធ្វើឲ្យកន្លែងនេះក្លាយទៅជាមន្ទីរសម្ងាត់បំផុតរបស់ខ្មែរក្រហមនៅក្នុងទឹកដីរំដោះ ។ នៅឆ្នាំ១៩៧៥ ប្រជាជនគ្រប់គ្នាដឹងថា តំបន់នេះគ្រប់គ្រងដោយកម្មាភិបាលធំៗបីនាក់គឺ វ៉ាត (សព្វថ្ងៃរស់នៅអណ្តូងថ្ម ឃុំពានរោង), សយ (ស្លាប់) និង កុយ ជាអតីតឃាតករដ៏សាហាវម្នាក់ក្នុងចំណោមបីនាក់ (សព្វថ្ងៃរស់នៅខេត្តសៀមរាប) ។

ក្រោយថ្ងៃជ័យជម្នះទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនជម្លៀសជាច្រើនត្រូវកងសន្តិសុខចាប់បញ្ជូនមកដាក់ក្នុងបរិវេណមន្ទីរសន្តិសុខតំបន់២៤ ដោយឲ្យនៅលាយឡំជាមួយទាហានឈ្លើយសឹកដែលចាប់មកពីមុន ។ អ្នកទោសទាំងនោះត្រូវ


ធឹម ធួន

ធ្វើការងារធ្ងន់ធ្ងរ ហើយបើអ្នកទោសដែលមិនអាចទ្រាំបាននឹងការងារនេះ ច្បាស់ជាត្រូវនាំយកទៅសម្លាប់ចោលមិនខាន ។ ការអប់រំបំពាក់បំប៉នគ្មានអ្វីក្រៅពីការជំរុញឲ្យខិតខំធ្វើស្រែតែប៉ុណ្ណោះ ។

ចាប់តាំងពីឆ្នាំ១៩៧៧មក ភូមិភាគបូព៌ាទាំងមូលបានធ្លាក់ក្នុងសភាពវឹកវរ ដោយសារតែ សោ ភឹម ក្បត់ នឹងបដិវត្តន៍ ។ កម្មាភិបាលខាង សោ ភឹម បាននាំគ្នារត់ភៀសខ្លួននិងត្រូវសម្លាប់ស្ទើរអស់ ។ ចំណែកយុទ្ធជនខ្លះត្រូវកម្មាភិបាលខាងភូមិភាគនិរតីចាប់បញ្ជូនមកដាក់ឃុំនៅមន្ទីរសន្តិសុខតំបន់២៤ ដើម្បីជម្រិតសួរយកចម្លើយមុននឹងសម្លាប់ចោល ។ ឈុន យ៉េង និយាយថា នៅចន្លោះឆ្នាំ១៩៧៧និង១៩៧៨ ប្រជាជនថ្មី ប្រជាជនមូលដ្ឋាន ទាហាន និងកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ាត្រូវកងសន្តិសុខមជ្ឈិមប្រមូលយកទៅសម្លាប់យ៉ាងច្រើននៅទីតាំងពិឃាតទួលក្រៀមគ ឬទួលក្រាំងគ ។ ធឹម ធួន រស់នៅភូមិជ្រៃលើង ៧ឃុំពានរោងបានរាយការណ៍ថា កម្មាភិបាលភូមិភាគនិរតីបានយកអណ្តូងទឹកពីរដែលជីកដោយកម្លាំងទាហានឈ្លើយសឹកកាលពីឆ្នាំ១៩៧៣ ធ្វើជារណ្តៅកប់សាកសពអ្នកទោសដែលសរុបទៅមានចំនួនប្រហែល៥០០នាក់ ។

ថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ បានធ្វើឲ្យមន្ទីរសន្តិសុខតំបន់២៤ត្រូវរលាយ ហើយអ្នកទោសស្ទើរតែទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោលមុនថ្ងៃរំដោះ ។ អ្នកគ្រប់គ្រងមន្ទីរនិងកងសន្តិសុខដទៃទៀតបានរត់ភៀសខ្លួនអស់ ។ យ៉ាត ជាអ្នកទោសតែម្នាក់គត់ដែលរួចខ្លួនពីការសម្លាប់របស់ខ្មែរក្រហម ហើយដែលបច្ចុប្បន្នរស់នៅភូមិអូរសង្កែ ឃុំព្រៃឃ្នេស ស្រុកព្រៃវែង ។

## ស្រុកស៊ីធរកណ្តាល

### ១៥) មន្ទីរសន្តិសុខវិទ្យាល័យព្រែកសណ្តែក

វិទ្យាល័យព្រែកសណ្តែក ស្ថិតនៅក្នុងភូមិព្រែកសណ្តែក ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ កាលពីជំនាន់ខ្មែរក្រហម វិទ្យាល័យនេះត្រូវបានជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខប្រចាំតំបន់២២ ។ អគារធំៗចំនួន៣ខ្នង ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។ អគារទីមួយមាន២ជាន់និង៨បន្ទប់ អគារពីរទៀតមានមួយជាន់និង៨បន្ទប់ ។ ក្រៅពីវិទ្យាល័យព្រែកសណ្តែក នៅមានព្រះវិហារវត្តព្រែកសណ្តែក និងមណ្ឌលសុខភាពមួយទៀត ដែលខ្មែរក្រហមយកជាមន្ទីរឃុំឃាំងអ្នកទោស ។ ជនរងគ្រោះភាគច្រើនជាប្រជាជនជម្លៀសនិងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលខ្មែរក្រហមចាប់មកពីទីកន្លែងផ្សេងៗជុំវិញតំបន់២២ និងមានប្រជាជនមូលដ្ឋានមួយចំនួន ។

ហាក់ ស្រ៊ន់ និង មឿង ហុកសេង បាននិយាយថា មុនដំបូងខ្មែរក្រហមបានប្រមូលជនរងគ្រោះដែលជាប្រជាជនសាមញ្ញមកពីទីក្រុងនិងតាមខេត្តនានាមកដាក់ក្នុងមន្ទីរសន្តិសុខនេះ បន្ទាប់មកទៀត ប្រមូលអ្នកដែលមានជាប់ពាក់ព័ន្ធជាមួយបងប្អូនដែលធ្លាប់ធ្វើការរបបមុនពីគ្រប់សហករណ៍ទូទាំងឃុំក្នុងស្រុកស៊ីធរកណ្តាល ហើយចុងក្រោយបង្អស់គឺកម្មាភិបាលខ្មែរក្រហមដែលកងសន្តិសុខប្រមូលមកពីឃុំនានាក្នុងស្រុក ព្រមទាំងកម្មាភិបាលមកពីស្រុកកោះសូទិន ខេត្តកំពង់ចាមផង ។

មឿង ហុក សេង ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខតំបន់២២បានឲ្យដឹងថា មានអ្នកទោសច្រើនណាស់ដែលត្រូវកងឈ្លបសម្លាប់ ។ តាមឯកសាររបស់សាលាស្រុកស៊ីធរកណ្តាល បានបង្ហាញថា អ្នកទោសប្រមាណ១.០៨៤នាក់ ត្រូវបានសម្លាប់នៅជុំវិញទីតាំងមន្ទីរសន្តិសុខនេះ ។

ភស់ សព្វថ្ងៃរស់នៅឃុំរំលេច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និងជាអតីតកងសន្តិសុខនៅមន្ទីរសន្តិសុខវិទ្យាល័យព្រែកសណ្តែកតែម្នាក់គត់ដែលនៅរស់រានមានជីវិត ។

**ផេង ពង្សរ៉ាស៊ី**

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី៣
## ការឡើងកាន់អំណាចរបស់ខ្មែរក្រហម

### ១) ការចូលកាន់កាប់ទីក្រុងភ្នំពេញ

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ចប់នូវការជ្រៀតជ្រែកពីសំណាក់បរទេស ការទម្លាក់គ្រាប់បែក និងការប្រឈមអាវុធដាក់គ្នានៃសង្គ្រាមស៊ីវិលខ្មែររយៈពេលប្រាំឆ្នាំនៅកម្ពុជា ។ ក៏ប៉ុន្តែនៅថ្ងៃដដែលនេះ ទីក្រុងភ្នំពេញបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់កងកម្លាំងកុម្មុយនីស្តទាំងស្រុង ។

កងកម្លាំងខទ្ទាមដែលប្រកបដោយឯកសណ្ឋានពណ៌ខ្មៅ និងពណ៌អាចម៍សេះបានធ្វើដំណើរចូលទីក្រុងពីគ្រប់ទិសទី ។ ប្រជាជនទីក្រុងទាំងអស់បាននាំគ្នាចេញមកឈរត្រៀបត្រាតាមដងផ្លូវ ហើយស្រែកអបអរសាទរនិងគ្រវីទង់ក្រណាត់ស ។ ទោះជាយ៉ាងនេះក្តី ក៏មានមនុស្សជាច្រើននាក់បានសម្ងំលាក់ខ្លួននៅក្នុងផ្ទះ ដោយព្រួយបារម្ភថា ខ្លួនអាចត្រូវចាប់ ឬបាញ់សម្លាប់ ព្រោះភ្លាមៗនោះខ្មែរក្រហមបានប្រកាសតាមវិទ្យុជាតិថាខ្លួនមិនមែនមកដើម្បីចរចាជាមួយនរណាទាំងអស់ ហើយនឹងធ្វើការប្រហារជីវិតមន្ត្រីជាន់ខ្ពស់និងមេបញ្ជាការទ័ពរបស់រដ្ឋាភិបាលចាស់ ។



កម្មាភិបាលខ្មែរក្រហមនិងទីប្រឹក្សាចិនឈរនៅពីមុខសណ្ឋាគារឡឺភ្នំ

ជនបរទេសរាប់រយនាក់និងជនជាតិខ្មែរមួយចំនួនបានរត់ទៅជ្រកកោននៅសណ្ឋាគារឡឺភ្នំ (បច្ចុប្បន្នសណ្ឋាគារឡឺរ៉ូយ៉ាល់) ដែលកាកបាទក្រហមអន្តរជាតិបានប្រកាសថាជាតំបន់អព្យាក្រឹត ។ ប៉ុន្តែនៅពេលដែលខ្មែរក្រហមចូលពិនិត្យបោសសំអាតសណ្ឋាគារនេះ ជនបរទេស អ្នកកាសែត និងជនជាតិខ្មែរប្រហែលមួយរយនាក់ផ្សេងទៀតបានរត់ទៅជ្រកកោនក្នុងបរិវេណស្ថានទូតបារាំងវិញ ។ ខ្មែរក្រហមបានបញ្ជាជនជាតិខ្មែរទាំងអស់នៅក្នុងស្ថានទូតឲ្យធ្វើដំណើរទៅជនបទដើម្បីធ្វើការងារកសិកម្ម ។ ជនបរទេសប្រមាណ៦១០នាក់បានបន្តស្នាក់នៅក្នុងស្ថានទូតអស់រយៈពេលពីរសប្តាហ៍ទៀត មុននឹងត្រូវដឹកជញ្ជូនតាមឡានទៅកាន់ព្រំដែនថៃ ។

ភ្លាមៗបន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ ខ្មែរក្រហមបានប្រហារជីវិតមេដឹកនាំជាន់ខ្ពស់បីរូប មន្ត្រីរាជការ និងនាយទាហានរាប់រយនាក់របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ។ មេដឹកនាំជាន់ខ្ពស់ទាំងបីរូបនេះរួមមាននាយករដ្ឋមន្ត្រី ឡុង បូរ៉េត ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ និង លន់ ណុន (ប្អូនប្រុសរបស់លោកសេនាប្រមុខ លន់ នល់) ។ លោកសេនាប្រមុខបានចាកចេញពីប្រទេសមុននេះបន្តិចជាមួយនឹងប្រាក់សោធននិវត្តន៍ចំនួនមួយលានដុល្លារអាមេរិក ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានយល់ព្រមជម្លៀសអ្នកទាំងបីទៅកាន់សហរដ្ឋអាមេរិក ប៉ុន្តែអ្នកទាំងនេះបានបដិសេធមិនព្រមចាកចេញ ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅស្ថានទូតសហរដ្ឋអាមេរិកដែលមានសេចក្តីថា ៖

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះសំបុត្រ និងការផ្តល់ជូនរបស់លោកដើម្បីនាំខ្ញុំទៅកាន់សេរីភាព ។ ប៉ុន្តែគួរឲ្យអនិច្ចា ខ្ញុំមិនអាចចាកចេញក្នុងសភាពដ៏កំសាកបែបនេះ

បានទេ ។ ចំពោះលោក ហើយជាពិសេសចំពោះប្រទេសដ៏អស្ចារ្យរបស់អ្នក ខ្ញុំមិនដែលជឿមួយវិនាទីណាឡើយថា លោកដាច់ចិត្តបោះបង់ចោលមនុស្សដែលបានជ្រើសរើសយកសេរីភាព ។ លោកបានបដិសេធមិនផ្តល់ការការពារដល់យើងខ្ញុំ ហើយយើងខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់...ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់គឺការជឿជាក់ទៅលើសហរដ្ឋអាមេរិក ។ សូមទទួលនូវការរាប់អានអំពីខ្ញុំ ឯកឧត្តម មិត្តជាទីស្រលាញ់របស់ខ្ញុំ មិត្តដ៏ស្មោះត្រង់និងរួសរាយរាក់ទាក់របស់ខ្ញុំ ។

## ២) ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន

ប្រជាជននៅតាមទីក្រុងនិងទីប្រជុំជនភាគច្រើនជឿជាក់ថា ខ្លួននឹងរស់នៅប្រកបដោយសុខសន្តិភាពក្រោមការគ្រប់គ្រងរបស់មេដឹកនាំថ្មីរបស់ខ្លួន ហើយថាប្រជាជនគ្រប់រូបនឹងពួតដៃគ្នាធ្វើការដើម្បីបង្រួបបង្រួមជាតិ ។ ផ្ទុយទៅវិញពីរឬបីម៉ោងបន្ទាប់ពីកាន់កាប់ទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមបាញ់រះទៅលើអាកាសជាសញ្ញាបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុង ។

ខ្មែរក្រហមបានបង្ខំអ្នករស់នៅទីក្រុងភ្នំពេញប្រហែលពីរលាននាក់ ដែលក្នុងនោះរួមបញ្ចូលទាំងអ្នកភៀសខ្លួនក្នុងអំឡុងពេលសង្គ្រាមជាងមួយលាននាក់ផងឲ្យទៅជនបទ ។ ក្នុងរយៈពេលមួយសប្តាហ៍ ប្រជាជនក្នុងទីក្រុងភ្នំពេញនិងទីប្រជុំជនផ្សេងៗទៀត ដែលធ្លាប់គ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរត្រូវបានបណ្តេញចេញទៅធ្វើការងារកសិកម្មនៅតំបន់ជនបទ ។

ស៊ុម សុត ហៅ កុយ ដែលជាអ្នកធាក់ស៊ីក្លូនៅទីក្រុងភ្នំពេញ បានរំឭកឡើងវិញនូវហេតុការណ៍ដែលគាត់បានឃើញក្នុងអំឡុងពេលជម្លៀស ៖

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចេញដំណើរទៅប្រកបរបរដូចធម្មតា ។ ពីរ-បីម៉ោងក្រោយមក ខ្ញុំឃើញកងទ័ពខ្មែរក្រហមធ្វើដំណើរមកភ្នំពេញ ។ ប្រជាជនបានចេញមកក្រៅហើយគ្រវីក្រណាត់សនិងអាវស្វាគមន៍ខ្មែរក្រហម ។ ភ្លាមៗនោះពួកគេបានបាញ់កាំភ្លើងទៅលើអាកាស បញ្ជាប្រជាជនឲ្យចាកចេញពីទីក្រុងដោយអះអាងថាអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក ។ ដូចអ្នកឯទៀតដែរ ខ្ញុំបានប្រញាប់ប្រញាល់ធ្វើដំណើរចាកចេញនៅម៉ោងដប់ជាមួយបងប្រុសខ្ញុំ មិត្តភក្តិនៅវត្តជាមួយខ្ញុំនិងលោកសង្ឃ ។ នៅលើផ្លូវដ៏ណែនណាន់តាន់តាប់ ខ្ញុំឮសូរសំឡេងមនុស្សម្នាស្រែកហៅរកឪពុកម្តាយនិងបងប្អូននិងសម្រែកក្មេងៗយំទាររកបាយ ។ ខ្មែរក្រហមបានរឹបអូសយករបស់របរប្រជាជន ។ អ្នកដែលជំទាស់មិនព្រមឲ្យនឹងត្រូវសម្លាប់ឬក៏ចាប់ខ្លួនយកទៅបាត់ ។



មេដឹកនាំកម្ពុជាប្រជាធិបតេយ្យជួបជាមួយគណៈប្រតិភូបរទេស

នៅពេលដែលខ្ញុំកំពុងតែដើរ ទ័ពខ្មែរក្រហមស្រីម្នាក់បានទាញកអាវខ្ញុំ ហើយសួរខ្ញុំថា ជាអតីតទាហានឬ? គាត់រុញខ្ញុំថយក្រោយវិញ នៅពេលដែលខ្ញុំប្រាប់គាត់ថាខ្ញុំជាកូនសិស្ស ។ ខ្ញុំក៏បានបន្តដំណើររបស់ខ្ញុំទៅក្រុងតាខ្មៅ ។ នៅតាមផ្លូវ ខ្ញុំបានឃើញសាកសពដែលទើបតែហើមថ្មីៗជាច្រើន ។ បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលបីថ្ងៃ ខ្ញុំបានមកដល់ខេត្តតាកែវ ។

មិនមានការលើកលែងណាមួយទេនៅក្នុងការជម្លៀសនេះ ។ អ្នកជំងឺត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យ ។ អ្នករៀសខ្លួនរាប់ពាន់នាក់ ជាពិសេសកូនក្មេង ចាស់ជរា និងអ្នកជំងឺបានស្លាប់នៅតាមផ្លូវ ។ ស្ត្រីមានផ្ទៃពោះជាច្រើនបានស្លាប់នៅពេលសម្រាលកូន ដោយសារគ្មានថ្នាំនិងសេវាសុខាភិបាល ។ កូនក្មេងបានវង្វេងបាត់ពីឪពុកម្តាយ ហើយប្រជាជនភាគច្រើនមិនដឹងថាតើមានអ្វីកំពុងតែកើតឡើងនោះទេ ។

សូ រី ប្រជាជនរស់នៅខេត្តតាកែវក៏បានរំឭកពីព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ ។ ប្តីរបស់ សូ រី គឺជាទាហានរបស់របបសាធារណរដ្ឋខ្មែរដែលត្រូវរបួសត្រង់ភ្លៅក្នុងពេលប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហម ហើយត្រូវបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យភ្នំពេញ ។ សូ រី បានរៀបរាប់ថាៈ

កងទ័ពខ្មែរក្រហមបានបញ្ជាឲ្យពួកយើងចេញពីទីក្រុង ។ ខ្ញុំនិយាយថា "ខ្ញុំមិនអាចទៅបានទេ ព្រោះខ្ញុំកំពុងមានផ្ទៃពោះ ហើយប្តីខ្ញុំមានរបួសធ្ងន់" ។ ពួកគេនៅតែបង្ខំឲ្យយើងចាកចេញ ។ ពួកយើងយំអើយយំ ព្រោះប្តីខ្ញុំដើរមិនរួច ។ បន្ទាប់មក យើងរកបានរទេះមួយ ។ ខ្ញុំគ្រាហ៍ប្តីខ្ញុំដាក់លើរទេះ ហើយបានដាក់ក្រមាទាក់កអូសប្តីខ្ញុំបន្តទៀត ។ យើងចង់ទៅតាកែវ តែខ្មែរក្រហមបានបង្ខំឲ្យយើងធ្វើដំណើរទៅមុខបន្តទៀតតាមផ្លូវជាតិលេខ៥ ។ យើងឆ្លងកាត់ព្រែកក្តាម ហើយក៏ឈប់ដាំបាយហូប ។ ពេលហូបបាយហើយគេប្រាប់យើងឲ្យទៅមុខទៀត ។ ខ្ញុំអូសរទេះឡើងលោកក្រលៀនអស់ហើយ ។ នៅតាមផ្លូវ ប្តីខ្ញុំត្រូវគេចាប់យកទៅសម្លាប់ចោល ។ ខ្ញុំយំខ្លាំងណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច ។ ខ្ញុំបានទៅដល់ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ មួយខែក្រោយមក ខ្ញុំឆ្លងទន្លេបានកូនស្រីមួយ ។


អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង(ភ្នំពេញ) ខែមេសា ឆ្នាំ១៩៧៥

ខ្មែរក្រហមបានពន្យល់ហេតុផលជាច្រើនអំពីមូលហេតុដែលអង្គការត្រូវបណ្តេញប្រជាជនទាំងអស់ឲ្យចេញពីទីក្រុង ។ ក្នុងអំឡុងពេលជម្លៀស ខ្មែរក្រហមបានប្រាប់ប្រជាជនថាសហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅភ្នំពេញ ហើយថាប្រជាជនមិនចាំបាច់ចាក់សោផ្ទះទេ ព្រោះថាប្រជាជនទាំងអស់នឹងអាចត្រឡប់មកវិញក្នុងរយៈពេលពីរ-បីថ្ងៃទៀត ។

អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យក្រោយមកបានពន្យល់ហេតុផលនៃការជម្លៀសថា បណ្តាលមកពីកង្វះខាតសម្ភារនិងមធ្យោបាយដឹកជញ្ជូនដើម្បី

ដឹកម្ហូបអាហារមកកាន់ទីក្រុង ។ ប៉ុល ពត នៅក្នុងពេលបំពេញទស្សនកិច្ចនៅប្រទេសចិននៅខែតុលា ឆ្នាំ១៩៧៧ បាននិយាយថាមូលហេតុនៃការជម្លៀសប្រជាជនគឺដើម្បីបំបែកក្រុមចារកិច្ចរបស់ខ្មាំង ។

ប្រវត្តិវិទូភាគច្រើនបានយល់ស្របថា ខ្មែរក្រហមមានការប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសរបស់កសិករនិងពលករដែលក្នុងនោះអំពើពុករលួយ សក្តិភូមិនិយមនិងមូលធននិយមនឹងត្រូវលុបបំបាត់ចោលទាំងស្រុង ។ ខ្មែរក្រហមយល់ឃើញថាប្រជាជននៅទីក្រុងនិងទីប្រជុំជននានាជាមនុស្សមិនស្អាតស្អំ ហើយមានតែកសិករនៅតាមទីជនបទប៉ុណ្ណោះដែលស្អាតស្អំគ្រប់គ្រាន់សម្រាប់បដិវត្តន៍របស់ខ្លួន ។

បន្ទាប់ពីការជម្លៀសបានបញ្ចប់ ទីក្រុងភ្នំពេញបានក្លាយទៅជា «ទីក្រុងខ្មោច» ដែលមានមនុស្សរស់នៅប្រហែលបួនម៉ឺននាក់ប៉ុណ្ណោះ ។ អ្នកដែលបន្តស្ថិតនៅក្នុងទីក្រុងគឺសុទ្ធតែជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ កងទ័ព និងកម្មកររោងចក្រ ។ មានហាងលក់ទំនិញតែមួយគត់នៅក្នុងទីក្រុង(ផ្សារធំថ្មី) ដែលបើកលក់សម្រាប់អ្នកការទូត ។ ខ្មែរក្រហមបានឯកោប្រទេសពីពិភពលោកខាងក្រៅ ។ ខ្មែរក្រហមមិនបើកទូលាយឲ្យជនបរទេសចូលមកក្នុងប្រទេសទេ ហើយក៏មិនបើកទូលាយឲ្យប្រជាជនខ្មែរចាកចេញពីប្រទេសដែរ ។

ពីរ-បីថ្ងៃបន្ទាប់ពី ប៉ុល ពត និងកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានធ្វើដំណើរចូលមកទីក្រុងដ៏ស្ងាត់ជ្រងំនេះ ក្រុមខ្មែរក្រហមបានរៀបចំពិធីបុណ្យរំឭកវិញ្ញាណក្ខន្ធចំពោះអ្នកដែលបានពលីជីវិតក្នុងអំឡុងពេលសង្គ្រាម ។ នៅទីក្រុងប៉េកាំងឯណោះវិញ មានមនុស្សជាងមួយម៉ឺននាក់និងមន្ត្រីជាន់ខ្ពស់ចិនជាច្រើនរូបបានប្រារព្ធពិធីជ័យជម្នះរបស់កងទ័ពកុម្មុយនីស្តកម្ពុជាលើរដ្ឋាភិបាលសាធារណរដ្ឋខ្មែរដែលគាំទ្រដោយសហរដ្ឋអាមេរិក ។

ទោះជាយ៉ាងណាក៏ដោយ ក៏សម្តេចព្រះនរោត្តម សីហនុ មេដឹកនាំមានតែឈ្មោះរបស់កងទ័ពបដិវត្តន៍មិនបានចូលរួមក្នុងពិធីនេះទេ ។ ព្រះអង្គគង់នៅក្បែរព្រះមាតារបស់ព្រះអង្គ គឺព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន សិរីវឌ្ឍនា ដែលកំពុងតែប្រឈួនជាទម្ងន់នៅទីក្រុងប៉េកាំង ។ ក្នុងអំឡុងពេលគង់នៅនិរទេសខ្លួន នៅទីក្រុងប៉េកាំងតាំងពីឆ្នាំ១៩៧០ រដ្ឋាភិបាលកុម្មុយនីស្តចិនបានថ្វាយព្រះអង្គនូវការគាំទ្រទាំងផ្លូវនយោបាយនិងផ្លូវចិត្ត ព្រមទាំងភូមិគ្រឹះប្រកបដោយផាសុកមួយទៀតផង ។ ក្រោយមកព្រះអង្គបានធ្វើសេចក្តីថ្លែងការណ៍មួយកោតសរសើរពីជ័យជម្នះរបស់ខ្មែរក្រហម ។ **(នៅមានត)**

**ឌី ខាំបូលី**



កម្មាភិបាលខ្មែរក្រហមនៅវាលស្រែ

# សេចក្តីរំពឹងទុកចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ហ៊ុល វី មានអាយុ៤៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងឃុំព្រែករកា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកម្តាយរបស់ វី ត្រូវស្លាប់ដោយជរាពាធ ។ ចំណែកបងប្អូន៧នាក់ក្នុងចំណោមបងប្អូន១១នាក់របស់គាត់បានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយមិនដឹងពីមូលហេតុពិតប្រាកដ ប៉ុន្តែ វី នៅតែមានសង្ឃឹមថាការស្លាប់របស់បងប្អូនរបស់គាត់នឹងអាចរកឃើញដោយអង្គជំនុំជម្រះវិសាមញ្ញនៅពេលឆាប់ខាងមុខនេះ ។



ហ៊ុល វី អាយុ ៤៨ឆ្នាំ

ក្រឡេកមើលទៅរយៈកាលជាង៣០ឆ្នាំមុន វី គ្រាន់ជាកុមារីម្នាក់ដែលបានទទួលការអប់រំត្រឹមថ្នាក់កុមារដ្ឋានប៉ុណ្ណោះ ពីព្រោះតាំងពីពេលដឹងក្តីមក វី ស្ថិតនៅក្នុងមជ្ឈដ្ឋានមួយដែលរីករាលដោយសង្គ្រាម ។ ភូមិស្រុកកំណើតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជាទីតាំងសមរភូមិប្រយុទ្ធក្តៅគគុករវាងកងទ័ពរំដោះ (ជាក្រុមអ្នកតស៊ូគាំទ្រសម្តេចសីហនុ ប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ) និងទាហានលន់នល់ ដែលជាមូលហេតុធ្វើឲ្យការរស់នៅរបស់ វី ត្រូវផ្លាស់ប្តូរទីកន្លែងជាញឹកញាប់ ។ ថ្វីដ្បិតតែស្រុកនេះមានព្រំប្រទល់ជាប់នឹងទីក្រុងភ្នំពេញ ប៉ុន្តែ វី មិនដែលស្គាល់ភ្នំពេញម្តងណាឡើយ សូម្បីតែបងប្អូនសាច់ញាតិដែលរស់នៅទីក្រុងភ្នំពេញក៏មិនអាចទាក់ទងគ្នាបានដែរ ។

ចាប់តាំងពីសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧០មក ក្រុមគ្រួសាររបស់ វី និងប្រជាជននៅក្នុងភូមិត្រូវបានជម្លៀសចេញដោយកងទ័ពរំដោះជាច្រើនលើកច្រើនសាដើម្បីគេចចេញពីការវាយប្រយុទ្ធគ្នា ។ នៅពេលដែលសភាពការណ៍ប្រយុទ្ធនៅក្នុងភូមិមានភាពស្ងប់ស្ងាត់ ប្រជាជនទាំងអស់បានវិលត្រឡប់មកផ្ទះសម្បែងរៀងៗខ្លួន ។ រាល់ពេលភៀសខ្លួនចេញម្តងៗបងប្អូនប្រជាជនអាចយកគ្រឿងឧបភោគជាប់ខ្លួនបានត្រឹមតែម្ហូបអាហារក្រៀមៗអង្ករនិងរបស់របរបន្តិចបន្តួចប៉ុណ្ណោះ នៅពេលខ្លះគាត់និងអ្នកភូមិត្រូវភៀសខ្លួននៅរដូវច្រូតកាត់ទាំងមិនទាន់បានច្រូតកាត់ផង ដូច្នេះទើបប្រជាជនទាំងអស់សម្រេចចិត្តត្រឡប់មកវិញដើម្បីមើលថែទាំជ្រូក មាន់ ទា ទ្រព្យសម្បត្តិ ផ្ទះសម្បែងនិងស្រែចម្ការច្បារដំណាំវិញ ។ ប្រជាជនទាំងអស់ដែលរស់នៅក្នុងតំបន់រំដោះ និងមានអាយុពេញវ័យចាប់ពី១៨ឆ្នាំឡើងទៅត្រូវបានកែនឲ្យធ្វើជាកងឈ្លបជាពិសេសយុវជនតែម្តង ។ បងប្អូន វី មួយចំនួនដែលពេញវ័យត្រូវបានកេណ្ឌធ្វើជាកងទ័ព ។ នៅក្នុងឆ្នាំ១៩៧៣ បងប្រុសបង្អស់ដែលមានអាយុ២០ឆ្នាំត្រូវបានបង្ខំឲ្យលាចាកពីសង្ឃមកធ្វើកងឈ្លបរបស់ខ្មែរក្រហម ។

ឆ្នាំ១៩៧៥ ពេលដែលកងទ័ពរំដោះទទួលជ័យជម្នះទាំងស្រុង ក្រុមគ្រួសាររបស់ វី និងប្រជាជនដែលមានដើមកំណើតនៅក្នុងតំបន់រំដោះទាំងអស់មិនត្រូវបានជម្លៀសទៅកន្លែងណាទេ ហើយត្រូវបានចាត់ទុកថាជាប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន ។ ប្រជាជនមូលដ្ឋានមានជីវភាពរស់នៅទាំងការងារនិងការហូបចុកប្រសើរជាងប្រជាជនជម្លៀសដែលមានងារថាជា "ប្រជាជនថ្មី ឬប្រជាជន១៧មេសា" ។ នៅក្នុងឆ្នាំដដែលនេះ វី បានទទួលសំបុត្រមួយច្បាប់ពីសមរភូមិមុខប្រាប់ថា បងប្រុសទីមួយដែលធ្វើទ័ពបានស្លាប់នៅក្នុងសមរភូមិប្រយុទ្ធ ហើយត្រូវបានយកមកកប់នៅវាលបញ្ចុះសពយុវជនពលីស្រុកកណ្តាលស្ទឹង ដែលពីមុនកន្លែងនោះគឺជាសាលាវិក្រិត្យការភូមិភាគស្រុកកណ្តាលស្ទឹង ហើយនៅក្នុងសម័យប៉ុលពតកន្លែងនេះត្រូវបានប្រែក្លាយទៅជាគុកសម្រាប់ឃុំឃាំងអ្នកទោសដែលមានឈ្មោះថា "មណ្ឌលអប់រំឬក៏គុកសង្ឃ" ។ វី ត្រូវអង្គការតែងតាំងជានារីពេទ្យប្រចាំតំបន់ដែលខ្លួនរស់នៅ ដោយសារតែគាត់ជាប្រជាជនមូលដ្ឋាននិងមានបងប្អូនច្រើននាក់ធ្វើជាកងទ័ព ។

រហូតមកដល់ឆ្នាំ១៩៧៧ ផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យមានការប្រេះស្រាំ ហើយភូមិភាគផ្សេងៗ

ទៀតមានការមិនទុកចិត្តគ្នានិងមានការផ្លាស់ប្តូរមនុស្សជាញឹកញាប់ ព្រមទាំងមានការកើនឡើងនូវការសម្លាប់រង្គាលទៀតផង ។ ប្រជាជនចាស់និងប្រជាជនថ្មីត្រូវបានសួរនាំពីប្រវត្តិរូបផ្ទាល់ខ្លួន និងធ្វើជីវទស្សន៍ជាញឹកញាយ ។ បន្ទាប់ពីមានការប្រជុំសម្ងាត់មួយ (ដែលមានសមាជិក៣-៤នាក់) វី ត្រូវបានដកពីមុខតំណែងជាបុគ្គលិកពេទ្យទៅធ្វើការនៅក្នុងកងកុមារវិញ ដែលគាត់មិនបានដឹងថា ខ្លួនឯងមានកំហុសអ្វីឡើយ ព្រោះថាពេលនោះគាត់ទើបតែមានអាយុ១៧ឆ្នាំប៉ុណ្ណោះ ។ ក្រោយមកទើបគាត់ដឹងថាខ្លួនមានប្រវត្តិរូបមិនល្អដោយសារតែមានសាច់ញាតិរស់នៅភ្នំពេញ ម្យ៉ាងទៀតបងប្អូនជីដូនមួយម្នាក់ត្រូវបានជាប់ឃុំឃាំងនៅក្នុងគុកសង់ទន្ទេបាទី ពីបទខុសសីលធម៌ ហើយក្រោយមកទៀតប្អូនរបស់គាត់ក៏ត្រូវបានចាប់បញ្ជូនទៅឃុំឃាំងនៅគុកសង់ទន្ទេបាទីដែរ ។ វី មានវាសនាមិនខុសពីកុមារដទៃទៀតឡើយ គាត់ត្រូវអង្គការបង្ខំឲ្យធ្វើការងារផ្សេងៗ ដូចជាកាប់ទន្រ្ទានខែត្រ កាប់រណ្តៅធំៗ ធ្វើជីនិងកាប់ដំបូកជាដើម ។ ដោយសារតែ វី មានអាយុច្រើនជាងក្មេងដទៃទៀត អង្គការក៏បានឲ្យគាត់ដឹកនាំក្មេងៗធ្វើការ ប៉ុន្តែ វី លែងមានសិទ្ធិទៅប្រជុំក្រុមស្នូលដូចមុនទៀតហើយ ។ ចាប់តាំងពីពេលនោះមក គ្រួសាររបស់គាត់ត្រូវបានបំបែកឲ្យទៅធ្វើការងារតាមកងរៀងៗខ្លួន ឪពុក-ម្តាយ បងប្អូនរបស់គាត់ក៏លែងបានជួបមុខគ្នា និងលែងបានឮដំណឹងពីសុខទុក្ខដូចមុនទៀត ។ សូម្បីតែជីដូនរបស់ វី ដែលមានជំងឺធ្ងន់ធ្ងរ ក៏អង្គការថ្នាក់លើមិនអនុញ្ញាតឲ្យគាត់មកជួបជីដូនដែរ ។

វី មានវិប្បដិសារីយ៉ាងខ្លាំង ដោយសារតែសមាជិកនៅក្នុងគ្រួសារ ព្រមទាំងបងប្អូនសាច់ញាតិជិតឆ្ងាយជាច្រើននាក់បានស្លាប់នៅក្នុងជំនាន់ប៉ុលពតដោយមិនបានដឹងពីមូលហេតុពិតប្រាកដ ។ សព្វថ្ងៃ វី នៅសល់តែបងប្អូន៤នាក់ប៉ុណ្ណោះ ។ វី បានរៀបការជាមួយបងប្អូនជីទួតមួយឈ្មោះ កូ យ៉េន អាយុ៤២ឆ្នាំ ដែលរស់នៅស្រុកកំណើតជាមួយនឹងគ្នា ។

ជាចុងក្រោយ វី សង្ឃឹមថា មានតែតុលាការដែលបានបង្កើតឡើងសម្រាប់កាត់ទោសក្រុមមេដឹកនាំខ្មែរក្រហមទេ ដែលអាចដឹងពីមូលហេតុនៃការស្លាប់ពិតប្រាកដរបស់សាច់ញាតិគាត់ ។ គាត់ជឿជាក់យ៉ាងមុតមាំថា តុលាការពិតជាអាចស្វែងរកយុត្តិធម៌ជូនគាត់និងប្រជាជនខ្មែរទូទាំងប្រទេសដែលបានឆ្លងកាត់របបដ៏ខ្មៅងងឹតនោះ ដោយសារតែមានការសហការរវាងអន្តរជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។

**គង់ សុភគឿន**

# ដំណឹងសួររកបងប្រុស

នាងខ្ញុំឈ្មោះ ប៉ិត កូយ ហៅអឿន សព្វថ្ងៃរស់នៅភូមិផ្លាំង ឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប ។ កាលពីមុននាងខ្ញុំមានស្រុកកំណើតនៅភូមិចក្រី ឃុំត្រីញ៉រ ស្រុកពួក ។ សូមសួររកបងប្រុសម្នាក់ឈ្មោះ ប៉ិត ឌី ដែលបានបែកគ្នាតាំងពីកងទ័ពខ្មែរក្រហមចូលជម្លៀសប្រជាជនចេញពីភូមិ ។ នាងខ្ញុំមានបងប្អូន៨នាក់ ឈ្មោះ ឌី, ឌឿន, ឌី, កូយ, ម៉ៅ, ដ័ន, គឿន និងឈួយ ។ ឪពុកឈ្មោះ ប៉ិត និងម្តាយឈ្មោះ ស្វាយ ដួន ។

ឌី ធ្លាប់បានផ្ញើសំបុត្រ និងរូបថតមកផ្ទះម្តងកាលពីឆ្នាំ១៩៧៩ តាមរយៈអ្នកភូមិធ្លាប់ស្គាល់គ្នានៅជំរំសាយធូ ប្រទេសថៃ។ នៅក្នុងសំបុត្រ គាត់បានប្រាប់ថា គាត់មានប្រពន្ធនៅខេត្តបាត់ដំបង ប៉ុន្តែរហូតមកដល់ឥឡូវនេះពុំដែលឃើញគាត់មកលេងស្រុកកំណើតឡើយ ។

ដូច្នេះបើបងបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាបានស្គាល់ឈ្មោះនេះ សូមទាក់ទងតាមលេខទូរស័ព្ទ ០១២ ៩៦៧ ៩១៣ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ឬតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# យុវជនកម្ពុជាសញ្ជឹងគិតនៅរកការផ្សះផ្សាជាតិ

យុវជនកម្ពុជាកំពុងតែចាប់ផ្តើមចូលរួមចំណែកក្នុងការជជែកពិភាក្សាយ៉ាងសកម្មនិងមានសារសំខាន់ចំពោះប្រទេសជាតិ អំពីវិធីដែលអ្នកនៅរស់មានជីវិតនិងប្រទេសទាំងមូលអាចជាសះស្បើយពីស្លាកស្នាមនៃអំពើប្រល័យពូជសាសន៍ដែលបានកើតមានឡើងកាលពី៣០ឆ្នាំមុន ។ ក្នុងខណៈពេលកំពុងពិភាក្សាអំពីវិធីដែលជនរងគ្រោះនិងជនដៃដល់នៃអំពើប្រល័យពូជសាសន៍កម្ពុជាអាចផ្សះផ្សាជាមួយគ្នា, ដំបូងសិស្សម្នាក់ជឿជាក់ថា វាមិនអាចទៅរួចទេ ប៉ុន្តែក្រោយមកមានយោបល់ថា ជំហានដំបូងអាចចាប់ផ្តើមដោយការនិយាយទល់មុខគ្នា ។ យោបល់នេះនិងយោបល់ផ្សេងទៀតត្រូវបានបញ្ជាក់ក្រោយពីការបញ្ចាំងភាពយន្តឯកសារមួយដែលមានចំណងជើងថា «នៅកៀនជញ្ជាំងមន្ទីរស-២១ៈ ប្រវត្តិសាស្ត្រផ្ទាល់មាត់ពីគុកទួលស្លែង» ។ ភាពយន្តឯកសារនេះគឺជាផ្នែកមួយនៃកម្មវិធីដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសមាគមយុវជនកម្ពុជាដែលផ្តោតទៅលើការអប់រំអំពើប្រល័យពូជសាសន៍ ។ លទ្ធផលមួយដែលសំខាន់របស់កម្មវិធីនេះគឺជាការសញ្ជឹងគិតយ៉ាងម៉ឺងម៉ាត់របស់យុវជនកម្ពុជាទៅលើបញ្ហាដូចជាយុត្តិធម៌និងការផ្សះផ្សាជាតិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីអប់រំស្តីពីអំពើប្រល័យពូជសាសន៍ជាមួយសិស្សអស់រយៈពេលជាច្រើនឆ្នាំមកហើយ តាមរយៈសកម្មភាពមួយចំនួនដែលមានកម្មវិធីសិស្សស្ម័គ្រចិត្តនៅពេលវិស្សមកាលនិងដំណើរទស្សនកិច្ចទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ក្នុងកម្មវិធីពិសេសនេះមានសិស្សវិទ្យាល័យនិងមហាវិទ្យាល័យមកពីខេត្តចំនួន៧ (បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម ព្រៃវែង សៀមរាប ស្វាយរៀង និងតាកែវ) បានមកទស្សនាមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បូជនីយដ្ឋានវាលពិឃាតជើងឯក និងអគារអង្គជំនុំជម្រះវិសាមញ្ញកម្ពុជាដែលជាកន្លែងសម្រាប់ធ្វើការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមក្នុងពេលឆាប់ៗនេះ ។ នៅក្នុងខែកក្កដា ឆ្នាំ២០០៧នេះ កម្មវិធីសិក្សាបីត្រូវបានរៀបចំឡើងសម្រាប់និស្សិតបីក្រុមខុសៗគ្នាដែលមាននិស្សិតសរុបទាំងអស់១៨៦នាក់ ។

ភាពចាំបាច់សម្រាប់កម្មវិធីនេះគឺមិនអាចរៀបរាប់ឲ្យអស់សេចក្តីបានទេ ។ បីទសវត្សរ៍បានកន្លងផុតទៅហើយក៏ដោយ ការរៀនសូត្រអំពីរបបកម្ពុជាប្រជាធិបតេយ្យ (ឈ្មោះជាផ្លូវការរបស់រដ្ឋាភិបាលខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩) នៅមិនទាន់បានបញ្ចូលជាផ្លូវការទៅក្នុងកម្មវិធីសិក្សានៅឡើយទេ ដែលធ្វើឲ្យយុវជនកម្ពុជាដឹងតិចតួចពីអ្វីដែលកើតមានឡើងតែម្តងពីរឿងខ្លីៗផ្ទាល់ខ្លួន តាមរយៈការនិទានប្រាប់របស់ឪពុកម្តាយប៉ុណ្ណោះ ។ យុវជនកម្ពុជាដែលបានដឹងឮអំពើប្រល័យពូជសាសន៍តាមរយៈឪពុកម្តាយនិយាយអំពីការធ្វើការដោយបង្ខំ កង្វះខាតចំណីអាហារ កង្វះខាតការថែទាំសុខភាព និងការសម្លាប់ដោយបំពាន ។ យុវជនមួយចំនួនជឿឪពុកម្តាយ ខណៈពេលដែលយុវជនមួយចំនួនផ្សេងទៀតគ្រាន់តែជឿខ្លះៗ ហើយនិងសង្ស័យថា ឪពុកម្តាយរបស់ខ្លួននិយាយបំផ្លើស ។ យុវជនកម្ពុជាជាច្រើនដែលមានកំណើតក្រោយអំពើប្រល័យពូជសាសន៍សួរសំណួរអំពីថាតើឪពុកម្តាយខ្លួនអាចរស់រានមានជីវិតដោយរបៀបណា បើគាត់ធ្វើការងារដ៏សែនលំបាកខណៈពេលគាត់បរិភោគបបររាវៗដែលគាត់ទទួលបានយ៉ាងស្តួចស្តើងបំផុតនោះ ។ ជាអកុសល ការពិតគឺថាប្រជាជនជាច្រើនបានត្រូវស្លាប់ ហើយអ្នកដែលនៅរស់គឺបានទទួលនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។

ដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរទួលស្លែងនិងបូជនីយដ្ឋានវាលពិឃាតជើងឯកជួយបញ្ជាក់ឲ្យយុវជនកម្ពុជាយល់ថា អំពើប្រល័យពូជសាសន៍យ៉ាងកំរោលនិងព្រៃផ្សៃពិតជាកើតមានមែន ។ ការស្តាប់ឮសម្តីរបស់មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅឯបន្ទប់សវនាការអំពីយុត្តិធម៌តាមផ្លូវច្បាប់សម្រាប់ប្រជាជនដែលបានរួចផុតពីរបបខ្មែរក្រហមក៏បានបញ្ជាក់ពីបទពិសោធន៍គួរឲ្យរន្ធត់របស់ឪពុកម្តាយុវជនកម្ពុជាទាំងនោះដែរ ជាសង្ខេប សិស្សវិទ្យាល័យនិងមហាវិទ្យាល័យដែលបានចូលរួមកម្មវិធីនេះ ទោះបីជាអ្នកទាំងនេះមិនបានដឹងពីរឿងខ្មែរក្រហមពីមុនមកក៏ដោយ ក៏តាម

រយៈដំណើរទស្សកិច្ចនេះគេចាប់ផ្តើមយល់ដឹងអំពីមហាវិនាសកម្ម និងជាផលវិបាកដែលធ្លាក់មកលើប្រទេសកម្ពុជាដែរ ។ ចេញពីការសម្ភាសន៍ជាច្រើនជាមួយអ្នកដែលនៅរស់ ប្រជាជនភាគច្រើនបានបញ្ចេញយោបល់ថា ការអប់រំយុវជនអំពីការសម្លាប់គឺសំខាន់ណាស់មិនត្រឹមតែជាប្រវត្តិសាស្ត្រមួយដែលយុវជនគួរតែដឹងនោះទេ ថែមទាំងការអប់រំនេះនឹងអាចជួយការពារកុំឲ្យការសម្លាប់បែបនេះកើតមានម្តងទៀត ។ បច្ចុប្បន្ន ការអប់រំនេះកាន់តែមានសារសំខាន់ពីព្រោះតែយុវជនកម្ពុជាអាចមានដើរតួនៅក្នុងការផ្សះផ្សាជាតិ ។ ការផ្សះផ្សាជាតិនៅកម្ពុជាអាចមានអត្ថន័យច្រើននិងអាចសម្រេចបានដោយវិធីខុសៗគ្នា ។ ជាលទ្ធផលនៃបរិបទរបស់របបខ្មែរក្រហមគឺអាចមានន័យពីការផ្សះផ្សាផ្ទាល់ខ្លួន ការផ្សះផ្សារវាងជនរងគ្រោះនិងជនដៃដល់ ឬក៏ការផ្សះផ្សាជាតិទៅនឹងអតីតកាល ។

ភាពយន្តឯកសារនៅកៀនជញ្ជាំងមន្ទីរស-២១ៈ ប្រវត្តិ-សាស្ត្រផ្ទាល់មាត់ពីគុកទួលស្លែង តម្រូវឲ្យអ្នកស្តាប់ធ្វើការពិនិត្យបញ្ហារវាងជនរងគ្រោះនិងជនដៃដល់រួមទាំងការផ្សះផ្សាជាតិ ។ ខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រដែលបាននាំអតីតអ្នកទោសពីរនាក់ ជុំ មុី និង ប៊ូ ម៉េង និងអតីតឆ្មាំគុកទួលស្លែង ហុឹម ហ៊ុយ ។ គុកដ៏សំខាន់នេះជាគុកកម្រិតខ្ពស់បំផុតរបស់ ប៉ុល ពត សម្រាប់ដាក់ទោសឧក្រិដ្ឋធ្ងន់ធ្ងរ ។ នៅក្នុងការចាប់ផ្តើមរបស់ភាពយន្តនេះ បុរសម្នាក់ៗនិយាយអំពីប្រវត្តិរូបសង្ខេបផ្ទាល់ខ្លួនបូករួមទាំងឋានៈគ្រួសារនិងការងារ ។ បន្ទាប់មកអ្នកទាំងនោះបរិយាយអំពីព្រឹត្តការណ៍ដែលនាំទៅដល់ការដាក់គុកហើយករណីរបស់ ហុឹម រៀបរាប់អំពីរបៀបដែល ហុឹម ទទួលបានតួនាទីជាឆ្មាំជាន់ខ្ពស់នៅក្នុងគុក ។ នៅខណៈដែលបុរសបីនាក់បានរ៉ាយរ៉ាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនម្នាក់ៗវាបានក្លាយទៅជាការបញ្ជាក់យ៉ាងច្បាស់ដែលថាមានបញ្ហាផ្សេងៗគ្នានៅក្នុងរឿងរបស់ម្នាក់ៗ ។

ជាចុងក្រោយរូបភាពទឹកមុខដ៏មុឹងម៉ាត់របស់អតីតឆ្មាំគុក ហុឹម ហ៊ុយ បានលេចឡើងនៅលើអេក្រង់ ។ ក្រោយខ្សែភាពយន្តនេះបញ្ចាំងចប់សិស្សត្រូវបានលើកទឹកចិត្ត ណែនាំឲ្យគិតនិងផ្តល់យោបល់ទៅលើការរៀបរាប់របស់អ្នកផ្តល់បទសម្ភាសន៍ម្នាក់ៗ និងធ្វើការពិចារណានៅក្នុងវិធីដែលជនរងគ្រោះនិងជនដៃដល់ សង្គមនិងប្រទេសជាតិទាំងមូលដែលអាចទទួលបានការផ្សះផ្សា ។ ការផ្លាស់ប្តូរទស្សនៈត្រូវបានបញ្ចេញ ។ សិស្សមួយចំនួនយល់ឃើញថាជនរងគ្រោះគឺត្រូវជានិច្ច ហើយអតីតកម្មាភិបាលខ្មែរក្រហមគឺខុសជានិច្ចដោយមិនគិតពីហេតុផលការពារខ្លួនដែលជនដៃដល់បានផ្តល់ឲ្យនោះទេ ។ ផ្នត់គំនិតនេះអាចឲ្យយល់បានពីភាពព្រៃផ្សៃដែលបានកើតឡើងនិងជាលទ្ធផលនៃអារម្មណ៍អវិជ្ជមានចំពោះអតីតទាហានខ្មែរក្រហម ។



ក្រុមនិស្សិតកំពុងមើលភាពយន្តឯកសារ ៈ នៅកៀនជញ្ជាំងមន្ទីរស-២១

ចំពោះបញ្ហានៃការផ្សះផ្សាជាតិ សិស្សមួយចំនួនបញ្ជាក់ពីការដែលអាចធ្វើទៅបានគឺប្រហែលជាជួយនាំឲ្យមានការបញ្ចប់រវាងជនរងគ្រោះនិងអ្នកប្រព្រឹត្តបទឧក្រិដ្ឋ ។ សិស្សជាច្រើនជឿជាក់ថា ការផ្សះផ្សាជាតិត្រូវតែចាប់ផ្តើមដំបូងជាមួយបុគ្គលម្នាក់ៗ ។

ផេង សុភា ជាសិស្សវិទ្យាល័យព្រែកសណ្តែកក្នុងខេត្តតាកែវ ជាដំបូងជឿថា ការផ្សះផ្សារវាងជនរងគ្រោះនិងអ្នកប្រព្រឹត្តបទឧក្រិដ្ឋគឺជាការមិនគួរឲ្យជឿ «ការផ្សះផ្សាគឺស្មុគស្មាញ

ពេករហូតដល់មិនអាចរកដំណោះស្រាយដើម្បីឲ្យជនរងគ្រោះនិងអ្នកប្រព្រឹត្តបទឧក្រិដ្ឋផ្សះផ្សាជាមួយគ្នា» ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយពេលឲ្យមានការគិតបន្ថែមលើបញ្ហានេះ ផេង សុភា បានបន្ថែមថា ការនិយាយទល់មុខគ្នាដោយផ្ទាល់រវាងជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហមអាចមានប្រយោជន៍ក្នុងជំហានដំបូង ។ សិស្សស្រីម្នាក់បានលើកឡើងពីបញ្ហាស្ថានភាពលំបាករបស់ ហ៊ឹម ហ៊ុយ ដែលត្រូវបានបង្ខំឲ្យធ្វើការនៅគុក ហើយបានសួរបែបវោហារសាស្ត្រថា «ប្រសិនបើអ្នកគឺជា ហ៊ឹម ហ៊ុយ តើអ្នកហ៊ានជំទាស់និងបញ្ជារបស់មេរបស់អ្នកទេ?» ក្នុងការឆ្លើយតប សិស្សមួយចំនួនបាននិយាយថា កម្មាភិបាលខ្មែរក្រហមពិតប្រាកដបានស្តាប់តាមការបញ្ជារបស់មេដឹកនាំ ដូច្នេះអាចបញ្ជាក់ថាកម្មាភិ-បាលខ្មែរក្រហមគឺគួរឲ្យជឿជាក់និងអង់អាច ។

អេង គឹម ជាគ្រូមធ្យមសិក្សានៅក្នុងខេត្តព្រៃវែងបាននិយាយអំពីវិធីនិយាយដោយផ្ទាល់រវាងជនរងគ្រោះនិងអតីតកម្មា-ភិបាលខ្មែរក្រហមនៅក្នុងភូមិរបស់គាត់បានជួយធ្វើឲ្យទំនាក់ទំនងរបស់ភាគីទាំងពីរកាន់ល្អប្រសើរឡើង ។ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ មេក្រុមខ្មែរក្រហមមួយរូបបានបង្ខំឲ្យស្ត្រីមានផ្ទៃពោះធ្វើការយ៉ាងលំបាកដូចជាជីកប្រឡាយនិងលើកទំនប់ ។ ក្រោយរបប ប៉ុល ពត មេក្រុមខ្មែរក្រហមនិងស្ត្រីមានផ្ទៃពោះបានរស់នៅក្នុងភូមិជាមួយគ្នា ហើយមិនដែលបាននិយាយរកគ្នាឡើយ ។ នៅថ្ងៃមួយមេក្រុមខ្មែរក្រហមនិងស្ត្រីនោះបានជួបគ្នានៅក្នុងការប្រជុំ ។ នៅទីបំផុតនៅក្នុងការប្រជុំ ស្ត្រីនោះបានទម្លាយភាពស្ងៀមស្ងាត់របស់គាត់ ហើយបង្ហាញពីកំហឹងចំពោះប្រធានក្រុមម្នាក់នោះដោយហៅថាជាមនុស្សអាក្រក់ ពីព្រោះខ្មែរក្រហមម្នាក់នេះបានបង្ខំឲ្យខ្លួនធ្វើការងារធ្ងន់ធ្ងរក្នុងខណៈដែលគាត់កំពុងតែមានផ្ទៃពោះ ។ ក្នុងការការពារខ្លួន បុរសនោះបានបញ្ជាក់ថា ការដាក់ឲ្យធ្វើការធ្ងន់នេះជាតួនាទីរបស់ប្រធានក្រុមដែលត្រូវស្តាប់តាមបញ្ជារបស់មេ បើមិនដូច្នេះទេខ្លួននឹងត្រូវទទួលការស្តីបន្ទោសឬក៏អាចនឹងត្រូវសម្លាប់ ។ គឹម យល់ឃើញថា ការធ្វើតាមការប្រឈមមុខនៅក្នុងការប្រជុំស្ត្រីនិងអតីតកម្មាភិបាលខ្មែរក្រហមនាពេលឥឡូវនេះគឺនិយាយរកគ្នាជាធម្មតា ។ គឹម ជឿថាការប្រជុំនេះគឺចាំបាច់ជំរុញឲ្យស្វែងយល់គ្នារវាងអ្នកទាំងពីរនិងការចាប់ផ្តើមដំណើរការផ្សះផ្សាជាតិ ។


ក្រុមនិស្សិតកំពុងមើលភាពយន្តឯកសារ ៖ នៅកៀនជញ្ជាំងមន្ទីរស-២១

បញ្ហាផ្សេងៗទៀតដែលបានលើកឡើងក្នុងខណៈពេលពិភាក្សានៅពេលបញ្ចាំងរួមមានការប្រើប្រាស់ពាក្យ «ខ្មែរក្រហម» ។ សិស្សមួយចំនួនបង្ហាញថាពាក្យនេះ គឺជាការរើសអើង ហើយមិនគួរប្រើប្រាស់បញ្ជាក់ចំពោះបុគ្គលទាំងឡាយដែលបានបម្រើឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩ទេ ។ ក្នុងផ្លូវនយោបាយខ្មែរក្រហមគឺជាអ្នកដែលបានតស៊ូប្រឆាំងនឹងរដ្ឋាភិបាលក្នុងគោលបំណងធ្វើឲ្យដោគវាសនារបស់ប្រទេសដែលកំពុងមានបញ្ហាកាន់តែប្រសើរឡើងជាងមុន ។ បច្ចុប្បន្នពាក្យសំអាងលើអារម្មណ៍នៃកំហឹងនិងភាពទុក្ខព្រួយគឺជាសញ្ញា «ភាពគ្មានឯកភាព» នៅក្នុងសង្គម ។ សិស្សម្នាក់បានយល់ថា «កម្ពុជាប្រជាធិបតេយ្យ» គួរតែត្រូវបានប្រើជំនួសវិញនៅពេលដែលធ្វើការសំដៅទៅលើរបបដែលនាំឲ្យមានការស្លាប់ប្រជាជនកម្ពុជាចំនួនពីរលាននាក់ពីឆ្នាំ១៩៧៥-១៩៧៩ ។ ការពិភាក្សានេះបានបន្តប្រហែលរយៈមួយម៉ោងបន្ទាប់ពីបញ្ចាំងខ្សែភាពយន្តចប់ ។

**លី សុខឃាង និង កែវ ដាស៊ីល**

# ការងារជាយោធាទ័ព១១២របស់ លន់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លន់ ជាអតីតយោធារបស់អង្គភាពវរសេនាតូច១១២ក្នុងសម័យខ្មែរក្រហម ។ លន់ បានប្រឡូកក្នុងសមរភូមិជាច្រើនកន្លែង ដូចជានៅតាមណោយផ្លូវជាតិលេខ៧ និងផ្លូវជាតិលេខ៥ ប្រឆាំងនឹងរបប លន់ នល់ ហើយក៏ធ្លាប់បានចូលរួមប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាមដែរ ។

ពីកុមារភាព លន់ រៀនបានត្រឹមថ្នាក់ទី១២ នៅសាលាវត្តបឹងដូត ។ នៅឆ្នាំ១៩៧៤ ខណៈពេលដែលស្ថានភាពប្រទេសកម្ពុជាកំពុងតែមានការប្រទាញប្រទង់គ្នាខ្លាំងរវាងរដ្ឋាភិបាលលន់នល់និងកងទ័ពខ្មែរក្រហម លន់ បានចូលបម្រើបដិវត្តន៍តាមរយៈ ឈួន ជាមេឃុំសង្កើយ ស្រុកជីក្រែង ក្នុងខេត្តសៀមរាប ដែលមានគ្នាទាំងអស់ចំនួន៣០០នាក់មកពីគ្រប់ភូមិទូទាំងឃុំ ដោយអ្នកខ្លះមានប្រពន្ធនិងខ្លះនៅលីវ ។ បន្ទាប់មក លន់ បានចូលរៀនវគ្គបណ្តុះបណ្តាលនៅម្តុំកំពង់ឃ្លាំងរយៈពេលបីខែ ក្រោមការបង្ហាត់បង្រៀនពីប្រធានភូមិនិងមេឃុំ ។ មេរៀនគឺផ្តោតទៅលើប្រវត្តិសាស្ត្រដែលនិយាយពីរបបសក្តិភូមិ ប្រតិកិរិយា នាយទុនការជិះជាន់កម្លាំងពលកម្មរបស់កម្មករនិងកសិករ ។ រៀនបានរយៈពេល៤ខែ ទើបមានការបែងចែកទៅតាមផ្នែកផ្សេងៗដូចជាអ្នកខ្លះចូលខាងយោធា សេដ្ឋកិច្ច និងខាងកម្មាភិបាល ។ ចំណែកលន់ ត្រូវបញ្ចូលខាងយោធានៅអង្គភាពវរសេនាតូច១១២ ដែលមានមិត្ត បូ ជាប្រធាន។ នៅហាត់រៀនក្បួនយោធារយៈពេល៦ខែ ក្រុមរបស់ លន់ ដែលមានសមាជិក៣០នាក់ ត្រូវបញ្ជូនទៅត្រៀមតាមមាត់ទន្លេនៅកំពង់ឃ្លាំងដើម្បីស្ទាក់បាញ់កប៉ាល់របស់លន់នល់ដែលតែងតែចេញចូលញឹកញាប់ ។ ទៅដល់មាត់ទន្លេក្រុមរបស់ លន់ ត្រូវបានបែងចែកជាក្រុមតូចៗទៀត ខ្លះឡើងទូកខ្លះឡើងដើមឈើ ខ្លះឈរយាមនៅមាត់ច្រាំង ។ ពេលមានការបាញ់ផ្តក់ម្តងៗ ទាហានលន់ នល់ ក៏បាញ់តបតមកវិញដែរដោយប្រើប្រាស់អាវុធទំនើបនិងមានយន្តហោះទម្លាក់គ្រាប់បែកអមពីលើទៀតផង ។ កងទ័ពខ្មែរក្រហមមួយចំនួនត្រូវទាហានលន់នល់បាញ់ស្លាប់ទើនៅលើដើមឈើ គុម្ពស្មៅ និងនៅលើទូកក៏មាន ។ ក្រុមរបស់លន់នៅរស់តែ៦នាក់ប៉ុណ្ណោះ ។ ដោយមិនអាចទប់ទល់នឹងការប្រយុទ្ធនេះបាន លន់ ក៏លោតចុះទឹកហែលបណ្តែតខ្លួនតាមទូករហូតដល់ព្រៃប្រស់ជីក្រែង ហើយចេញពីព្រៃប្រស់ធ្វើដំណើរត្រឡប់ទៅផ្ទះវិញ ។ ក៏ប៉ុន្តែគ្រួសាររបស់ លន់ ត្រូវខ្មែរក្រហមកៀរឲ្យទៅនៅកំពង់ក្តីទៅហើយ ព្រោះថានៅក្នុងភូមិមានការប្រយុទ្ធគ្នាជាមួយនឹងទាហានលន់ នល់ ។ លន់ ក៏ត្រឡប់ទៅកំពង់ក្តីហើយបានជួបប្រពន្ធនិងកូននៅទីនោះ និងរស់នៅជុំគ្នាបាន៨ថ្ងៃដែរ ។ ក្រោយមកខាងអង្គភាពស៊ើបដឹងថា លន់ នៅរស់ក៏ហៅឲ្យត្រឡប់ចូលធ្វើការនៅក្នុងអង្គភាពវិញ ។ ហ្វឹកហាត់នៅអង្គភាពបានមួយរយៈ ទើប លន់ ត្រូវអង្គការបញ្ជូនឲ្យទៅវាយនៅសមរភូមិស្រុកភ្នំសន្ទុក ព្រៃគុយ និងសាលាវិស័យ និងបន្ទាប់មកនៅសមរភូមិមុខកំពូល អង្គរស្ស ភ្នំប្រសិទ្ធិ និងនៅព្រែកព្នៅតាមបណ្តោយផ្លូវជាតិលេខ៥ដែលជាសមរភូមិក្តៅ ។ ពេលនៅព្រែកព្នៅលន់ ស្ថិតនៅកងពលលេខ១ក្រោមការគ្រប់គ្រងរបស់តាអឿន ។ នៅទីនោះ លន់ ឡើងវាយនៅពេលយប់ ពេលខ្លះត្រូវហែលឆ្លងទឹកទៅវាយ ហើយមានអ្នកខ្លះដេកលក់នៅពេលកំពុងប្រយុទ្ធក៏មាន ។ មានពេលមួយ ខាងខ្មែរក្រហមបានបញ្ជូនមួយវរសេនាធំ៣០០នាក់ឡើងសមរភូមិ ហើយត្រូវស្លាប់ទាំងអស់ ចំណែកខាងលន់នល់ក៏ស្លាប់ដែរ ប៉ុន្តែស្លាប់តិចជាង ពីព្រោះថាខាងលន់នល់មានកងពលពិសេសទី៧ជាកងទ័ពរថក្រោះនិងជាកងដែលខ្លាំងជាងគេក្នុងចំណោមកងពលទាំងអស់ ដូច្នេះពេលដែលកងទ័ពថ្មើរជើងរបស់ខ្មែរក្រហមជួបប្រយុទ្ធជាមួយកងពលទី៧នេះម្តងៗតែងតែបរាជ័យជានិច្ច ។

ឆ្នាំ១៩៧៥ កងទ័ពរបស់ តាអឿន បានវាយចូលកៀកទីក្រុងភ្នំពេញនៅម្តុំពោធិចិនតុង នៅទីនោះមិនសូវបាញ់គ្នានិងផ្ទុះអាវុធខ្លាំងក្លាដូចនៅសមរភូមិព្រែកព្នៅទេ ។ ពេលវាយចូលដល់ទីក្រុងភ្នាម លន់ ត្រូវបញ្ជូនទៅនៅក្រុមការពារ ឈរការពារនៅខាងក្រៅផ្ទះ ហើយឲ្យក្រុមផ្សេងទៀតចូលទៅឆែកឆេរក្នុងផ្ទះក្រែងមានទាហានលន់នល់នៅបង្កប់ខ្លួន ឬមានប្រជាជនចេញមិន

ទាំងអស់ ។ ចំពោះប្រជាជនផ្សេងទៀតដែលនៅសេសសល់បន្ទាប់ពីជម្លៀសនិងអ្នកដែលត្រូវបញ្ជូនមកពីតាមបណ្តាខេត្តផ្សេងៗ ដែលត្រូវចោទប្រកាន់ថាជាអ្នក១៧មេសា ឬអ្នកជាប់ពាក់ព័ន្ធ ទាហានលន់នល់រាប់ពាន់នាក់ត្រូវបានបញ្ជូនយកទៅសម្លាប់ចោល នៅម្តុំទួលគោក ។

ក្រោយពេលជម្លៀស អង្គការចាប់ផ្តើមរៀបចំកម្លាំងទ័ពសាជាថ្មី ។ គ្រប់កងពលទាំងអស់ លើកលែងតែកងទី២ ត្រូវដកកម្លាំងឲ្យទៅធ្វើស្រែ ។ កងរបស់ លន់ ត្រូវបញ្ជូនទៅធ្វើស្រែនៅឃ្មួញ កប់ស្រូវ និងអន្លង់ក្ងាន ដោយទទួលរបបអាហារដូចប្រជាជនសាមញ្ញ ។ មិនតែប៉ុណ្ណោះគាត់ត្រូវបានថ្នាក់លើប្រាប់ថា "ឲ្យលត់ដំខ្លួនឯង ព្រោះប្រទេសយើងក្រ ត្រូវសន្សំសំចៃទុកទិញសម្ភារៈសម្រាប់ប្រើប្រាស់" ។ ក្រោយពីនោះ លន់ ត្រូវបញ្ជូនឲ្យទៅពេជ្រនិល ដើម្បីកាប់ឈើដុតធ្វើធ្យូង ។ នៅទីនោះកងទ័ពខ្មែរក្រហមបានយកឡានអាមេរិកាំងច្នៃឲ្យទៅជារថយន្តប្រើប្រាស់ថាមពលធ្យូង ដោយគាត់ដាក់ធុងសាំងកម្ពស់ប្រហែលជាង១ម៉ែត្រ នៅចំកណ្តាលរថយន្ត ហើយដាក់ធ្យូងឲ្យពេញ រួចដុតឲ្យឆេះសុះលុះត្រាតែឆ្នាំងនោះមើលទៅចង់ធ្លុះពីម្ខាងទៅម្ខាង ពេលនោះម៉ាស៊ីនរថយន្តចាប់ផ្តើមបឺតផ្សែងចូល ទើបម៉ាស៊ីនរថយន្តរោទិ៍ ហើយអាចបើកទៅមុខបាន ។ នៅលើរថយន្តមានតែអ្នកបើកម្នាក់ប៉ុណ្ណោះ គ្មានអ្នកជិះទេព្រោះក្តៅពេក ។

រស់នៅពេជ្រនិលបានមួយរយៈ តាអឿន បានហៅ លន់ ឲ្យមកនៅវត្តភ្នំវិញ ហើយឲ្យចូលរៀនផ្នែកតាមដានប្រវត្តិរូបរបស់កងទ័ពរយៈពេល៣ខែ ។ លន់ ស្ថិតនៅក្នុងក្រុមមួយដែលមានសមាជិក៦នាក់និងប្រធានម្នាក់ឈ្មោះ ណាក់ ។ ក្រោយពីបញ្ចប់វគ្គសិក្សា អង្គការបានចែកម៉ូតូឲ្យម្នាក់មួយគ្រឿងសម្រាប់ចុះធ្វើការនៅតាមខេត្តនានា ដូចជាខេត្តក្រចេះ កំពង់ចាម បាត់ដំបង និងសៀមរាបជាដើម ។ លន់ មាននាទីយកប្រវត្តិរូបរបស់កងទ័ពដែលមានស្រាប់ចុះទៅសាកសួរឪពុកម្តាយនិងបងប្អូនរបស់ម្ចាស់ប្រវត្តិរូបបន្ថែមទៀត ។ បន្ទាប់មក យកប្រវត្តិរូបដើមមកផ្ទៀងផ្ទាត់ជាមួយចម្លើយរបស់ឪពុកម្តាយ បងប្អូន និងម្ចាស់ប្រវត្តិរូប ប្រសិនបើចម្លើយខុសពីប្រវត្តិរូប ត្រូវហៅម្ចាស់ប្រវត្តិរូបមកសាកសួរម្តងទៀត ហើយបើនៅតែឆ្លើយខុសគ្នាទៀតនឹងត្រូវចាប់ខ្លួនយកទៅឃុំឃាំង ចំណែកអ្នកខ្លះក៏ត្រូវអង្គការសម្លាប់ចោលដែរ បន្ទាប់ពីសួរចម្លើយរួច ។ កន្លែងសម្លាប់នៅក្បែរវត្តភ្នំ ហើយសាកសពកប់នៅក្បែរៗថ្នល់ ។ ប្រវត្តិរូបទាំងអស់ចំនួនជាង ២០០០០នាក់ ក៏ប៉ុន្តែ លន់ ធ្វើបានតែជាង១០០០ប្រវត្តិរូបប៉ុណ្ណោះ ហើយក្នុងចំណោមនោះក្រោយពីផ្ទៀងផ្ទាត់ចម្លើយ មានអ្នកឆ្លើយខុសគ្នាជិត២០០នាក់ ។ ចំពោះអ្នកដែលឆ្លើយខុសគ្នាត្រូវយកទៅសម្លាប់ចោលទាំងអស់ ។ លន់ ត្រូវឈ្មោះ ណាក់ ប្រាប់ឲ្យផ្អាកការងារនេះ ពីព្រោះក្រុមរបស់គាត់ត្រូវបានចោទថាធ្វើការហួសថ្ងៃកំណត់ ។ លន់ និងសមាជិកក្រុមត្រូវបានទុកពេលឲ្យ៧ថ្ងៃសម្រាប់ត្រៀមខ្លួននៅពេលថ្នាក់លើហៅទៅសួរចម្លើយ ។ បានរយៈពេលតែ៦ថ្ងៃឈ្មោះ ណាក់ ត្រូវអង្គការបញ្ជូនយកទៅសម្លាប់ដោយមិនដឹងពីមូលហេតុ ចំណែកក្រុម លន់ ទាំង៥នាក់ក៏បានរួចខ្លួន ។

ឆ្នាំ១៩៧៦ លន់ បានផ្លាស់ទៅនៅក្នុងក្រុមការពារដែលមានសមាជិកសរុបទាំងអស់៣០នាក់ ដើម្បីតាមការពារ ធុច (កុយ ធួន) និងមេធំៗមួយចំនួនទៀតធ្វើដំណើរទៅប្រទេសថៃ តាមខ្សែរថភ្លើងឆ្លងកាត់បាត់ដំបងនិងប៉ោយប៉ែត ។ ពេលទៅដល់ព្រំដែន ក្រុមរបស់ លន់ ត្រូវដេកចាំនៅប៉ោយប៉ែត មានតែមេធំៗ២-៣នាក់ប៉ុណ្ណោះដែលអនុញ្ញាតឲ្យចូលប្រទេសថៃដោយស្នាក់នៅថៃរយៈ៣ថ្ងៃទើបត្រឡប់មកភ្នំពេញវិញ ។ វិលមកបានមួយសប្តាហ៍ស្រាប់តែមានយន្តហោះពីខាងថៃមកទម្លាក់គ្រាប់បែកនៅមន្ទីរពេទ្យខេត្តសៀមរាបបណ្តាលឲ្យខូចខាតទាំងស្រុង ។ បួនខែក្រោយ លន់ បានឮដំណឹងថា ធុច ត្រូវចាប់ខ្លួនដោយចោទថាខុសសីលធម៌ជាមួយនារីចម្រៀង បន្ទាប់មកចាប់ខ្លួន តាអឿន ទៀត ដោយចោទថា ជាប់ខ្សែរយៈជាមួយ ធុច ហើយចុងក្រោយចាប់ខ្លួន រឿង ដោយចោទប្រកាន់ថា ធ្វើឲ្យបាក់រនាស់ បាក់នង្គ័ល និងធ្វើឲ្យគោក្របីងាប់ ។ បន្ទាប់ពីចាប់ខ្លួន តាអឿន ឆន ប្រធានវរសេនាធំមកពីខាងនិរតីត្រូវបានតែងតាំងជាប្រធានកងពលជំនួសវិញ ហើយយុទ្ធជនមួយចំនួនដែលនៅជិតដិត តាអឿន ត្រូវបញ្ឈរជើងមួយរយៈ ។ ចំណែក លន់ ត្រូវចាត់តាំងឲ្យទៅឃ្វាលគោក្របីនៅព្រែកក្តាម តាំងពីរដូវប្រាំងរហូតដល់រដូវវស្សា ទើបបញ្ជូនឲ្យទៅធ្វើស្រែនៅអន្លង់ក្ងាននិងកប់ស្រូវវិញ ។

ខែមេសា ឆ្នាំ១៩៧៧ លន់ ត្រូវបានបញ្ចូលទៅក្នុងកងពល

ទី១វិញ ក្រោមការគ្រប់គ្រងរបស់ ឆន ប្រធានភូមិភាគ ។ ពេលនោះខាងខ្មែរក្រហមនិងខាងវៀតណាមក៏កំពុងមានទំនាស់រឿងបញ្ហាបន្ទាត់ព្រំដែន ។ ដូច្នេះ លន់ ត្រូវបញ្ជូនទៅត្រៀមនៅខាងលិចទន្លេបិទខេត្តកំពង់ចាម ។ ចេញពីទន្លេបិទ លន់ ត្រូវបញ្ជូនបន្តទៅក្រែក (នៅបន្ទាយ២៧)ទៀត ដើម្បីទប់ទល់ពីការវាយលុករបស់កងទ័ពវៀតណាម ។ នៅសមរភូមិក្រែក មានការប្រយុទ្ធយ៉ាងខ្លាំងរវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម ។ ខាងខ្មែរក្រហមមានរថយន្តសម្រាប់ដឹកគ្រាប់ ចំណែកកងទ័ពថ្មើរជើងត្រូវលីគ្រាប់ដោយខ្លួនឯងទៀតដើម្បីត្រៀមបាញ់ ។ លន់ និងមួយកងពលដែលមានកងទ័ព៦០០នាក់ ក្រោមការគ្រប់គ្រងរបស់ ឆន បានទៅវាយនៅសមរភូមិផ្សារក្រដាស ។ ប៉ុន្តែលទ្ធផលចុងក្រោយ មួយកងពលស្លាប់ស្ទើរអស់នៅសល់តែ៦នាក់ប៉ុណ្ណោះដែលរត់រួច ។ ពេលនោះអង្គការក៏បានដកពួកដែលធ្វើស្រែនៅឃ្លាំង អន្លង់ក្ងាន កប់ស្រូវ និងពួកមជ្ឈិមទៅជួយដើម្បីទប់ទល់ជាមួយកងទ័ពវៀតណាម ប៉ុន្តែត្រូវទទួលបរាជ័យទៀត ។

រហូតដល់ដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយកាន់តែខ្លាំងចូលទីរួមខេត្តកំពង់ចាម កងទ័ពខ្មែរក្រហមបានបាក់ទ័ពរត់បែកខ្ញែកមកភាគខាងលិចអស់ ។ ចំណែក លន់ រត់សំដៅទៅស្រុកកំណើតវិញ ។ ពេលមកដល់ផ្ទះទើប លន់ ដឹងថាប្អូនប្រុសពីរនាក់ដែលធ្វើទាហានឈ្មោះ ឡេង និង លាត់ ត្រូវអង្គការបាញ់សម្លាប់ដោយចោទប្រកាន់ថាក្បត់ ។

បច្ចុប្បន្ន លន់ មានអាយុ៥៦ឆ្នាំ ប្រកបមុខរបរស្រែចម្ការនិងឆ្លៀតពេលទំនេរដើរធ្វើការងារសំណង់ដើម្បីរកប្រាក់បន្ថែមសម្រាប់ឧបត្ថម្ភកូនទាំង៦នាក់បានរៀនសូត្រគ្រប់គ្នានិងចិញ្ចឹមគ្រួសារ ។ ថ្វីដ្បិតតែ លន់ មមាញឹកនឹងការងារក៏ដោយ ក៏ លន់ បានស្តាប់ព្រឹត្តិទាមវិទ្យុថាមានការកាត់ទោសខ្មែរក្រហមដែរ ។ លន់ ចង់ឲ្យមានតុលាការនេះកើតឡើងយូរមកហើយដើម្បីវិនិច្ឆ័យទោសនិងឲ្យឃើញច្បាស់ថានរណាខុសនរណាត្រូវ ព្រោះថាបងប្អូនពីរនាក់របស់គាត់ត្រូវបានសម្លាប់នៅក្នុងរបបនោះដែរ ។

**សោម ប៊ុនថន**

# គ្រោះថ្នាក់ដោយប្រយោលទៅកាន់មនុស្សទី២ ៖ ការផ្ទេរការប៉ះទង្គិចផ្លូវចិត្តទៅឱ្យអ្នកជំនាន់បន្តបន្ទាប់

ការស្តាប់ជនរងគ្រោះម្នាក់ដែលមានការប៉ះទង្គិចផ្លូវចិត្ត ការស្តាប់ព្រឹត្តិអំពីការឈឺចាប់ ការប្រឈមមុខនឹងការប៉ះទង្គិចផ្លូវចិត្តជារៀងរាល់ថ្ងៃ និងការកត់សម្គាល់ពីទុក្ខព្រួយដ៏ស្ងប់ស្ងាត់ជាមួយនឹងសំឡេងរបស់ជនរងគ្រោះអាចជះឥទ្ធិពល (ទោះបីជាមិនមានការប៉ះទង្គិចផ្លូវចិត្ត) ទៅលើអ្នកស្តាប់នូវរឿងរ៉ាវរបស់ជនរងគ្រោះ ។ នៅក្នុងទិដ្ឋភាពអ្នកស្តាប់ម្នាក់ក្នុងតួនាទីជា «សាក្សីរបស់សាក្សី» ម្នាក់ទៀត ត្រូវបានជជែកវែកញែកថា វាជាការចាំបាច់ដែលអ្នកស្តាប់ត្រូវនៅកន្លែងដាច់ដោយឡែកនិងមិនមានទំនាក់ទំនងជាមួយជនរងគ្រោះ ។ លោក ឡូប យកចំណុចជាច្រើនមកបង្ហាញពីអារម្មណ៍ដែលមនុស្សម្នាក់អាចជួបប្រទះក្នុងនាទីជាអ្នកស្តាប់នូវរឿងរ៉ាវរបស់សាក្សី ។ រាប់បញ្ចូលពីការតក់ស្លុតទាំងស្រុង ការដកខ្លួនចេញ និងភាពស្ពឹក រហូតដល់ការរំជួលចិត្តហួសហេតុ លោក ឡូប រំពឹកថា អ្នកស្តាប់សាច់រឿងដែលបង្កប់នូវការប៉ះទង្គិចផ្លូវចិត្តចាំបាច់ត្រូវដឹងទាំងអារម្មណ៍ទាំងនេះ និងក្នុងពេលជាមួយគ្នាត្រូវចេះគ្រប់គ្រងនូវអារម្មណ៍ទាំងនេះផង ។

បរិយាកាសព្យាបាលរវាងគ្រូពេទ្យឯកទេសចិត្តវិកលនិងជនរងគ្រោះគឺជា «ការប្រឈមមុខនឹងការប៉ះទង្គិចផ្លូវចិត្ត» ឬ «ការផ្ទេរការប៉ះទង្គិចផ្លូវចិត្ត» ដែលអ្នកព្យាបាលអាចចាប់ផ្តើមជួបប្រទះនឹងរោគសញ្ញានៃជំងឺបាក់ស្បាត ។ ការស្តាប់ពីរឿងភ័យខ្លាចរបស់អ្នកជំងឺប៉ះទង្គិចផ្លូវចិត្តអាចរំឭកឡើងនូវបទពិសោធន៍ពីមុនរបស់គ្រូពេទ្យ ហើយការរំឭកឡើងនូវអតីតកាលដូចនេះស្តែងចេញឡើងតាមរយៈរូបភាពថ្មីៗទាក់ទងជាមួយនឹងអ្នកជំងឺផ្លូវចិត្តដូចជា

សុបិនអាក្រក់ ឬ ការស្រមើស្រមៃឃើញអតីតកាល ។ ការស្តាប់អាចធ្វើឲ្យគ្រូពេទ្យមានទំនាក់ទំនងអារម្មណ៍ជាមូលដ្ឋាននិងជំនឿផ្សេងៗដូចជាអ្នកជំងឺដែរ ។ នៅក្នុងកម្រិតធ្ងន់ជាងនេះមួយទៀត ព្រឹត្តិការណ៍នេះត្រូវបានស្គាល់ថាជាការប៉ះទង្គិចផ្លូវចិត្តច្រើនជំនាន់ ឬក៏ជាព្រឹត្តិការណ៍នៃការផ្ទេរការប៉ះទង្គិចផ្លូវចិត្តពីជំនាន់មួយទៅកាន់ជំនាន់មួយទៀត ។ តាមរយៈទំនាក់ទំនងក្រោមដំបូលផ្ទះតែមួយ ទំនាក់ទំនងនិងការបែងចែក (តាមដែលលោក ឡូប បានពិពណ៌នា) ប្រហែលជាពិបាក (បើទោះបីជាអាចទៅរួចក៏ដោយ) សម្រាប់សមាជិកគ្រួសារ ជាពិសេសកូនរបស់ជនរងគ្រោះ ដើម្បីការពារខ្លួនពីការប៉ះពាល់នេះ ។ ការណ៍នេះកាន់តែស្មុគស្មាញនៅក្នុងរង្វង់គ្រួសាររបស់ជនរងគ្រោះដែលបានបាត់បង់សមាជិកគ្រួសារជាច្រើនក្នុងរបបប្រល័យពូជសាសន៍ និងដែលកំពុងរៀបចំដំណើរការធ្វើអន្តោប្រវេសន៍ ។ តាមរយៈ ឃីនហ្ស៊ី «សមាជិកគ្រួសារដែលនៅរស់រានមានជីវិតត្រូវការការរស់នៅជិតគ្នាទៅវិញទៅមកដើម្បីទទួលបាននូវភាពជិតដិតទាំងផ្លូវកាយនិងផ្លូវចិត្ត» ។

ក្មេងដែលកើតក្នុងគ្រួសារឪពុកម្តាយដែលមានជំងឺបាក់ស្បាត ជារឿយៗនិងញឹកញាប់ឃើញឪពុកម្តាយរបស់ខ្លួនទទួលការឈឺចាប់តាមរយៈការប៉ះទង្គិចផ្លូវចិត្តនេះ ហើយខ្ញុំអាចហៅក្មេងទាំងនោះថាជា «អ្នកស្តាប់គ្មានទីបញ្ចប់» ចំពោះការប៉ះទង្គិចផ្លូវចិត្ត ។ ទោះបីជាក្នុងមុខងារជាអ្នកស្តាប់ដែលមិនត្រូវបានគេចាប់អារម្មណ៍ឬក៏ទទួលស្គាល់ថាជាអ្នកស្តាប់នៅខាងក្នុងផ្ទះ ឬក៏ក្នុងសង្គមក៏ដោយ ក៏ក្មេងទាំងនោះស្តាប់ឮពីរោគសញ្ញានិងពីការរន្ធត់ចិត្តដែលកើតចេញពីការប៉ះទង្គិចផ្លូវចិត្តនេះ ។ វាមិនមានការភ្ញាក់ផ្អើលទេថា កូនៗរបស់ជនរងគ្រោះដែលមិនធ្លាប់ឆ្លងកាត់ការប៉ះទង្គិចផ្លូវចិត្តដំបូង បានទទួលរងនូវការប៉ះពាល់ផ្លូវចិត្ត (បើទោះជាមិនកើតជំងឺផ្លូវចិត្ត) ដោយសារការរស់នៅក្នុងមជ្ឈដ្ឋានបែបនេះ ។

ខ្ញុំគិតថាការធ្វើការសង្ខេបតាមបែបទំនើបរបស់ ចាត ពិសាធ ដែលជាជាងគំនូរកម្ពុជានិងជាអ្នកដែលរស់រានមានជីវិតពីរបប ប៉ុល ពត រំឭកពីបទពិសោធន៍នៃការប៉ះទង្គិចផ្លូវចិត្ត ។ នៅក្នុងគំនូររបស់ ពិសាធ គូររូបមនុស្សដែលមើលមុខមិនច្បាស់៥នាក់ តំណាងឲ្យក្មេងៗដែលស្ថិតនៅក្នុងរង្វង់ដៃរបស់ស្ត្រីម្នាក់ដែលមើលទៅដូចជាម្តាយកំពុងឱបកូន ។ រូបភាពដែលធំនិងមានពណ៌ល្អក់ស្ថិតនៅពីក្រោយរូបស្ត្រីនិងកូនក្មេងទាំងនោះ បញ្ជាក់ពីវត្តមានសាកសពជាច្រើន ហើយរូបភាពនេះដូចជាបង្ហាញអំពីការចងចាំនិងកេរដំណែលនៃអំពើប្រល័យពូជសាសន៍ ។ ដៃរបស់ម្តាយក្តាប់និងទាញកូនទាំង៥មកឱបនៅក្នុងទ្រូងរបស់នាងយ៉ាងណែន ។ ខ្ញុំយល់ថាការឱបរបស់ម្តាយ ការផ្ទេរការឈឺចាប់ បង្ហាញពីការចម្លងការប៉ះទង្គិចផ្លូវចិត្តនេះដែលផ្ទេរការប៉ះទង្គិចផ្លូវចិត្តពីជំនាន់មួយទៅជំនាន់បន្ទាប់មួយទៀត ។ ដូច្នេះរូបភាពស្រពេចស្រពិលមិនត្រឹមតែហ៊ុមព័ទ្ធតែស្ត្រីជាម្តាយប៉ុណ្ណោះទេ ប៉ុន្តែមើលទៅដូចជាព្រលឹងខ្មោចហោះចុះហោះឡើងរវាងជំនាន់របស់ម្តាយនិងកូន ដែលរូបភាពនេះមើលទៅដូចជាការចងចាំពីអតីតកាលដ៏ជូរចត់និងកេរដំណែលនៃការប៉ះទង្គិចផ្លូវចិត្ត ។ គំនូរនេះកាន់តែមានការទាក់ទាញជាមួយនឹងសេចក្តីសរុបរបស់ពេទ្យវិកលចរិត លោក ដេវីដ គីនហ្ស៊ី *(J. David Kinzie)* នៅក្នុងអត្ថបទឥទ្ធិពលនៃការប៉ះទង្គិចផ្លូវចិត្តមកលើឪពុកម្តាយនិងកូនកម្ពុជាៈ

ការសិក្សារបស់យើងបង្ហាញថា ជំងឺបាក់ស្បាតកើតឡើងនៅក្នុងចង្កោមគ្រួសារ ។ អត្រានៃជំងឺបាក់ស្បាតដែលកើតឡើងចំពោះកូនក្មេងកើនឡើងនៅពេលឪពុកឬម្តាយមានជំងឺបាក់ស្បាត ហើយនឹងកើនឡើងគួរឲ្យកត់សម្គាល់ប្រសិនបើឪពុកនិងម្តាយមានជំងឺបាក់ស្បាត ។ ការឆាប់ខឹង គេងមិនលក់ ការគេចវេះ ការភ្ញាក់ និងសុបិនអាក្រក់គឺជាសញ្ញារបស់ជំងឺបាក់ស្បាតដែលអាចធ្វើឲ្យឪពុកម្តាយទន់ខ្សោយដោយផ្ទាល់ តាមរយៈការនេវនាវនិងការគេចវេះ ឬក៏មិនផ្ទាល់តាមរយៈការអស់កម្លាំងខ្លាំង និងការមានទុក្ខកង្វល់ ហើយជាលទ្ធផលរោគសញ្ញាទាំងអស់នេះជះឥទ្ធិពលមិនល្អយ៉ាងខ្លាំងដល់កុមារ ។ ការណ៍នេះហើយទើបកុមារអាចនិងពេលខ្លះវិវឌ្ឍ ឬក៏មានសញ្ញានៃជំងឺបាក់ស្បាតនេះតែម្តង ។

បញ្ហាដ៏ចម្បងមួយនៅក្នុងគ្រួសារដែលបន្សល់ទុកដោយរបបប្រល័យពូជសាសន៍នៅកម្ពុជាគឺការស្លាប់របស់បុរសជាច្រើន និងបន្សល់ទុកស្ត្រីឲ្យធ្វើជាមេគ្រួសារ ចិញ្ចឹមនិងមើលថែកូននិងទ្រទ្រង់បន្ទុកគ្រួសារតែម្នាក់ឯង ដែលនៅក្នុងសង្គមគ្រួសារកម្ពុជាពីមុនធ្លាប់តែមានឪពុកនិងម្តាយធ្វើការរួមគ្នា ។ នៅក្នុងផ្ទាំងគំនូរដែលមានឈ្មោះថា «ការប្រកួតកាត់នៃសង្គ្រាមជាសន្លាក់ៈ ស្ត្រីមេម៉ាយ» (ឆ្នាំ១៩៩៩) របស់វិចិត្រករកម្ពុជាឈ្មោះ ស្វាយ គេន បង្ហាញពី

ចំនួនស្ត្រីដែលបានបាត់បង់ប្តីនៅក្នុងរបបប្រល័យពូជសាសន៍ ។ គេនគូរពីស្ត្រីនៅក្នុងសម្លៀកបំពាក់ពណ៌សអង្គុយជាជួរ ហាក់ដូចជាស្ត្រីមេម៉ាយកំពុងកាន់ទុក្ខប្តីដែលបានស្លាប់ក្រោមកណ្តាប់ដៃរបស់បនប៉ុលពត ។ រូបស្ត្រីអង្គុយលាតសន្ធឹងពីចុងម្ខាងដល់ចុងម្ខាងទៀត និងពីផ្នែកខាងក្រោមដល់ផ្នែកខាងលើនៃផ្ទាំងគំនូរដែលមើលទៅឃើញដាច់កន្ទុយភ្នែក បញ្ជាក់ថា មានស្ត្រីជាច្រើនពាន់នាក់ទៀតដែលមានវាសនាដូចគ្នានឹងស្ត្រីដែលបានគូរនៅក្នុងផ្ទាំងគំនូរនោះដែរ ។ ស្ត្រីមេម៉ាយទាំងអស់ស្លៀកសម្លៀកបំពាក់សជាមួយនឹងក្រណាត់ខ្មៅតូចមួយដុំកិបជាប់នៅលើផ្នែកអាវពណ៌សនៅដើមទ្រូងខាងស្តាំដូចគ្នា ហើយក្រណាត់ខ្មៅមួយដុំមួយដុំនោះមើលទៅប្រហាក់ប្រហែលទៅនឹងផ្លាក់ឈ្មោះមើលមិនយល់ ។ ស្ត្រីទាំងនោះក៏គ្មានឈ្មោះដែរ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំយល់ថា សភាពនៃទឹកមុខ សម្លៀកបំពាក់ និងទឹកចិត្តរបស់ស្ត្រីនៅក្នុងគំនូរនោះបង្ហាញពីភាពស្រដៀងគ្នាពីធម្មជាតិពីការតស៊ូក្នុងជីវិតដែលស្ត្រីមេម៉ាយ ឬម្តាយទោលគ្រប់រូបត្រូវឆ្លងកាត់ ។

ដូច្នេះ លោក ឃីនហ្សី ពន្យល់ថា តួនាទីជាម្តាយទោលបានដើរតួក្នុងនាមជាមេគ្រួសារដែលពុំសូវមានអំណាចក្នុងគ្រប់គ្រងកូន និងបង្កើតនូវតួនាទីត្រឡប់គ្នារវាងម្តាយនិងកូន ។ ឃីនហ្សីបញ្ជាក់ថា នៅពេលដែលគ្រួសារកម្ពុជាធ្វើអន្តោប្រវេសន៍ទៅកាន់ប្រទេសផ្សេងទៀត ក្មេងៗបានមានឱកាសច្រើនសម្រាប់ទទួលការសិក្សាអប់រំល្អ និងងាយបំបែកគំនាបផ្នែកវប្បធម៌ និងភាសាជាងអ្នកជំនាន់មុន ដែលជាហេតុធ្វើឲ្យក្មេងៗទាំងនោះផ្លាស់ប្តូរតួនាទីទៅជាឪពុកឬម្តាយទោលគ្រប់គ្រងខ្លួនឯងនៅក្នុងគ្រួសារ ។

## សរុបសេចក្តី

នៅក្នុងសៀវភៅរបស់គ្រីស៊ីន ស៊ីល «ក្បាលកោរសក់» (Shaved Heads) បញ្ជាក់ពីការឈឺចិត្តថា «*នៅខណៈពេលដែលការប៉ះទង្គិចផ្លូវចិត្តមានសភាពធ្ងន់ធ្ងរពេក ជនរងគ្រោះប្រហែលជាត្រូវការនរណាម្នាក់ជាជាងខ្លួនឯងផ្ទាល់ដើម្បីនិយាយជំនួសរូបគេ ហើយការជាសះស្បើយអាស្រ័យលើការនិយាយរបស់ជនរងគ្រោះក្នុងនាមខ្លួនឯងផ្ទាល់*» ។ ជាការពិតណាស់ ការជាសះស្បើយគឺត្រូវពឹងផ្អែកលើជនរងគ្រោះក្នុងការនិយាយនិងបញ្ជាក់ពីបទពិសោធន៍ផ្ទាល់ខ្លួនដោយបុគ្គលផ្ទាល់ ។ ក៏ប៉ុន្តែនៅពេលជាមួយគ្នានេះដែរ ខ្ញុំយល់ថា ដំណើរការឲ្យជនរងគ្រោះ «*និយាយក្នុងនាមខ្លួនឯងផ្ទាល់*» គឺអាស្រ័យទៅនឹងបុគ្គលម្នាក់ផ្សេងទៀត ។ អត្ថបទនេះបានបង្ហាញពីវិធីដែលអ្នកស្តាប់មិនថាតាមរយៈអ្នកព្យាបាលជំងឺ សមាជិកគ្រួសារ មិត្តភក្តិឬក៏សង្គម) អាចជួយឲ្យអ្នកដែលនៅរស់តែតម្រូវនិងទទួលបាននូវសមត្ថភាពចិត្តវិទ្យាដែលត្រូវបានបំផ្លាញដោយបទពិសោធន៍ដ៏ជូរចត់នោះ ។ ហឺមែន បានលើកឡើងថា «*ដើម្បីដាក់តតិយភាពនៃការប៉ះទង្គិចផ្លូវចិត្តក្នុងការយល់ដឹងទាមទារឲ្យស្ថានភាពសង្គមជួយពង្រឹងនិងការពារជនរងគ្រោះនិងជួយបង្រួបបង្រួមជនរងគ្រោះនិងសាក្សីនៅក្នុងសម្ព័ន្ធភាពសាមញ្ញមួយ*» ។ ខ្ញុំនឹងធ្វើសេចក្តីសំអាងថា ឯកសារប្រព័ន្ធឃោសនានេះផ្តល់ឲ្យជាសញ្ញាណមួយសម្រាប់អ្នកស្តាប់ដើរតួនាទីសំខាន់ក្នុងការជួយឲ្យជនរងគ្រោះជាសះស្បើយពីបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្ត ។ ក៏ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ ខ្ញុំសូមបញ្ជាក់ដែរថា ផ្ទាំងអត្ថបទនេះក៏មានឥទ្ធិពលក្នុងការផ្តល់នូវវេទិកាសង្គមសម្រាប់ជនរងគ្រោះនិងអ្នកស្តាប់ដើម្បីមានដៃគូសិប្បនិម្មិត ហើយដៃគូសិប្បនិម្មិតនេះហើយដែលអនុញ្ញាតឲ្យជនរងគ្រោះនិងអ្នកស្តាប់ដែលមកពីជំនាន់ខុសគ្នា តំបន់ភូមិសាស្ត្រខុសគ្នា និងប្រវត្តិវប្បធម៌ខុសគ្នាដើម្បីចែករំលែកបទពិសោធន៍ ជាពិសេសបញ្ជាក់ថាបទពិសោធន៍ពិតជាមានពិតប្រាកដ និងអាចប្រើប្រាស់ក្នុងផ្លូវច្បាប់បាន ។

ស្របពេលជាមួយគ្នានេះ ការរកឃើញគ្រោះថ្នាក់ដែលកើតឡើងក្នុងដំណើរការនៃការស្តាប់ (ដំណើរការដែលអាចបន្តពីជំនាន់មួយទៅជំនាន់មួយ) ក៏ជាភ័ស្តុតាងមួយបញ្ជាក់ថាការបំផ្លិចបំផ្លាញដែលបន្សល់ដោយខ្មែរក្រហមមានទំហំកាន់តែធំនិងធ្ងន់ធ្ងរចំពោះអ្នកស្តាប់ជាងជនរងគ្រោះដែលត្រូវបានខ្មែរក្រហមធ្វើទារុណកម្ម សម្លាប់ បង្អត់អាហារ និងបានធ្វើទុក្ខបុកម្នេញដោយផ្ទាល់ ។ វាជាការបំផ្លាញយ៉ាងជាក់ស្តែងដែលបន្តជ្រួតជ្រាបទាំងក្នុងនិងក្រៅប្រទេសនៅពេលដែលអ្នកស្តាប់បានបន្តការចូលរួមក្នុងដំណើរដ៏គ្រោះថ្នាក់ (មិនថារយៈពេលវែងឬខ្លី) ទៅរកភាពជាសះស្បើយ ហើយជាការជាសះស្បើយដែលកម្ពុជានិងប្រជាជនកម្ពុជានៅតែមានការប្រយុទ្ធនិងប្រឈមមុខនៅក្នុងពេលបច្ចុប្បន្ននេះ ។

**សារ៉ាស ចនឌីគិន**

# ការចង់បានរបស់ប្រជាជនកម្ពុជានៅតាមជនបទស្តីអំពីការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ១) *សេចក្តីណែនាំ*

*មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទង់មតិនេះដើម្បីធ្វើជាផ្នែកមួយនៃកម្មវិធីឯកសាររស់និងការផ្សព្វផ្សាយ ។ គោលបំណងនៃការធ្វើការស្ទង់មតិនេះគឺចង់បញ្ជាក់ពីមធ្យោបាយដែលប្រជាជនកម្ពុជានៅតាមជនបទទទួលបានព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងកម្ពុជា (ឬក៏អាចនិយាយបានថា ជាតុលាការឬក៏សាលាក្តីខ្មែរក្រហម) និងដើម្បីវាយតម្លៃទៅលើវិធីនិងប្រភពព័ត៌មានដែលនឹងមានប្រសិទ្ធភាពបំផុតក្នុងការផ្តល់ទៅប្រជាជនកម្ពុជានៅពេលខាងមុខ ។*

*សហការីផ្នែកច្បាប់ពីរនាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ Norman Pentelovitch និង Kathryn Simon និងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ លី សុខឃាង ដែលជាអ្នកគ្រប់គ្រងគម្រោងបានរៀបចំការស្ទង់មតិនេះឡើង ។ លោក សុខឃាង បានសម្ភាសមនុស្សចំនួន៣១នាក់ក្នុងរយៈពេល៣ថ្ងៃនៅក្នុងខេត្តចំនួន៣ដែលចំណាយពេលធ្វើដំណើរតែរយៈពេលពី១ទៅ៣ម៉ោងពីទីក្រុងភ្នំពេញ ។*

*លទ្ធផលនៃការស្ទង់មតិគឺមិនមែនតំណាងឲ្យប្រជាជនកម្ពុជាទូទៅឬក៏តំណាងឲ្យខេត្តបទសម្ភាសន៍ដែលបានរៀបចំឡើងនេះដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ទិន្នន័យដែលទទួលបានក្នុងអំឡុងពេលធ្វើការស្ទង់មតិគឺមានប្រយោជន៍ក្នុងការធ្វើការបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងនានានៅពេលអនាគតដើម្បីផ្តល់ឲ្យសាធារណជនកម្ពុជានូវព័ត៌មានពិតអាចយល់បាន និងព័ត៌មានដែលអាចទទួលបានអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

## ២) *វិធីនៃការស្ទង់មតិ*

*ពាល់ការខំប្រឹងត្រូវបានធ្វើឡើងដើម្បីធ្វើឲ្យការស្ទង់មតិមានភាពយុត្តិធម៌និងមិនលម្អៀងតាមតែអាចធ្វើបាន ។ ដើម្បីសម្រេចគោលបំណងនេះការការពារជាច្រើនត្រូវបានធ្វើឡើងដើម្បីធានាឲ្យប្រាកដថាលទ្ធផលនេះឆ្លុះបញ្ចាំងពីឥរិយាបថពិតរបស់អ្នកដែលបានធ្វើសម្ភាសន៍ដែលមិនមែនជាទស្សនៈរបស់អ្នកស្រាវជ្រាវ ។*

*កន្លែងសម្ភាសន៍មាន៣កន្លែង (ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល) ត្រូវបានជ្រើសរើស ដោយសារខេត្តទាំងបីនេះនៅជិតទីក្រុងភ្នំពេញ និងដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជានិងសហគមន៍ទាំងនេះមានទំនាក់ទំនងគ្នា ។ កម្រិតថវិកា និងពេលវេលាក៏បានជះឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការរៀបចំការសម្ភាសន៍នៅក្នុងខេត្តទាំងនេះដែរ ។ លើសពីនេះទៀត ខេត្តទាំងនេះត្រូវជ្រើសរើសដើម្បីបង្ហាញវិធីរបស់ក្រុមដែលចាប់អារម្មណ៍នឹងអាចប្រើប្រាស់ដើម្បីផ្សព្វផ្សាយឲ្យដល់ប្រជាជនកម្ពុជាមួយចំនួនធំដែលរស់នៅទីជនបទក្នុងរយៈពេលដ៏ខ្លីជាមួយនឹងថវិកាដែលមានកំណត់ ។*

*សមាជិកសហគមន៍ពីរប្រភេទដែលបានចូលរួមនៅក្នុងការធ្វើការស្ទង់មតិៈ ប្រធានភូមិឬឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ។ អ្នកទាំងនោះត្រូវបានរកឃើញជាដំបូងតាមការសាកសួរអ្នកភូមិពីកន្លែងដែលអាចរកប្រធានភូមិឬក្រុម និងបន្ទាប់មកធ្វើការបញ្ជាក់ពីអត្តសញ្ញាណតាមរយៈផ្នែកជីវប្រវត្តិនៃសំណួរស្ទាបស្ទង់មតិ ។*

*មុនពេលចាប់ផ្តើមធ្វើកិច្ចសម្ភាសន៍នីមួយៗលោក សុខឃាង បានណែនាំខ្លួនជាភាសាខ្មែរនិងបានពន្យល់ពីគោលបំណងនៃការស្ទង់មតិនេះ ហើយក៏បានទទួលការអនុញ្ញាតពីអ្នកផ្តល់បទសម្ភាសន៍ឲ្យថតសំឡេងដាក់កាសែតពីការសន្ទនានេះ ។ បន្ទាប់មកធ្វើសម្ភាសន៍ទាក់ទងនឹងព័ត៌មានអំពីជីវប្រវត្តិរួមមានៈ ឈ្មោះ អាយុ កម្រិតការសិក្សា មុខងារ ឃុំ-សង្កាត់ឬភូមិដែលគាត់ជាអ្នកតំណាងឲ្យគ្រួសារមួយចំនួនដែលកំពុងរស់នៅក្នុងតំបន់របស់អ្នកតំណាងនោះ និងបុគ្គលមួយចំនួនដែលចេញពីគ្រួសារនីមួយៗ ។ ក្នុងករណីជាច្រើនចំនួនជាក់លាក់ត្រូវបានផ្តល់ព័ត៌មាន ក្រុមអ្នកស្ទង់មតិយល់ឃើញ*

ថា ការរាប់ចំនួនប្រជាជនគឺត្រូវបានរៀបចំរួចជាស្រេច (ថ្វីបើមិនបានទាំងស្រុងក៏ដោយ) ។

ការស្ទង់មតិមានជាសំណួរនិងចម្លើយទូទៅដែលអ្នកឆ្លើយត្រូវបានសុំឲ្យជ្រើសរើសតាមលំដាប់ពីការពេញចិត្តច្រើនទៅរកការពេញចិត្តតិចតួច ។ ជម្រើសទាំងនេះត្រូវបានបង្ហាញនៅក្នុងលំដាប់ផ្សេងៗគ្នាសម្រាប់បទសម្ភាសន៍នីមួយៗ ដើម្បីធានាឲ្យប្រាកដថា វិធីដែលបានសួរនឹងមិនលម្អៀងចំពោះចម្លើយ ។

នៅពេលដែលអាចទៅបាន អ្នកធ្វើសម្ភាសន៍បានព្យាយាមបញ្ជាក់ចម្លើយ (ឧទាហរណ៍ ស្វែងរកការបញ្ជាក់លើអត្ថន័យពាក្យ «រដ្ឋាភិបាល» និង «ស្ថាប័ន») ។ តាមដែលអាចធ្វើទៅបាន ការពិភាក្សានោះគួរតែកុំសួរអ្នកផ្តល់បទសម្ភាសន៍អំពីបទឧក្រិដ្ឋកម្មដែលគាត់បានឆ្លងកាត់ ចៀសវាងការរំខានដល់លទ្ធផលនៃការធ្វើសម្ភាសន៍ ។ ថ្វីបើមានការប្រុងប្រយ័ត្ននេះក៏ដោយ អ្នកផ្តល់បទសម្ភាសន៍មួយចំនួនជ្រើសរើសយកការនិយាយប្រាប់អំពីរឿងរ៉ាវបទពិសោធន៍របស់គាត់ក្រោមរបបខ្មែរក្រហម ។ ដោយចេះចាប់យកចំណុចរឿងទាំងនេះនិងការអត់ធ្មត់គឺជាវិធីដំបូងដែលត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយនៅពេលជួបបទពិសោធន៍បែបនេះ ។

តាមរយៈការសន្ទនាធម្មតាៗជាមួយអ្នកផ្តល់សម្ភាសន៍ របាយការណ៍ជាក់លាក់ស្តីពីចំណូលចិត្តមិនអាចធ្វើទៅបានទេ ដូច្នេះការនិយាយយោងមួយចំនួនត្រូវបានទាញចេញពីការសន្ទនាទាំងអស់នោះ ។ នៅក្នុងការឆ្លើយតបនឹងសំណួរ អ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានសម្តែងការពេញចិត្តប្រហាក់ប្រហែលគ្នា ឧទាហរណ៍ នៅពេលដែលបានសួរថាតើវិធីមួយណានៃការផ្សព្វផ្សាយព័ត៌មានមានលក្ខណៈល្អបំផុត អ្នកឆ្លើយតបជាច្រើនបានឆ្លើយថា «ទូរទស្សន៍» និង«វិទ្យុ» ។ អាស្រ័យហេតុនេះ ចំនួននៃប្រភពព័ត៌មាន«ដ៏ប្រសើរបំផុត» នៅក្នុងប្រភេទមួយចំនួនគឺខ្ពស់ជាងចំនួនប្រជាជនដែលបានសម្ភាសន៍ ។

លើសពីនេះទៀត ដូចដែលបទសម្ភាសន៍បានដំណើរការ សំណួរប្រកបដោយលំដាប់លំដោយត្រូវបានសួរទៅកាន់អ្នកផ្តល់បទសម្ភាសន៍ ។ ជាញឹកញាប់តាមដែលអាចធ្វើទៅបាន ក្រុមអ្នកសម្ភាសន៍ (សហការីផ្នែកច្បាប់ពីរនាក់ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា) បានធ្វើការពិភាក្សាខ្លីៗអំពីសំណួរស្ទាបស្ទង់មតិដើម្បីបញ្ជាក់ថា សំណួរទាំងនោះមិនមានភាពលម្អៀងចំពោះចម្លើយពិតប្រាកដឡើយ ។ ទោះបីជាសំណួរទាំងនេះមិនបានពិនិត្យដូចជាទម្រង់សំណួរដំបូង កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីឲ្យសំណួរស្ទាបស្ទង់មតិនេះមានលក្ខណៈអព្យាក្រឹត ។

## ៣) លទ្ធផលស្ទង់មតិ

### ព័ត៌មានជីវប្រវត្តិស្តីពីអ្នកចូលរួមនៅក្នុងការស្ទង់មតិ

ភាគច្រើននៃអ្នកផ្តល់សម្ភាសន៍បានទទួលការអប់រំនៅក្នុងប្រព័ន្ធអប់រំកម្ពុជា និងជាមធ្យមរៀនដល់ថ្នាក់ទី៧ (ថ្នាក់ទី៦នៅប្រទេសភាគខាងលិច) ។ ភាគច្រើនមានអាយុចន្លោះពី៥០និង៧០ឆ្នាំ ។ ថ្វីបើការខំប្រឹងសម្ភាសន៍ជាមួយស្ត្រី ក្រុមអ្នកស្ទង់មតិអាចជួបតែប្រធានដែលជាបុរស (ក្នុងចំណោមអ្នកដែលបានផ្តល់បទសម្ភាសន៍៣១នាក់ មាន២នាក់គឺជាសមាជិកក្រុមប្រឹក្សា ក្រៅពីនោះ ជាមេភូមិ និងមេឃុំ) ។

ព័ត៌មានជីវប្រវត្តិរបស់អ្នកចូលរួមនិងព័ត៌មានអំពីភូមិនិងឃុំបានបង្ហាញនៅក្នុងការស្ទង់មតិ បានសង្ខេបដូចខាងក្រោមៈ

- ◆ ចំនួនឃុំ (ឃុំតំណាង)ៈ ១៧នាក់
- ◆ ចំនួនភូមិៈ ១២នាក់
- ◆ ចំនួនគ្រួសារតំណាងៈ ២៦.៥៤១នាក់
- ◆ ចំនួនប្រជាជនអ្នកតំណាងដោយមេភូមិ និងមេឃុំៈ ១៣៩.៩៤៨នាក់
- ◆ អាយុជាមធ្យមរបស់អ្នកផ្តល់បទសម្ភាសន៍ៈ ៥៦ឆ្នាំ (មនុស្សវ័យចំណាស់បំផុតត្រឹម៧០ឆ្នាំនិងក្មេងបំផុតអាយុ៤៧ឆ្នាំ)
- ◆ កម្រិតអប់រំរបស់អ្នកផ្តល់បទសម្ភាសន៍ជាមធ្យមៈ ថ្នាក់ទី៧ (ប្រព័ន្ធអប់រំពីសង្គមចាស់)
- ◆ កម្រិតអប់រំរបស់អ្នកផ្តល់បទសម្ភាសន៍ខ្ពស់បំផុតៈ បញ្ចប់ការសិក្សាពី «សាលាពិសោធន៍»
- ◆ កម្រិតអប់រំរបស់អ្នកផ្តល់បទសម្ភាសន៍ទាបបំផុតៈ ថ្នាក់ទី១០ (ថ្នាក់ទី៣នៅប្រទេសភាគខាងលិច) ឬក៏បានសិក្សានៅវត្តរយៈពេលមួយឆ្នាំ ។

### វិធីដែលអ្នកចូលរួមបានដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញ

- ◆ តាមវិទ្យុ ៈ ១៦នាក់
- ◆ ដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅ

តុលាការខ្មែរក្រហមៈ ១៣នាក់

◆ ទូរទស្សន៍ ៖ ៦នាក់

◆ កាសែត, ទស្សនាវដ្ដី, ស្វែងរកការពិតៈ ៨នាក់

◆ សៀវភៅតូចៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖ ១នាក់

◆ ការិយាល័យសាលាខេត្ត ៖ ១នាក់

◆ អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ៖ ១នាក់

**វិធីដែលប្រសើរដើម្បីទទួលព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញ**

◆ ទូរទស្សន៍ ៖ ១៩នាក់

◆ វិទ្យុ ៖ ១៥នាក់

◆ កាសែត ទស្សនាវដ្ដី ស្វែងរកការពិតនិងអង្គជំនុំជម្រះវិសាមញ្ញ

◆ កូនសៀវភៅណែនាំ និង ប័ណ្ណផ្សព្វផ្សាយ ៖ ៥នាក់

◆ ការប្រជុំរបស់អង្គការក្រៅរដ្ឋាភិបាល ៖ ៣នាក់

◆ ការបញ្ចាំងភាពយន្តនៅក្នុងភូមិ ៖ ២នាក់

◆ ដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅអង្គជំនុំជម្រះវិសាមញ្ញ ៖ ២នាក់

◆ ការសម្ដែងល្ខោនៈ ១នាក់

**ប្រភពព័ត៌មានដែលប្រសើរ ៖**

◆ អង្គជំនុំជម្រះវិសាមញ្ញ ៖ ១២នាក់

◆ រដ្ឋាភិបាល ៖ ១១នាក់ពីរដ្ឋាភិបាល និង៦នាក់ពីអង្គជំនុំជម្រះវិសាមញ្ញ

◆ អង្គការក្រៅរដ្ឋាភិបាល ៖ ២នាក់

**៤) ការវិភាគទៅលើលទ្ធផលស្ទង់មតិ**

**ផ្នែកទី១ៈ តើប្រជាជនដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញដោយវិធីណា?**

សំណួរដំបូងដែលក្រុមអ្នកស្រាវជ្រាវបានសួរគឺថាតើអ្នកផ្ដល់បទសម្ភាសន៍និងអ្នកភូមិឬក៏ឃុំបានឮអំពីអង្គជំនុំជម្រះវិសាមញ្ញដោយរបៀបណា ។ ការផ្សព្វផ្សាយតាមវិទ្យុ (សេចក្ដីរាយការណ៍ព័ត៌មាននិងការសន្ទនា) និងការធ្វើដំណើរទស្សនកិច្ចរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាទៅកាន់អង្គជំនុំជម្រះវិសាមញ្ញគឺជាវិធីដែលសាមញ្ញបំផុតដែលអ្នកចូលរួមបានឮពីអង្គជំនុំជម្រះនេះ ។

**លទ្ធផល**

***វិទ្យុៈ*** អ្នកចូលរួម១៦នាក់បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមរយៈវិទ្យុ ។ វាគឺមិនបានច្បាស់ថាអ្នកចូលរួមបានឮអំពីអង្គជំនុំជម្រះវិសាមញ្ញ តាមរយៈការសន្ទនាឬតាមព័ត៌មាន ។ ដូច្នេះក្រុមអ្នកស្រាវជ្រាវក៏បានសួរពីប្រភេទកម្មវិធីដែលអ្នកចូលរួមបានស្ដាប់និងប្រសិនបើបានឮពីកម្មវិធីផ្សាយខ្លីៗរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ គ្មានអ្នកចូលរួមណាម្នាក់បាននិយាយថាបានឮពីកម្មវិធីផ្សាយខ្លីៗ ហើយភាគច្រើនបាននិយាយថាបានឮអំពីការផ្សាយអង្គជំនុំជម្រះវិសាមញ្ញ តាមរយៈផ្សព្វផ្សាយព័ត៌មាននិងការសន្ទនាតាមវិទ្យុ ។

ការស្ទង់មតិក៏បានបង្ហាញថា ប្រជាជនជាច្រើននៅក្នុងភូមិមានវិទ្យុ ដូច្នេះការទទួលបានព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញអាចទទួលបាននិងមានប្រសិទ្ធភាព ។ អ្នកចូលរួមបានបង្ហាញថាការសន្ទនាមានប្រយោជន៍ជាពិសេសពីព្រោះសំណួរនីមួយៗអំពីអង្គជំនុំជម្រះសាមញ្ញត្រូវបានឆ្លើយតប ។ ទោះបីជាយ៉ាងក៏ដោយអ្នកផ្ដល់បទសម្ភាសន៍ (និងអ្នកភូមិ-ឃុំ) នៅតែមានសំណួរនៅពេលដែលការកាត់ទោសនឹងកើតមាននិងអ្នកដែលត្រូវទទួលការកាត់ទោស ។

មេភូមិម្នាក់នៅក្នុងខេត្តកំពង់ឆ្នាំងបាននិយាយថា ទោះបីជាគាត់បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមវិទ្យុ គាត់ឆ្ងល់ថា តុលាការណា(ទាំងក្នុងស្រុកនិងអន្តរជាតិ) នឹងជំនុំជម្រះទោសខ្មែរក្រហម? មេភូមិក៏បានបន្តថា ប្រជាជនក្នុងភូមិបានសួរគាត់ជាច្រើនដងថាតើខ្មែរក្រហមនឹងត្រូវបានកាត់ទោសដោយតុលាការណាមួយ ហើយគាត់មិនបានដឹងពីវិធីឆ្លើយតបទៅនឹងអ្នកភូមិរបស់គាត់ទេ ។ ការឆ្លើយដូច្នេះបង្ហាញពីកង្វះការយល់ដឹងអំពីអង្គជំនុំជម្រះក្នុងចំណោមប្រជាជនកម្ពុជានៅតាមជនបទ ។

មេភូមិម្នាក់ទៀតនៅក្នុងខេត្តកណ្ដាលបាននិយាយថាគាត់និងអ្នកភូមិនៅខេត្តកណ្ដាលបានឮពីអង្គជំនុំជម្រះវិសាមញ្ញតាមវិទ្យុដោយឡែកថា អង្គជំនុំជម្រះវិសាមញ្ញខ្វះឯកសារនិងមូលនិធិ ។ មេភូមិបន្ថែមថា ប្រជាជនមានសំណួរជាច្រើនអំពីបញ្ហានេះប៉ុន្តែមិនដឹងថាត្រូវទៅសួរនរណាឬកន្លែងណាដើម្បីរកព័ត៌មានបន្ថែម ។ ក្រុមអ្នកស្រាវជ្រាវយល់ឃើញថាមេឃុំបានព្យាយាមរកព័ត៌មានបន្ថែមអំពីតុលាការជាងមេភូមិ ដូចជាក្រុមមុនៗជាច្រើន

បានមកដល់អង្គជំនុំជម្រះវិសាមញ្ញតាមរយៈដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេភូមិហាក់ដូចជាមានកម្រិតយល់ដឹងទាបអំពីអង្គជំនុំជម្រះវិសាមញ្ញនេះ ។

**ដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាៈ**

អ្នកចូលរួមចំនួន១៣នាក់បានដឹងអំពីតុលាការតាមរយៈដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកទាំងនោះភាគច្រើនបាននិយាយថា ដំណើរទស្សនកិច្ចនេះបានជួយឲ្យក្រុមអ្នកចូលរួមបានយល់ពីអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកផ្តល់បទសម្ភាសន៍ទាំងនេះបានជួបមន្ត្រីព័ត៌មានសហចៅក្រម ព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដែលក្រុមអ្នកចូលរួមយល់ឃើញថាជាប្រភពព័ត៌មានអាចជឿជាក់បាន ។ ក្រុមអ្នកធ្វើសម្ភាសន៍ក៏យល់ឃើញថា អ្នកដែលបានធ្វើទស្សនកិច្ចទៅអគារអង្គជំនុំជម្រះវិសាមញ្ញគឺមានកម្រិតយល់ដឹងអំពីតុលាការប្រសើរជាងអ្នកដែលបានឮអំពីតុលាការដោយវិធីផ្សេងទៀត ។ ឧទាហរណ៍ អ្នកផ្តល់បទសម្ភាសន៍មួយចំនួនដែលបានធ្វើទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញយល់ថា តុលាការត្រូវការប្រមូលឯកសារឬក៏សំណុំរឿងមុនដំណើរការការកាត់ទោសអាចចាប់ផ្តើម ។

ជាទូទៅ អ្នកផ្តល់បទសម្ភាសន៍បានឆ្លើយយ៉ាងច្បាស់លាស់នៅពេលដែលបានសួរអំពីការធ្វើទស្សនៈរបស់ក្រុមអ្នកចូលរួមទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ។ ឧទាហរណ៍ អ្នកចូលរួមម្នាក់នៅក្នុងខេត្តកណ្តាលបាននិយាយថាមុនពេលមកធ្វើទស្សនកិច្ច គាត់មិនគិតថា អង្គជំនុំជម្រះវិសាមញ្ញមានសារសំខាន់ទេ ប៉ុន្តែបន្ទាប់បានធ្វើទស្សនកិច្ចគាត់ទទួលស្គាល់ថា ពិតជាមានសារសំខាន់និងថាប្រជាជនគួរតែទទួលព័ត៌មានបន្ថែមអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកផ្តល់បទសម្ភាសន៍ម្នាក់មកពីខេត្តតាកែវបានបញ្ជាក់ពីសារសំខាន់របស់ការធ្វើទស្សនកិច្ចក្នុងការផ្តល់ព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញ ។

អ្នកជាច្រើនដែលបានធ្វើទស្សនកិច្ចនៅតុលាការបានត្រឡប់ទៅផ្ទះវិញនឹងនិយាយប្រាប់អ្នកដទៃទៀតអំពីអ្វីដែលបានឃើញ ។ ក្រុមមួយចំនួនដែលបានធ្វើទស្សនកិច្ចនៅតុលាការបានពិភាក្សាជាមួយអ្នកភូមិឬឃុំរបស់អ្នកដែលបានធ្វើទស្សនកិច្ចអំពីអង្គជំនុំជម្រះវិសាមញ្ញនៅពេលដែលក្រុមនេះត្រឡប់ទៅផ្ទះវិញ ។ ជាក់ស្តែង មេភូមិម្នាក់នៅក្នុងខេត្តតាកែវបាននិយាយក្រោយពេលដែលគាត់ត្រឡប់មកពីធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញវិញ គាត់បានប្រាប់ប្រជាជនអំពីការកាត់ទោសតាមរយៈឧគ្ឃោសនស័ព្ទ ដូច្នេះប្រជាជនជាច្រើនអាចឮអំពីការកាត់ទោសនេះ ។

ទោះបីជាការធ្វើទស្សនកិច្ចមានប្រសិទ្ធភាពក៏ដោយ ប្រជាជននៅក្នុងភូមិនិងឃុំនៅតែមានសំណួរសំខាន់ៗអំពីអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ឧទាហរណ៍ សំណួរធម្មតាត្រូវបានលើកឡើងនៅក្នុងអំឡុងពេលធ្វើការស្ទង់មតិទាំងអ្នកចូលរួមនិងប្រជាជនដែលជាតំណាងពាក់ព័ន្ធនៅពេលដែលការកាត់ទោសនឹងកើតមាននិងអ្នកដែលត្រូវទទួលការកាត់ទោស ។

**ទូរទស្សន៍ៈ** អ្នកចូលរួម៦នាក់បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមទូរទស្សន៍ ទោះបីជាឮមិនបានច្បាស់ សូម្បីតែក្រោយពេលដែលក្រុមស្រាវជ្រាវបានសួរសំណួរបន្ថែមអំពីប្រភេទកម្មវិធីទូរទស្សន៍ដែលអ្នកចូលរួមបានទស្សនារួច ។ ទូរទស្សន៍គឺជាការទំនាក់ទំនងដ៏ល្អជាមួយប្រជាជនក្នុងខេត្ត ។ ឧទាហរណ៍ ប្រធានភូមិ២នាក់នៅក្នុងខេត្តកណ្តាលបានបញ្ជាក់ថា ក្រុមគ្រួសារនីមួយៗនៅក្នុងភូមិរបស់គាត់សុទ្ធតែមានទូរទស្សន៍ ។

**កាសែត ទស្សនាវដ្តី កូនសៀវភៅណែនាំរបស់អង្គជំនុំជម្រះវិសាមញ្ញ និង ប័ណ្ណផ្សព្វផ្សាយ (ផូស្ទ័រ)**

អ្នកចូលរួមមួយចំនួនតូចបាននិយាយថា បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមរយៈប្រភពសរសេរដូចជាសៀវភៅណែនាំរបស់អង្គជំនុំជម្រះវិសាមញ្ញនិងទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកចូលរួមទាំងនេះជាធម្មតាបានទទួលសម្ភារៈទាំងនេះនៅខណៈដែលខ្លួនចូលរួមក្នុងដំណើរទស្សនកិច្ចមកកាន់អង្គជំនុំជម្រះវិសាមញ្ញ ។

អ្នកផ្តល់បទសម្ភាសន៍ម្នាក់អធិប្បាយថា សំណួរនិងចម្លើយនៅក្នុងកូនសៀវភៅណែនាំរបស់អង្គជំនុំជម្រះវិសាមញ្ញមានប្រយោជន៍ណាស់សម្រាប់គាត់ ។ មេឃុំម្នាក់ទៀតនៅក្នុងខេត្តកំពង់ឆ្នាំងបាននិយាយថា អតីតទាហានថ្នាក់ទាបរបស់ខ្មែរក្រហមមួយចំនួននៅក្នុងភូមិរបស់គាត់បានសួរថា តើអតីតទាហានខ្មែរក្រហមនឹងត្រូវទទួលការកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញទេ ។ មេឃុំបានបញ្ជាក់ថា ក្រោយការអានកូនសៀវភៅណែនាំ

របស់អង្គជំនុំជម្រះវិសាមញ្ញនិងទស្សនាវដ្តីស្វែងរកការពិត គាត់យល់ថា មានតែមេដឹកនាំដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតទេដែលនឹងទទួលការកាត់ទោស ហើយគាត់ក៏បានពន្យល់រឿងនេះទៅប្រជាជននៅក្នុងភូមិរបស់គាត់ ។ មានតែអ្នកចូលរួមម្នាក់ប៉ុណ្ណោះ បាននិយាយអំពីប័ណ្ណផ្សព្វផ្សាយ(ផូស្ទ័រ) របស់អង្គជំនុំជម្រះវិសាមញ្ញជាប្រភពព័ត៌មាន ។

អ្នកផ្តល់សម្ភាសន៍ដែលបានឮបន្តិចបន្តួចឬមិនធ្លាប់ឮអំពីការជំនុំជម្រះវិសាមញ្ញបញ្ជាក់ថា ប្រការនេះដោយសារតែគាត់មានការមមាញឹកនឹងការងារពេករហូតមិនអាចចូលប្រជុំ អានឯកសារដែលចែកជូន ឬក៏ផ្តោតអារម្មណ៍ទៅលើវិទ្យុ ឬទូរទស្សន៍ ។

## ***សេចក្តីសរុប***

ការឆ្លើយតបបញ្ជាក់ថាការធ្វើទស្សនកិច្ចទៅអង្គជំនុំជម្រះវិសាមញ្ញកម្ពុជានិងប្រព័ន្ធឃោសនាដូចជាវិទ្យុនិងទូរទស្សន៍ជាមធ្យោបាយទំនាក់ទំនងព័ត៌មានដ៏សំខាន់អំពីអង្គជំនុំជម្រះវិសាមញ្ញកម្ពុជា ។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួនតូចបានឮអំពីតុលាការតាមរយៈឯកសារសរសេរដូចជាកូនសៀវភៅណែនាំ ទស្សនាវដ្តី និងប័ណ្ណផ្សព្វផ្សាយ ។ អ្នកចូលរួមមួយចំនួនបង្ហាញថា អ្នកចូលរួមនិងអ្នកភូមិនៅក្នុងភូមិឬនៅក្នុងឃុំដូចគ្នារវល់នឹងការងារណាស់ដែលមិនអាចអានឯកសារដូចនេះបានទេ ។ គ្មាននរណាម្នាក់ដែលបានសម្ភាសន៍និយាយថា បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមអ៊ីនធឺណែតដែលមិនអាចទំនាក់ទំនងទៅដល់នៅតាមទីជនបទក្នុងប្រទេសកម្ពុជា ។

មានការចាំបាច់មួយសម្រាប់សកម្មភាពផ្សព្វផ្សាយដើម្បីឲ្យបានដល់ប្រជាជនកម្ពុជាមួយចំនួនធំ ជាពិសេសគឺអ្នកដែលមិនទាន់បានឮអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកដែលបានសម្ភាសមួយភាគធំបានបង្ហាញថា ក្រុមអ្នកចូលរួមបានឮពីអង្គជំនុំជម្រះវិសាមញ្ញកម្ពុជាតាមរយៈវិទ្យុនិងទូរទស្សន៍ និងពីការធ្វើទស្សនកិច្ចទៅអង្គជំនុំជម្រះវិសាមញ្ញដែលបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នេះគួសបញ្ជាក់ពីសារសំខាន់នៃវិធីសាស្ត្រផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងការផ្សព្វផ្សាយព័ត៌មាននិងទំនាក់ទំនងផ្ទាល់ជាមួយនិងមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញ ។

អ្នកចូលរួមដែលបានទស្សនាតុលាការឬបានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមវិទ្យុនៅតែមានសំណួរសំខាន់អំពីដំណើរការកាត់ទោសនេះ ។ បន្ថែមពីនេះ អ្នកចូលរួមដែលបានឮអំពីអង្គជំនុំជម្រះវិសាមញ្ញតាមវិទ្យុបាននិយាយថា គាត់និងប្រជាជនក្នុងភូមិឬឃុំនៅតែភ័ន្តច្រឡំអំពីបញ្ហាដូចជាថា នរណាដែលនឹងត្រូវកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញនិងពេលវេលាការកាត់ទោសនឹងកើតមាន ។

## ***ផ្នែកទី២ៈ តើការផ្សព្វផ្សាយមួយណាដែលប្រជាជនចង់បានដើម្បីទទួលព័ត៌មាន?***

សំណួរទី២គឺទាក់ទងនឹងអ្វីដែលអ្នកផ្តល់បទសម្ភាសន៍យល់ថាអ្នកភូមិឬឃុំជាមួយគ្នានឹងត្រូវការប្រភពព័ត៌មានចម្បងអំពីអង្គជំនុំជម្រះវិសាមញ្ញ ។

## ***លទ្ធផល***

***ទូរទស្សន៍និងវិទ្យុ*** ៖ អ្នកចូលរួម១៩នាក់ (ជិត២ភាគ៣នៃអ្នកដែលបានសម្ភាស) បានបញ្ជាក់ថា គាត់គិតថាទូរទស្សន៍គឺជាវិធីល្អបំផុតក្នុងការបញ្ជាក់ឲ្យអ្នកភូមិឬឃុំដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញកម្ពុជា ។ អ្នកចូលរួម១៥នាក់ទៀតបានឲ្យចម្លើយថា ជាវិទ្យុ ។

អ្នកចូលរួមបានផ្តល់ហេតុផលខុសៗគ្នាសម្រាប់ការឆ្លើយតបរបស់គាត់ ឧទាហរណ៍ៈ

- ប្រជាជនជាច្រើននៅក្នុងភូមិមានវិទ្យុនិងទូរទស្សន៍ និងដែលកាន់តែធ្វើការឲ្យលទ្ធភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទងសម្រាប់ប្រជាជននៅតាមជនបទក្នុងប្រទេសកម្ពុជា ។
- ការសន្ទនានិងសេចក្តីរាយការណ៍ព័ត៌មានភាពងាយស្រួលដើម្បីយល់និងផ្តល់ចម្លើយសម្រាប់សំណួរមួយជាច្រើន ។
- ទូរទស្សន៍ទាញចំណាប់អារម្មណ៍របស់ប្រជាជន ជាពិសេសយុវជនកម្ពុជាដែលចូលចិត្តមើលរូបភាពរបស់តុលាការនៅលើកញ្ចក់ទូរទស្សន៍ជាងការអានអក្សរ ។
- ប្រជាជនកម្ពុជាតែងតែយល់ថា ជាការពិបាកក្នុងការធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញដោយផ្ទាល់ ដូច្នេះទូរទស្សន៍និងវិទ្យុផ្តល់ប្រភពព័ត៌មានជំនួសបានល្អ ។

អ្នកផ្តល់បទសម្ភាសន៍ក៏បានឲ្យយោបល់ថា ជាការចាំបាច់សម្រាប់ការប្រជុំនិងពិភាក្សាតាមវិទ្យុនិងទូរទស្សន៍ ដើម្បីឆ្លើយនឹងសំណួរដែលនៅមានអំពីអង្គជំនុំជម្រះវិសាមញ្ញ ។

### កាសែត ទស្សនាវដ្តី កូនសៀវភៅណែនាំរបស់អង្គជំនុំជម្រះវិសាមញ្ញ ប័ណ្ណផ្សព្វផ្សាយ (ផូស្ទ័រ)

អ្នកចូលរួម៥នាក់បាននិយាយពីឯកសារសរសេរដូចជាកូនសៀវភៅណែនាំរបស់អង្គជំនុំជម្រះវិសាមញ្ញនិងទស្សនាវដ្តីស្វែងរកការពិត ជាមធ្យោបាយដ៏ប្រសើរសម្រាប់ការផ្សព្វផ្សាយព័ត៌មាន ។ អ្នកផ្តល់បទសម្ភាសន៍បានបញ្ជាក់ថា កូនសៀវភៅណែនាំរបស់អង្គជំនុំជម្រះវិសាមញ្ញគឺមានប្រយោជន៍សំខាន់តាមរយៈផ្នែកសំណួរនិងចម្លើយ ។ មួយចំនួនផ្សេងទៀតបានបង្ហាញថា រូបភាពគឺអាចជួយឲ្យកាន់តែយល់អំពីអង្គជំនុំជម្រះវិសាមញ្ញ ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកចូលរួមម្នាក់ដែលមកពីខេត្តកំពង់ឆ្នាំង ដែលជាអ្នកបានធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញបានជជែកថា ប័ណ្ណផ្សព្វផ្សាយនឹងមានប្រយោជន៍សម្រាប់ការផ្សព្វផ្សាយព័ត៌មាន អ្នកចូលរួមមួយចំនួនដែលអវត្តមានក្នុងដំណើរទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញថា ប័ណ្ណផ្សព្វផ្សាយធ្វើឲ្យប្រជាជនច្របូលច្របល់និងសុំឲ្យមានការពន្យល់បន្ថែម ។

គ្មានអ្នកចូលរួមណាម្នាក់និយាយថា កាសែតជាប្រភពដ៏ប្រសើរក្នុងការផ្សព្វផ្សាយនោះទេ ។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួននិយាយថា កាសែតមិនអាចទៅដល់ប្រជាជននៅក្នុងខេត្តនិងមួយចំនួនទៀតនិយាយថា ប្រជាជនកម្ពុជារវល់ការងារមិនអាចអានព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញទេ ។ មេឃុំម្នាក់នៅក្នុងខេត្តកំពង់ឆ្នាំងក៏បានជជែកថា ប្រជាជនទាំងអស់មិនអាចអានទស្សនាវដ្តី ឬក៏សៀវភៅទេ ដូច្នេះការធ្វើទស្សនកិច្ចនៅតុលាការនឹងកាន់តែមានប្រសិទ្ធភាពនៅក្នុងការពន្យល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

### ដំណើរទស្សនកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញកម្ពុជា

ទោះជាយ៉ាងណាក៏ដោយអ្នកចូលរួមតែ២នាក់ប៉ុណ្ណោះនិយាយថា អ្នកទាំងពីរគិតថា អ្នកភូមិឬឃុំជាមួយគ្នានឹងពេញចិត្តទទួលព័ត៌មានតាមរយៈដំណើរទស្សនកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ អ្នកដែលបានធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់ថា ការធ្វើទស្សនកិច្ចដូចនេះគឺជាវិធីដែលមានប្រយោជន៍ដើម្បីជូនដំណឹងដល់ប្រជាជនអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកចូលរួមជាច្រើនបានលើកទឹកចិត្តឲ្យបន្តការធ្វើទស្សនកិច្ចដើម្បីឲ្យបានទៅដល់ប្រជាជនកម្ពុជាជាច្រើនថែមទៀតរួមទាំងអ្នកដែលមិនបានឮពីអង្គជំនុំជម្រះវិសាមញ្ញ ។ បន្ថែមពីនេះទៀត អ្នកធ្វើសម្ភាសន៍យល់ថា អ្នកដែលបានធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញដោយផ្ទាល់ មានកម្រិតយល់ដឹងខ្ពស់អំពីតុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ចម្លើយរបស់អ្នកចូលរួមបញ្ជាក់ថា ប្រជាជនកម្ពុជាមានការមមាញឹករហូតមិនអាចចូលរួមដំណើរទស្សនកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក៏បញ្ជាក់ថា ការផ្សព្វផ្សាយពីទំនាក់ទំនងមិនអាចទៅដល់ប្រជាជនកម្ពុជាជាច្រើន។

### ការប្រជុំនៅតាមភូមិ-ឃុំ ការបញ្ចាំងភាពយន្ត ការសម្តែងល្ខោន

អ្នកចូលរួម៣នាក់បាននិយាយពីសារសំខាន់នៃការជួបប្រជុំរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងភូមិឬឃុំដើម្បីណែនាំឲ្យមានការយល់ដឹងបន្ថែមអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកចូលរួម២នាក់ផ្សេងទៀតបាននិយាយអំពីការបញ្ចាំងភាពយន្តគឺជាវិធីដ៏ល្អដើម្បីទាញការចាប់អារម្មណ៍របស់ប្រជាជននិងជួយឲ្យប្រជាជនសួរសំណួរអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកឆ្លើយតបម្នាក់បានឲ្យយោបល់ថា យុវជនតែងតែបែរការចាប់អារម្មណ៍មើលខ្សែភាពយន្តនៅតាមទូរទស្សន៍ ដូច្នេះគាត់យល់ថា ការប្រជុំគឺជាវិធីមួយដ៏ល្អដើម្បីទទួលបានការយកចិត្តទុកដាក់ពីយុវជន ។ ទោះបីជាយ៉ាងណាក៏ដោយ ស្របពេលជាមួយគ្នានេះដែរ ការសម្ភាសន៍មួយផ្សេងទៀតបានទាក់ទងនឹងសមាជិកអ្នកភូមិឬឃុំចាស់ៗគឺមានការរវល់និងចូលរួមក្នុងការប្រជុំ ។

ថ្វីដ្បិតតែការឆ្លើយតបខុសៗគ្នានេះ អំពីការប្រជុំនឹងមានប្រយោជន៍សម្រាប់ការផ្សព្វផ្សាយក៏ដោយ អ្នកចូលរួមមួយចំនួនធំបានមានសំណួរផ្ទាល់ខ្លួន ហើយបានប្រាប់អ្នកធ្វើសម្ភាសន៍អំពីសំណួរនៅតុលាការនឹងត្រូវបានលើកឡើងនៅក្នុងភូមិនិងឃុំរបស់អ្នកចូលរួម ។

អ្នកចូលរួមម្នាក់ឲ្យយោបល់ថា ការសម្តែងល្ខោននឹងជួយក្នុងការពន្យល់ប្រជាជនអំពីតុលាការ ហើយនឹងជួយប្រជាជនកម្ពុជាបង្កើនការយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញ ។

### សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះបង្ហាញថា ប្រជាជនកម្ពុជាចូលចិត្ត

ទទួលព័ត៌មានស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញតាមវិទ្យុឬទូរទស្សន៍ជាមធ្យម ។ វេទិការដែកសួរឆ្លើយតាមវិទ្យុ កម្មវិធីទូរទស្សន៍និងការទស្សនាខ្សែភាពយន្តគឺជាវិធីទាក់ទាញក្នុងការផ្សព្វផ្សាយព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ ការជួបប្រជុំនៅតាមឃុំឬតាមភូមិ និងឯកសារដែលត្រូវបានចងក្រងដូចជាកូនសៀវភៅណែនាំនិងទស្សនាវដ្តីមានលក្ខណៈមធ្យមដែលតាមរយៈនេះប្រជាជនកម្ពុជាក៏អាចរៀនសូត្រអំពីតុលាការខ្មែរក្រហមដែរ ។

### ផ្នែកទី៣៖ តើនរណាដែលប្រជាជនកម្ពុជាអាចទទួលព័ត៌មានបានប្រសើរពីអង្គជំនុំជម្រះវិសាមញ្ញ?

សំណួរទីបីទាក់ទិននៅនឹងអ្នកដែលអាចផ្តល់ព័ត៌មានប្រសើរជាងគឺរដ្ឋាភិបាលកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញឬអង្គការក្រៅរដ្ឋាភិបាល ។

### លទ្ធផល

គំរូមួយដែលច្បាស់បានលេចចេញពីការស្ទង់មតិនេះ ។ លើកលែងអ្នកផ្តល់បទសម្ភាសន៍តែពីរនាក់ប៉ុណ្ណោះ នៅក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន៣១នាក់បានសម្តែងមតិថា ខ្លួនចង់ទទួលព័ត៌មានមួយច្បាស់ចេញពីរដ្ឋាភិបាល ឬចេញពីតុលាការខ្លួនឯងផ្ទាល់ ។ ទោះបីជាយ៉ាងណា ប្រជាជន៦នាក់ក្នុងចំណោម១៧នាក់បាននិយាយថា ខ្លួនចង់បានព័ត៌មានចេញពីរដ្ឋាភិបាលដែលអាចប្រសើរជាងចេញពីតុលាការខ្លួនឯង ។ ដុយពីអ្នកទាំង៦នាក់ឆ្លើយដំបូងថា ខ្លួនចង់ទទួលព័ត៌មានពីរដ្ឋាភិបាល ។ បន្ទាប់មកអ្នកឆ្លើយសំណួរចង់បានការពិភាក្សាពីភាគីអង្គការសហប្រជាជាតិ ឬជាមួយភាគីកម្ពុជានិងអង្គការសហប្រជាជាតិធ្វើការជាមួយគ្នាបានបញ្ជាក់ថា ពួកគាត់ចង់បានព័ត៌មានអំពីតុលាការពីភាគីកម្ពុជាជាង ។ បន្ថែមពីនេះ អ្នកឆ្លើយមួយចំនួននិយាយថា ខ្លួនចង់បានព័ត៌មានពីមន្ត្រីរដ្ឋាភិបាលដែលធ្វើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វាអាចថា ចម្លើយដែលទទួលបានបែបនោះជារឿងធម្មតាទេ ដោយសារប្រជាជនកម្ពុជាជាទូទៅមិនស្គាល់ឬមិនសាំុនឹងពាក្យ «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។

អ្នកចូលរួម១៧នាក់បានឆ្លើយនឹងសំណួរថា តើប្រភពណាដែលអ្នកអាចទទួលព័ត៌មានដ៏ប្រសើរបំផុត? ចម្លើយរបស់គាត់គឺតាមរយៈ«រដ្ឋាភិបាល» ។ អ្នកចូលរួមម្នាក់ចង់បានព័ត៌មានចេញពីរដ្ឋាភិបាលដោយសារគាត់យល់ថា រដ្ឋាភិបាលអាចពន្យល់ប្រជាជនអំពីខ្មែរក្រហម ។ ចំណែកអ្នកផ្សេងទៀតចង់រៀនសូត្រពីរដ្ឋាភិបាលពីព្រោះរដ្ឋាភិបាលជាសម្រេចនៅពេលដែលរឿងរ៉ាវនឹងកើតឡើង និងដើរតួយ៉ាងសំខាន់ក្នុងការប្រាប់ប្រជាជនឲ្យដឹងនូវដែលកំពុងកើតឡើង ។ អ្នកផ្តល់បទសម្ភាសន៍មួយភាគបីបានជ្រើសរើសប្រភពនេះដោយសារគាត់ជឿជាក់ថា តុលាការអាច



កើតឡើងលុះត្រាណាតែរដ្ឋាភិបាលខ្លួនឯងបានជួយធ្វើឲ្យបញ្ហានេះកើតឡើង ។

កាន់តែសំខាន់ជាងនេះ អ្នកចូលរួម៦នាក់ក្នុងចំណោមអ្នកទាំង១៧នាក់ដំបូងបានឆ្លើយថា គាត់ចង់ទទួលព័ត៌មានពីរដ្ឋាភិបាលក្រោយមកចាត់ទុកចម្លើយរបស់ខ្លួនសំដៅទៅលើអង្គជំនុំជម្រះវិសាមញ្ញវិញ ។ ជាក់ស្តែង ប្រធានភូមិម្នាក់នៅក្នុងខេត្តកំពង់ឆ្នាំងបាននិយាយថា គាត់ចង់បានព័ត៌មានអំពីតុលាការតាមរយៈរដ្ឋា-

ភិបាល ។ នៅពេលដែលសុំឲ្យគាត់ជួយបញ្ជាក់តើគាត់យល់យ៉ាងដូចម្តេចចំពោះ «រដ្ឋាភិបាល» ប្រធានភូមិម្នាក់នោះនិយាយថា គាត់ចង់សំដៅលើស្ថាប័នដែលអាចនាំខ្មែរក្រហមមកកាត់ទោស ។ ប្រធានភូមិផ្សេងទៀតបានមានប្រសាសន៍ថា គាត់ចង់ទទួលព័ត៌មានអំពីតុលាការខ្មែរក្រហមតាមរយៈរដ្ឋាភិបាល បន្ទាប់មកគាត់សង្កត់ធ្ងន់ពីសារសំខាន់របស់មន្ត្រីរដ្ឋាភិបាលនៅក្នុងអង្គជំនុំ



ប្រជាជនទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ជម្រះវិសាមញ្ញមកកាន់ភូមិរបស់គាត់ ។ គាត់សន្និដ្ឋានដោយនិយាយថា «ប្រជាជនពិតជាយល់ច្បាស់ថា គាត់ចង់ឮចេញពីមន្ត្រីតុលាការ» ។ នេះជាការបង្ហាញប្រាប់ម្តងទៀតថាអ្នកចូលរួមចង់សំដៅលើមន្ត្រីរដ្ឋាភិបាលដែលបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

**អង្គជំនុំជម្រះវិសាមញ្ញៈ** អ្នកឆ្លើយ១២នាក់បានឆ្លើយថា គាត់ចង់បានបំផុតដើម្បីដឹងអំពីតុលាការចេញពីមន្ត្រី ឬតំណាងរបស់មន្ត្រីតុលាការខ្លួនឯង ។ ជាទូទៅការឆ្លើយតបទាំងនេះពិតជាបង្ហាញច្បាស់ ហើយសំណួរបន្តបន្ទាប់ទៀតបានថ្លែងថា ហេតុអ្វីអ្នកចូលរួមគិតថា តុលាការអាចជាប្រភពព័ត៌មានដ៏សំខាន់ ។ លោកជំទប់ទី១ឃុំទឹកវិលបាននិយាយថា គាត់ចង់បានព័ត៌មានពីតុលាការខ្លួនឯងពីព្រោះថាជាស្ថាប័នដែលផ្តើការងារលើតុលាការនេះ ។ ស្រដៀងគ្នានេះ មេឃុំស្នោបាននិយាយថាអង្គជំនុំជម្រះវិសាមញ្ញជាប្រភពព័ត៌មានល្អបំផុត ពីព្រោះស្ថាប័ននេះទទួលខុសត្រូវក្នុងការនាំមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។

ភាគច្រើននៃអ្នកចូលរួមបានឆ្លើយថា ខ្លួនចង់ទទួលព័ត៌មានពីតុលាការដែលមានហេតុផលប្រហាក់ប្រហែលគ្នា ដែលរួមមានអង្គជំនុំជម្រះវិសាមញ្ញមានអ្នកជំនាញច្រើនដែលអាចវិធីល្អបំផុតដើម្បីពន្យល់អំពីដំណើរការតុលាការ ហើយអាចជួយឲ្យប្រជាជនកម្ពុជាស្វែងយល់អ្វីដែលកំពុងតែកើតឡើង ។

**អង្គការក្រៅរដ្ឋាភិបាលៈ** អ្នកចូលរួមពីរនាក់ឆ្លើយថា គាត់ទាំងពីរពេញចិត្តបំផុតក្នុងការទទួលព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាលមួយ ។ ជាលើកទី១នៃអ្នកចូលរួមទាំងអស់ដែលបានចូលរួមទស្សនកិច្ចជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា អង្គការក្រៅរដ្ឋាភិបាលមានខ្សែបណ្តាញទាក់ទងនៅក្នុងឃុំរបស់គាត់ ។ គាត់បន្តទៀតថា គាត់មិនចង់បានព័ត៌មានចេញពីវិទ្យុនិងទូរទស្សន៍ទេ ពីព្រោះប្រជាជនស្តាប់តាមប្រព័ន្ធផ្សព្វផ្សាយដូចជាស្តាប់ដូរតន្ត្រីប៉ុណ្ណោះ ដូច្នេះហើយពួកគាត់មិនអាចទទួលព័ត៌មានច្រើនបានទេ ប្រសិនបើគ្មានកម្មវិធីអប់រំតាមមូលដ្ឋានដឹកនាំតែតាមរយៈប្រព័ន្ធផ្សព្វផ្សាយទាំងនេះ ។

អ្នកឆ្លើយផ្សេងទៀតដែលបានដកស្រង់ចេញពីសេចក្តីថ្លែងជម្រើសនេះបាននិយាយថា គាត់ចូលចិត្តទទួលព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាលជាងរដ្ឋាភិបាល ពីព្រោះរដ្ឋាភិបាលមានភាពស្មុគស្មាញណាស់ ។ គាត់មិនបានបង្ហាញថា គាត់បានដឹងច្បាស់តាមរយៈអង្គការក្រៅរដ្ឋាភិបាលទេ ហើយក៏មិនបានសំដៅទៅលើដំណើរទស្សនកិច្ចទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។

## សេចក្តីសន្និដ្ឋាន

អ្នកចូលរួមទាំងអស់ចង់ស្វែងយល់ព័ត៌មានអំពីតុលាការ

ចេញពីប្រភព “ផ្លូវការ” ។ ទិន្នន័យនេះបញ្ជាក់ថា អ្នកភូមិនិងប្រធានឃុំដែលបានស្ទង់មតិ ចូលចិត្តបំផុតក្នុងទទួលព័ត៌មានអំពីតុលាការពីប្រភពផ្លូវការ ដូច្នេះផ្ទុយពីអង្គការក្រៅរដ្ឋាភិបាល ។ មានតែមេឃុំពីរនាក់ប៉ុណ្ណោះបានថ្លែងថា ការចូលចិត្តបែបផ្សេងៗគ្នាសម្រាប់អង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់ព័ត៌មាន ហើយវាអាចថាជាជម្រើសរបស់អង្គការក្រៅរដ្ឋាភិបាលដែលមិនមានរៀបរាប់នៅក្នុងបញ្ជី ហើយអង្គការជាច្រើនមិនបានផ្តល់ឲ្យជាការពេញចិត្តទាល់តែសោះ ។ លទ្ធផលនេះជាការភ្ញាក់ផ្អើលបន្តិចបន្តួច ដូច្នេះស្ទើរតែពាក់កណ្តាលនៃប្រជាជនដែលបានសម្ភាសន៍បានស្វែងយល់អំពីអង្គជំនុំជម្រះវិសាមញ្ញតាមរយៈដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ថ្វីបើទំនាក់ទំនងស្តែងចេញយ៉ាងច្បាស់ថា មេឃុំនោះមានចំណូលចិត្តជាមួយអង្គការក្រៅរដ្ឋាភិបាល ហើយកត្តាដែលថាភាគច្រើននៃព័ត៌មានគាត់បានទទួលអំពីតុលារការចេញមកពីលទ្ធផលនៃការងាររបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់មានម្នាក់ដែលបានមកទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាមានអារម្មណ៍ថាវាការសំខាន់បំផុតដើម្បីទទួលព័ត៌មានពីអង្គការ ។ ហេតុផលនេះបញ្ជាក់ថា វាមានសារសំខាន់ចំពោះអង្គការក្នុងការបន្តទំនាក់ទំនងសកម្មភាពអប់រំនៅតាមមូលដ្ឋាន ហើយជាព័ត៌មានដែលមានពីប្រភពផ្សេងដែលប្រជាជនកម្ពុជាទុកចិត្តបំផុតថាត្រឹមត្រូវបំផុត ហើយផ្អែកទៅលើការស្វែងយល់អំពីតុលារការខ្មែរក្រហមទាំងអស់នេះគឺចេញពី “ផ្លូវការ” ។

អ្នកឆ្លើយជាច្រើនមិនដឹងថា តុលាការខ្មែរក្រហមជាស្ថាប័នឯករាជ្យពីរដ្ឋាភិបាលកម្ពុជា ។ ជាក់ស្តែងប្រជាជនកម្ពុជាជាច្រើនមិនយល់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីដើរតួនាទីដោយឯករាជ្យពីរដ្ឋាភិបាលកម្ពុជា ។ ភាគច្រើននៃអ្នកឆ្លើយបានដាក់បញ្ចូលរវាងអង្គជំនុំជម្រះវិសាមញ្ញនិងរដ្ឋាភិបាលជាតិដែលជារដ្ឋាភិបាលគ្រប់គ្រងប្រទេស ដូច្នេះរាជរដ្ឋាភិបាលគួរតែផ្តល់ព័ត៌មានឲ្យយើងអំពីតុលាការខ្មែរក្រហម ។ ជាឧទាហរណ៍ អ្នកឆ្លើយមួយចំនួនមិនបានយល់ពីភាពខុសគ្នារវាងតុលាការខ្មែរក្រហមនិងរដ្ឋាភិបាលជាតិ ហើយសុំឲ្យមន្ត្រីរដ្ឋាភិបាលម្នាក់ចេញពីតុលាការចែកចាយព័ត៌មានជាមួយនឹងតំណាងចេញពីខាងអង្គការសហប្រជាជាតិ ។ វានៅតែមិនច្បាស់លាស់ចេញពីបទសម្ភាសន៍ថាតើអ្នកឆ្លើយចង់មានន័យថា ជាតំណាងមន្ត្រីរដ្ឋាភិបាលម្នាក់ខាងភាគីកម្ពុជារបស់តុលាការឬតំណាងជនសាមញ្ញម្នាក់របស់រដ្ឋាភិបាលជាតិ ។

កង្វះការយល់ដឹងបែបនេះចំពោះភាពដាច់ដោយឡែកជាមូលដ្ឋាននិងឯករាជ្យភាពរបស់តុលាការ ប្រហែលជាអាចយល់បានសម្រាប់អ្នកឆ្លើយទាំងនោះដែលមិនបានទទួលការសិក្សាពីតុលាការនិងអ្នករស់នៅក្នុងតំបន់ដាច់ស្រយាលដែលមិនបានទទួលព័ត៌មានច្រើនអំពីតុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ការឆ្លើយតបរបស់អ្នកចូលរួមប្រាំមួយនាក់បញ្ជាក់ថា ពួកគាត់មិនទាន់យល់ច្បាស់អំពីការបង្កើតតុលាការនេះថាជាស្ថាប័នមួយធ្វើការសម្រេចចិត្តដោយឯករាជ្យចេញពីរដ្ឋាភិបាល បើទោះបីជាគាត់បានទទួលការអប់រំស្តីអំពីតុលាការខ្មែរក្រហម ឬក៏តាមរយៈដំណើរទៅកាន់អង្គជំនុំជម្រះវិសាមញ្ញដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារ ឬក៏តាមរយៈអង្គជំនុំជម្រះខ្លួនឯងក៏ដោយ ។

## ៥) អនុសាសន៍

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គួរតែផ្តោតទៅលើការផ្សព្វផ្សាយតាមមូលដ្ឋានរបស់ខ្លួនទៅលើការផ្តល់ព័ត៌មានឲ្យកាន់តែច្បាស់ដែលខ្លួនមានអំពីតុលាការ ហើយបែងចែកព័ត៌មានទាំងនេះតាមកម្មវិធីវិទ្យុនិងទូរទស្សន៍ ។ អ្នកស្រាវជ្រាវជឿជាក់ថា ការរកឃើញពីសារសំខាន់បំផុតចេញពីការសិក្សានេះគឺថាអ្នកដែលផ្តល់បទសម្ភាសចង់រៀនសូត្រអំពីតុលាការនេះចេញពីប្រភពផ្លូវការ ។ ភាគច្រើននៃអ្នកឆ្លើយតបចាត់ទុករដ្ឋាភិបាលនិងមន្ត្រីតុលាការជាប្រភពដែលគាត់ចាត់ទុកថាជាព័ត៌មានផ្លូវការ ។ ការស្វែងរកបញ្ហាស្មុគស្មាញទាំងអស់នេះគឺថា ការផ្សព្វផ្សាយទៅតាមមូលដ្ឋានអាចកាន់តែពេញនិយមប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញខិតខំប្រឹងប្រែងអនុវត្តកម្មវិធីផ្សព្វផ្សាយតាមមូលដ្ឋាននេះដោយផ្ទាល់ ហើយបញ្ឈប់ការពឹងពាក់លើសង្គមស៊ីវិលដើម្បីពិនិត្យឡើងវិញនូវបណ្តាញទាក់ទងរបស់ខ្លួនក្នុងការចែកចាយព័ត៌មាន ។ នេះមិនមែនមានន័យថាអង្គជំនុំជម្រះវិសាមញ្ញរំពឹងថា អនុវត្តការងារទាំងអស់នោះដោយគ្មានការគាំទ្រនោះទេ ។ ជាងនេះទៅទៀត

ការពិនិត្យនូវឯកសារជាក់លាក់មួយចំនួនតាមរយៈអង្គការក្រៅរដ្ឋាភិបាលជាមួយអ្នកជំនាញទៅលើផ្នែកណាមួយជាក់លាក់ (ឧទាហរណ៍ ការពិនិត្យមើលទៅលើរូបភាពតាមរយៈអង្គការចិត្តសង្គមអន្តរវប្បធម៌ ដើម្បីធានាឲ្យបានថាប្រជាជនមិនមានផលប៉ះពាល់ផ្លូវចិត្ត) អាចជួយបង្កើនប្រសិទ្ធភាពការផ្តល់សាររបស់តុលាការទៅដល់ប្រជាជន ។

ទិន្នន័យខាងលើនេះបញ្ជាក់ថា កម្មវិធីវិទ្យុនិងទូរទស្សន៍ដែលផ្សព្វផ្សាយតាមស្ថានីយ៍និងនៅពេលវេលាសមស្របមួយនឹងឮដល់ប្រជាជនជាច្រើន ។ ការផ្សព្វផ្សាយនេះប្រហែលជាអាចជួយបង្កើតជាមូលដ្ឋានដល់ប្រជាជនដែលគាត់អាចផ្តល់ប្រភពព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញទៅដល់ប្រជាជនកម្ពុជាដទៃទៀត ។ អនុសាសន៍ជាក់លាក់មួយចំនួនទាក់ទងនឹងសកម្មភាពក្នុងការផ្តល់ព័ត៌មានដែលមានប្រសិទ្ធភាពនិងអាចធ្វើទៅបានរួមមាន ÷

- ផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់កម្មវិធីវិទ្យុខ្លីៗ ដូច្នេះប្រជាជនកម្ពុជាមួយចំនួនអាចទទួលបានព័ត៌មានតាមរយៈកម្មវិធីវិទ្យុទាំងអស់នោះ ។
- ផ្តោតសំខាន់ទៅលើកម្មវិធីវិទ្យុនិងទូរទស្សន៍ដែលចូលរួមពីមន្ត្រីតុលាការជាមធ្យោបាយមួយក្នុងការប្រាប់ប្រជាជនអំពីតុលាការពិសេសតាមរយៈការថតយកការពិភាក្សានូវចំណុចពិសេសណាមួយរបស់តុលាការ (ឧទាហរណ៍ វគ្គមួយអំពីរចនាសម្ព័ន្ធការបោះឆ្នោតនិងវគ្គមួយអំពីសារសំខាន់របស់សាក្សី) ។ វិធីទាំងនោះត្រូវសរសេរជាលាយលក្ខណ៍អក្សរដើម្បីណែនាំពីនីតិវិធីដ៏ស្មុគស្មាញ និងប៉ាន់ស្មានពីកម្រិតយល់ដឹងជាមូលដ្ឋានដែលមានអំពីតួនាទីរបស់ប្រព័ន្ធច្បាប់ ។
- បង្កើតការជជែកពិភាក្សាជាមួយបុគ្គលិករបស់តុលាការ (ហើយបន្តចូលរួមក្នុងការពិភាក្សាដែលមានស្រាប់) ដើម្បីលើកកម្ពស់ការពិភាក្សានិងសំណួរឆ្លើយអំពីអង្គជំនុំជម្រះវិសាមញ្ញ ។
- ធានាថាឯកសារជាអក្សរដែលយកមកប្រើប្រាស់ វាជាក់លាក់និងប្រើពាក្យសាមញ្ញដែលអាចបកស្រាយជូនប្រជាជនដែលទទួលព័ត៌មានទាំងអស់នោះ ជាពិសេសសំណួរមួយចំនួនដែលប្រជាជនសួរជដែល ដូចជានរណានឹងត្រូវនាំមកកាត់ទោស? ហើយតើតុលាការនឹងកើតឡើងនៅពេលណា?
- រៀបចំការប្រជុំនៅតាមខេត្តជាមួយមន្ត្រីតុលាការដោយមានខ្សែភាពយន្តរឿងនិងសម្តែងសិល្បៈមួយចំនួនដើម្បីលើកទឹកចិត្តឲ្យប្រជាជនចូលរួមនិងពិភាក្សាអំពីតុលាការ ។
- ផ្តល់ឯកសារជាអក្សរដូចជាកូនសៀវភៅណែនាំនិងប័ណ្ណផ្សព្វផ្សាយមួយចំនួនដែលជាប្រភពព័ត៌មានកំណត់ ឬជាព័ត៌មានបំពេញបន្ថែមសម្រាប់អ្នកទាំងឡាយណាដែលមានការអប់រំខ្ពស់មានពេលវេលានិងមានចំណាប់អារម្មណ៍ខ្លាំងជាដាច់យកឯកសារទាំងនេះធ្វើប្រភពព័ត៌មានដំបូងសម្រាប់ប្រជាពលរដ្ឋទូទៅ ។

អង្គជំនុំជម្រះវិសាមញ្ញគួរតែផ្តោតទៅលើឯកសារអប់រំទូទៅដើម្បីបង្កើនការស្វែងយល់របស់ប្រជាជនកម្ពុជាអំពីចំណុចសំខាន់ៗរបស់តុលាការ ។ ជាលទ្ធផលនៃការសិក្សានេះបង្ហាញថា អ្នកផ្តល់បទសម្ភាសន៍យល់ដឹងជាទូទៅអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការមិនឯករាជ្យចេញពីរដ្ឋាភិបាល ប៉ុន្តែធ្វើការងារឯករាជ្យមួយក្នុងដែនកំណត់ប៉ុណ្ណោះ ។ ដូច្នេះតុលាការមានសារសំខាន់ក្នុងការដើរតួ និងបង្ហាញតួនាទីជាស្ថាប័នមួយដែលឯករាជ្យមិនស្ថិតក្រោមការសម្រេចចិត្តរបស់រដ្ឋាភិបាល ។ ដោយយោងតាមផ្នែកដ៏សំខាន់មួយទៀតនៃព័ត៌មានអំពីតួនាទីរបស់តុលាការចាំបាច់ត្រូវតែផ្សព្វផ្សាយជាសាធារណៈ ។ អ្នកជំនាញចេញពីស្ថាប័នកម្ពុជានិងស្ថាប័នបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលបានពិភាក្សាគ្នាជាពិសេសពីភាពឯករាជ្យរបស់តុលាការគួរតែជួយបញ្ជាក់ឲ្យច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាស្ថាប័នឯករាជ្យមួយរបស់រដ្ឋាភិបាល ។ ការពិភាក្សានេះផងដែរជាកាតព្វកិច្ចរបស់តុលាការត្រូវធ្វើទៅតាមច្បាប់របស់តុលាការនៅពេលដែលធ្វើការសម្រេចចិត្តនិងគួរតែជួយធ្វើឲ្យតុលាការនេះកាន់តែមានភាពឯករាជ្យថែមទៀត ។

បន្ថែមពីនេះ ការជូនដំណឹងគួរតែធ្វើឲ្យបានច្បាស់លាស់តាមរយៈការពិភាក្សានៅតាមវិទ្យុដើម្បីកុំឲ្យប្រជាជនយល់ច្រឡំថាអ្នកដែលត្រូវនាំយកមកកាត់ទោសមានទោសកំហុសមុនពេលសាលក្រមស្ថាពរ(លែងមានសិទ្ធិតវ៉ា)កំណត់ថា ជននោះមានទោស ហើយការជូនដំណឹងមួយទៀតគឺថាតុលាការត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនដោយផ្អែកលើច្បាប់ ។

**ន័រមិន, ភារតេរីន និង សុខឃាង**

# តួនាទីទូលំទូលាយរបស់សាលាក្តី៖ ការជំរុញឱ្យមានការផ្សះផ្សា សន្តិភាព និងសន្តិសុខ

ក៏ដូចតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម័យទំនើបផ្សេងៗទៀតដែរ គោលបំណងចម្បងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺដើម្បីស្វែងរកយុត្តិធម៌ ដោយនាំយកជនដែលដឹកនាំរបបដ៏ព្រៃផ្សៃនេះមកកាត់ទោសដូចជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទោះជាយ៉ាងនេះក្តី សាលាក្តីខ្មែរក្រហមក៏ចែករំលែកគោលដៅធំនៃដំណើរការជំរុញឲ្យមានការទទួលខុសត្រូវរបស់អន្តរជាតិដែរ ។ សាលាក្តីនេះមានសក្តានុពលក្នុងការចូលរួមក្នុងគោលដៅទូលំទូលាយនេះ ដូចជាការកសាងការផ្សះផ្សាជាតិ សន្តិភាព សន្តិសុខ និងការអភិវឌ្ឍន៍ ។

## ការសម្រេចឲ្យបាននូវការផ្សះផ្សាជាតិ

ការផ្សះផ្សារះជាតិមិនចាំជាគោលដៅពិតប្រាកដរបស់សាលាក្តីដូចយុត្តិធម៌ទេ ។ ក្រុមអ្នកគាំទ្រសាលាក្តីបានអះអាងយ៉ាងត្រឹមត្រូវថា សក្តានុពលនៃការកាត់ក្តីរឿងព្រហ្មទណ្ឌនឹងជួយសម្រួលដល់ដំណើរការនៃការផ្សះផ្សាជាតិ បើទោះបីជាបទពិសោធន៍ពីអតីតកាលរបស់តុលាការអន្តរជាតិនិងតុលាការចម្រុះបានបង្ហាញថា ឥទ្ធិពលរបស់សាលាក្តីទៅលើការព្យាបាលផ្នែកសង្គមទូលំទូលាយមួយគឺប្រហែលជាមានការលំបាកក្នុងការវាស់វែង ។ ទោះជាយ៉ាងនេះក្តី ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនឹងគាំទ្រដល់ដំណើរការផ្សះផ្សាជាតិ ដោយធ្វើការលាតត្រដាងការពិតតាមផ្លូវច្បាប់ក្នុងទ្រង់ទ្រាយធំមួយនិងដាក់ឲ្យជនដែលដល់ប្រឈមមុខនឹងទោសកំហុសរបស់ខ្លួនជាសាធារណៈ ។ ការយល់ដឹងកាន់តែប្រសើរឡើងនូវអ្វីដែលបានកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មូលហេតុនៃការកើតឡើងនិងអ្នកណាជាអ្នកទទួលខុសត្រូវចំពោះសោកនាដកម្មនាសម័យនោះអាចជួយឲ្យប្រជាជនសម្រេចបាននូវអារម្មណ៍នៃការបញ្ចប់រឿងរ៉ាវពីអតីតកាល និងបោះជំហានឆ្ពោះទៅមុខ ។

## ការផ្សះផ្សានៅក្នុងសង្គម

*"ការផ្សះផ្សា"*គឺជាភាសាទូលំទូលាយមួយ ដែលមានការពិបាកក្នុងការកំណត់និយមន័យ ។ ក្នុងនាមជាដំណើរការមួយ ការផ្សះផ្សាអាចត្រូវបានពណ៌នាថាជាការវិវត្តន៍មួយដែលតាមរយៈនេះប្រជាជនយល់ដឹងអំពីរឿងរ៉ាវពីអតីតកាលបានដាក់រឿងរ៉ាវទាំងអស់នេះទៅក្នុងគោលគំនិតមួយ ហើយបោះជំហានឆ្ពោះទៅអនាគតមួយដែលមានស្ថិរភាពនិងរួបរួមគ្នា ។ ការផ្សះផ្សាតម្រូវឲ្យមានការចូលរួមពីសំណាក់អតីតគូបដិបក្ខ ។ វាតម្រូវឲ្យគូភាគីទាំងឡាយប្រឈមមុខនឹងអតីតកាលដោយជាក់ស្តែង ដោយសីលធម៌ និងដោយផ្លូវចិត្ត ។ ធ្វើដូច្នេះ អ្នកទាំងនេះអាចផ្តោតទៅលើអនាគតមួយដែលត្រូវចែករំលែកគ្នា ។ មានន័យថា អតីតគូបដិបក្ខត្រូវបង្កើតឡើងវិញនូវទំនាក់ទំនងល្អប្រសើរ ដូច្នេះរឿងរ៉ាវពីអតីតកាលនឹងមិនបន្តផ្តល់ផលប៉ះពាល់អវិជ្ជមានមកលើជីវិតរស់នៅរួមគ្នាទៀត ។ និយាយដោយសាមញ្ញទៅ ការបំភ្លេចចោលអតីតកាលមិនគ្រប់គ្រាន់ទេ ។ លោក Archbishop Desmond Tutu ពីប្រទេសអាហ្វ្រិកខាងត្បូងបានពណ៌នាការផ្សះផ្សាថា មានទំនាក់ទំនងទៅនឹង*"ដំណើរដ៏វែងឆ្ងាយនិងឈឺចាប់ ដូចជាការបង្ហាញការឈឺចាប់និងទុក្ខវេទនារបស់ជនរងគ្រោះ យល់ដឹងអំពីការជំរុញលើកទឹកចិត្តឲ្យប្រព្រឹត្តបទល្មើសរបស់ជនល្មើស ការនាំយកសហគមន៍ទាំងឡាយដែលបែកបាក់មករួបរួមគ្នា និងសេចក្តីព្យាយាមដើម្បីស្វែងរកផ្លូវទៅកាន់យុត្តិធម៌ ការពិត និងចុងក្រោយបំផុតនោះគឺសន្តិភាព"* ។

នៅក្នុងប្រទេសដែលទើបផុតពីសង្គ្រាម ការកសាងឡើងវិញនូវការទុកចិត្តគ្នាគឺជាជំហានមួយដ៏លំបាកក្នុងដំណើរការនៃការផ្សះផ្សា ។ បីទសវត្សរ៍បន្ទាប់ពីរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ *"ការនាំយកសហគមន៍ដែលបែកបាក់មករួមរស់ជាមួយគ្នា"* គឺជាតម្រូវការចាំបាច់មួយនៅកម្ពុជា ។ តាមការស្ទាបស្ទង់មតិបង្ហាញ

ថា ប្រជាជនកម្ពុជាជាច្រើនចង់បានការផ្តោតការយកចិត្តទុកដាក់ទៅលើការស្តារឡើងវិញនូវការជឿទុកចិត្តគ្នា ដោយធ្វើដំណើរឆ្ពោះទៅកាន់ចំណុចមួយ នៅពេលដែលអតីតគូបដិបក្ខ *«អាចញញឹមនិងទុកចិត្តគ្នាម្តងទៀត»* ។ ដោយលាតត្រដាងនូវការពិតនិងបែងចែកភាពខុសគ្នារវាងការពិតនិងពាក្យចចាមអារ៉ាម តុលាការខ្មែរក្រហមអាចជួយកសាងការជឿទុកចិត្តគ្នាក្នុងចំណោមអ្នករស់នៅក្បែរខាងគ្នានៅតាមភូមិនិងសហគមន៍ ។

## ការផ្សះផ្សាចំពោះបុគ្គល

បន្ថែមពីលើទិដ្ឋភាពសង្គមនិងនយោបាយ ការផ្សះផ្សាជាទូទៅច្រើនជាបទពិសោធន៍ផ្ទាល់ខ្លួន ។ ការរំលោភទៅលើសិទ្ធិមនុស្សធ្ងន់ធ្ងរ បានបន្សល់ទុកស្លាកស្នាមផ្លូវចិត្តយ៉ាងច្រើនដល់ជនរងគ្រោះ ហើយប្រជាជនកម្ពុជាក៏ស្ថិតនៅក្នុងករណីនោះដែរ ។ ការសិក្សាមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការចិត្តសង្គមអន្តរវប្បធម៌ នៅក្នុងឆ្នាំ២០០៤និងឆ្នាំ២០០៥ បានរកឃើញថា មនុស្សម្នាក់ក្នុងចំណោមបីនាក់ដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យទទួលរងនូវជំងឺបាក់ស្បាត ។ អ្នកទាំងអស់នេះទទួលរងនូវរោគសញ្ញាជាច្រើនដូចជាគេងមិនលក់ ធ្លាក់ទឹកចិត្ត យល់សប្តិអាក្រក់ ឈឺក្បាល វិលមុខ ជំងឺពោះវៀន សន្លប់បាត់ស្មារតី និងឆាប់ខឹង ។ ជំងឺបាក់ស្បាតមានជាប់ពាក់ព័ន្ធទៅនឹងគ្រឿងញៀន ការញៀនគ្រឿងស្រវឹង ការធ្វើអត្តឃាត អំពើហិង្សាលើប្តីប្រពន្ធនិងកូន និងជំងឺសង្គមជាច្រើនផ្សេងទៀត ។ ក្នុងចំណោមប្រជាជន១២លាននាក់ ពាក់កណ្តាលជាអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ការសិក្សាបង្ហាញថា ប្រជាជនប្រហែលពីរលាននាក់មានជំងឺបាក់ស្បាត ហើយមានមនុស្សតិចតួចណាស់បានទទួលការព្យាបាល ។ ប្រជាជនរាប់លាននាក់ផ្សេងទៀតទទួលរងនូវជំងឺថប់បារម្ភ ។ ប្រការនេះបានជួយពន្យល់ឲ្យឃើញថា មានអត្រានៃការប្រព្រឹត្តបទឧក្រិដ្ឋនិងអាកប្បកិរិយាប្រឆាំងនឹងសង្គមយ៉ាងខ្ពស់នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ។

ជំងឺបាក់ស្បាតនិងជំងឺផ្លូវចិត្តនិងផ្លូវអារម្មណ៍ដទៃទៀត គឺគ្រាន់តែជាពាក្យស័ព្ទសម្រាប់ពណ៌នាជំងឺចិត្តសាស្ត្រដែលបុគ្គលទាំងឡាយទទួលរងពីការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ខ្លួន ។ សម្រាប់កម្រិតបុគ្គល *«ការផ្សះផ្សា»* អាចត្រូវបានមើលឃើញថាជាដំណើរការបន្តបន្ទាប់មួយនៃការព្យាបាល ដែលអនុញ្ញាតឲ្យបុគ្គលម្នាក់ចូលរួមសាជាថ្មីឡើងវិញនៅក្នុងសង្គមនិងលះបង់ចោលនូវទម្ងន់នៃការឈឺចាប់ដែលមានពីអតីតកាល ។ ការផ្សះផ្សារបៀបនេះអាចសម្រេចទៅបានដោយមធ្យោបាយជាច្រើន ។ ជំនឿនិងការប្រតិបត្តិសាសនា ការព្យាបាលតាមចិត្តសាស្ត្រ កិច្ចសន្ទនាជាមួយជនរងគ្រោះដូចគ្នាឬជាមួយជនដៃដល់និងពេលវេលា សុទ្ធតែអាចជួយបង្កឲ្យមានអារម្មណ៍សន្តិភាពក្នុងចិត្តយ៉ាងច្រើន ។ ដំណើរការតាមផ្លូវតុលាការអាចជួយពង្រឹងវិធីសាស្ត្រទាំងនេះ ដោយធ្វើការលាតត្រដាងនូវការពិត បង្កើតឡើងនូវការពិតមួយដែលអាចទទួលយកបានឲ្យជនដៃដល់ធ្វើការសុំទោសនិងដាក់ទណ្ឌកម្ម ។ បទពិសោធន៍នៃការផ្សះផ្សាចំពោះបុគ្គលគឺពិតជាផ្សារភ្ជាប់ទៅនឹងការព្យាបាលក្នុងកម្រិតសង្គម ។ នេះជាការដាក់បន្ទុកកាតព្វកិច្ចទៅលើក្រុមមេដឹកនាំសាសនា អាជ្ញាធរដែនដី ថ្នាក់ដឹកនាំសាលា មណ្ឌលសុខភាព និងរចនាសម្ព័ន្ធទ្រទ្រង់សហគមន៍ផ្សេងៗទៀត ដែលត្រូវចូលរួមជាមួយដំណើរការជុំវិញកិច្ចការតុលាការ ។ ការស្វែងរកយុត្តិធម៌ជាសាធារណៈក្នុងអង្គជំនុំជម្រះវិសាមញ្ញប្រហែលជានឹងបើកកកាយដំបៅចាស់ជាច្រើន ទោះបីជាដំណើរការនេះជួយព្យាបាលរបួសផ្លូវចិត្តទាំងនោះក៏ដោយ ។

## ការបង្កើតការផ្សះផ្សាតាមរយៈយុត្តិធម៌

នៅពេលកាត់ក្តីដោយជោគជ័យតែមួយមិនអាចធានាបាននូវការព្យាបាលជំងឺផ្លូវចិត្តរបស់បុគ្គលនិងសង្គមនោះ វាមានការពិបាកក្នុងការសម្រេចឲ្យបានការផ្សះផ្សាដោយមិនមានយុត្តិធម៌ ។ ដោយសារមួយផ្នែកធំនៃស្ថានភាពនយោបាយ យុត្តិធម៌បានក្លាយទៅជាសមាសភាពអវត្តមានមួយនៅក្នុងដំណើរការផ្សះផ្សានៅកម្ពុជារហូតមកទល់នឹងសព្វថ្ងៃនេះ ។ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត *«នយោបាយផ្សះផ្សាជាតិ»* ដោយផ្តល់ការលើកលែងទោសដល់អតីតកងទ័ពនិងមេដឹកនាំខ្មែរក្រហមទាំងឡាយណាដែលយល់ព្រមចុះចូលនិងគាំទ្ររដ្ឋាភិបាល ។ មេដឹកនាំនយោបាយនៅទីក្រុងភ្នំពេញ បានចាត់ទុកគោលនយោបាយនេះថាជាវិធីសាស្ត្រដ៏មានសារសំខាន់ក្នុងការដោះស្រាយបញ្ហាខ្មែរក្រហមនិងបោសសម្អាតក្រុមខ្មាំងទ័ពព្រៃ ។

ប្រជាជនកម្ពុជាភាគច្រើនបានយល់ស្របនឹងនយោបាយលើកលែងទោសនេះ ហើយនយោបាយនេះអាចជួយរំងាប់បានមួយផ្នែកនៃការទាមទារចង់បានយុត្តិធម៌ ។

ទោះជាយ៉ាងនេះក្តី នៅឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីនាំយកអតីតមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ នៅឆ្នាំ ១៩៩៩ បន្ទាប់ពីមានសម្ពាធពីក្នុងស្រុកនិងអន្តរជាតិនិងការចូលរួមរបស់មន្ត្រីនិងកម្មាភិបាលខ្មែរក្រហមសេសសល់មួយចំនួនទៅក្នុងកងយោធពលខេមរភូមិន្ទ រាជរដ្ឋាភិបាលបានប្រកាសថាការផ្សះផ្សាត្រូវបានសម្រេចដោយជោគជ័យនៅកម្ពុជា ហើយថាពេលវេលាក្នុងការស៊ើបអង្កេតលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមបានមកដល់ហើយ ។ ជំហរនយោបាយថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបង្ហាញពីការបែងចែកក្លែងក្លាយមួយរវាងការផ្សះផ្សានិងយុត្តិធម៌នោះ បាននាំទៅដល់ការអនុម័តច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ នៅឆ្នាំ ២០០៤ ។

ក្រុមអ្នករិះគន់រាជរដ្ឋាភិបាលកម្ពុជាជាច្រើនជឿជាក់ថា “*ការផ្សះផ្សា*” ដែលទទួលបានតាមរយៈនយោបាយលើកលែងទោសរបស់រាជរដ្ឋាភិបាលគ្រាន់តែជាការបំភ័ន្តភ្នែកប៉ុណ្ណោះ ។ ហេតុផលចម្បងពីរយ៉ាងត្រូវបានលើកឡើងដើម្បីគាំទ្រគំនិតនេះ ។ ទីមួយ ដំណើរការផ្សះផ្សាជាតិមិនត្រូវបានចូលរួមពីសំណាក់ប្រជាជននៅតាមមូលដ្ឋានឲ្យបានច្រើននោះទេ ។ ជាជាងពិចារណាអំពីទស្សនៈរបស់ប្រជាជនកម្ពុជា ការផ្សះផ្សានេះគឺគ្រាន់តែជាការដោះដូរមួយនៅក្នុងកម្រិតនយោបាយរវាងរាជរដ្ឋាភិបាលកម្ពុជានិងថ្នាក់ដឹកនាំខ្មែរក្រហមប៉ុណ្ណោះ ។ ជាលទ្ធផល ការលើកលែងទោសត្រូវបានមើលឃើញថាជាល្បិចនយោបាយច្រើនជាងការអត់ឱនទោសពីសំណាក់ប្រជាជនកម្ពុជា ។ ដូចអ្នកស្រាវជ្រាវជាន់ខ្ពស់ ស៊ូហ្សាណា លីនតុន បានលើកឡើងថាការផ្សះផ្សាត្រូវតែធ្វើឡើងនៅថ្នាក់មូលដ្ឋានដើម្បីឲ្យការផ្សះផ្សានោះអាចចាក់ឫសបានជ្រៅនៅក្នុងសង្គមមួយ ។ ដំណើរការផ្សះផ្សាដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មើលទៅផ្នែកខ្លះហាក់ដូចជាការដោះដូររវាងគូបដិបក្ខនយោបាយ ។ ទីពីរ កង្វះខាតការពន្យល់និងការសុំទោសពីសំណាក់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានបន្សល់ទុកនូវចម្ងល់ដែលគ្មានចម្លើយជាច្រើនអំពីរយៈកាលនៃរបបខ្មែរក្រហម ។ បញ្ហានេះធ្វើឲ្យប្រជាជនកម្ពុជាមានការពិបាកក្នុងការប្រឈមមុខនឹងអតីតកាលនិងអត់ឱនចំពោះអំពើអយុត្តិធម៌ក្នុងអតីតកាល ។ អវត្តមាននៃការបកស្រាយឬការសុំទោសឲ្យបានច្បាស់លាស់រួមផ្សំនិងបរាជ័យនៃការកាត់ទោសឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមនឹងបង្អាក់ដល់ដំណើរការផ្សះផ្សាជាតិ ។

សាលាក្តីខ្មែរក្រហមមានសក្តានុពលក្នុងការពន្លឿន ការផ្សះផ្សា សម្រាប់ហេតុផលជាច្រើន ។ ដោយផ្តោតជាសំខាន់ទៅលើការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនឹងបង្ហាញពីភាពខុសគ្នារវាងអ្នកច្បាប់និងអ្នកអនុវត្តច្បាប់ ។ ប្រការនេះអាចជួយសម្រាលភាពតានតឹងរវាងប្រជាជនកម្ពុជាសាមញ្ញ និងចូលរួមចំណែកក្នុងការនាំអតីតកម្មាភិបាលខ្មែរក្រហមមករួមរស់ក្នុងសង្គមកម្ពុជាវិញ ។ ជាងនេះទៅទៀត ជនរងគ្រោះអាចមានអារម្មណ៍ចង់សងសឹកនៅពេលគាត់មើលឃើញអតីតមេដឹកនាំខ្មែរក្រហមត្រូវនាំយកមកកាត់ទោសប្រឈមមុខចំពោះបទឧក្រិដ្ឋនិងទទួលការដាក់ទណ្ឌកម្ម ។ ជាមួយនឹងការសុំខមាទោសនិងការបកស្រាយពន្យល់ពីសំណាក់ចុងចោទខ្មែរក្រហម កត្តាទាំងនេះអាចជួយជនរងគ្រោះក្នុងការអត់ឱន ផ្សះផ្សា និងធ្វើដំណើរឆ្ពោះទៅមុខ ។

## ចំណុចពិសេសនៃការផ្សះផ្សានៅក្នុងបរិបទប្រទេសកម្ពុជា

បរិបទសង្គម នយោបាយ និងវប្បធម៌ ដែលនាំទៅរកយុត្តិធម៌ ក៏មានសារសំខាន់ណាស់ដែរ ។ ស្ថានភាពនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នហាក់ដូចជាមានទំនោរទៅរកការផ្សះផ្សា ។ ទីមួយ ប្រពៃណីសាសនារបស់ប្រទេសនេះ អាចយកមកអនុវត្តបាននៅក្នុងដំណើរការព្យាបាលរបួសផ្លូវចិត្ត ហើយមិនមានពាក់ព័ន្ធជាមួយនឹងអំពើហិង្សាឬការដាក់ទណ្ឌកម្មក្រៅផ្លូវច្បាប់ឡើយ ។ ពុទ្ធសាសនានិកាយហីនយានគឺជាសាសនាចម្បងនៅកម្ពុជា ដែលការប្រៀនប្រដៅជាបឋមសង្កត់ធ្ងន់ទៅលើការអត់ឱនទោស ។ ព្រះពុទ្ធសាសនាមានគោលការណ៍ប្រហាក់ប្រហែលទៅនឹងការកាត់ទោស

ផ្នែកព្រហ្មទណ្ឌដែរ ដូចដែលមេដឹកនាំសាសនាដ៏ល្បីល្បាញ មហាឃោសនន្ទ និងមេដឹកនាំដទៃទៀតបានលើកឡើង ។ ទោះជាយ៉ាងនេះក្តី គោលការណ៍របស់ព្រះពុទ្ធសាសនាចំពោះយុត្តិធម៌បានបញ្ជាក់ថា ការចងពៀរបញ្ចប់ដោយការមិនបន្តការឈឺចាប់ដល់អ្នកដទៃ ប៉ុន្តែសម្រេចបានតាមការរំងាប់អារម្មណ៍ ព្យាយាមអត់ឱនចំពោះរាល់អំពើអយុត្តិធម៌ពីអតីតកាលនិងរំសាយកំហឹងពៀរ ។ ការប្រារព្ធពិធីអបអរសាទរ "ទិវាចងកំហឹង" ជារៀងរាល់ឆ្នាំនៅកម្ពុជាដើម្បីរំឭកដល់ការរំលោភបំពានក្នុងរបបខ្មែរក្រហមចង្អុលបង្ហាញថា ដំណើរការផ្សះផ្សាមានលក្ខណៈចប់សព្វគ្រប់ ។ ទោះជាយ៉ាងនេះក្តី ដោយដាក់ឲ្យមានការទទួលខុសត្រូវជាបុគ្គល ការកាត់ក្តីផ្នែកព្រហ្មទណ្ឌអាចជួយឲ្យរំសាយកំហឹង កាត់បន្ថយនូវសារជាតិនៃអំពើហិង្សា និងជំរុញការផ្សះផ្សា ។ ទីពីរ ពេលវេលាកន្លងទៅតាំងពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យបានបង្ហាញកាន់តែច្បាស់ថា យន្តការតាមផ្លូវតុលាការអាចរួមចំណែកដល់ការផ្សះផ្សាជាតិបាន ។ តុលាការអន្តរជាតិ និងតុលាការចម្រុះដទៃទៀតត្រូវបានបង្កើតឡើងនៅពេលជម្លោះកំពុងតែបន្តឬទើបតែបញ្ចប់ ។ នៅក្នុងករណីជាច្រើន អតីតគូបដិបក្ខពីគ្រប់ភាគីទាំងអស់ចាត់ទុកសាលាក្តីថាជាឧបករណ៍នយោបាយមិនស្របច្បាប់មួយ និងមានការគោរពតិចតួចបំផុតចំពោះសាលក្រម ។ វាមិនមាន "ភាពខុសគ្នា" សំខាន់ណាមួយនោះទេក្នុងការអនុញ្ញាតឲ្យប្រជាជនដែលទទួលរងទុក្ខដោយសារសង្គ្រាមមើលឃើញតុលាការក្នុងន័យវិជ្ជមាន ហើយមានសង្ឃឹមតិចតួចណាស់ក្នុងការជំរុញឲ្យមានការផ្សះផ្សា ។ ផ្ទុយទៅវិញ ក្នុងរយៈពេល២៧ឆ្នាំចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម ប្រជាជនកម្ពុជាមិនមានជម្រើសអ្វីក្រៅពីការបន្តដំណើរជីវិតរបស់ខ្លួនទៅមុខនិងចាប់ផ្តើមបំភ្លេចរឿងរ៉ាវពីអតីតកាលនោះទេ ។ ជារួម តុលាការនេះនឹងជួយប្រជាជនកម្ពុជាឲ្យធ្វើដំណើរឆ្លងកាត់មេរៀនចុងក្រោយនៃដំណើរការព្យាបាលរបួសផ្លូវចិត្តដ៏លំបាកលំបិននេះ ។

ជាចុងក្រោយ អង្គការមួយចំនួនដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយឲ្យប្រជាជនកម្ពុជាជាច្រើនរៀបចំខ្លួនដើម្បីដោះស្រាយបញ្ហាពីអតីតកាលតាមរយៈគម្រោងដែលបង្ហាញពីការពិត ។ គម្រោងទាំងអស់នេះនឹងជួយឲ្យប្រជាជនទទួលបាននូវភាពចាស់ទុំដើម្បីប្រឈមមុខទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម និងប្រឈមមុខទៅនឹងដំណើរការកាត់សេចក្តីដែលនឹងមកដល់ខាងមុខ ។ ធ្វើដូច្នេះ វាបានបង្ហាញឲ្យឃើញថា ទាំងជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនស្វាគមន៍ចំពោះការបង្កើតសាលាក្តីនេះឡើង ។ ខណៈពេលដែលជនរងគ្រោះរង់ចាំមើលកងយុត្តិធម៌ចាប់ផ្តើមដំណើរការ អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបជាច្រើនសង្ឃឹមថាការកាត់សេចក្តីនេះនឹងជួយបែងចែកពួកគាត់ចេញពីមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ។

## សន្តិភាព សន្តិសុខ និងនីតិរដ្ឋ

បញ្ហាចុងក្រោយ នៅពេលចាត់វិធានការចំពោះការដាក់ឲ្យមានការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងឡាយ គឺថាតើការកាត់សេចក្តីនេះនឹងនាំទៅរកសន្តិភាព សន្តិសុខ និងនីតិរដ្ឋរឹងមាំមួយដែរឬយ៉ាងណា ។ ទាំងនេះសុទ្ធតែជាចំណុចសំខាន់ៗសម្រាប់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ក៏ដូចជាអភិវឌ្ឍជីវិតឲ្យបានប្រសើរជាងមុនសម្រាប់ប្រជាជនសាមញ្ញ ដែលនេះជាគោលដៅចុងក្រោយសម្រាប់ដំណើរការផ្សះផ្សាជាតិ ។

## សន្តិសុខនិងស្ថិរភាពនៅកម្ពុជា

ក្រុមអ្នកគាំទ្រសាលាក្តីខ្មែរក្រហមបានអះអាងថា បរាជ័យក្នុងការកាត់ទោសយ៉ាងហោចណាស់មន្ត្រីសំខាន់ៗមួយចំនួននៃរបបកម្ពុជាប្រជាធិបតេយ្យនឹងធ្វើឲ្យវប្បធម៌និទ្ទណ្ឌភាពនៅកម្ពុជាកាន់តែចាក់ឫសខ្លាំងឡើង ដែលជាចុងក្រោយអាចបណ្តាលឲ្យមានអស្ថិរភាពនិងអសន្តិសុខដល់ប្រជាជន ។ ជាងនេះទៅទៀត ក្រុមអ្នកគាំទ្រជឿជាក់ថា ដំណើរការកាត់ទោសរបស់តុលាការនឹងជួយពង្រឹងប្រព័ន្ធយុត្តិធម៌ឲ្យកាន់តែល្អនឹងបង្កើតការគោរពច្បាប់នៅកម្ពុជា ដែលរួមចំណែកក្នុងការថែរក្សាសន្តិភាពនិងស្ថិរភាពយូរអង្វែង ។ ទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអះអាងយ៉ាងដូច្នេះថា "សន្តិភាពទាមទារច្រើនជាងអវត្តមាននៃកងទ័ពនៅក្នុងជម្លោះដោយចំហ ។ សង្គមសន្តិភាពគឺជាសង្គមយុត្តិធម៌មួយ ហើយប្រជាជនកម្ពុជាមិនទាន់រកឃើញយុត្តិធម៌នៅឡើយទេ ។ សន្តិភាពនឹងមិនអាចកើតមានពិតប្រាកដនៅកម្ពុជាបានទេ លុះត្រាតែមានយុត្តិធម៌ពិតប្រាកដសម្រាប់

ឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម» ។

ផ្ទុយទៅវិញ ក្រុមអ្នករិះគន់សាលាក្តីបានអះអាងថា ការចុះចាញ់របស់ក្រុមខ្មាំងខ្មែរក្រហមតាមរយៈកម្មវិធីលើកលែងទោសរបស់រាជរដ្ឋាភិបាលបាននាំមកនូវការផ្សះផ្សានិងសន្តិភាពដល់កម្ពុជារួចទៅហើយ ។ អ្នកទាំងនេះអះអាងថា ការកាត់ទោសអំពើឧក្រិដ្ឋទាំងនេះអាចគំរាមកំហែងដល់សន្តិភាពនិងនាំឲ្យមានជម្លោះឡើងវិញ ។ នៅពេលថ្មីៗក្នុងខែកក្កដា ឆ្នាំ២០០៦ កន្លងទៅនេះ ព្រះមហាក្សត្រ នរោត្តម សីហមុនី បានព្រមានថា ការកាត់ក្តីនឹងអាចបង្កឲ្យមានដំបៅនយោបាយនិងសង្គមឡើងវិញ ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវគោលជំហរបែបនេះរហូតដល់ឆ្នាំ១៩៩៧ ដោយអះអាងថា កម្មវិធីលើកលែងទោសរបស់រដ្ឋាភិបាលគឺទទួលខុសត្រូវក្នុងការផ្តាច់ខ្លួនរបស់អតីតកម្មាភិបាលខ្មែរក្រហមនិងបានលើកឡើងថា ការកាត់ទោសនឹងអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សន្តិភាពដែលកើតចេញពីកម្មវិធីលើកលែងទោសនេះ ។ ឥស្សរជនសំខាន់ៗមួយចំនួន រួមទាំងបងប្រុសរបស់ព្រះមហាក្សត្រ ព្រះអង្គម្ចាស់ នរោត្តម យុវនាថ បានបន្តព្រមានចំពោះសក្តានុពលនៃអស្ថិរភាពក្នុងសង្គមដែលជាផលប៉ះពាល់នៃសាលាក្តីនេះ ។ ទោះជាយ៉ាងនេះក្តី គោលជំហររបស់រាជរដ្ឋាភិបាលបានផ្លាស់ប្តូរដែលបានអនុញ្ញាតឲ្យមានការកាត់ទោស យ៉ាងហោចណាស់អតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួនដែលរស់រានជីវិតមកដល់បច្ចុប្បន្ន ។

ការអះអាងដែលថាការកាត់ទោសនឹងបង្កឲ្យមានអំពើហិង្សាមិនគួរត្រូវបានបដិសេធចោលទេនៅក្នុងប្រទេសមួយដែលបានជួបប្រទះនូវភាពវឹកវរផ្នែកនយោបាយ នៅក្នុងទសវត្សរ៍ថ្មីៗនេះ ។ ទោះជាយ៉ាងនេះក្តី នៅទីបំផុតការអះអាងរបៀបនេះមិនត្រូវបានជឿជាក់ទេ ។ តុលាការចម្រុះត្រូវបានអនុវត្តនៅប្រទេសទីម័រខាងកើត សៀរ៉ាឡេអូន និងកូសូវ៉ូ ហើយដំណើរការទាំងនោះមិនបានធ្វើឲ្យលេចឡើងនូវភាពវឹកវរបន្ថែមណាមួយក្នុងចំណោមប្រជាជនសាមញ្ញនោះទេ ។ វាមានការពិបាកក្នុងការវិនិច្ឆ័យថាការកាត់ក្តីនឹងបង្កឲ្យមានផលប៉ះពាល់ដល់ការស្តារសន្តិភាពនិងស្ថិរភាពសង្គម ។ ទោះជាយ៉ាងនេះក្តី អ្នកវិភាគជាច្រើនជឿជាក់ថាការកាត់ក្តីនឹងមិនគំរាមកំហែងដល់សន្តិភាពដែលកើតមានរួច


ការប្រជុំស៊ុយទិតៀន

ហើយនោះទេ ។ តុលាការចម្រុះអាចបណ្តាលឲ្យមានការរិះគន់និងបាតុកម្មមួយចំនួន ប៉ុន្តែមិនបង្កឲ្យមានអំពើហិង្សាទេ ។ រឿងរ៉ាវដូចគ្នានេះបានកើតមានឡើងនៅសាលាក្តីអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉ាន់ដា ។ យោងតាមបទពិសោធន៍អន្តរជាតិពីអតីតកាលនិងពេលវេលាដែលកន្លងផុតទៅយូរមកហើយចាប់តាំងពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ វាហាក់ដូចជាមិនអាចកើតមានបានទេដែលថាការកាត់ក្តីនេះនឹងគំរាមកំហែងដល់សន្តិភាពនិងស្ថិរភាពក្នុងខ្ទីរបស់កម្ពុជានាពេលបច្ចុប្បន្ននេះ ។

**ការអភិវឌ្ឍនិងនីតិរដ្ឋ**

បន្ថែមពីលើបញ្ហាសីលធម៌នៃដំណើររបស់ «តុលាការកង់ហ្គូរូ» (តុលាការក្រៅប្រព័ន្ធច្បាប់) ប្រទេសដែលអនុញ្ញាតឲ្យនិទ្ទណ្ឌភាពកើតមានតទៅទៀតនិងបដិសេធសិទ្ធិរបស់ចុងចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងបង្កឲ្យមានផលប៉ះពាល់យ៉ាង



ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចនិងនយោបាយរបស់ខ្លួន ។ ដំណើរការតុលាការប្រកបដោយអយុត្តិធម៌ជាភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរារែកក្នុងការផ្តល់ជំនួយទៅឲ្យប្រទេសនោះ ហើយអាចនឹងបង្កឲ្យមានការបង្កបង្កើតក្រុមនយោបាយប្រឆាំងទៅនឹងរដ្ឋាភិបាលនៃប្រទេសនោះថែមទៀតផង ។ អ្នកជំនួញនិងវិនិយោគិនបរទេសក៏សម្លឹងមើលយ៉ាងយកចិត្តទុកដាក់ផងដែរទៅលើយុត្តិធម៌និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការរបស់ប្រទេសនោះ មុនការពិភាក្សាអំពីធនធានផ្នែកឯកជនដែលត្រូវការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ។ ហេតុដូច្នេះហើយ ការកសាងនីតិរដ្ឋមិនមែនមានសារសំខាន់ត្រឹមតែបញ្ហាសីលធម៌ប៉ុណ្ណោះទេ វាថែមទាំងជួយបង្កើនផលប្រយោជន៍សេដ្ឋកិច្ចនិងនយោបាយរបស់ប្រទេសនោះឲ្យកាន់តែទូលំទូលាយថែមទៀត ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការពិតទាំងនេះ ដោយបានចាត់ទុកកំណែទម្រង់ប្រព័ន្ធតុលាការនិងច្បាប់ជាសសរមួយនៃផែនការអភិវឌ្ឍជាយុទ្ធសាស្ត្ររបស់ជាតិសម្រាប់ឆ្នាំ២០០៦ដល់ឆ្នាំ២០១០ ។

**សេចក្តីសន្និដ្ឋាន ៖ សម្លឹងមើលទៅអនាគត**

ដើម្បីសម្រេចឲ្យបាននូវគោលដៅរបស់ខ្លួន តុលាការខ្មែរក្រហមគួរសិក្សាស្វែងយល់អំពីបទពិសោធន៍ពីតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការចម្រុះដទៃទៀត ។ បុគ្គលិកបម្រើការងារក្នុងតុលាការ រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិត្រូវធ្វើការប្រមើលមើលនិងរៀបចំរួចជាស្រេចដើម្បីទប់ទល់នឹងបញ្ហាបរាជ័យដែលអាចកើតមានឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ហើយក៏គួរតែព្យាយាមពង្រឹងចំណុចខ្លាំងរបស់តុលាការជាច្រើនដោយប្រើប្រាស់ដំណើរការនេះដើម្បីបង្កើតទំនាក់ទំនងល្អជាមួយសាធារណជន ។ នៅពេលជាមួយគ្នានេះដែរ ទាំងប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិគួរតែរក្សានូវការរំពឹងទុកពិតប្រាកដមួយអំពីអ្វីដែលតុលាការអាចធ្វើបាន ។ តុលាការនេះមិនមែនជាឱសថទិព្វសម្រាប់ព្យាបាលជំងឺគ្រប់បែបយ៉ាងដែលបង្កើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយក៏មិនអាចជាយន្តការចុងក្រោយនិងតែមួយគត់សម្រាប់ដោះស្រាយជាមួយឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ ការកាត់ក្តីផ្នែកព្រហ្មទណ្ឌគឺជាដំណើរការដ៏មានសារសំខាន់មួយ ប៉ុន្តែជាផ្នែកមួយដែលមានកម្រិតក្នុងការឆ្លើយតបទៅនឹងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ។

ជាការពិតណាស់ ដំណើរការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហមនឹងបន្សល់ទុកនូវចម្ងល់ជាច្រើនដែលត្រូវការឲ្យមានការស្រាវជ្រាវនិងពិភាក្សាបន្ថែមទៀត ។ យន្តការបន្ទាប់បន្សំដទៃទៀតសម្រាប់ដោះស្រាយជាមួយអំពើឃោរឃៅដ៏ធ្ងន់ធ្ងរនេះគួរតែត្រូវបានបង្កើតឡើងដើម្បីបំពេញបន្ថែមដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ។ យន្តការទាំងនេះរួមមានកម្មវិធីស្វែងរកការពិតនិងការផ្សះផ្សា ការអប់រំប្រជាជន និងការពិគ្រោះយោបល់ផ្នែកប៉ះទង្គិចផ្លូវចិត្ត ។ ការរួមបញ្ចូលគ្នានូវវិធីសាស្ត្រទាំងនេះនឹងផ្តល់នូវឱកាសដ៏ប្រសើរមួយក្នុងការសម្រេចឲ្យបាននូវដំណើរការនៃការទទួលខុសត្រូវ យុត្តិធម៌ និងការជួសជុលផ្នែកសង្គមដែលប្រជាជនកម្ពុជាចង់បានជាយូរមកហើយ ។ **ហែឡេន អ៊ុយណាក់**

# ការវិនិច្ឆ័យលើអំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈប្រភពដើមនៃមនោគមវិជ្ជាខ្មែរក្រហម

ការជជែកវែកញែកលើបញ្ហាតើនរណាបន្តឲ្យមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជាត្រូវចំណាយពេលវេលាអស់ជាច្រើនទសវត្សរ៍មកហើយ ។ ទោះបីជាខណៈពេលដែលប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់ប្រទេសកម្ពុជាទទួលរងនូវឥទ្ធិពលនិងអន្តរាគមន៍ពីសំណាក់បរទេសក៏ដោយ ក៏ភាពមិនច្បាស់លាស់នៅតែបន្តមានទាក់ទិននឹងអំពើព្រៃផ្សៃពីការបង្ខំមនុស្សឲ្យធ្វើការហួសប្រមាណដោយការបង្អត់អាហារ និងការឈានទៅដល់ការយកទៅសម្លាប់ដែលប្រជាជនកម្ពុជាទទួលរងក្នុងរបបនោះ ។

តាមរយៈការសិក្សាមនោគមវិជ្ជាខ្មែរក្រហម យើងអាចបង្កើនការយល់ដឹងពីការជំរុញផ្នែកទ្រឹស្តីពីក្រោយប្រតិបត្តិការរបស់ខ្មែរក្រហម និងការបកស្រាយពីអំពើដ៏ឃោរឃៅក្នុងគំនិតរបស់មេដឹកនាំរបបខ្មែរក្រហម ។ ប្រភពនៃមនោគមវិជ្ជាជួនកាលត្រូវបានមើលរំលង ។ អ្នកប្រវត្តិសាស្ត្រជាច្រើនផ្តោតការសិក្សាលើរយៈកាលខ្មែរក្រហមកំពុងក្តោបក្តាប់ប្រទេសពីអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ដោយសារព្រឹត្តិការណ៍ដ៏ឈឺចាប់ពីរបបកម្ពុជាប្រជាធិបតេយ្យទាក់ទាញចំណាប់អារម្មណ៍អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រនិងដូចគ្នានឹងមិត្តអ្នកអានដែរ ។ ប៉ុន្តែបើងាកត្រឡប់ទៅពិនិត្យមើលឲ្យវែងឆ្ងាយពីសកម្មភាពការងារនិងមនោគមវិជ្ជារបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ រួចសិក្សាពីការអភិវឌ្ឍនិងការសម្រេចគោលនយោបាយខ្មែរក្រហម ធ្វើឲ្យយើងអាចបង្កើនការយល់ដឹងកាន់តែស៊ីជម្រៅពីកត្តាជ្រៅជ្រែងដល់របបកម្ពុជាប្រជាធិបតេយ្យ ។ ឥទ្ធិពលផ្នែកមនោគមវិជ្ជាមកលើខ្មែរក្រហមមានឫសគល់ចេញពីប្រវត្តិសាស្ត្រទំនាក់ទំនងដ៏យូរលង់ជាមួយលទ្ធិកុម្មុយនីស្តឥណ្ឌូចិននិងអឺរ៉ុប ។

អ្នកប្រាជ្ញមួយចំនួនជឿជាក់ថា មនោគមវិជ្ជានៃបក្សកុម្មុយនីស្តកម្ពុជានិងបក្សប្រជាជនបដិវត្តន៍ខ្មែរមុននោះ ត្រូវបានបង្កើតឡើងដោយប្រទេសជាប់ខាងកើតខ្លួនគឺប្រទេសវៀតណាម ។ ខណៈពេលដែលជនកុម្មុយនីស្តនិយមវៀតណាមសម្តែងចំណាប់អារម្មណ៍កាន់តែខ្លាំងចំពោះការពង្រីកបណ្តាញរបស់ខ្លួនមកលើប្រទេសឡាវនិងកម្ពុជា ជនទាំងនោះចាប់ផ្តើមមើលឃើញថាបដិវត្តន៍ដែលខ្លួនកំពុងធ្វើជា "បដិវត្តន៍ប្រចាំនៅឥណ្ឌូចិនដែលជាផ្នែកមួយនៃចលនាសង្គមនិយមដ៏ធំមួយនៅអាស៊ី-អាគ្នេយ៍" ។ នេះមានន័យថា ទង្វើមនឹងការដាក់បន្ទាយទាហានការពារយ៉ាងមាំទាំប្រជាជនកម្ពុជាដែលគាំទ្របដិវត្តន៍នេះ ត្រូវបានបង្រៀនពីមនោគមវិជ្ជាកុម្មុយនីស្តវៀតណាម ។ ហេ្គាស្កា គត់សម្គាល់ឃើញថា "យុទ្ធសាស្ត្រនិងមនោគមវិជ្ជាត្រូវបានផ្សារភ្ជាប់ទៅនឹងលក្ខខណ្ឌឥណ្ឌូចិន" ។ ការបំពាក់បំប៉នបែបយុទ្ធសាស្ត្រនៅប្រទេសឡាវនិងកម្ពុជាកើតឡើងបានត្រឹមតែមួយភាគប៉ុណ្ណោះដោយសារប្រទេសថៃបិទព្រំដែនភាគខាងលិច ជាចំណុចដែលវៀតណាមជំរុញបណ្តាញថៃរបស់ខ្លួនចូលទៅភាគខាងកើតនៃប្រទេសឡាវនិងកម្ពុជា ។

នៅឆ្នាំ១៩៤៨ បក្សកុម្មុយនីស្តឥណ្ឌូចិនចាប់ផ្តើមបញ្ជូនកម្មាភិបាលវៀតណាមទៅបង្កើតបក្សបដិវត្តន៍នៅកម្ពុជា ។ ដោយចាប់ផ្តើមនៅឆ្នាំ១៩៥០ វៀតណាមបង្កើនការខំប្រឹងប្រែងក្នុងក្តីសង្ឃឹមថា នឹងអាចរក្សាស្ថិរភាពបដិវត្តន៍ឥណ្ឌូចិន ។ ផែនការរបស់វៀតណាមដំណើរការទៅមុខបានដោយសារមានកម្មាភិបាលវៀតណាមជាច្រើននាក់ចូលរួមកសាងរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងយោធានៅកម្ពុជា ។ ជនដែលត្រូវបានជ្រើសរើសជាមេដឹកនាំចលនាបដិវត្តន៍នៅកម្ពុជាគឺ សឺង ង៉ុកមិញ ជាជនកុម្មុយនីស្តជាតិកម្ពុជាដែលចេះភាសាវៀតណាមយ៉ាងស្ទាត់ជំនាញនិងបានទទួលការផ្សព្វផ្សាយមនោគមវិជ្ជាពីវៀតណាមយ៉ាងជ្រួតជ្រាបតាមរយៈកិច្ចការរបស់គាត់ឯរោងពុម្ពនៅក្រុងព្រៃនគរ ។

តើមនោគមវិជ្ជាខ្មែរក្រហមកកើតចេញពីការប្រឈមនឹងកុម្មុយនីសវៀតណាមត្រឹមកម្រិតណា? ទាក់ទិននឹងចំណុចនេះ អ្នកប្រវត្តិសាស្ត្រមានគំនិតប្រឆាំងគ្នា ដោយខ្លះថា មនោគមវិជ្ជាខ្មែរក្រហមបណ្តុះចេញពីមេដឹកនាំខ្មែរក្រហមខ្លួនឯង ដែលភាគ

ច្រើនទទួលការបំពាក់បំប៉នលទ្ធិកុម្មុយនីស្តមកពីប្រទេសបារាំងមិនមែនប្រទេសវៀតណាមឡើយ ។ អ្នកប្រវត្តិសាស្ត្រមួយចំនួនទៀតយល់ថា អ្នកបម្រើការភាគច្រើនរបស់បក្សបដិវត្តន៍ខ្មែរក្រហមសុទ្ធសឹងទទួលបានការហ្វឹកហ្វឺនលទ្ធិកុម្មុយនីស្តវៀតណាមដែលអាចជះឥទ្ធិពលដល់គំនិតមនោគមវិជ្ជារបស់អ្នកទាំងនោះ ។

គួរកត់សម្គាល់និងចាប់អារម្មណ៍ផងដែរថា សឺង ង៉ុកមិញ និងសមាជិកបក្សបួន-ដប់នាក់ទទួលការអប់រំនៅវិទ្យាស្ថានត្រឹងជិញនៅឯវៀតណាមខាងត្បូង ជាសាលាបង្រៀនមនោគមវិជ្ជាដល់កម្មាភិបាលនៃបក្សកុម្មុយនីស្តឥណ្ឌូចិន ។ ជាងនេះទៅទៀតមកដល់ឆ្នាំ១៩៥១ សេចក្តីសម្រេចជាផ្លូវការរបស់បដិវត្តន៍កម្ពុជាត្រូវឆ្លងកាត់វៀតណាមជាមុនសិន ។ នេះចង្អុលបង្ហាញឲ្យឃើញថា អ្នកផ្តាច់ការខ្មែរទទួលបទពិសោធន៍ពីលទ្ធិកុម្មុយនីស្តដំបូងតាមរយៈបណ្តាញបដិវត្តន៍អាស៊ី-អាគ្នេយ៍ដឹកនាំដោយវៀតណាមដែលបណ្តាញនេះត្រូវបានបញ្ជូនឆ្លងកាត់ប្រទេសថៃទៅ វ៉ាច់ហ្កាមិនមែនតាមរយៈ ទីក្រុង មូស្គូ ឬប៉ារីសឡើយ ។

ដើម្បីសរុបជារួមនូវករណីរបបកុម្មុយនីស្តកម្ពុជាទទួលឥទ្ធិពលពីវៀតណាម យើងគួរលើកឡើងអំពីទំនាក់ទំនងរវាង សឺង ង៉ុកមិញ និងរដ្ឋាភិបាលដឹកនាំដោយ ម៉ៅ សេងទុង ។ ទំនាក់ទំនងចិនចាំបាច់ត្រូវសម្គាល់ទុកព្រោះទំនាក់ទំនងនេះជាឥទ្ធិពលចម្បងចំពោះមនោគមវិជ្ជាកុម្មុយនីស្តឥណ្ឌូចិន ។ យ៉ាងណាមិញ គឺវៀតណាមដែលណែនាំផ្សព្វផ្សាយមនោគមវិជ្ជាទាំងនេះដល់កម្ពុជា ។ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៥៣ វិទ្យុប៉េកាំងបានចេញផ្សាយបទវិចារណកថាមួយដើម្បីជាការរំឭកខួបបីឆ្នាំ នៃការទទួលបានឯករាជ្យនៅកម្ពុជា ។ វិចារណកថានោះសរសេរថា “ក្រោមការដឹកនាំរបស់ សឺង ង៉ុកមិញ ការតស៊ូដំណើរការឈានទៅមុខយ៉ាងអស្ចារ្យ” ។ ខណៈដែលទំនាក់ទំនងដុះដាលចេញពីការបើកឲ្យមានបណ្តាញបដិវត្តន៍ឆ្នាំ១៩៥០ នៅភាគខាងកើតប្រទេសឡាវនិងកម្ពុជា ដោយមានការចូលរួមពីសំណាក់បក្សកុម្មុយនីស្តឥណ្ឌូចិននោះ ប៉ុល ពត និងសមាជិកនានាដែលចាត់ថ្នាក់ក្នុង “ក្រុមទី២”នៃមេដឹកនាំផ្តាច់ការនៅកម្ពុជាប្រាកដជាមិនមែនជាជនទីមួយដែលចូលមកទំនាក់ទំនងជាមួយ ម៉ៅ សេទុង និងមនោគមវិជ្ជារបស់ ម៉ៅ ទេ ។

“ក្រុមទី២”អាចចាត់ទុកថាជាជនផ្តាច់ការខ្មែរដែលបានទទួលការអប់រំនៅទីក្រុងប៉ារីស ។ ដូច្នេះអ្នកប្រាជ្ញមួយចំនួនអះអាងថាសមាជិកក្រុមទី២បានទទួលយកការបកស្រាយរបស់បារាំងលើមនោគមវិជ្ជាម៉ាក្សស៊ីស ។ សមាជិកក្រុមនេះរួមមានជនពីរនាក់កាន់អំណាចកំពូលនៅក្នុងរបបខ្មែរក្រហម គឺ ប៉ុល ពត និង ខៀវ សំផន ដែលសុទ្ធសឹងបានចូលរៀននៅសកលវិទ្យាល័យឯទីក្រុងប៉ារីស ។ ទំនាក់ទំនងរវាងអាហារូបករណ៍បារាំងនិងជនជាតិខ្មែរ



កម្មាភិបាលខ្មែរក្រហមសម្ពោធទំនប់

ផ្តាច់ការកើតមានឡើងតាំងពីជំនាន់ព្រះបាទ ស៊ីសុវត្ថិ ធ្វើទស្សនកិច្ចនៅប្រទេសបារាំងកាលពីឆ្នាំ១៩០៦ ជាឆ្នាំដែលទំនាក់ទំនងរវាងខ្មែរនិងបារាំងស្ងប់ស្ងាត់បន្ទាប់ពីទំនាស់ផ្សេងៗត្រូវបានដោះស្រាយ ។ ព្រះបាទ ស៊ីសុវត្ថិ បានអនុញ្ញាតជាផ្លូវការឲ្យបើកវិទ្យាល័យមួយនៅទីក្រុងភ្នំពេញហៅថា "វិទ្យាល័យស៊ីសុវត្ថិ" ដែលសិស្សានុសិស្សត្រូវទទួលការអប់រំតាមប្រព័ន្ធសិក្សាបារាំង ។ ខ្មែរផ្តាច់ការដែលទទួលការសិក្សានៅទីក្រុងប៉ារីស សុទ្ធតែបានបញ្ចប់ការសិក្សាពីវិទ្យាល័យនេះ រួមមាន ខៀវ សំផន និង អៀង សារី ។ ខៀវ សំផន សរសេរនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្លួនអំពីសេដ្ឋកិច្ចកម្ពុជានៅសាប៊ុនណេ ។ សំណេរនេះត្រូវបានអ្នកប្រាជ្ញជាច្រើនចាត់ទុកថាជាឯកសារល្អឥតខ្ចោះបង្ហាញពីមូលវិវដ្តនិយមរបស់ខ្មែរ ។

អ្នកប្រវត្តិសាស្ត្រជាច្រើនជឿថា មនោគមវិជ្ជាដែលប្រតិបត្តិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានប្រភពពីប្រទេសបារាំង ។ មនោគមវិជ្ជាត្រូវបានដាក់ចេញឲ្យអនុវត្តដោយថ្នាក់លើដែលសុទ្ធសឹងតែបានទទួលអាហារូបករណ៍ទៅរៀននៅទីក្រុងប៉ារីស ។ ខ្មែរផ្តាច់ការទទួលការហ្វឹកហ្វឺននៅប៉ារីសទទួលបានផលប្រយោជន៍ពេលដែលមេដឹកនាំកុម្មុយនីស្តសម្ងាត់ ទូ សាមុត ដែលការស្លាប់របស់គាត់ក្នុងឆ្នាំ១៩៦២ស្ថិតក្នុងភាពអាថ៌កំបាំង ដែលទំនងជាស្នាដៃកងកម្លាំងប៉ូលិសរបស់សម្តេចសីហនុ ។ ប៉ុល ពត ឈ្មោះដើមហៅ សាឡុត ស, អៀង សារី និង ស៊ុន សេន សុទ្ធតែធ្លាប់រៀននៅទីក្រុងប៉ារីស ។ អ្នកទាំងបីជាអ្នកត្រួតពិនិត្យការរំសាយបក្សប្រជាជនបដិវត្តន៍ខ្មែរ ដោយយោងតាមខ្សែបន្ទាត់នយោបាយថ្មីមួយក្នុងការរៀបចំបក្សនេះឡើងវិញ ។ យោងតាម ប៊ែន ឃៀរនិន "មេដឹកនាំដើមចាស់របស់បក្សដែលមួយភាគធំមានប្រភពមកពីទីជនបទ វត្តអារាម និងគាំទ្រភាគីវៀតណាមបន្តិចដែរត្រូវបានជំនួសដោយមេដឹកនាំវ័យក្មេងទីក្រុងមានប្រវត្តិសិក្សាមកពីបារាំង ហើយប្រឆាំងនឹងក្រុមជ្រុលនិយមវៀតណាម ។

ជាក់ស្តែងបក្សប្រជាជនបដិវត្តន៍ជួបប្រទះបម្រែបម្រួលភ្លាមៗជាច្រើនសានៅទសវត្សរ៍ឆ្នាំ១៩៥០ ដែលអាចធ្វើឲ្យជះឥទ្ធិពលដល់គោលជំហរមនោគមវិជ្ជារបស់ខ្លួន ។ នៅឆ្នាំ១៦៥៤ វៀតណាមដកខ្លួនចេញពីប្រទេសកម្ពុជា ហើយកម្មាភិបាលប្រមាណ១ពាន់នាក់ (ប្រមាណជាងពាក់កណ្តាលនៃជនកុម្មុយនីស្តកម្ពុជា) និរទេសខ្លួនឯងទៅទីក្រុងហាណូយ ។ កម្មាភិបាលដែលបន្តរស់នៅកម្ពុជាពេលនោះរស់នៅដោយលួចលាក់ ហើយក្នុងរយៈពេល៥ឆ្នាំបន្ទាប់ កម្មាភិបាលបក្សជាច្រើនត្រូវបានរកឃើញ ហើយចាប់យកទៅសម្លាប់ដោយទាហានលន់នល់ ។ ព្រឹត្តិការណ៍នេះធ្វើឲ្យបក្សរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរ ។ "យោងតាម ប៉ុល ពត ចន្លោះឆ្នាំ១៩៥៥-១៩៥៩ សមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរប្រមាណ៩០ភាគរយត្រូវចាប់ខ្លួននិងសម្លាប់ចោល" ។ ក្នុងលទ្ធផលក្រោយវិសុទ្ធកម្មបក្សត្រូវបានរំសាយ ចុះខ្សោយអានុភាពនិងអន់ថយការដឹកនាំ ។ ពេលមេដឹកនាំបក្ស ទូ សាមុត ត្រូវបានធ្វើឃាតក្នុងឆ្នាំ១៩៦២ ប៉ុល ពត និងជនកុម្មុយនីស្តដែលទទួលបានការបំពាក់បំប៉ននៅទីក្រុងប៉ារីស (ដូចជា អៀង សារី និង ស៊ុន សេន) មានលទ្ធភាពបំពាក់បំប៉ននយោបាយថ្មីនិងមនោគមវិជ្ជាថ្មីដល់សមាជិកបក្សរបស់ខ្លួន ។

សរុបជារួម យើងនៅមិនទាន់ច្បាស់ថាមានមនោគមវិជ្ជាប៉ុន្មានដែលលូតលាស់មានប្រភពពីវៀតណាមដែលប្រើប្រាស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការស្រាវជ្រាវស៊ីជម្រៅលើមនោគមវិជ្ជាដែលខ្មែរក្រហមយកមកប្រើប្រាស់ និងការសិក្សាប្រៀបធៀបជាមួយមនោគមវិជ្ជានៅវៀតណាមខាងជើង(និងប៉ារីស) អាចចង្អុលបង្ហាញពីបញ្ហានេះបាន ។ យ៉ាងណាមិញ ចម្ងល់តិចតួចនៅតែមានទាក់ទិននឹងបញ្ហាវៀតណាមមានឥទ្ធិពលចម្បងមកលើលទ្ធិកុម្មុយនីស្តកម្ពុជា ដោយសារការដាក់ទ័ពនិងផ្នែកមនោគមវិជ្ជានៅកម្ពុជាធ្វើឡើងស៊ីសង្វាក់គ្នា ។ សំណួរមួយថាតើនៅសល់មនោគមវិជ្ជាអ្វីខ្លះដែលត្រូវបានប្រើប្រាស់ក្នុងសកម្មភាពបដិវត្តន៍នៃបក្សនៅចុងទសវត្សរ៍ឆ្នាំ១៩៥០ ។ យើងចាំបាច់ត្រូវសួរខ្លួនឯងថាតើខ្មែរផ្តាច់ការមកពីប៉ារីសទទួលឥទ្ធិពលពីជំហរមនោគមវិជ្ជាពីបក្សកម្រិតណា ។ ពេលដែលសំណួរនេះមានចម្លើយ យើងនឹងទទួលបានកត្តាចង្អុលបង្ហាញផ្សេងទៀតដែលបង្កប់ខាងក្រោយ "អំពើដ៏ឃោរឃៅ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសកម្មភាពក្រោមរូបរាងជាការប្រល័យពូជសាសន៍ ។ ប្រហែលជា "អំពើដ៏ឃោរឃៅ" នេះអាចត្រូវបានពន្យល់ល្អបំផុតដោយអ្នកនិពន្ធរឿងល្ខោន រ៉ើសព្យែរ ដែលជាវីរបុរសរបស់ ប៉ុល ពត ។ រ៉ើសព្យែរ និយាយថា "គុណធម៌ជាហិង្សា ហិង្សាជាគុណធម៌" ។ **អ៊ីសាក់ ថាច័រ**

# ការដោះស្រាយបញ្ហាវិបត្តិផ្លូវចិត្តដោយរបបខ្មែរក្រហម

របបខ្មែរក្រហមពីឆ្នាំ១៩៧៥ - ៧៩ បានបន្សល់ទុកនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរ ។ របបនោះបានឆក់យកជីវិតប្រជាជនកម្ពុជាអស់ប្រមាណ១,៧លាននាក់ (ជិតមួយភាគបួននៃចំនួនប្រជាជនសរុប) និងបានធ្វើឲ្យសេដ្ឋកិច្ច របនាសម្ព័ន្ធ និងស្ថាប័នរដ្ឋផ្សេងៗស្ថិតនៅក្នុងភាពខ្ទេចខ្ទាំ ។ ប៉ុន្តែ ការលំបាក ទុក្ខវេទនានិងអារម្មណ៍ភ័យខ្លាចដែលប្រជាជនបានឆ្លងកាត់នៅក្នុងរបបនោះមិនទាន់បញ្ចប់នៅឡើយ សូម្បីតែមកដល់សព្វថ្ងៃនេះក៏ដោយ ។ ភាគច្រើនជនរងគ្រោះដែលរស់ជីវិតពីរបបនោះមានជំងឺផ្លូវចិត្តតិចឬច្រើនទាក់ទងនឹងបទពិសោធន៍នៃអំពើហិង្សាដែលអ្នកទាំងនោះបានឆ្លងកាត់ ។

បើយោងតាមការសិក្សាមួយរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ដែលធ្វើការងារទាក់ទងនឹងបញ្ហាផ្លូវចិត្ត ប្រជាជនកម្ពុជាប្រមាណ៨១ភាគរយធ្លាប់ឆ្លងកាត់អំពើហិង្សា២៨,៤ភាគរយមានជំងឺបាក់ស្បាត ១១,៥ភាគរយមានបញ្ហាអារម្មណ៍វិបល្លាស និង៤០ភាគរយមានបញ្ហាថប់អារម្មណ៍ ។ របបខ្មែរក្រហមបានកន្លងផុតទៅស្ទើរតែ៣០ឆ្នាំទៅហើយ ប៉ុន្តែជនរងគ្រោះទាំងនេះទទួលបាននូវការយកចិត្តទុកដាក់តិចតួចឬគ្មានទាល់តែសោះពីរដ្ឋដែលមានលទ្ធភាពផ្តល់ការព្យាបាលតិចតួច ។ ក្រសួងការបរទេសអាមេរិកផ្នែកសេវាកម្មសុខាភិបាល និងមនុស្សសាស្ត្រក៏បានសិក្សាអំពីបញ្ហាប៉ះពាល់ផ្លូវចិត្តទៅលើជនរងគ្រោះនៃរបបខ្មែរក្រហមដែលរស់នៅក្នុងសហរដ្ឋអាមេរិកដែរ ។ ការសិក្សានោះបានរកឃើញថា ៦២ភាគរយមានជំងឺបាក់ស្បាតនិង៥១ភាគរយ មានជំងឺព្រួយចិត្ត (នៅក្នុងចំណោមប្រជាជនអាមេរិកដែល៣,៦ភាគរយមានជំងឺបាក់ស្បាត និង៩,៥ភាគរយមានជំងឺធ្លាក់ទឹកចិត្ត) ។ តួលេខនេះមិនមែនជាការចម្លែកទេ ប្រសិនបើយើងមើលអំពីការសន្និដ្ឋានរបស់ការសិក្សានេះ ដែលក្នុងនោះ៩៩ភាគរយនៃជនភៀសខ្លួនកម្ពុជាទាំងនេះស្ទើរតែដាច់ពោះស្លាប់ ៩៦ភាគរយធ្វើការហួសកម្លាំង៩០ភាគរយមានសមាជិកគ្រួសារបាត់បង់ជីវិត និង៥៤ភាគរយទទួលរងទារុណកម្ម ។

តួរលេខគួរឲ្យព្រួយបារម្ភនេះបានអំពាវនាវសុំឲ្យមានវិធានការដើម្បីជួយដល់ជនរងគ្រោះដែលចង់មានជីវិតរស់នៅជាធម្មតា ប៉ុន្តែមិនអាចមានជីវិតធម្មតាបែបនោះបានអស់រយៈពេលជិត៣០ឆ្នាំមកហើយ ។ រ៉ូនី យឹមស៊ុត ដែលក្រុមគ្រួសារទាំងមូលរបស់គាត់ត្រូវបានយកទៅសម្លាប់ បានរំឭកអំពីស្ថានភាពរបស់គាត់ថា:

ខ្ញុំនៅតែមានយល់សប្តិ៍អាក្រក់អំពីការសម្លាប់នៅរាត្រីងងឹតក្នុងខែធ្នូដដែល ។ វាមិនព្រមរសាត់ចេញពីអារម្មណ៍របស់ខ្ញុំទាល់តែសោះ ហើយខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាចដោយគ្រាន់តែគិតអំពីព្រឹត្តិការណ៍នោះ ។ ពេលវេលាមិនអាចជួយព្យាបាលវិបត្តិផ្លូវចិត្តនេះបានទេ យ៉ាងហោចណាស់មិនអាចទៅរួចសម្រាប់ខ្ញុំ ។

ការបង្កើតសាលាជំនុំជម្រះក្តីខ្មែរក្រហម និងការផ្តោតការយកចិត្តទុកដាក់ថ្មីៗនេះដែលប្រព័ន្ធផ្សព្វផ្សាយបានផ្តោតទៅលើបញ្ហាសុខភាពផ្លូវចិត្តបានជួយឲ្យប្រជាជនកម្ពុជាចាប់ផ្តើមពិភាក្សាអំពីបញ្ហាទាំងនេះ ។ ប៉ុន្តែតុលាការខ្មែរក្រហមទំនងជាធ្វើឲ្យមនុស្សជាច្រើនរំឭកឡើងវិញនូវបញ្ហាផ្លូវចិត្តនេះ ហើយការណ៍នេះទំនងជាបង្កជាគំនាបសង្កត់បន្ថែមដល់សង្គមកម្ពុជាបច្ចុប្បន្ន ។

## សាលាជំនុំជម្រះក្តីខ្មែរក្រហមនិងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ

មេដឹកនាំរបបខ្មែរក្រហមបានទទួលនូវនិទ្ទណ្ឌភាពអស់រយៈពេលជិត៣០ឆ្នាំហើយ ខណៈពេលដែលជនរងគ្រោះអន្ទះសាចង់បានយុត្តិធម៌ ។ ទន្ទឹមនឹងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃយុត្តិធម៌នឹងមកដល់ក្នុងពេលឆាប់ៗនេះ ។ សាលាជំនុំជម្រះក្តីនេះទំនងជាមានឥទ្ធិពលយ៉ាងខ្លាំងមកលើប្រទេសកម្ពុជាទាំងវិជ្ជមាននិងអវិជ្ជមាន ។ ខាងផ្នែកវិជ្ជមាន សាលាជំនុំជម្រះក្តីនេះទំនងជាអាចជួយកែប្រែមុខមាត់កម្ពុជាឲ្យទៅជាប្រទេសនីតិរដ្ឋនិងចាកផុតពីឈ្មោះជាប្រទេសដែលខ្ទេចខ្ទាំដោយសារសង្គ្រាម ។ អត្ថបទផ្សេងៗដែលចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយអាចទាក់ទាញចំណាប់អារម្មណ៍ភ្ញៀវទេសចរណ៍មកកាន់ប្រទេសកម្ពុជា ។ សាលាជំនុំជម្រះក្តីនេះក៏ផ្តល់ឳកាសដល់អ្នកច្បាប់នៅក្នុង

ប្រទេសដើម្បីទទួលបានបទពិសោធន៍ផ្នែកច្បាប់ពីសហការីបរទេសរបស់ខ្លួនពីសាលាជំនុំជម្រះក្តីនេះ ហើយនេះអាចជាការចាប់ផ្តើមនូវកំណែទម្រង់ផ្នែកច្បាប់នៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺថា សាលាជំនុំជម្រះក្តីដែលទទួលបាននូវការគាំទ្រយ៉ាងទូលំទូលាយត្រូវបានរំពឹងថានឹងនាំមកនូវការផ្សះផ្សាជាតិនៅក្នុងចំណោមប្រជាជនកម្ពុជាប្រសិនបើអ្នកទាំងនោះទទួលបាននូវយុត្តិធម៌ត្រឹមត្រូវ ។

ផលវិជ្ជមានទាំងនេះអាចកើតឡើងពិតប្រាកដតែក្នុងករណីដែលសាលាជំនុំជម្រះក្តីនេះទទួលបានជោគជ័យប៉ុណ្ណោះ ប៉ុន្តែក្តីសង្ឃឹមអំពីជោគជ័យទាំងនេះគឺនៅមិនទាន់ច្បាស់នៅឡើយ ។ មេដឹកនាំធំៗរបស់របបខ្មែរក្រហមចំនួន៣រូប (ប៉ុល ពត, កែ ពក និងតា ម៉ុក) បានបាត់បង់ជីវិតរួចហើយ ។ មេដឹកនាំខ្មែរក្រហមតែមួយរូបប៉ុណ្ណោះដែលនៅក្នុងមន្ទីរឃុំឃាំងបច្ចុប្បន្ននេះ ។ មេដឹកនាំខ្មែរក្រហមផ្សេងទៀតមានវ័យចំណាស់ៗ (ក្នុងវ័យ៧០ ឬ៨០ឆ្នាំ) ហើយអ្នកទាំងនេះភាគច្រើនមានជំងឺទៀតផង ។ វាមិនច្បាស់នៅឡើយ ថាតើមេដឹកនាំខ្មែរក្រហមដែលនឹងត្រូវចោទប្រកាន់ដោយសាលាជំនុំជម្រះក្តីខ្មែរក្រហមអាចមានជីវិតរហូតដល់ការជំនុំជម្រះត្រូវបញ្ចប់ជាស្ថាពរឬទេ ។ មកទល់ពេលនេះ ភាពចម្រូងចម្រាស់លើបញ្ហានីតិវិធីភាគច្រើនត្រូវបានដោះស្រាយរួចរាល់ហើយ ។

បើទោះបីជាមានផលជាវិជ្ជមានទាំងនេះក៏ដោយ ក៏គេរំពឹងទុកថា ការជំនុំជម្រះនេះនឹងធ្វើឲ្យស្នាមរបួសចាស់រើឡើងវិញ និងបន្តជាការទឹងសម្បានៅក្នុងចំណោមជនរងគ្រោះនៅពេលដែលរំឭកឡើងវិញនូវបទពិសោធន៍ក្នុងរបបខ្មែរក្រហម ។ ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការក្រៅរដ្ឋាភិបាលបានដើរតួនាទីជាអ្នកជំរុញឲ្យប្រជាជនពិភាក្សាអំពីបទពិសោធន៍របស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយការពិភាក្សានេះបានជួយអ្នកខ្លះឲ្យចាប់ផ្តើមជាសះស្បើយវិញ ។ លោកវេជ្ជបណ្ឌិត កា ស៊ុនបូណាត ដែលជានាយកផ្នែកសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា បាននិយាយថា «អ្នកជំងឺខ្លះបានមើលឃើញសាលាជំនុំជម្រះក្តីខ្មែរក្រហមថា ជាវិធីសម្រាប់ព្យាបាលជំងឺផ្លូវចិត្តតែម្តង ។ ការបង្ហាញនូវកំហុសអាចជួយឲ្យអ្នកទាំងនោះចាប់ផ្តើមជីវិតរបស់ខ្លួនសាជាថ្មី» ។ ប៉ុន្តែការណ៍នេះប្រហែលជាមិនអាចទៅរួចទេចំពោះអ្នកដែលនឹងផ្តល់សក្ខីភាពនៅក្នុងសវនាការសាលាជំនុំជម្រះក្តី បើទោះបីជាអ្នកទាំងនោះជាសាក្សីរបស់ព្រះរាជអាជ្ញាឬមេធាវីចុងចោទក្តី ។ ភាគច្រើននៃអ្នកដែលធ្លាប់ឆ្លងកាត់អំពើហិង្សាធ្ងន់ធ្ងរនៅក្នុងរបបនោះនៅតែមិនចង់រំឭកពីអតីតកាល ជាពិសេសជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ ។ គាំង គីម ដែលជាជនរងគ្រោះនៃអំពើរំលោភផ្លូវភេទក្នុងរបបខ្មែរក្រហមមិនដែលបង្ហើបរឿងរ៉ាវរបស់គាត់ប្រាប់កូនចៅរបស់គាត់ ឬអនុញ្ញាតឲ្យកូនចៅរបស់គាត់បានមើលភាពយន្តឯកសារអំពីគាត់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផលិតអំពីគាត់ឡើយ ។

## សាក្សីនិងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ

នៅពេលដែលមនុស្សរៀបរាប់អំពីទុក្ខសោក វាអាចជួយឲ្យអ្នកនោះសះស្បើយអំពីរបួសផ្លូវចិត្ត ប៉ុន្តែសកម្មភាពនេះអាចបង្កជាគ្រោះថ្នាក់ដល់សាក្សីសំខាន់ៗនៅក្នុងសវនាការ ។ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិនានាបានបង្កើតជាវិធានការផ្សេងៗដើម្បីជួយកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តនេះ ។ ជាក់ស្តែងសាលាជំនុំជម្រះក្តីខ្មែរក្រហមបានបង្កើតឲ្យមានអង្គភាពជនរងគ្រោះស្រដៀងគ្នាទៅនឹងអង្គភាពជនរងគ្រោះនៅក្នុងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិនៅប្រទេសយូហ្គោស្លាវី នៅរ៉្វាន់ដា និងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិដើម្បីជួយការពារសាក្សី ។ វិធាន៣៣នៃវិធានផ្ទៃក្នុងរបស់សាលាជំនុំជម្រះក្តីខ្មែរក្រហមបានចែងអំពីការការពារសាក្សីមិនឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ។ វិធាន៣៤បានចែងថា ចៅក្រមស៊ើបអង្កេត ឬតាមរយៈភាគីណាមួយ ឬមេធាវីអាចស្នើសុំឲ្យចាត់វិធានការដើម្បីការពារអាយុជីវិត និងសុខភាពរបស់ជនរងគ្រោះ សាក្សី និងក្រុមគ្រួសាររបស់ជនរងគ្រោះ ។ វិធាននេះបានចែងបន្តអំពីវិធានការបែបនោះដូចជាលាក់អត្តសញ្ញាណរបស់សាក្សីដែលរួមមានការប្រើឈ្មោះមិនពិត លាក់បាំងអាសយដ្ឋាន ប្រើឧបករណ៍ផ្លាស់ប្តូរសំឡេង ឬរូបរាងរបស់សាក្សី សវនាការជាសម្ងាត់ និងដាក់ទណ្ឌកម្មចំពោះអ្នកបង្ហើបអត្តសញ្ញាណ ឬអាសយដ្ឋានរបស់សាក្សី ។ ដើម្បីការពារសុវត្ថិភាពរបស់សាក្សី សាលាជំនុំជម្រះក្តីអាចទុកសាក្សីឬជនរងគ្រោះឲ្យនៅក្នុងទីកន្លែងសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជាឬក្រៅប្រទេស ។

សុវត្ថិភាពរបស់សាក្សីត្រូវតែយកចិត្តទុកដាក់បំផុតដោយសារតែអ្នកទាំងនេះត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងដរាបណាអ្នកទាំងនោះត្រូវបានកំណត់ថាជាសាក្សីរបស់សាលាជំនុំជម្រះក្តី ។ ជាក់ស្តែង សាក្សីសំខាន់ពីររូបនិងក្រុមគ្រួសាររបស់អ្នកទាំងពីរនៅឯសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិនៅប្រទេសយូហ្គោស្លាវីត្រូវបានធ្វើឃាតនៅក្នុងអំឡុងពេលស៊ើបអង្កេតជនជាប់ចោទមួយរូប ។ ស្រដៀងគ្នានេះដែរ ការសម្លាប់សាក្សីរបស់តុលាការកាឆាឆារបស់ប្រទេសរ៉្វាន់ដាបានកើនឡើងយ៉ាងខ្លាំង ។ ក្រៅពីសុវត្ថិភាព អាយុជីវិតសាក្សីត្រូវប្រឈមមុខនឹងការភ័យខ្លាចថែមទៀតៈ សាក្សីតម្រូវឲ្យស្បថ ហើយប្រសិនបើមិនព្រមស្បថ សាក្សីអាចត្រូវប្រឈមមុខនឹងបទចោទប្រកាន់ថា កុហកតុលាការ ឬពីបទរំខានដល់សវនាការ ។

ទោះបីជាវិធាន៣៨នៃវិធានផ្ទៃក្នុងរបស់សាលាជំនុំជម្រះក្តីខ្មែរក្រហមបានចែងការពារអាយុជីវិត និងសុខភាពរបស់សាក្សីនិងក្រុមគ្រួសារសាក្សីក៏ដោយ ក៏មិនអាចការពារសាក្សីពីការប៉ះពាល់ផ្នែកស្មារតីឡើយ ។ សាក្សីនឹងត្រូវប្រឈមមុខនឹងការសួរដេញដោលយ៉ាងធ្ងន់ធ្ងរនៅពេលសវនាការដែលទំនងជាធ្វើឲ្យគាត់រន្ធត់ជាខ្លាំង ។

តាមរយៈការសិក្សាពីអំពើសម្លាប់រង្គាលនៅក្នុងសង្គ្រាមលោកលើកទី២ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិនិងសម្រាប់ប្រទេសរ៉្វាន់ដាបានបង្ហាញថា ការចងចាំរបស់សាក្សីចំពោះព្រឹត្តិការណ៍ទុក្ខសោកបានល្អជាងព្រឹត្តិការណ៍ «ធម្មតា» ។ ប៉ុន្តែសាក្សីនៅក្នុងករណីទាំងនេះគឺបានផ្តល់សក្ខីភាពរយៈពេលពីរ-បីឆ្នាំបន្ទាប់ពីព្រឹត្តិការណ៍នោះកើតឡើង ។ ប៉ុន្តែខុសគ្នាទៅនឹងសាក្សីដែលនឹងត្រូវផ្តល់សក្ខីភាពនៅក្នុងសាលាជំនុំជម្រះក្តីខ្មែរក្រហម ព្រោះរឿងរ៉ាវបានកន្លងផុតទៅស្ទើរតែ៣០ឆ្នាំទៅហើយ ។ ជាងនេះទៅទៀត ការចងចាំរបស់សាក្សីដែលបានឃើញព្រឹត្តិការណ៍ដូចគ្នាអាចផ្លាស់ប្តូរ បន្ទាប់ពីអ្នកទាំងនេះបាននិយាយជាមួយគ្នា ឬទទួលបានព័ត៌មានថ្មីតាមប្រព័ន្ធផ្សព្វផ្សាយ ។ ការណ៍នេះអាចធ្វើឲ្យមានការសង្ស័យចំពោះសុក្រឹតភាពនៃការចងចាំរបស់សាក្សី ។ តើសាក្សីទាំងនេះនឹងមានប្រតិកម្មយ៉ាងដូចម្តេច ប្រសិនបើព្រះរាជអាជ្ញា ឬមេធាវីចុងចោទសាកសួរអំពីការចងចាំរបស់គាត់? ការផ្តល់សក្ខីភាពភាគច្រើនផ្តល់នូវបទពិសោធន៍អវិជ្ជមានដល់អ្នកដែលជាសាក្សី ។ សាក្សីម្នាក់របស់សាលាជំនុំជម្រះក្តីសម្រាប់ប្រទេសយូហ្គោស្លាវីបាននិយាយថាៈ

ខ្ញុំមានភាពអាម៉ាស់យ៉ាងខ្លាំង ។ ពេលមេធាវីចុងចោទបានសួរសំណួរនោះមកខ្ញុំ ខ្ញុំបានងាកទៅរកព្រះរាជអាជ្ញាឲ្យជួយ ។ ប៉ុន្តែគាត់គិតតែសម្លឹងមើលក្រដាសនៅលើតុរបស់គាត់ ។ ខ្ញុំមានការភិតភ័យយ៉ាងខ្លាំង ។ បេះដូងរបស់ខ្ញុំចាប់ផ្តើមលោតខុសសង្វាក់ រកកលចង់បាត់បង់ស្មារតី... ទេ ខ្ញុំនឹងមិនធ្វើជាសាក្សីទៀតទេ ។

វាទំនងណាស់ថា យ៉ាងហោចណាស់សាក្សីខ្លះនៅក្នុងសាលាជំនុំជម្រះក្តីខ្មែរក្រហមនឹងទទួលបានបទពិសោធន៍ស្រដៀងគ្នា ឬពិបាកជាងអ្វីដែលបានរៀបរាប់ខាងលើ បើពិនិត្យមើលអំពីសុក្រឹតភាពនៃការចងចាំរបស់គាត់ដែលមានចំណាស់៣០ឆ្នាំនេះ ។ ដូច្នេះជាការចាំបាច់ណាស់ដែលសាក្សីត្រូវការជូនដំណឹងជាមុនអំពីអ្វីដែលគេរំពឹងថានឹងកើតឡើងនៅក្នុងសវនាការ និងទទួលបាននូវការថែទាំផ្នែកសុខភាពផ្លូវចិត្តទាំងមុន អំឡុងពេលនិងក្រោយពេលជំនុំជម្រះ ។

## ភាពជឿជាក់របស់សាក្សីដែលមានជំងឺបាក់ស្បាត

ដោយសារតែចំនួនប្រជាជនកម្ពុជាច្រើនដែលមានជំងឺបាក់ស្បាតដែលបន្សល់ទុកពីរបបខ្មែរក្រហម វាទំនងណាស់ថាភាគច្រើននៃសាក្សីនៅចំពោះមុខសាលាជំនុំជម្រះក្តីខ្មែរក្រហមនឹងមានជំងឺបែបនេះដែរ ។ គ្រោះថ្នាក់ទីមួយគឺថាសាក្សីនឹងចោទសួរសំណួរលំបាកៗនៅពេលសួរដេញដោល ។ ជាពិសេសមេធាវីចុងចោទដែលព្យាយាមកាត់បន្ថយភាពយកជាសាក្សីបាននឹងទំនងជាលើកឡើងថា សក្ខីភាពដែលផ្តល់ឲ្យដោយសាក្សីដែលមានជំងឺបាក់ស្បាត មិនអាចជឿជាក់បាន ឬយកជាការបានទេ ។

ប៉ុន្តែការសិក្សាខ្លះបានរកឃើញថា ការធុញថប់ក្នុងអារម្មណ៍ខ្លាំងមិនមែនកាត់បន្ថយភាពចងចាំរបស់ខួរក្បាលនោះទេៈ បើទោះបីជាមនុស្សដែលធុញថប់បំផុតមិនអាចចងចាំព្រឹត្តិការណ៍ណាមួយបានពិស្តារក៏ដោយ ក៏អ្នកនោះអាចចងចាំចំណុចសំខាន់ៗនៃព្រឹត្តការណ៍នោះបានដែរ ។ ការរកឃើញនេះត្រូវបានគាំទ្រដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីដែលបានថ្លែងថា «សូម្បីតែមនុស្សម្នាក់ដែលមានជំងឺបាក់ស្បាតក៏ដោយ ក៏មិនមែនមានន័យថា ជននោះមិនអាចផ្តល់ភ័ស្តុតាង

*ដែលអាចយកជាការបាននោះទេ ។ គ្មានមូលហេតុណាមួយដែលថាមនុស្សដែលមានជំងឺបាក់ស្បាតមិនអាចធ្វើជាសាក្សីដែលអាចយកជាការបាននោះឡើយ» ។*

## ដំណោះស្រាយជំងឺផ្លូវចិត្តនៅកម្ពុជា

កាលពីដើមទសវត្សរ៍ឆ្នាំ១៩៧០ ប្រទេសកម្ពុជាមានវេជ្ជបណ្ឌិតចំនួន៤៥០នាក់ដែលក្នុងចំណោមនោះ មានតែ៤៣នាក់ប៉ុណ្ណោះដែលនៅរស់ជីវិតពីរបបខ្មែរក្រហម ។ ភាគច្រើននៃអ្នកចេះដឹងត្រូវបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមឬចាកចេញពីប្រទេស ។

ជាងនេះទៅទៀត រចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជាស្ទើរតែត្រូវបំផ្លិចបំផ្លាញទាំងស្រុងៈ «ប្រទេសកម្ពុជាបានធ្លាក់ទៅដល់ស្ថានភាពមួយដែលគ្មានទីផ្សារ គ្មានអគ្គិសនី គ្មានទឹកស្អាត គ្មានប្រព័ន្ធលូ និងគ្មានការចាយលុយ» ។ ការកសាងប្រទេសដោយជំនួយបន្តិចបន្តួចពីប្រទេសវៀតណាម និងសហភាពសូវៀតគឺជាការងារដ៏លំបាកដូចដែលអ្នកកាសែតវៀតណាមម្នាក់បានសរសេរថាៈ

*នៅពេលដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាឡើងកាន់អំណាចដំបូង សូម្បីតែអ្នកសង្កេតការណ៍ដែលមានសុទិដ្ឋិនិយមបំផុតក៏មិនដឹងថា តើរបបថ្មីនឹងធ្វើឲ្យប្រជាជនមានជីវភាពធម្មតាវិញដោយរបៀបណានៅចំពោះមុខភាពខ្ទេចខ្ទាំនៃសង្គមទាំងមូលដែលរួមមានទាំងការខូចខាតសហគមន៍ និងគ្រួសារទាំងអស់... ទឹកដីអង្គរគឺត្រូវខ្ទេចខ្ទាំ ប្រជាជនមានភាពវង្វេងវង្វាន់ និងឆ្ងល់ថាតើអនាគតបែបណាដែលនៅរង់ចាំពួកគាត់ ។*

ផ្នែកសុខាភិបាលក៏មានការលើកលែងដែរ ខ្មែរក្រហមបានធ្វើឲ្យខ្ទេចខ្ទាំអស់នូវសេវាកម្មផ្នែកសុខភាពនេះ ។ ក៏ដូចជាក្រសួងផ្សេងៗទៀតដែរ ក្រសួងសុខាភិបាលខ្វះខាតគ្រប់បែបយ៉ាងសូម្បីតែសម្ភារៈការិយាល័យបន្តិចបន្តួច ។

## ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលជាតិបច្ចុប្បន្ន

ទោះបីជារបបខ្មែរក្រហមបានរលត់ផុតទៅអស់រយៈពេល២៨ឆ្នាំក៏ដោយ ផ្នែកសុខាភិបាលនៅប្រទេសកម្ពុជានៅតែស្ថិតក្នុងភាពអន់ថយ បើប្រៀបធៀបទៅនឹងតំបន់ប៉ាស៊ីហ្វិកភាគខាងលិច ។ ប្រជាជនភាគច្រើនមិនទទួលបាននូវសេវាសុខភាពពីស្ថាប័នរដ្ឋទេ ហើយបើយោងតាមរបាយការណ៍របស់រដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨បានបង្ហាញថា នៅតាមមណ្ឌលសុខភាពសាធារណៈខ្វះនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានបញ្ហាខ្វះខាតហិរញ្ញវត្ថុនិងធនធានមនុស្ស ។ ទោះបីជាសេវាទាំងនេះមានឈ្មោះមិនយកប្រាក់ ប៉ុន្តែមណ្ឌលសុខភាពសាធារណៈទាំងនោះនៅតែបន្តយកប្រាក់ឈ្នួលក្រៅផ្លូវការ ហើយគុណភាពនៃសេវាកម្មនោះជាទូទៅនៅតែមានកម្រិតទាប ។ ប្រជាជនភាគច្រើនបានបាត់បង់ជំនឿចិត្តទៅលើមណ្ឌលសុខភាពសាធារណៈហើយបែរទៅរកការព្យាបាលដោយខ្លួនឯងនិងទៅតាមកន្លែងផ្តល់សេវាកម្មសុខភាពឯកជនវិញ ។ ទោះបីរបាយការណ៍នេះនិងរបាយការណ៍ដទៃទៀតបានពិសោធន៍ឲ្យយើងឃើញពីបញ្ហាសុខភាពដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏សុខភាពផ្លូវចិត្តនៅតែមិនត្រូវបានរាប់បញ្ចូលដែរ ។

មានតែនៅក្នុងឆ្នាំ១៩៩២ប៉ុណ្ណោះដែលក្រសួងសុខាភិបាលបានបង្កើតអនុគណៈកម្មាធិការផ្នែកសុខភាពផ្លូវចិត្ត ហើយចាប់ផ្តើមពង្រឹងខាងយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាជំងឺផ្លូវចិត្ត ។ សព្វថ្ងៃប្រទេសកម្ពុជាមានមន្ទីរពេទ្យផ្លូវចិត្តតែមួយគត់ដែលបានកសាងឡើងនៅក្នុងឆ្នាំ១៩៣៥ ហើយនៅខែមករា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវគម្រោងអភិវឌ្ឍន៍ជាតិជាយុទ្ធសាស្ត្រអាចនឹងចំណាយថវិកាអស់៣,៥ពាន់លានដុល្លារសហរដ្ឋអាមេរិកទៅលើវិស័យនីមួយៗក្នុងអំឡុងពេល៥ឆ្នាំខាងមុខ ។ ផ្នែកដែលត្រូវចំណាយថវិកាច្រើនបំផុតគឺវិស័យសុខាភិបាល (៦០០លានដុល្លារអាមេរិក) វិស័យអប់រំ (៥៥០លានដុល្លារអាមេរិក) និងវិស័យគមនាគមន៍៥៥០លានដុល្លារអាមេរិក) ។ ស្របពេលជាមួយថវិកាប្រចាំឆ្នាំលើវិស័យសុខាភិបាលចំណាយអស់១២០លានដុល្លារអាមេរិក ប៉ុន្តែគេនៅមិនទាន់ដឹងថា ថវិកាចំនួនប៉ុន្មានដែលនឹងត្រូវប្រើប្រាស់សម្រាប់បញ្ហាសុខភាពផ្លូវចិត្តនេះ និងថាតើជនរងគ្រោះទាំងឡាយដែលមានបញ្ហាផ្លូវចិត្តនិងភាពស្មុគស្មាញផ្សេងៗទៀត ទទួលបានផលប្រយោជន៍ប៉ុន្មានពីថវិកាទាំងនេះ ។

បច្ចុប្បន្នបើយោងតាមរបាយការណ៍របស់អង្គការចិត្តសង្គមអន្តរវប្បធម៌បានបង្ហាញឲ្យឃើញថា ប្រទេសកម្ពុជាមានវេជ្ជបណ្ឌិតផ្នែកចិត្តសាស្ត្រចំនួន២៦រូប និងអ្នកទទួលបានការហ្វឹកហាត់ផ្នែកសុខភាពផ្លូវចិត្តនេះរយៈពេល១២សប្តាហ៍ចំនួន១០០នាក់ទៀត ។ អង្គការជាតិនិងអន្តរជាតិដែលបានយកចិត្តទុកដាក់និងដោះស្រាយ

បញ្ហាផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជាមានចំនួន៩អង្គការដែលមិនអាចនឹងគ្រប់គ្រាន់សម្រាប់ប្រជាជនកម្ពុជាជាង១៤លាននាក់ដែលកំពុងជួបបញ្ហានេះទេ ។

ការប្រឹងប្រែងរបស់អង្គការក្រៅរដ្ឋាភិបាលៈ ជីវភាពប្រចាំថ្ងៃគឺជាអាទិភាពចម្បងសម្រាប់ប្រជាជនដែលបានរួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយ៣៥ភាគរយនៃប្រជាជនកម្ពុជាដែលរកប្រាក់ចំណូលបានតិចជាងមួយដុល្លារអាមេរិកក្នុងមួយថ្ងៃភាគតិចណាស់នៅក្នុងចំណោមប្រជាជនទាំងនេះដែលអាចមានលទ្ធភាពធ្វើដំណើរមករកសេវាព្យាបាលជំងឺផ្លូវចិត្ត ។ ជាងនេះទៅទៀត ដោយសារការយល់ដឹងមានកម្រិតនិងទទួលបានព័ត៌មានមិនគ្រប់គ្រាន់នេះបានធ្វើឲ្យប្រជាជនជាច្រើនមិនបានយល់ដឹងថាសុបិនអាក្រក់ដែលតែងតែរំខានដំណេករបស់គាត់គឺជារោគសញ្ញានៃជំងឺម្យ៉ាង ។

ដូច្នេះប្រជាជនបានព្យាយាមស្វែងរកជំនួយដោយព្យាបាលតាមវិធីបុរាណ ទទួលទានថ្នាំបុរាណ ឬតាមរយៈហោរាទស្សន៍ទាយដើម្បីដោះស្រាយនូវការឈឺចាប់ផ្លូវចិត្តទាំងនេះ ។ អង្គការក្រៅរដ្ឋាភិបាលបានផ្តល់កិច្ចសង្គ្រោះដល់កន្លែងមួយចំនួន ក៏ប៉ុន្តែជំនួយនេះនៅមានកម្រិតដោយយោងទៅលើផ្នែកហិរញ្ញវត្ថុនិងកង្វះខាតអ្នកជំនាញឯកទេសខាងផ្នែកផ្លូវចិត្តនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការចិត្តសង្គមអន្តរវប្បធម៌គឺជាវិទ្យាស្ថានធំពីរដែលបានគាំទ្រនិងផ្តល់នូវសេវាសុខភាពផ្លូវចិត្តដល់ជនរងគ្រោះដែលបានរួចជីវិតពីរបបខ្មែរក្រហម ។ រយៈពេលពីរឆ្នាំនៃគម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្មរបស់អង្គការទាំងពីរបានប្រឹងប្រែងជួយជនរងគ្រោះដែលមានជំងឺផ្លូវចិត្តនិងពីរបួសចាស់ដែលបានឆ្លងកាត់នូវរបបដ៏ឃោឃៅរបស់ខ្មែរក្រហម ។ តាមរយៈការធ្វើសម្ភាសន៍បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំណត់រកអ្នកដែលមានជំងឺបាក់ស្បាត ហើយអង្គការចិត្តសង្គមអន្តរវប្បធម៌បានផ្តល់ការព្យាបាលនិងប្រឹក្សា ។ ក្រុមបុគ្គលិករបស់អង្គការទាំងពីរបានផ្តល់នូវវិធីព្យាបាលធម្មតាដល់អ្នកដែលមានជំងឺផ្លូវចិត្ត ដែលក្នុងនេះមានវិធីបន្ធូរសាច់ដុំ លំហាត់ដកដង្ហើម ការឃុំគ្រងកំហឹងក្នុងខ្លួន ដំណើររំជួលចិត្តនូវការចងចាំនៃរបួសចាស់និងវិធីបំបាត់ការឈឺចាប់តាមរបៀបពុទ្ធសាសនា ។

ក្នុងអំឡុងគម្រោងការនេះ ប្រជាជនចំនួន៣០២នាក់ដែលមកពីខេត្តចំនួន៣ត្រូវបានសម្ភាសក្នុងចំណោមនោះមានប្រជាជនចំនួន៩៥រូបរកឃើញថាមានជំងឺបាក់ស្បាត ។ វិធីព្យាបាលនោះរាប់បញ្ចូលទាំងការផ្តល់ការប្រឹក្សាជាបុគ្គលដល់អ្នកដែលមានរោគសញ្ញាជំងឺផ្លូវចិត្តធ្ងន់ធ្ងរ វិធីព្យាបាលជាក្រុមនិងការថែទាំសុខភាពផ្លូវចិត្ត ។ ក្នុងចំណោម៩៥នាក់ដែលបានរកឃើញថាមានជំងឺបាក់ស្បាតមានតែ៦០នាក់ប៉ុណ្ណោះដែលអាចទទួលការព្យាបាលដោយសារតែចំនួនបុគ្គលិករបស់អង្គការចិត្តសង្គមអន្តរវប្បធម៌មានមិនគ្រប់គ្រាន់ (ការធ្វើដំណើរទៅតាមខេត្តនីមួយៗដើម្បីផ្តល់ប្រឹក្សាជាបញ្ហាធំ) ។ ទាំងនេះគឺបានឆ្លុះបញ្ចាំងអំពីប្រទេសកម្ពុជាដែលមានកង្វះធនធានមនុស្សនៅក្នុងមុខជំនាញសុខភាពផ្លូវចិត្ត ទោះបីជាមានជំនួយខាងហិរញ្ញវត្ថុឬការផ្តោតចំណាប់អារម្មណ៍ទៅលើជនរងគ្រោះបន្ថែមទៀតក៏ដោយ ក៏កង្វះខាតអ្នកឯកទេសជំនាញនេះអាចធ្វើឲ្យការប្រឹងប្រែងដោះស្រាយបញ្ហានេះនឹងជួបបញ្ហាលំបាកដែរ ។

**អនុសាសន៍ៈ** ក្រៅពីការសិក្សារបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ គ្មានមជ្ឈដ្ឋានណាដែលបានបង្ហាញនូវស្ថិតិស្តីអំពីបញ្ហាសុខភាពផ្លូវចិត្តនៅកម្ពុជាទេ ។ ការមិនយកចិត្តទុកដាក់ទៅលើបញ្ហានេះគឺទាមទារឲ្យមានការសិក្សាដ៏ហ្មត់ចត់មួយដើម្បីពង្រឹងយុទ្ធសាស្ត្រផ្នែកសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា ។ សូមថ្លែងអំណរគុណដល់ការបង្កើតឡើងនូវសាលាជំនុំជម្រះក្តីនេះដែលបានធ្វើឲ្យមជ្ឈដ្ឋានទាំងឡាយកាន់តែចាប់ផ្តើមចាប់អារម្មណ៍ទៅលើបញ្ហាសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ ។

អ្នកសង្គមវិជ្ជាខាងវិជ្ជាពេទ្យកម្ពុជាបានមានប្រសាសន៍ថាបញ្ហាសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជាបានក្លាយទៅជារោគរាតត្បាតមួយ ហើយប្រទេសកម្ពុជាត្រូវការវិធីព្យាបាលរោគនេះ ។ ប្រសិនបើគម្រោងផ្នែកសុខភាពផ្លូវចិត្តរបស់រដ្ឋអាចដំណើរការបាន នោះពិតជាអាចជាផលប្រយោជន៍ដ៏ល្អដល់ប្រជាជនដែលមានជំងឺបាក់ស្បាត ។ ទោះយ៉ាងណាក៏ដោយ គម្រោងការនេះមិនអាចចាប់សន្ធិឡើងក្នុងពេលឆាប់ៗនេះបានទេ បើពិនិត្យមើលអំពីកង្វះខាតផ្នែកហិរញ្ញវត្ថុនិងអ្នកឯកទេសផ្នែកចិត្តសាស្ត្រ ។ នេះមានន័យថា ប្រទេសកម្ពុជាត្រូវការជំនួយពីប្រទេសដទៃទៀត

(ទាំងផ្នែកហិរញ្ញវត្ថុ អ្នកជំនាញឯកទេសនិងការហ្វឹកហ្វឺន) ដើម្បីធ្វើឲ្យគម្រោងសុខភាពផ្លូវចិត្តរបស់រដ្ឋចេញជារូបរាងឡើងពិតប្រាកដ ។

ការបង្កើនតួលេខនិងគុណភាពគ្លីនិកសុខភាពផ្លូវចិត្តឲ្យមានគ្រប់តំបន់នៅក្នុងប្រទេសគឺជារឿងដ៏សំខាន់មួយ ។ ផែនការនេះអាចនឹងកើតឡើងដោយសារតែកាលពីពេលថ្មីៗនេះយើងបានរកឃើញនូវស្រទាប់រ៉ែប្រេងនិងឧស្ម័នធម្មជាតិដែលមានទីតាំងនៅក្នុងសមុទ្រប្រទេសកម្ពុជា ។ ការធ្វើអាជីវកម្មទៅលើធនធានធម្មជាតិនេះអាចបង្កើនប្រាក់ចំណូលរហូតដល់៦ពាន់លានដុល្លារអាមេរិកនៅឆ្នាំ២០១០ ហើយប្រសិនបើមានការគ្រប់គ្រងត្រឹមត្រូវនោះចំណូលថវិកាទាំងនេះអាចនឹងឲ្យប្រទេសកម្ពុជារួចចាកផុតពីភាពក្រីក្រ ។ ជាងនេះទៅទៀត មន្ត្រីរដ្ឋាភិបាលម្នាក់បានថ្លែងប្រាប់ដល់វិទ្យុអាស៊ីសេរីថា ប្រាក់ចំណូលដែលគាត់រកបានពីធនធានធម្មជាតិទាំងនេះនឹងត្រូវទុកមួយចំណែកសម្រាប់ពង្រីងវិស័យអប់រំនិងវិស័យសុខាភិបាលឲ្យកាន់តែប្រសើរឡើង ហើយគេក៏រំពឹងទុកថាបញ្ហាសុខភាពផ្លូវចិត្តនឹងអាចទាញយកផលប្រយោជន៍ពីប្រាក់ចំណូលនេះ ។ លើសពីនេះទៅទៀត វិស័យសេដ្ឋកិច្ចប្រទេសកម្ពុជាបានឡើងដល់១០,៥ភាគរយនៅឆ្នាំ២០០៦ ដែលរំពឹងថាសេដ្ឋកិច្ចជាតិនឹងកើនឡើង៩ភាគរយនៅក្នុងរយៈពេល២ឆ្នាំខាងមុខជាបន្តបន្ទាប់ ហើយនៅពេលនោះផ្នែកសុខភាពផ្លូវចិត្តនឹងអាចទទួលផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចជាតិនេះ ។ ក្នុងពេលជាមួយគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត កំពុងតែស្វែងរកនូវដំណោះស្រាយបន្ថែមទៀតខាងចិត្តសាស្ត្រដើម្បីទ្រទ្រង់និងផ្តល់សេវាឲ្យប្រជាជនដែលមានជំងឺបាក់ស្បាតនេះ ។ ម្យ៉ាងវិញទៀត យើងអាចបង្រៀនប្រជាជននៅតាមថ្នាក់មូលដ្ឋានដើម្បីឲ្យពួកគាត់អាចនឹងជួយកំណត់រកអ្នកដែលមានបញ្ហាជំងឺបាក់ស្បាត ហើយអាចបញ្ជូនអ្នកជំងឺទាំងនោះមកទទួលការព្យាបាលពីការផ្តល់សេវាកម្មខាងសុខភាពផ្លូវចិត្ត ។ យើងក៏អាចបង្កើននូវសមត្ថភាពរបស់ពុទ្ធសាសនិកជនដូចជាព្រះសង្ឃ ដូនជី គ្រូខ្មែរបុរាណ ឬជាគ្រហស្ថនៃអ្នកកាន់ពុទ្ធសាសនាដែលមានជំនាញដើម្បីផ្តល់ការព្យាបាលដល់ជនទីទ័លក្រដែលត្រូវការការគាំទ្រដល់សុខភាពផ្លូវចិត្ត ។

ការផ្តល់ព័ត៌មានបន្ថែមគឺជារឿងសំខាន់ ។ ជនរងគ្រោះម្នាក់ដែលមានជំងឺបាក់ស្បាតបាននិយាយថា «ពេលដែលខ្ញុំកំពុងធ្វើស្រែដូនការវិញ្ញាណរបស់ខ្ញុំមិននៅជាប់នឹងខ្លួនខ្ញុំទេ វាបានរសាត់ចេញទៅទីណាក៏មិនដឹង ហើយខ្ញុំតែងតែនឹកឃើញពីរឿងអតីតកាលទាំងនោះជានិច្ច ។ ពេលខ្លះខ្ញុំមិនត្រូវអ្នកដទៃដែកគ្នាទេ សូម្បីតែអ្នកដែលនៅជិតខ្ញុំក៏ដោយ ហើយពេលខ្លះពួកគេស្រែកហៅខ្ញុំខ្លាំងៗ ធ្វើឲ្យខ្ញុំភ្ញាក់និងញ័រពេញខ្លួន» ។ អ្នកជំងឺបាក់ស្បាតម្នាក់ទៀតបានបន្ត «ខ្ញុំបានក្លាយទៅជាមនុស្សដែលឆាប់ខឹងនិងគ្មានហេតុផល ហើយជាញឹកញយខ្ញុំតែងតែបញ្ចេញកំហឹងទៅលើកូនចៅរបស់ខ្ញុំនៅពេលដែលវាគ្រាន់តែបើកទ្វារក្នុងពេលដែលខ្ញុំកំពុងតែសម្រាកនៅក្នុងផ្ទះប៉ុណ្ណោះ» ។ អ្នកជំងឺទាំងនេះមិនបានយល់ច្បាស់ទេថា រាល់ការរំខានទាំងនោះសុទ្ធសឹងតែជាជំងឺម្យ៉ាងដែលអាចព្យាបាលបាន ដោយហេតុផលនេះហើយការផ្សព្វផ្សាយគួរតែធ្វើឲ្យបានច្រើនទាក់ទងនឹងរោគសញ្ញានៃជំងឺបាក់ស្បាតនេះថាតើត្រូវថែរក្សាដោយវិធីណា វិធីព្យាបាលដោយខ្លួនឯង ឬវិធីផ្សេងៗទៀតដើម្បីដោះស្រាយ ឬធ្វើឲ្យរោគសញ្ញានៃរបួសចាស់និងការខ្វល់ខ្វាយទាំងនោះមានអាការៈអន់ថយជាងមុន ។ ការផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍និងវិទ្យុគឺជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្សព្វផ្សាយអំពីបញ្ហាជំងឺផ្លូវចិត្តនេះ ។ **ជី ធេរិទ្ធិ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា

ថ្ងៃនេះ

សហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មានអង្គហេតុដែលអាចផ្សំបានជាឧក្រិដ្ឋកម្ម ហើយនឹងស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើឧក្រិដ្ឋកម្មនិងជនសង្ស័យទាំងនោះ ។

តាមច្បាប់ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរគឺជាឯកសារសម្ងាត់ ។ ទោះយ៉ាងដូច្នេះក្តី ដោយមានការទទួលស្គាល់លក្ខណៈវិសាមញ្ញនៃតុលាការនេះ និងតម្រូវក្នុងការផ្តល់ព័ត៌មានដល់សាធារណជនអំពីវិវឌ្ឍនភាពនៃដំណើរការនីតិវិធីវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុញ្ញាតឲ្យសហព្រះរាជាអាជ្ញាធ្វើការផ្សព្វផ្សាយនូវព័ត៌មានសង្ខេបនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយត្រូវការពារនូវបូរណភាពនៃការស៊ើបអង្កេត អត្តសញ្ញាណនៃជនរងគ្រោះនិងសាក្សី ហើយនិងសច្ចធារណ៍នៃនិរទោសរបស់ជនសង្ស័យ ។ ដូច្នេះ ដោយមានការពិចារណាពីការសង្ឃឹមរង់ចាំដ៏ត្រឹមត្រូវតាមផ្លូវច្បាប់របស់ប្រជាពលរដ្ឋខ្មែរ ព្រមទាំងសហគមន៍អន្តរជាតិផងនោះ ទើបសហព្រះរាជអាជ្ញាបានសម្រេចចេញផ្សាយនូវសេចក្តីថ្លែងការណ៍នេះឡើង ។

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ដែលបង្កើតបានជាប្រព័ន្ធមួយមិនស្របច្បាប់និងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា ព្រមទាំងការធ្វើទុក្ខបុកម្នេញទៅលើក្រុមគោលដៅផ្សេងៗដែលបានកំណត់ទុកជាមុន ។ មូលហេតុដែលអះអាងអំពីផែនការឧក្រិដ្ឋកម្មរួមនេះ គឺបានធ្វើឲ្យមានការផ្លាស់ប្តូរទាំងស្រុងនូវសង្គមកម្ពុជាឲ្យទៅតាមខ្សែបន្ទាត់មនោគមវិជ្ជា ពួកជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងគោលនយោបាយ រួមទាំងអ្នកដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ដោយអនុលោមទៅតាមការស៊ើបអង្កេតបឋមរបស់ខ្លួន សហព្រះរាជអាជ្ញាបានកំណត់និងស្នើបញ្ជូនសម្រាប់ការស៊ើបសួរអំពីអង្គហេតុខុសៗគ្នាចំនួន២៥ ស្ថានភាពដែលមានជាអាទិ៍ ÷ ឃាតកម្ម ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ការបង្ខំឲ្យធ្វើពលកម្ម ព្រមទាំងការធ្វើទុក្ខបុកម្នេញលើសាសនា នយោបាយ និងជនជាតិភាគតិចដែលជាភស្តុតាងនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិក្នុងការអនុវត្តផែនការឧក្រិដ្ឋកម្មរួមនេះ ។ ការចោទប្រកាន់តាមអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះផ្សំបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្មនិងការធ្វើទុកបុកម្នេញផ្នែកសាសនា ដូច្នេះសហព្រះរាជអាជ្ញាបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ពួកជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ។

ការស៊ើបអង្កេតបឋមនេះ បានបង្ហាញលទ្ធផលក្នុងការកំណត់បាននូវជនសង្ស័យចំនួន៥រូប ដែលបានប្រព្រឹត្ត បានជួយ បានជំរុញឲ្យមានឧក្រិដ្ឋកម្មទាំងនោះ និងឬមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ។ ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ សហព្រះរាជអាជ្ញាបានផ្តល់អត្តសញ្ញាណរបស់ពួកគេជូនដល់សហចៅក្រមស៊ើនអង្កេតនិងសុំឲ្យសហចៅក្រមស៊ើបអង្កេតចាត់ការតាមផ្លូវច្បាប់ ។

ដើម្បីគាំទ្រដល់ការបញ្ជូនអង្គហេតុ សហព្រះរាជអាជ្ញាបានបញ្ជូនឯកសារជាង ១.០០០ច្បាប់ ដែលផ្សំបានជាង ១៨.០០០ទំព័រ រួមទាំងចម្លើយរបស់ភាគីទីបី និងឬកំណត់ត្រាជាលាយលក្ខណ៍អក្សររបស់សាក្សីជាង ៣៥០នាក់ បញ្ជីសាក្សីសក្តានុពលចំនួន៤០ ផ្សេងទៀតឯកសារសម័យកម្ពុជាប្រជាធិបតេយ្យជាច្រើនម៉ឺនទំព័រ ព្រមទាំងទីតាំងរណ្តៅសាកសពរួមដែលមិនទាន់មានគេគាស់កកាយជាង៤០រណ្តៅទៀតផង ។ ឯកសារទាំងនេះត្រូវបានធ្វើឲ្យទៅជាឌីជីថល និងជាលិបិក្រមក្នុងប្រព័ន្ធទិន្នន័យ ។ ច្បាប់ចម្លងឯកសារទាំងនេះជាអេឡិចត្រូនិកនិងជាក្រដាស ត្រូវបានផ្តល់ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតរួចហើយ ។ ភស្តុតាងមួយចំនួនធំត្រូវបានប្រមូលឡើងដោយមានការជួយជ្រោមជ្រែងពីសំណាក់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ឥឡូវនេះ សហព្រះរាជអាជ្ញាកំពុងតែបន្តការងាររបស់ខ្លួនតទៅទៀត ហើយក៏នឹងចូលរួមផងដែរក្នុងការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតទៅលើអំពើឧក្រិដ្ឋដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ។ **លោកស្រី ជា លាង និង រ៉ូប៊ឺត ពេទីត**

# ស្ទើរបាត់បង់ជីវិតដោយសារប្រឆាំងនឹងបដិវត្តន៍

ខ្ញុំសព្វថ្ងៃរស់នៅភូមិអូររំចេក ឃុំម្រោម ស្រុកបន្ទាយមាស ខេត្តកំពត ។ ក្រោយពីខ្ញុំបានអានសៀវភៅទស្សនាវដ្តី «ស្វែងរកការពិត» នៅឆ្នាំ២០០២ ខ្ញុំមានការចាប់អារម្មណ៍ទៅលើសៀវភៅនេះណាស់ ហើយក៏បានសរសេរពីរឿងរ៉ាវជីវិតរបស់ខ្ញុំផ្ញើជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង ។

នៅឆ្នាំ១៩៧០ ខ្ញុំបានបួសនៅវត្តប្រាបជនបទ ។ ក្រោយពីសឹកនៅឆ្នាំ១៩៧១ ខ្ញុំបានចូលធ្វើជាទ័ពវៀតកុងវៀតណាមខាងជើងរយៈពេល៥ខែ ។ បន្ទាប់មកមេដឹកនាំខ្មែរក្រហម ប៉ុល ពត តាម៉ុក និងខៀវ សំផន ដែលជាអគ្គមេបញ្ជាការទ័ពបានដកខ្មែរទាំងអស់ចេញពីវៀតកុងមកបង្កើតជាកងពលទី១ ដែលបោះទីតាំងនៅទិសពាយ័ព្យ ក្រុងភ្នំពេញ ដើម្បីវាយប្រឆាំងទាហាន លន់ នល់ តាមដងផ្លូវជាតិលេខ៤ និងលេខ៥ និងក្រុងភ្នំពេញ ។

មុនពេលចូលវាយនៅទីក្រុងភ្នំពេញ ខ្ញុំមានតួនាទីជាមេបញ្ជាការកងពិសេសអនុសេនាតូចប្រចាំនៅវរសេនាតូចលេខ ១៨០ ចំណុះកងវរសេនាធំលេខ១៦ កងពលទី១ ។ ពិតមែនតែខ្ញុំធ្វើជាកងទ័ពខ្មែរក្រហម ប៉ុន្តែខ្ញុំបានចូលរួមធ្វើសកម្មភាពប្រឆាំងនឹងអង្គការតាំងពីឆ្នាំ១៩៧៣មក ។ ពេលកងទ័ពខ្មែរក្រហមចូលដល់ព្រលានយន្តហោះពោធិចិនតុង ទាហាន លន់ នល់ មួយចំនួនកំពុងរៀបកាំភ្លើងទុក ។ កុម្ម៉ង់ដូស្រីៗកាន់បាច់ផ្ការង់ចាំទទួលកងទ័ពខ្មែរក្រហម ។ ពេលនោះអង្គការបញ្ជាឲ្យកងទ័ពជម្លៀសប្រជាជនចេញពីទីក្រុងហើយ ខ្ញុំបានឃើញកងទ័ពខ្មែរក្រហមខ្លះបាញ់សម្លាប់ស្ត្រី និងខ្លះចាក់សម្លាប់មនុស្សនឹងកាំបិតចំពុះទង់ ។

ខ្ញុំត្រូវមេបញ្ជាការបញ្ជាឲ្យឈរជើងនៅប៉ែកខាងជើងមួយយប់ ។ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាពបងប្រុសខ្ញុំ ខ្ញុំបានទៅជួបគាត់ដើម្បីប្រាប់គាត់ឲ្យចាកចេញពីទីនេះភ្លាម ពីព្រោះមិនមែនជាមុខសញ្ញារបស់ខ្ញុំ ព្រមទាំងឲ្យគាត់រត់ទៅខេត្តកំពតវិញ ។ ខ្ញុំប្រាប់គាត់បន្ថែមថា ខ្ញុំបានទទួលដំណឹងថាអង្គការចាប់ឪពុកនិងបងប្អូនដទៃទៀតទៅដាក់គុកសួរចម្លើយហើយ ។ ពេលខ្ញុំត្រឡប់ទៅពោធិ៍ចិនតុងបានប្រហែល ១ម៉ោង មេបញ្ជាការកងវរៈ បានហៅមេកងតូច កងធំមកប្រជុំ (ដោយប្រាប់មិនឲ្យកងទ័ពដើរទៅណាឆ្ងាយទេ) ឲ្យនៅចាំទទួលបញ្ជាពីថ្នាក់លើពីរយប់បីថ្ងៃ ។ នៅយប់ទី៣ថ្ងៃទី៤ ប៉ុល ពត និង តាម៉ុក បញ្ជាឲ្យប្រធានកងពលឈ្មោះ មេត សឿង និងសារី បញ្ជាមកវរសេនាធំឈ្មោះ ឡូញ រ៉ុន ឲ្យវរសេនាតូចលេខ១៨០ ចេញដំណើរតាមរថយន្តតាមផ្លូវជាតិលេខ៤ ។ ពេលជិតទៅដល់ចំណោតរាម យើងបានឈប់នៅទីនោះ ។ ស្អែកឡើង ប៉ុល ពត បញ្ជាឲ្យជីកលេណដ្ឋានក្បែរមាត់សមុទ្រ ត្រៀមប្រយុទ្ធជាមួយនាវាអាមេរិកបីគ្រឿង ។ ឪពុកមារបស់ខ្ញុំឈ្មោះ ប៉ាង ជាទាហាន លន់ នល់ ប្រចាំនៅសមុទ្ររាមបានបើកកប៉ាល់ចេញទៅក្រៅវង្វេងកណ្តាលសមុទ្រ ហើយបានបើកត្រឡប់មកវិញជួបខ្មែរត្រៀមរបស់ខ្ញុំ ។ កងទ័ពរបស់ខ្ញុំបម្រុងបាញ់កម្ទេចកប៉ាល់នោះចោល ប៉ុន្តែខ្ញុំបានបង្វែងដានថាគ្នាយើងទេ ។ បន្ទាប់មកខ្ញុំបានចុះ



ទៅកប៉ាល់គាត់យ៉ាងលឿនដើម្បីប្រាប់ឲ្យគាត់ដោះសម្លៀកបំពាក់ដែលមានពាក់ស័ក្តិចេញ ហើយស្លៀកពាក់របៀបជាអ្នកនេសាទត្រីវិញ ។ រយៈពេលពីរយប់ យើងចាប់បាននាវាសេដ្ឋកិច្ចអាមេរិកមួយគ្រឿង ប៉ុន្តែនាវាផ្ទុកយន្តហោះចាប់ពុំបានទេ ។

នៅឆ្នាំ១៩៧៥ ប៉ុល ពត បានចាត់តាំងប្រធានតំបន់ស្រុក ឃុំ និងភូមិឲ្យមកកាន់កាប់នៅខេត្តកោះកុងទាំងមូល ។ កងឈ្លបខ្មែរក្រហមបានចាប់ប្រជាជនណាដែលជាប់ខ្សែស្រឡាយជាជនជាតិថៃយកទៅសម្លាប់ចោលនៅតាមកោះនានា ។ ខ្ញុំដឹងច្បាស់មួយកន្លែងគឺខ្មែរក្រហមបានបញ្ជូនប្រជាជនខ្មែរទាំងក្មេងចាស់ប្រុសស្រីប្រហែលជា២០០នាក់ មកវាយសម្លាប់ចោលនៅក្នុងរណ្តៅតែមួយខាងក្រោយដំណាក់ ចម្ងាយប្រហែលជា៩០០ម៉ែត្រក្នុងរយៈពេលមួយយប់ប៉ុណ្ណោះ ។ ចុងឆ្នាំ១៩៧៥ ប៉ុល ពត បានប្រកាសប្រាប់កងទ័ពថា ដល់ដំណាក់កាលទី១ដែលយើងត្រូវកសាងសង្គមនិយម ហើយត្រូវកម្ទេចចោលឲ្យអស់ពួកសក្តិភូមិនិយម ម៉ាក្សលេនីននិយម បក្សពួកនិយម សេរីនិយម យើងកម្ចាត់ខ្មាំងចក្រពត្តិ ។ ក្រោយពីបក្សតំណាងភូមិភាគបស្ចិម ចាន ស៊ី ប្រជុំរួច៣ថ្ងៃមក អង្គការបានចាប់មេបញ្ជាការវរៈឈ្មោះ ប៊ុន ថេង ជាអតីតមេឃុំនៅស្រុកកំពង់ត្រាច ខេត្តកំពត យកទៅសម្លាប់ចោល បន្ទាប់មកចាប់មេបញ្ជាការម្នាក់ទៀតឈ្មោះ បងស៊ុត ជាអតីតស្មៀននៅឃុំបន្ទាយមាស ខេត្តកំពត ។ ក្រោយពីចាប់មេបញ្ជាការវរសេនាតូចទាំងពីរមក ប៉ុល ពត និង តាម៉ុក បានប្រគល់តំបន់ត្រួតត្រាឲ្យទៅ អេង ហៅ នៅ និង ណា គី ជាមេទ័ពតំបន់ និង រ៉ែន ជាគណៈតំបន់ ។ រ៉ែន បានបញ្ជាឲ្យ នៅ និង គី ហៅទ័ពដែលចូលសម្ព័ន្ធយុវកក បក្ខជនក្នុងកងវរសេនាតូចលេខ១៨០ ចាស់ទៅត្រពាំងរូងដើម្បីប្រជុំ ។ ខ្ញុំ និង ចន្ទា គឺជាជនក្បត់អង្គការ ប៉ុន្តែមិនបានរត់គេចពីការប្រជុំទេ ។ ខ្ញុំទាំងពីរនាក់បានសម្រេចចូលរួមប្រជុំដោយមាន នៅ និង គី ជាអ្នកបើកអង្គប្រជុំចាត់តាំងប្រធានវរៈថ្មី ។ នៅពេលល្ងាចក្រោយពីប្រជុំចប់ គេឲ្យសមាជិកឡើងមានយោបល់ ។ គ្មាននរណាម្នាក់មានយោបល់ទេ មានតែ ចន្ទា ម្នាក់ដែលឡើងសួរ ប៉ុន្តែនិយាយមិនទាន់ចប់ផង ស្រាប់តែ គី និង នៅ ចោទថាជាសម្ព័ន្ធខ្មាំងបង្កប់ សម្រេចត្រូវកម្ចាត់ចោល ។ ពេលនោះអ្នកទាំងពីរបញ្ជាឲ្យអង្គរក្សចាប់ខ្លួន ចន្ទា ដែលអង្គុយនៅក្បែរខ្ញុំ ។ ខ្ញុំអង្គុយភាំងស្មារតី កាំភ្លើងខ្លីមួយដើមសៀតនៅនឹងចង្កេះគិតដកបាញ់ គី និងនៅ ឲ្យស្លាប់មុន ប៉ុន្តែអ្នកទាំងពីរមិននិយាយអ្វីទាំងអស់ រួចដើរចេញ ។ ប្រធានវរៈថ្មីបានប្រើសម្តីថា «បងកុំធ្វើអ្វីខុសដូចមិត្ត ចន្ទា វាមិនអីទេយើងធានា» ។ ក្រោយមកប្រហែលជា៤០នាទីស្នូរកាំភ្លើងមួយគ្រាប់បាញ់ផ្ទុះបនឹងដី ។ ខ្ញុំឮនិរសាររបស់ គី និង នៅ រាយការណ៍ឲ្យអ្នកទាំងពីរថាឲ្យវាជីករណ្តៅខ្លួនឯង ហើយបាញ់កាំភ្លើងមួយគ្រាប់កាយដីកប់នៅក្បែរខាងកើតសាលារៀន ។ ពេលខ្ញុំត្រឡប់មកដងទង់វិញបានតែបីយប់ ខាងតំបន់ធ្វើសំបុត្រឲ្យមកខាងប្រធានវរៈថ្មីមកប្រាប់ខ្ញុំដោយផ្ទាល់ថាសមមិត្ត សឿន ឯងនិងមិត្តបីនាក់ត្រូវទៅខាងតំបន់ មិនបាច់យកកាំភ្លើងទៅទេ ។ គេឲ្យកាណូតមួយតូចជូនដំណើរពួកខ្ញុំទាំង៤នាក់ទៅ ។ ទៅដល់កោះក្រឡៅសម្រាកនៅទីនោះមួយយប់ ព្រឹកឡើងខាងតំបន់បើកកាណូតជូនពួកខ្ញុំកាត់កោះកុងដល់ត្រពាំងរូង ។ នៅម៉ោងប្រហែល៩ព្រឹក និរសារតំបន់៣នាក់ មានអាវុធគ្រប់ដៃបានសួរទៅអ្នកបើកកាណូតថា ឯណាកម្លាំងបងឲ្យមក ។ បន្ទាប់មកនិរសារក្មេងៗនោះលើកកាំភ្លើងចង្អុលផ្លូវ ហើយបញ្ជាយើងយ៉ាងប្រញាប់ប្រញាល់ឲ្យដើរទៅមុខទៀត ។ និរសារក្មេងៗដើរពីក្រោយពួកខ្ញុំចម្ងាយប្រហែលជា៥០ទៅ៦០ម៉ែត្រ ។ ធ្វើដំណើរប្រហែលជា៥០នាទីដល់ស្ពានធំមួយហៅថា អូរកំបុត មានកម្មករ៨នាក់កំពុងធ្វើស្ពាន និងកងទ័ពតំបន់មួយក្រុមនៅយាមកម្មករធ្វើស្ពាននោះ ។ ពេលនោះខ្ញុំទាំងបួននាក់ត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកនៅត្រង់នោះបន្តិច ។ ក្នុងចំណោមកងទ័ពតំបន់នោះមានម្នាក់បានប្រាប់និរសារក្មេងៗនោះថា ឲ្យពួកខ្ញុំទាំងបួននៅជាមួយអ្នកធ្វើស្ពានសិនហើយ ។ ថូ ជាអ្នកប្រចាំការនៅទីនោះ ។ ក្រោយមកពួកខ្ញុំទាំងបួន និងកម្មករធ្វើស្ពានត្រូវបានគណៈតំបន់ឈ្មោះ រ៉ែន បញ្ជាឲ្យជួលជុលផ្លូវគោកចាប់ពីស្រែអំបិលទៅដល់ទីរួមខេត្តកោះកុង ។

ពាក់កណ្តាលឆ្នាំ១៩៧៧ មានមេបញ្ជាការ៤-៥នាក់ជិះរថយន្តម៉ាក G.M.C ដែលបានប្រជុំចប់នៅកោះកុង ហើយត្រូវត្រឡប់ទៅភ្នំពេញវិញតាមផ្លូវត្រពាំងរូង អណ្តូងទឹកស្រែអំបិលបានមកឈប់នៅក្បាលស្ពានដែលខ្ញុំកំពុងជួសជុលវាយតម្រង់ដែកទាម ។ បងជីដូនមួយខ្ញុំម្នាក់ឈ្មោះ យាន ហៅ រស្មី ជាមេបញ្ជាការ

វរសេនាធំលេខ១៧ ក្នុងកងពលទី១បានចុះពីលើឡានឃើញខ្ញុំក៏បានកេះខ្ញុំឲ្យទៅឆ្ងាយបន្តិច រួចប្រាប់ខ្ញុំទាំងអួលដើមកថា «អាប្អូនទ្រាំរស់នៅទីនេះបន្តិចសិនទៅ ទៅដល់ភ្នំពេញវិញ យើងរៀបចំធ្វើរដ្ឋប្រហារប្រឆាំងជាមួយ ប៉ុល ពត ហើយត្រូវចេះប្រយ័ត្នខ្លួនបំពាក់ប្រជាជននៅជាមួយយើង» ។ ខ្ញុំរង់ចាំដំណឹងនេះប្រហែលជាបីខែ ដោយគ្មានឮអ្វីទាំងអស់មានតែដំណឹងអាក្រក់តាមរយៈតំបន់ថាអង្គការបក្សយើងយល់ដឹងវៃឆ្លាត ចាប់ជនក្បត់ប្រឆាំងបក្សបានស្ទើរតែទាំងអស់ហើយ ពិសេសពួកក្បត់នៅក្នុងជួរកងទ័ព ។ ពេលនោះខ្ញុំអស់សង្ឃឹមមានតែរកផ្លូវមួយទៀតគឺរកមធ្យោបាយនាំបងប្អូនរត់ចូលព្រៃ ។ នៅខែតុលា និរសារតំបន់បានមកធ្វើប្រវត្តិរូបពួកខ្ញុំទាំងបួននាក់ ។ និរសារនេះមកសួរនាំខ្ញុំចំនួនពីរដងហើយ ប៉ុន្តែខ្ញុំនៅតែកុហកថា ខ្ញុំចូលបដិវត្តន៍ឆ្នាំ១៩៧៣ កម្រិតវប្បធម៌ត្រឹមថ្នាក់ទី១២សង្គមចាស់ ។ ៣ថ្ងៃក្រោយមក ពួកខ្ញុំទាំងបួនត្រូវបានបញ្ជូនទៅអណ្តូងទឹក ។ សម្រាកបានមួយយប់ម៉ោងប្រហែល៨ រ៉ែន បានប្រកាសតាមមីក្រូឲ្យកងទ័ពទាំងអស់ឡើងទូកបេអឹធំៗចំនួន៤គ្រឿង ។ ដល់ស្រែអំបិល មានទ័ពស្រុកមួយចំនួនធំបានរង់ចាំនៅទីនោះនិងរថយន្ត១០គ្រឿងបានដឹកទ័ពទាំងអស់ទៅវាលរេញ ។ សម្រាកនៅទីនោះ១យប់ទៀត មានសេចក្តីប្រកាសតាមមីក្រូថាឲ្យកងទ័ពទាំងអស់គ្នាឡើងលើទូរថភ្លើងវិញ ។

ចូលដល់ភ្នំពេញនៅម៉ោង៩យប់ រថយន្តជាង១០គ្រឿង បានបើកចុះបើកឡើងរយៈពេល៤០នាទី មិនដឹងថាយកទៅកន្លែងណាទេ ។ បន្ទាប់មកក្រុមខ្ញុំ៥០នាក់ដែលជិះក្នុងរថភ្លើងជាមួយគ្នាត្រូវបានបញ្ជូនឲ្យសម្រាកនៅអគារជាន់ទី៤ ។ យប់នោះ ខ្ញុំអង្គុយមើលតាមបង្អួចឃើញក្រុងភ្នំពេញមានសភាពស្ងាត់ជ្រងំ ងងឹតប្រៀបដូចជានៅកណ្តាលព្រៃភ្នំ ។ ព្រឹកឡើងខ្ញុំឃើញចិនអង្គុយនិងដើរលេងនៅជុំវិញបរិវេណ ទើបខ្ញុំច្បាស់ថានៅជិតស្ថានទូតចិន ។ នៅព្រឹកថ្ងៃទី២ ខ្ញុំបានឃើញ សាឡុត ស រួមដំណើរជាមួយចិនប្រមាណ៥នាក់ដើរត្រួតពលមួយជុំរយៈពេល១០នាទី ដោយមិននិយាយអ្វីទាំងអស់ ។ នៅពេលព្រឹកថ្ងៃទី៦ ក្រោយពីហូបបាយរួច ប៉ុល ពត បញ្ជាឲ្យមនុស្សម្នាក់មកនិយាយលើកទឹកចិត្តកងទ័ពទាំងអស់និងចាត់តាំងត្រឹមប្រធានកងអនុសេនាធំ១២នាក់រួមទាំងខ្ញុំម្នាក់ផង ឲ្យស្ថិតនៅក្រោមបញ្ជាអគ្គបញ្ជាការ សុន សេន និងអគ្គសេនាធិការ ពីន ជាកងអន្តរាគមន៍ពិសេសលេខ៦៤ ហើយប្រាប់ឲ្យកងទ័ពទាំងអស់ត្រូវទៅវាយដណ្តើមយកទឹកដីយើងពីសំណាក់វៀតណាមឈ្លានពានឲ្យបានដាច់ខាតដើម្បីមកជូនបក្សយើង ។ បន្ទាប់មករថយន្តហ្ស៊ីប G.M.C និងរថក្រោះ អុីម១១៣ រួមទាំងអស់៣០គ្រឿងដឹកទ័ពពេញបើកឆ្ពោះទៅទិសខាងជើងដល់ព្រែកក្តាម ទើបឈប់នៅទីនោះ ។ ស្រឡាង៤គ្រឿងបានចម្លងរថយន្តដល់ត្រើយខាងកើត ។ រថយន្តឆ្ពោះទៅទិសខាងកើតដល់ខេត្តកំពង់ចាមឆ្លងស្រឡាងទន្លេបិទ រួចចេញដំណើរតាមរថយន្តទៅវត្តស្រះ ។ ពាក់កណ្តាលយប់ទៅដល់កន្លែងរបស់តាពីន គាត់បានរៀបចំចែកកាំភ្លើងស្ពាយបត់ថ្មីរបស់ចិន បេ៤០ ទំនើប ឡង់អាតេថ្មីៗទាំងអស់ និងសេរិនធីណាយរបស់អាមេរិកមួយចំនួន ។ ម៉ោង៧ព្រឹក តាពីន បញ្ជាទ័ពទាំងអស់ឲ្យប្រជុំជាជួររួចចែកមុខសញ្ញាតាមកងធំ៥មុខព្រួញ អមដោយកងរថក្រោះចិនតេ៦២, ៦៣ និង ៦៤ ចំនួន២៥គ្រឿង និងអុីម១១៣ចំនួន


សុន សេន អៀង សារី នួន ជា

៥គ្រឿងឡើងទៅវាយវៀតណាម ។ វាយប្រយុទ្ធរយៈពេលប្រហែលជា៥ថ្ងៃ កងទ័ពវៀតណាមបានដកថយទៅប្រមូលផ្តុំគ្នានៅមេមត់ ។ ប្រហែល២ខែ នៅឆ្នាំ១៩៧៨ កងអនុសេនាធំកងអនុរាគមន៍និងកងរថក្រោះចិន៤០គ្រឿងវាយយកបានទឹកដីមេមត់ ប៉ុន្តែកងថ្មើរជើងនិងកងរថក្រោះត្រូវខូចខាតនិងស្លាប់អស់ជាងពាក់កណ្តាល ។ បន្ទាប់ពីដណ្តើមបានទីនោះហើយ ប៉ុល ពត, សុន សេន និងតាពីន បញ្ជាឲ្យកងអនុរាគមន៍លេខ៦៤ត្រៀមនៅទីនោះ និងដីកលេណដ្ឋានទល់មុខខ្សែត្រៀមរបស់វៀតណាមឆ្ងាយបំផុតត្រឹម១០០ម៉ែត្រ ជិតបំផុតត្រឹម៥០ម៉ែត្រ និងបញ្ជាឲ្យវាយទ័ពវៀតណាមជាបន្តបន្ទាប់ ។ ថ្ងៃមួយ ប៉ុល ពត បានបញ្ជាឲ្យសេនាធិការដឹកអ៊ីវ៉ាន់មកដល់កន្លែងខ្ញុំនិងបញ្ជីឈ្មោះទ័ពដែលត្រូវចុះទៅប្រទេសវៀតណាម ដើម្បីចូលទៅឲ្យបានជ្រៅធ្វើសកម្មភាពវាយប្រហារឲ្យចំគោលដៅ ។ ចំណែកទីកន្លែងដែលត្រូវទំនាក់ទំនងជាមួយវៀតណាមធីវគីនិងខ្មែរកម្ពុជាក្រោមគឺត្រូវធ្វើទៅតាមភាពជាក់ស្តែង ។ ក្រោយពីការត្រឡប់មកវិញ ខ្ញុំគិតថាជាឱកាសល្អសម្រាប់ខ្ញុំ ខ្ញុំបានប្រាប់ទៅមេបញ្ជាកងធំដែលប្រចាំការនៅកន្លែងថា «បើបាត់ខ្ញុំហួសផែនការបក្ស ខ្ញុំច្បាស់ជាស្លាប់ហើយ» ។ នៅម៉ោង១២យប់ ខ្ញុំត្រូវនាំកម្លាំង៩០នាក់ដើរឆ្លងកាត់ព្រំប្រទល់ខ្សែត្រៀមវៀតណាមឲ្យតាមត្រីវិស័យនិងផែនទី ។ មកដល់ពាក់កណ្តាលភ្នំមួយ ខ្ញុំបានសម្រាកនៅទីនោះដើម្បីស្តាប់សភាពការណ៍និងឡើងធ្វើដំណើរឆ្លងទៅភ្នំមួយទៀតដែលអាចមើលឃើញទឹកដីវៀតណាម ។ ខ្ញុំចែកជា៣ក្រុមដើម្បីធ្វើសកម្មភាព មួយក្រុមទទួលបានខោអាវ មួក១៥កំប្លេ និងវិទ្យុទាក់ទងសេ២៥មួយគ្រឿង និងផែនទីមួយ ត្រីវិស័យមួយ ហើយធ្វើដំណើរទៅតាមទិសរៀងខ្លួន ។ ពួកខ្ញុំបានវាយធ្វើសកម្មភាពទាក់ទងអស់រយៈពេល២០ថ្ងៃ សេន និងពីន បានស្រែកហៅតាមវិទ្យុទាក់ទង ខ្ញុំក៏ឆ្លើយរាយការណ៍តាមដំណើរដែលពួកខ្ញុំអនុវត្តនិងបានជួបប្រទះ ។ ពីន បានដាក់បញ្ជាឲ្យខ្ញុំត្រូវតែធ្វើឲ្យបានដាច់ខាត គឺនៅរយៈពេល១០ថ្ងៃទៀត ចាប់ពួកវៀតណាមឲ្យបានយ៉ាងតិច៥នាក់ ស្រីឬប្រុសក៏បាន ។ ពេលជិតត្រឡប់មកកម្ពុជាវិញ ខ្ញុំចាប់បានតែវៀតណាម៣នាក់ និងបានបោកគ្រាប់បែកដើម្បីរំដោះកងទ័ពយើង ។ គ្រាប់បែកនោះបានផ្ទុះផ្ទួនៗធ្វើឲ្យទ័ពវៀតណាមស្លាប់ស្ទើរអស់ ។ ចំណែកកងទ័ពខ្មែរក្រហមស្លាប់ពីរនាក់ របួសធ្ងន់ម្នាក់ និងរបួសស្រាលបួននាក់រួមទាំងខ្ញុំម្នាក់ផង ។ ប្រហែលជាម៉ោង៧ព្រឹក ខ្ញុំបានប្រគល់វៀតណាមបីនាក់ឲ្យទៅ តាពីន ។ តាពីន មិនបាននិយាយអ្វីឡើយ រួចបញ្ជូនរថយន្តមកដឹកអ្នករបួសទៅដេកនៅពេទ្យសួង ។ ខ្ញុំសម្រាកនៅពេទ្យនេះបាន៥ថ្ងៃ តាពីន បានឲ្យអង្គរក្សបើករថយន្តមកយកខ្ញុំទៅវិញ និងឲ្យសម្រាកជាបណ្តោះអាសន្នពេលមកដល់វត្តស្រះ ។

បន្ទាប់មក ប៉ុល ពត បានដាក់ផែនការនិងស្តីបន្ទោសទៅថ្នាក់កម្មាភិបាលយោធា និងថ្នាក់កម្មាភិបាលមូលដ្ឋាននៅតាមតំបន់ភូមិភាគបូព៌ា និងចម្ការកៅស៊ូ ។ តាពីន ក៏បានបញ្ជាឲ្យខ្ញុំនាំកម្លាំង២០០នាក់ដែលមានអាវុធគ្រប់ដៃ និងរថក្រោះ M១១៣ ចំនួន៧គ្រឿង នៅយាមចម្ងាយ១គីឡូម៉ែត្រ ឆ្ងាយពី ប៉ុល ពត ប្រជុំ ។ ខ្ញុំមិនអាចស្តាប់បានក៏ត្រឡប់មកសួរអង្គរក្សតាពីន វិញ ។ តាពីន បានជិះរថយន្តហ្ស៊ីបក្រោយរថយន្តអង្គរក្ស ចំណែកខ្ញុំនៅក្រោយគេ ។ មកដល់ជិតវត្តស្រះ កងឈ្លបយួន-ខ្មែរបាញ់បេ៤០ ចំនួនពីរគ្រាប់ មួយគ្រាប់ត្រូវចំរថយន្ត តាពីន និងមួយគ្រាប់ទៀតហោះរំលងរថយន្ត តាពីន ។ ពេលនោះរថយន្ត តាពីន ត្រូវក្រឡាប់ក្រវែង តាពីន និងអង្គរក្ស៤នាក់ចេញពីរថយន្តចម្ងាយ៧ម៉ែត្រ ។ ពួកខ្ញុំនៅខាងក្រោយ បានបញ្ជាឲ្យកងទ័ពមួយក្រុមមកមើល តាពីន ដេកសន្លប់ ។ ខ្ញុំបានធ្វើចលនាបេះដូងឲ្យគាត់ ។ នៅពេលគាត់ដឹងខ្លួន តាពីន បានបញ្ជាឲ្យខ្ញុំតាមចាប់ខ្មាំង ។ ខ្ញុំទទួលបញ្ជាពីគាត់ ប៉ុន្តែខ្ញុំត្រឡប់មកក្រោយវិញប្រាប់កងទ័ពខ្ញុំថា នាំគ្នាទៅយាមនិងដេកតាមឡានរៀងៗខ្លួនទៅព្រោះគ្មាននរណារកមនុស្សពួនយប់ឃើញទេ ។

ព្រឹកឡើង តាពីន ឲ្យអង្គរក្សតាមមកហៅខ្ញុំឲ្យទៅកន្លែងគាត់ និងឲ្យខ្ញុំអង្គុយនៅតុមួយដែលមាន ម្ហូប បាយ និងស្រាមួយដប ។ នៅពេលគាត់ហូបបាយរួច គាត់បញ្ជាខ្ញុំឲ្យនាំកម្លាំងមួយចំនួនទៅវ៉ាសព្រៃខាងលិចត្បូង ហើយប្រសិនបើមានពួកចោរព្រៃ ត្រូវចាប់យកមកកុំឲ្យស្លាប់ ។ ខ្ញុំក៏នាំកម្លាំងជាង១០០នាក់ចែកជាបីមុខព្រួញនៅមាត់ព្រៃ និងណាត់គ្នាថាម៉ោង៤ត្រូវមកជួបគ្នានៅប្រឡាយធំមួយនៅខាងលិច ។ ដើរចូលព្រៃ គ្មានឃើញអ្វីទាំងអស់ ឃើញមានតែខ្ទមរោងចាស់នៅចម្ការមួយ ។ ពេលត្រឡប់មកវិញ

ពួកខ្ញុំបាននាំគ្នាឆ្លងកាត់ភូមិមួយដែលមានផ្ទះធំៗ៦-៧ខ្នង និងមានមនុស្សអឹងកង ឮសំឡេងបុកស្រូវ ។ ចូលទៅដល់ក្នុងភូមិ ខ្ញុំបានបញ្ជាឲ្យកងទ័ពបាញ់កាំភ្លើងឡើងទៅលើដើម្បីបញ្ឈប់សកម្មភាព ។ ខ្ញុំមានបំណងរាយការណ៍ឲ្យ តាពីន ប៉ុន្តែ សុន សេន ជាមួយអង្គរក្សបីនាក់ និងទីប្រឹក្សាចិន៥នាក់ បញ្ជាឲ្យ តាពីន ទៅបង្ហាត់ទ័ពថ្មីៗជាច្រើន ។ តាពីន បានចែកសៀវភៅក្បួនយុទ្ធសាស្ត្រចិនដែលបកប្រែជាភាសាខ្មែរចំនួន៩ក្បាលឲ្យអង្គរក្ស៨នាក់និងខ្ញុំមួយក្បាល ។ បន្ទាប់មក តាពីន បាននាំកម្លាំងថ្មីក្មេងៗទៅហាត់នៅភូមិមួយនៅខាងជើងចម្ងាយពីកន្លែងគាត់២គីឡូម៉ែត្រ ។ ខ្ញុំក៏ទៅបង្ហាត់នៅទីនោះបានពីរយប់ដែរ ប៉ុន្តែនៅយប់ទី៣ត្រូវកងឈ្លបយួន-ខ្មែរវាយ៣យប់ជួនៗ បណ្តាលឲ្យស្លាប់បុគ្គលិកពេទ្យប្រចាំការម្នាក់ និងរបួស៨នាក់ ។ ឃើញដូចនេះ ខ្ញុំបានសុំ តាពីន មកនៅកន្លែងគាត់វិញ ។

នៅពេលនោះ តាពីន បានចាប់ប្រជាជនជាច្រើននាក់មកឃុំទុកនៅកន្លែងគាត់ ។ បន្ទាប់មក តាពីន បានឲ្យអង្គរក្ស ៨-៩នាក់ រួមទាំងខ្ញុំ យកជនជាតិយួនកាត់ខ្មែរម្នាក់ទៅសួរចម្លើយ ។ ខ្ញុំជាអ្នកកត់ត្រាចម្លើយឲ្យ តាពីន និង៨នាក់ទៀតជាអ្នកធ្វើទារុណកម្ម ។ អ្នកទាំងបួននោះបានយកម្ជុលខ្វាស់ដោតទៅលើត្រចៀកទាំងពីរ រួចយកខ្សែភ្លើងឆក់សន្ទប់បាត់ស្មារតី១០នាទី ។ ខ្ញុំបាននិយាយថា ធ្វើទារុណកម្មយ៉ាងនេះឲ្យឆ្លើយយ៉ាងម៉េចទៅ អ្នកទាំងបួនបែរជាថា «កុំចេះនេះជាផែនការ អឹកត់ចេះតែកត់ទៅ» ។ ខ្ញុំបានយកចម្លើយដែលខ្ញុំកត់ត្រាទៅឲ្យ តាពីន ដើម្បីពិនិត្យមើល ។ ប៉ុន្តែចម្លើយនេះមិនអាចយកជាការបានទេ ។ ក្រោយមកអ្នកទោសម្នាក់នេះត្រូវបានអង្គការបញ្ជូនទៅភ្នំពេញបាត់ ។ តាពីន បានឲ្យខ្ញុំទៅចាត់ចែងកន្លែងយាមប្រជាជនដែលគាត់ចាប់ដាក់ខ្នោះជាង១០០នាក់ ដោយមិនដឹងមូលហេតុ ។ អ្នកទោសទាំងនេះត្រូវបានដាក់ខ្នោះជើងទាំងពីរ ។ ខ្ញុំបានយកថ្នាំជក់ឲ្យពួកគាត់ជក់ និងបាយឲ្យគាត់ហូបច្រើនៗ ព្រមទាំងប្រាប់ឲ្យឆ្លើយដូចៗគ្នាថាមិនដឹងអ្វីទាំងអស់ ។ ក្រោយមកទៀតខ្ញុំបានជួយសង្គ្រោះពួកគេឲ្យរួចខ្លួនទាំងអស់ ។

ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមអមដោយរថក្រោះគេ៥៨សូវៀត ព្រមទាំងយន្តហោះប្រដេញសូវៀត បានបើកការវាយប្រហារដណ្តើមបានស្រុកមេមត់ និងបន្តវាយចូលដល់ក្រែក ទោះបីជាមានកងអន្តរាគមន៍លេខ៦៨ថ្មីៗជាច្រើន និងកងរថក្រោះចិនរាប់សិបគ្រឿងទៅជួយទប់ស្កាត់ក៏ដោយ ក៏មិនអាចទប់ទល់សភាពការណ៍នេះបានដែរ ។ ឃើញដូចនេះ សុន សេន និង អង្គរក្សបានបញ្ជាឲ្យ តាពីន នាំកម្លាំងទាំងអស់ (ទាំងចាស់ ទាំងថ្មី) ឡើងទៅវាយនៅក្រែក ។ ប៉ុន្តែ តាពីន មិនធ្វើតាមទេ គាត់បានរត់បាត់ ។ សុន សេន ក៏បែរជាទៅបញ្ជាឲ្យមេបញ្ជាការរថក្រោះធ្វើបន្ត ។ បន្ទាប់មកមេបញ្ជាការរថក្រោះបញ្ជាឲ្យខ្ញុំប្រមូលកងថ្មើរជើងទាំងអស់ឡើងរថក្រោះ ។ ពេលមេបញ្ជាការរថក្រោះនោះដើរសំដៅទៅរថក្រោះបាន៨-៩ជំហាន ខ្ញុំបាញ់កាំភ្លើងអាកាទៅលើគ្នារបស់ពួកគេស្លាប់អស់ពីរនាក់ ។ ឆ្លៀតឱកាសនោះ ខ្ញុំប្រមូលកងទ័ពបានជិត១០០០នាក់ និងដាក់បញ្ជាយ៉ាងតឹងរ៉ឹងបំផុតចំពោះទាហានណាដែលប្រឆាំង ។ ប៉ុន្តែក្រោយមកផែនការខ្ញុំត្រូវបរាជ័យ កម្លាំងនៅសល់តែបីនាក់ អ្នកនៅខាងក្រោយនាំគ្នារត់ប្រាសអាយុ ពេលឃើញកងទ័ពវៀតណាមឡើងមក៨ខ្សែ ។

ពេលធ្វើដំណើរត្រឡប់មកវិញ ខ្ញុំស្លុតស្មាញចិត្តយ៉ាងខ្លាំង ខ្ញុំចូលវៀតណាមក៏មិនកើត បើវិលទៅរក ប៉ុល ពត វិញខ្ញុំពិតជាស្លាប់ ។ ខ្ញុំបានរំសាយកងទ័ពមួយចំនួនធំដែលមានផ្ទះនៅជិតស្រុក ដោយទុកតែអ្នកដែលមានផ្ទះនៅឆ្ងាយចំនួនជាង២០០នាក់ធ្វើដំណើរមកជិតភ្នំពេញវិញ ។ ដល់ត្រើយម្ខាងកោះខញ៉ាតី ខ្ញុំទុកកងទ័ពមួយចំនួនធំឲ្យនៅចាំទីនេះ រួចនាំកម្លាំង៥០នាក់ឡើងកោះ ។ គ្រាន់តែពួកខ្ញុំទៅដល់ប្រាំង កងការពារកាំភ្លើងធំដែលបាញ់យន្តហោះ១២គ្រឿងបានភ្ជង់គំរាមពួកខ្ញុំឲ្យទម្លាក់អាវុធ ។ ខ្ញុំបញ្ជាកងទ័ពមិនឲ្យទម្លាក់អាវុធជាដាច់ខាត ហើយសួរទៅវិញថាពួកមិត្តឯងឈ្មោះអ្វី ។ ក្នុងចំណោមនោះ មានម្នាក់ឆ្លើយថាគ្មានអ្នកណាធំជាង បងម៉េត ទេ ។ ខ្ញុំក៏សារភាពថាភ្ជង់កាំភ្លើងពួកខ្ញុំខុសហើយ ព្រោះ បងម៉េត ឲ្យយើងដើរធ្វើការជុំវិញក្រុងនេះ ។ មួយសន្ទុះក្រោយមកពួកគេទម្លាក់អាវុធចុះ រួចបន្តថា បើអឺចឹងចាំសួរទៅ បងម៉េត សិន បើមិនមែនពួកមិត្តសុទ្ធជាខ្លាំង ។ សភាពការណ៍ពេលនោះជ្រួលច្របល់ បងម៉េតថាឲ្យពួកខ្ញុំនៅទីនេះសិន ចាំស្អែកគាត់ទៅមើល ។ ពេលនោះ បងម៉េត នៅឯពោធិ៍ចិនតុងកំពុងបញ្ជាទ័ពឲ្យបាញ់យន្តហោះ ឆ្លៀតឱកាសនោះ ខ្ញុំប្រមូលកងទ័ពបាន

ចំនួន៥០នាក់និងភ្ជង់កាំភ្លើងគំរាមអ្នកបើកកាណូតដឹកអង្ករឆ្លងទៅត្រើយម្ខាងវិញ ។ ខ្ញុំនិងកងទ័ព៥០នាក់ធ្វើដំណើរដល់ព្រៃនៃទឹកដីខេត្តកំពង់ធំ បានចាប់ប្រជាជនបីនាក់ឲ្យជូនទៅរកព្រៃក្រយាជង់ក្តារ ។ ខ្ញុំមិនសូវបន្តដំណើរទេ កន្លះខែទើបទទួលដំណឹងពី តាពីន ថានៅរស់ទីនោះ ។ ខ្ញុំសម្រាកនៅឆ្ងាយពីកន្លែងរបស់គាត់ប្រហែលជា២-៣គីឡូម៉ែត្រនិងជូរកន្លែងស្នាក់នៅជារៀងរាល់ថ្ងៃ ។ រយៈពេលបីថ្ងៃក្រោយមក មានក្រុមពិសេសរបស់ ប៉ុល ពត និង តាម៉ុក ត្រូវបានចាត់តាំងឲ្យរកកន្លែងលាក់ខ្លួនរបស់ តាពីន ។ ប្រធានក្រុមពិសេសម្នាក់ធ្លាប់ស្គាល់ខ្ញុំបានប្រាប់ថា ប៉ុល ពត និង តាម៉ុក ឲ្យនាំសំបុត្រក្លែងក្លាយមករកកន្លែង តាពីន ដើម្បីបាញ់គាត់ចោល ។ ពេលឮខ្ញុំមានចិត្តភ័យអរ រួចនិយាយបន្ថែមថាមែនហើយ តាពីន រត់ចោលសមរភូមិបើកដៃឲ្យខ្មាំងវៀតណាមចូលមក ខ្ញុំរួមដៃជាមួយមិត្តដែរ ពួកយើងដឹងកន្លែង តាពីន ។ ក្រោយពីស្រុះស្រួលជាមួយគ្នា ក្រុមពិសេសដែលមានអាវុធម៉ាកបេ៤០ទំនើប៧ដើម អាកា៨ដើម និងមីន៦៩គ្រាប់នៅគ្រប់ដៃ និងក្រុមរបស់ខ្ញុំមានបេ៤០ចំនួន២០ដើម អាកា៣០ដើម និងគ្រាប់បែកមីនមានគ្រប់ដៃធ្វើដំណើរយ៉ាងប្រុងប្រយ័ត្ន ។ មកដល់ខ្សែការពារទី១ មេបញ្ជាការនៅទីនោះមិនបើកផ្លូវឲ្យទេ ។ ខ្ញុំព្រិចភ្នែកជាសញ្ញាប្រធានក្រុមពិសេស ស្ទុះទៅច្របាច់កម្នាក់នោះស្លាប់ភ្លាម ។ គ្នារបស់វាបម្រុងនឹងចូលជួយ ក៏ប៉ុន្តែខ្ញុំប្រាប់ទៅកងទ័ពទាំងនោះថា កុំបាញ់នេះគឺជាវៀតណាម ពួកមិត្តនៅជាមួយវៀតណាមមិនដឹងទេឬ ។ ពេលក្រុមពិសេស១៥នាក់ចូលទៅកន្លែង តាពីន ខ្ញុំនាំកម្លាំង៥នាក់តាមពីក្រោយ ។ ខ្ញុំនាំកងទ័ពទៅទិសប៉ែកខាងជើងដើរមួយយប់ទល់ភ្លឺ ប្រមូលទ័ពបានជាង៣០០នាក់ រួចបន្តដំណើរមកដល់ភូមិមួយឈ្មោះភូមិកំពង់ក្របី ដែលមានតែផ្ទះគ្មានមនុស្សនៅ ហើយមានតែដានកងទ័ពវៀតណាម ។ ខ្ញុំបាននាំកម្លាំងកងទ័ព៣០នាក់ដើរពិនិត្យជុំវិញភូមិនោះ ឃើញសាកសពជាច្រើននៅក្នុងរូងដីជ្រៅមួយ ដែលមើលទៅដូចជាសាកសពទាហាន លន់ នល់ និងសាកសពប្រជាពលរដ្ឋ ។ ពេលកងទ័ពវៀតណាមដឹងថាខ្ញុំនៅទីនេះ ក៏បានឡើងមកឡោមព័ទ្ធពួកខ្ញុំនៅវេលាទៀបភ្លឺ ប៉ុន្តែទុកផ្លូវមួយនៅទិសខាងជើងដែរ ។ ប្រយុទ្ធគ្នាអស់រយៈពេលកន្លះម៉ោង ពួកខ្ញុំដកកម្លាំងចេញបានមួយចំនួនធំនៅ៥០នាក់របួសនិងខ្លះស្លាប់ ។ នៅសល់កម្លាំងទ័ពជាង២០០នាក់ ខ្ញុំនាំគេចទៅទិសខាងលិចខាងត្បូង ចូលទៅក្បែរភូមិមួយនៅកណ្តាលព្រៃឈ្មោះខ្នាយទូរ ។ ប៉ុន្តែទីនោះក៏នៅតែត្រូវទ័ពវៀតណាមតាមវាយជាបន្តបន្ទាប់ ធ្វើឲ្យកម្លាំងរបស់ខ្ញុំត្រូវបែកបាក់អស់ជាង១០០នាក់ ។ កាលៈទេសៈពេលនោះធ្វើឲ្យខ្ញុំមានការពិបាកជាខ្លាំង ជាហេតុធ្វើឲ្យខ្ញុំសម្រេចចិត្តចាកចោលកងទ័ពជាច្រើននាក់ដែលរបួសធ្ងន់ ឈឺ និងដើរពុំរួចទុកឲ្យពួកគេនៅកណ្តាលព្រៃ ។ ខ្ញុំនាំកម្លាំងដែលអាចដើរបានធ្វើដំណើរទៅទិសខាងជើងវិញ ។ ពេលជួបជាមួយកងពិសេសដែលទទួលបញ្ជាពី ប៉ុល ពត និងតាម៉ុក ឲ្យតាមរកខ្ញុំត្រឡប់ទៅវិញ ក៏បានប្រយុទ្ធជាមួយពួកគេទៀត ។ ខ្ញុំមិន បានទៅជាមួយកងពលនេះទេ ខ្ញុំរស់នៅក្នុងព្រៃឆ្ងាយពីភូមិជាមួយខ្សែសេរីកាចំនួន១០នាក់ ។ អ្នកទាំង១០នាក់បានសុំកម្លាំងមួយចំនួនរបស់ខ្ញុំទៅវាយជាមួយវៀតណាមដើម្បីយកអង្ករ ។ ដោយរង់ចាំយូរពេក ខ្ញុំបានសម្រេចចិត្តនាំកម្លាំងខ្ញុំទាំងអស់ឆ្លងស្ទឹងសែនទៅភ្នំគូលេន ហើយរស់នៅក្នុងព្រៃអស់រយៈពេល



តា ម៉ុក

ជាយូរខែ ។

នៅឆ្នាំ១៩៧៩ពេលជិតរំដោះបាន ទីក្រុង កងពលរបស់ វិន ដែលជាកូនប្រសាររបស់ តាម៉ុក ប្រមាណ៥០០នាក់មកជួបខ្ញុំ ដោយប្រាប់ថា គាត់ក៏ដូចជាខ្ញុំដែរត្រូវ ប៉ុល ពត និងតាម៉ុក ចោទថាបើកផ្លូវឲ្យវៀតណាមចូលមក និងហៅតាមទូរលេខឲ្យប្រមូលកម្លាំងទាំងអស់ទៅជួប ប៉ុន្តែគាត់បិទមិនទាក់ទងយូរមកហើយ ។ ខ្ញុំជឿជាក់លើ វិន រួចនាំកម្លាំងទាំងអស់បង្កើតជំរំឯកាមួយនៅភ្នំដងរែក ដើម្បីរង់ចាំមើលសភាពការណ៍ ។ ខ្ញុំហៅកងទ័ពទាំងអស់មកប្រជុំចាត់តាំងប្រធានកងអនុសេនាតូចជាថ្មី និងក្រុមបានចំនួន ៤កង ។ នៅលើភ្នំរយៈពេល២ខែ វិន បាននាំកងទ័ពចេញពីទីនោះឆ្លងកាត់ភ្នំដងរែកទៅទិសខាងជើងនិងខាងកើត ។ ក្រោយពីបានពិនិត្យភូមិសាស្ត្រជាច្រើនកន្លែង វិន សម្រេចចិត្តបោះទីតាំងនៅក្បែរស្ទឹងមួយដែលមានប្រភពទឹកហូរពីទឹកដីថៃ ។

នៅឆ្នាំ១៩៨១ ប៉ុល ពត និង តាម៉ុក បានចេញបញ្ជាឲ្យប្រមូលទ័ពមកឡោមព័ទ្ធកម្ទេចខ្ញុំ និង វិន នៅពាក់កណ្តាលយប់ ។ ក្រុមពិសេសរបស់ ប៉ុល ពត និង ម៉ុក បានចូលបោកគ្រាប់បែកកម្ទេចទីតាំងរបស់ វិន មុនគេ បន្ទាប់មករកខ្ញុំ ប៉ុន្តែរកមិនឃើញ ។ ស្នូរកាំភ្លើងផ្ទុះពេញជំរំប្រហែល១០នាទីទើបស្ងាត់ បន្ទាប់មកមានសេចក្តីស្រែកតាមមីក្រូថា «បងប្អូនមិត្តយើងទាំងអស់ដាក់អាវុធទៅ មេក្បត់របស់បងប្អូនយើងស្លាប់អស់ហើយនៅម្នាក់ឈ្មោះ សឿន សូមមិត្តដាក់អាវុធ នាំមិត្តយើងត្រឡប់ទៅអ៊ំពត និងតាម៉ុកវិញ ពួកគាត់មិនប្រកាន់ទេ» ។ កងទ័ពរបស់ខ្ញុំមួយចំនួនបានចុះចូល ហើយមួយចំនួនទៀតប្រយុទ្ធប្រឆាំងដើម្បីរំដោះខ្លួនចាកចេញពីទីនោះ ។ ក្នុងចំណោមនោះ ក្រុមរបស់ខ្ញុំ៩នាក់បានរត់រួច ប៉ុន្តែបានវង្វេងព្រៃទៅប៉ះខ្សែត្រៀមទាហានរដ្ឋាភិបាលថៃ ។ ទាហានថៃបានចាប់ពួកខ្ញុំបញ្ជូនទៅបន្ទាយវ៉ា ឃុំអស់រយៈពេល១២យប់ ។ ប៉ុន្តែមិនមែនតែពួកខ្ញុំ៩នាក់ទេដែលជាប់នៅទីនោះ ពួកទ័ពតំបន់ភូមិភាគរបស់ ប៉ុល ពត និង តាម៉ុក ក៏ជាប់នៅទីនោះដែរ ។ ទាហានថៃនេះក៏មានការលើកលែងដែរ ប្រសិនបើជាពលរដ្ឋមិនមែនជាប់ខ្សែស្រឡាយប៉ុល ពត ត្រូវបញ្ជូនចេញវិញ ។

នៅពេលទាហានថៃបញ្ជាឲ្យកងទ័ពចេញសម្អាតបន្ទាយ ខ្ញុំបានឃើញ តាម៉ុក កំពុងអង្គុយនិយាយជាមួយទាហានថៃ ។ ពេលនោះខ្ញុំគិតថា តាម៉ុក ពិតជាមកទាក់ទងថៃយកខ្ញុំនិងទ័ពដទៃទៀតយកទៅសម្លាប់ចោលហើយ ។ ប្រហែលជាម៉ោង៧ព្រឹក ទាហានថៃបានឲ្យកងទ័ពទាំងអស់ហូបទឹកយ៉ាងឆ្អែតហើយប្រាប់ថាជិតបានទៅវិញហើយ ។ ម៉ោង១២ថ្ងៃត្រង់ ខ្ញុំចូលទៅកន្លែងវិញឆ្លៀតឱកាសពេលនោះ គ្នាខ្ញុំ៧នាក់ប្រញាប់កទាហានថៃម្នាក់ស្លាប់ និងខ្ញុំយកកាំភ្លើងបាញ់រះទៅលើបន្ទាយថៃ ធ្វើឲ្យប្រឞូកប្រចបល់ពេញបន្ទាយ ។ រយៈពេល២ម៉ោង ខ្ញុំនាំគ្នារត់ឡើងភ្នំដងរែកនិងដើរវង្វេងផ្លូវរយៈពេល៥យប់៥ថ្ងៃ រួចដើរទៅដល់ជំរំប៉ារ៉ារបស់ តា សឺន សាន ។ ជំរំនោះមិនអនុញ្ញាតឲ្យខ្ញុំស្នាក់នៅទេ ហើយប្រាប់ឲ្យពួកខ្ញុំទៅទិសខាងលិច ព្រោះនៅទីនោះនឹងមានជំរំមួយទៀត ហើយប្រហែលជាពួកខ្ញុំអាចស្នាក់អាស្រ័យបាន ។ ខ្ញុំនាំគ្នាធ្វើដំណើរតាមផ្លូវរយៈពេលមួយថ្ងៃកន្លះ ទើបឈប់នៅមាត់ផ្លូវចុះមួយ ។ ពេលនោះខ្ញុំបានឮសំឡេងកាប់ឈើនិងមនុស្សស្រែក ។ ខ្ញុំបានចូលសម្ងំនៅក្នុងព្រៃមួយម៉ោងចាំមើលសភាពការណ៍ ។ មួយសន្ទុះ ខ្ញុំបានឃើញ ប៉ុល ពត និង តាម៉ុក និងកងទ័ពមានប្រមាណ១០០នាក់ឡើងដល់ខ្នងភ្នំសំដៅទៅទិសខាងកើតតាមបណ្តោយផ្លូវដែលខ្ញុំមក ។ ឃើញដូចនេះខ្ញុំនាំគ្នាដើរកាត់បណ្តោយភ្នំទៅទិសខាងលិចឆ្ងាយពី ប៉ុល ពត និង តាម៉ុក វិញ ។ ចុះមកដល់វាលរាប ខ្ញុំឃើញទាហានប៉ារ៉ា៣៥នាក់កំពុងបររទេះគោក្របីជាច្រើនដឹកអ៊ីវ៉ាន់នៅជំរំអូរបុក ជំរំទន់ចាយ និងបាក់រនាស់ ។ ខ្ញុំបានប្រគល់អាវុធឲ្យទាហានប៉ារ៉ាទាំងអស់និងអង្វរសុំធ្វើប្រជាពលរដ្ឋលាក់ខ្លួននៅក្នុងជំរំនេះដែរ ។ ទាហានប៉ារ៉ានេះពុំអាចទទួលពួកខ្ញុំ៦នាក់ឲ្យស្នាក់នៅនាក់ទេ ប៉ុន្តែអនុញ្ញាតឲ្យពួកខ្ញុំរស់នៅខាងត្បូងជាមួយប្រជាជននៅខាងក្រោមភ្នំវិញ និងអាចបើកអង្ករខោអាវ ត្រីខពីរកំប៉ុង និងអីវ៉ាន់ផ្សេងៗ ។ រស់នៅទីនោះអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានយកប្រពន្ធនៅទីនោះនិងមានកូនបីនាក់ ។ សព្វថ្ងៃនេះខ្ញុំធ្វើជាកសិកររកស៊ីធម្មតានៅព្រំដែនកម្ពុជា-ថៃ ។

ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមខ្ញុំយល់ថាត្រូវតែធ្វើកាត់ទោសឲ្យបានជាដាច់ខាត ព្រោះខ្ញុំមានបងប្អូន៣នាក់ដែលបានស្លាប់បាត់បង់ជីវិតនៅរបបខ្មែរក្រហមដែរ ។

**អ៊ូ ជាង ហៅ អ៊ុំ សឿន**

# ដំណឹងស្វែររកបងស្រី

នាងខ្ញុំឈ្មោះ យូ សៀមអេង អាយុ៥៨ឆ្នាំ (ឪពុកឈ្មោះ យូ ប៉េងស៊ា និងម្តាយឈ្មោះ វ៉ាន់ សាវ៉ុន) និងស្វាមីឈ្មោះ ប៉ាន់ ជឿន អាយុ៦១ឆ្នាំ ដែលពីមុនរស់នៅភូមិខ្សា ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ ហើយបច្ចុប្បន្នរស់នៅភូមិជើងស៊ឹង ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប សូមស្វែររកបងស្រីឈ្មោះ យូ សៀមចេង និងស្វាមីឈ្មោះ ជីង ហាំងវេង មុនឆ្នាំ១៩៧៥ គាត់ទាំងពីររស់នៅទីក្រុងភ្នំពេញហើយត្រូវអន្តការជម្លៀសទៅខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៥ ក្រោយមកទើបឮដំណឹងថាប្តីគាត់ស្លាប់ នៅសល់តែកូននិងបងស្រីខ្ញុំប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៩ ឮដំណឹងថាគាត់នៅទឹកថ្លាទីក្រុងភ្នំពេញ តែក្រោយមកបាត់ដំណឹងសូន្យឈឹងតែម្តង ។

សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ឬតាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៣៧២ ៥៨១ ឬ (៨៥៥) ៩២ ២៥៣ ៧៧០ ។

# ដំណឹងស្វែររកបងស្រី និងបងប្រុស

នាងខ្ញុំឈ្មោះ ឈុន រ៉ុំ អាយុ៥៣ឆ្នាំ រស់នៅភូមិមមាញ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានបងប្អូន៥នាក់ ។ ឪពុកឈ្មោះ ឈុន ផម និងម្តាយឈ្មោះ ឃុន រឿន ។ នាងខ្ញុំសូមស្វែររក ៖ ១) បងស្រី ឈុន រ៉ែន និងប្តី (ជាប្អូនបង្កើតរបស់អ្នកចម្រៀងឈ្មោះ មាស សាម៉ន) ជាអតីតទាហានម៉ារីនមុនឆ្នាំ១៩៧៥ អ្នកទាំងពីររស់នៅទីក្រុងភ្នំពេញ ហើយបាត់ដំណឹងតាំងពីពេលអន្តការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ២) បងប្រុស ឈុន រៀន ដែលបានចេញទៅបម្រើកងទ័ពរំដោះនៅឆ្នាំ១៩៧២ ហើយក៏បាត់ដំណឹងរហូត ។ មុនឡើងរថយន្តចាកចេញពីភូមិជាមួយយុទ្ធជនដទៃទៀត រៀន បានផ្ញើសំបុត្រមួយច្បាប់ប្រាប់ក្រុមគ្រួសារថាខ្លួនចាកចេញពីភូមិហើយ ហើយឲ្យក្រុមគ្រួសារទៅយកកង់របស់ខ្លួនពីកន្លែងហ៊ឹកហាត់នៅជិតមន្ទីរឃុំ ។

ដូច្នេះបើបងប្រុសនិងបងស្រីបានឮឬបានអានសេចក្តីប្រកាសនេះសូមរកប្អូនតាមអាសយដ្ឋានខាងលើកុំខាន ។ សូមអរគុណ ។

# ដំណឹងស្វែររកកូនប្រុសម្នាក់ និងក្មួយប្រុសពីរនាក់

ក្រូច កាន ភេទស្រី អាយុ៦៣ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ សូមស្វែររកកូនប្រុសឈ្មោះ នេត ចៀន និងក្មួយប្រុសឈ្មោះ សៃ អន និងឈ្មោះ ជា លន់ ។ អ្នកទាំងបីបានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៦ នៅពេលដែលប្រធានកងចល័តឃុំ ជ្រើសរើសឲ្យទៅសមរភូមិមុខ ។ បើបងប្អូនឬញាតិមិត្តបានស្គាល់ឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ។ សូមអរគុណ ។

# លិខិតជូនព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧នេះ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញបានដាក់ឈ្មោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានសម្រេចឃុំខ្លួនជននេះជាបណ្តោះអាសន្ន ។ ក្នុងស្មារតីនៃការធានាតម្លាភាពដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននឹងដាក់ផ្សាយនៅលើគេហទំព័ររបស់តុលាការៈ http://www.eccc.gov.kh

## កម្មាភិបាលខ្មែរក្រហមសម្ភោធទំនប់



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 91, July 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.